

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ សគាថវគ្គ
# បឋមភាគ
# ២៩



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## SANYUTTANIKĀYA

## SAGĀTHAVAGGA

## PAṬHAMABHĀGA

## 29

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី ប៊ូរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប៊ួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ទឹកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## សំយុត្តនិកាយ  សគាថវគ្គ

## បឋមភាគ

## ២៩

ព. ស. ២៤០៦

# សុត្តន្តបិដកេ សំយុត្តនិកាយស្ស

# សគាថវគ្គោ

## បឋមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ទេវតាសំយុត្តំ

### បឋមោ នឡវគ្គោ

### បឋមំ ឱឃតរណសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភា-សេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

# សុត្តន្តបិដក សំយុត្តនិកាយ

# សគាថវគ្គ

# បឋមភាគ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## ទេវតាសំយុត្ត

## នឡវគ្គ ទី ១

## ឱឃតរណសូត្រ ទី ១

[១] *ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង លុះរាត្រីបឋមយាមកន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីរុងរឿងញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយឈរក្នុងទីដ៏សមគួរ ។*

[២] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច កថំ នុ ត្វំ មារិស ឱឃមតរីតិ ។ អប្បតិដ្ឋំ ខ្វាហំ អាវុសោ អនាយូហំ ឱឃមតរិន្តិ ។ យថាកថំ បន ត្វំ មារិស អប្បតិដ្ឋំ អនាយូហំ ឱឃមតរីតិ ។ យទា ស្វាហំ អាវុសោ សន្តិដ្ឋាមិ តទាស្សុ សំសីទាមិ យទា ស្វាហំ អាយូហាមិ[១] តទាស្សុ និវុយ្ហាមិ[២] ឯវំ ខ្វាហំ អាវុសោ អប្បតិដ្ឋំ អនាយូហំ ឱឃមតរិន្តិ ។

ចិរស្សំ វត បស្សាមិ ព្រាហ្មណំ បរិនិព្វុតំ

អប្បតិដ្ឋំ អនាយូហំ តិណ្ណំ លោកេ វិសត្តិកន្តិ ។

[៣] ឥទមវោច សា ទេវតា សមនុញ្ញោ សត្ថា អហោសិ ។ អថខោ សា ទេវតា សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

១ ឱ. យទា ស្វាហំ អាវុសោ អយូហាមិ ។ ២ ឱ. និព្វុយ្ហាមិ ។

[២] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គនិទ៌ុក្ខ ព្រះអង្គឆ្លងនូវអន្លង់ ដោយហេតុដូចម្តេចហ្ន៎ ។ ព្រះអង្គត្រាស់ថា ម្នាលអាវុសោ តថាគតមិនឈប់ មិនប្រឹង តែឆ្លងអន្លង់បាន ។ បពិត្រព្រះអង្គនិទ៌ុក្ខ ចុះព្រះអង្គមិនឈប់ មិនប្រឹង តែឆ្លងអន្លង់បាន តើដូចម្តេច ។ ម្នាលអាវុសោ កាលណា តថាគតឈប់ តថាគតនឹងលិចចុះក្នុងកាលនោះ កាលណា តថាគតប្រឹង តថាគតនឹងរសាត់ឃ្លាតទៅក្នុងកាលនោះ ម្នាលអាវុសោ តថាគតមិនឈប់ មិនប្រឹង តែឆ្លងអន្លង់បាន យ៉ាងនេះឯង ។

តាំងពីយូរណាស់ហើយ ខ្ញុំទើបតែនឹងបានឃើញខីណាសវ-
ព្រាហ្មណ៍ ជាអ្នករំលត់កិលេស ដែលមិនឈប់ មិនប្រឹង
តែឆ្លងតណ្ហាដែលផ្សាយទៅក្នុងលោកបាន ។

[៣] លុះទេវតានោះ ពោលពាក្យនេះចប់ហើយ ព្រះសាស្តាក៏មានព្រះហឫទ័យរីករាយ ។ គ្រានោះឯង ទេវតាអង្គនោះ ដឹងថាព្រះសាស្តារបស់អញ មានព្រះហឫទ័យរីករាយដូច្នេះហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយក៏បាត់ទៅ ក្នុងទីនោះឯង ។

៣



# ទុតិយំ និមោក្ខសុត្តំ

[៤] សាវត្ថិយំ... អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[៥] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច ជានាសិ នោ ត្វំ មារិស សត្តានំ និមោក្ខំ បមោក្ខំ វិវេកន្តិ ។ ជានាមិ ខ្វាហំ អាវុសោ សត្តានំ និមោក្ខំ បមោក្ខំ វិវេកន្តិ ។ យថាកថំ បន ត្វំ មារិស ជានាសិ សត្តានំ និមោក្ខំ បមោក្ខំ វិវេកន្តិ ។

# និមោក្ខសូត្រ ទី ២

[៤] ទៀបក្រុងសាវត្ថី... គ្រានោះឯង លុះរាត្រីបឋមយាមកន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីរុងរឿង ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

[៥] លុះទេវតាអង្គនោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គនិទ៌ុក្ខ ព្រះអង្គទ្រង់ជ្រាបនូវមគ្គជាគ្រឿងរួចចាកកិលេស នូវផលជាគ្រឿងផុតចាកកិលេស និងព្រះនិព្វានជាទីស្ងាត់ចាកកិលេស របស់សត្វទាំងឡាយដែរឬ ។ ម្នាលអ្នកមានអាយុ តថាគតដឹងនូវមគ្គជាគ្រឿងរួចចាកកិលេស នូវផលជាគ្រឿងផុតចាកកិលេស និងព្រះនិព្វានជាទីស្ងាត់ចាកកិលេស របស់សត្វទាំងឡាយដែរ ។ បពិត្រព្រះអង្គនិទ៌ុក្ខ ចុះព្រះអង្គទ្រង់ជ្រាបនូវមគ្គជាគ្រឿងរួចចាកកិលេស នូវផលជាគ្រឿងផុតចាកកិលេស និងព្រះនិព្វានជាទីស្ងាត់ចាកកិលេស របស់សត្វទាំងឡាយ ដោយប្រការដូចម្ដេចអេះ ។

[៦] នន្ទិភវបរិក្ខយា សញ្ញាវិញ្ញាណសង្ខយា
វេទនានំ និរោធា[១] ឧបសមា
ឯវំ ខ្វាហំ អាវុសោ ជានាមិ
សត្តានំ និមោក្ខំ បមោក្ខំ វិវេកន្តិ ។

## តតិយំ ឧបនេយ្យសុត្តំ

[៧] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ឧបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានីតិ ។

១ សារត្ថប្បកាសនីអដ្ឋកថា មរម្មបោត្ថកេសុ វេទនានិរោធាតិ បាឋោ ទិស្សតិ ។

[៦] ព្រះមានព្រះភាគត្រាស់តបថា ម្នាលអ្នកមានអាយុ ព្រោះការអស់ទៅនៃកម្មនិងភព ដែលមាននន្ទីជាឫសគល់ និងការអស់ទៅព្រមនៃសញ្ញានិងវិញ្ញាណ ព្រោះរលត់ស្ងប់រម្ងាប់វេទនាទាំងឡាយ យ៉ាងនេះ បានជាតថាគតដឹងនូវមគ្គជាគ្រឿងរួចចាកកិលេស នូវផលជាគ្រឿងផុតចាកកិលេស និងព្រះនិព្វានជាទីស្ងាត់ចាកកិលេស របស់សត្វទាំងឡាយ ។

# ឧបនេយ្យសូត្រ ទី ៣

[៧] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ជីវិតគឺអាយុ (របស់សត្វទាំងឡាយ) តិចតួចពេកណាស់ ដ្បិតជរា តែងនាំចូលទៅរក (សេចក្ដីស្លាប់) កាលបើសត្វដែលត្រូវជរានាំចូលទៅជិត (សេចក្ដីស្លាប់) ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គល បានសំឡឹងឃើញភ័យនុ៎ះ ក្នុងសេចក្ដីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសុខមកឲ្យ ។

ទេវតាសំយុត្តស្ស នឡវគ្គេ កាលាទិព្យាករណំ

[៨] ឧបនីយតិ ជីវិតមប្បមាយុំ

ជរូបនីតស្ស ន សន្តិ តាណា

ឯតំ ភយំ មរណេ បេក្ខមានោ

លោកាមិសំ បជហេ សន្តិបេក្ខោតិ ។

## ចតុត្ថំ អច្ចេន្តិសុត្តំ

[៩] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ

វយោគុណា អនុបុព្វំ ជហន្តិ

ឯតំ ភយំ មរណេ បេក្ខមានោ

បុញ្ញានិ កយិរាថ សុខាវហានីតិ ។

[៨] ព្រះមានព្រះភាគត្រាស់ថា ជីវិតគឺអាយុ (របស់សត្វទាំងឡាយ) តិចតួចពេកណាស់ ដ្បិតជរា តែងនាំចូលទៅរក (សេចក្ដីស្លាប់) កាលបើសត្វ ដែលត្រូវជរានាំចូលទៅជិត (សេចក្ដីស្លាប់) ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គលសំឡឹងឃើញភ័យនុ៎ះ ក្នុងសេចក្ដីស្លាប់ហើយ ជាអ្នកប្រាថ្នាសេចក្ដីស្ងប់ ត្រូវតែលះបង់អាមិសៈ ក្នុងលោកចេញ ។

# អច្ចេន្តិសូត្រ ទី ៩

[៩] ទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

កាលទាំងឡាយ តែងកន្លងផុតទៅ រាត្រីទាំងឡាយ តែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ កាលបើបុគ្គលបានសំឡឹងឃើញភ័យនុ៎ះ ក្នុងសេចក្ដីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសុខមកឲ្យ ។

[១០] អច្ចេន្តិ កាលា តរយន្តិ រត្តិយោ
វយោគុណា អនុបុព្វំ ជហន្តិ
ឯតំ ភយំ មរណេ បេក្ខមានោ
លោកាមិសំ បជហេ សន្តិបេក្ខោតិ ។

## បញ្ចមំ កតិឆ្ឆិន្ទិសុត្តំ

[១១] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ[១]

កតិ ឆិន្ទេ កតិ ជហេ
កតិ វុត្តរិ[២] ភាវយេ
កតិ សង្គាតិតោ[៣] ភិក្ខុ
ឱឃតិណ្ណោតិ វុច្ចតីតិ ។

[១២] បញ្ច ឆិន្ទេ បញ្ច ជហេ
បញ្ច វុត្តរិ ភាវយេ
បញ្ច សង្គាតិតោ ភិក្ខុ
ឱឃតិណ្ណោតិ វុច្ចតីតិ ។

---

១ ឱ. ម. ភគវតោ សន្តិកេ ឥមំ គាថំ អភាសីតិ ទិស្សន្តិ ។ ២ ម. ឧត្តរិ ។ ៣ ឱ. ម. សង្គាតិគោ ។ ម. សង្គាតិតោ (សង្គេ អតីតោ អតិក្កន្តោ) ។

[១០] ព្រះមានព្រះភាគត្រាស់ថា កាលទាំងឡាយតែង កន្លងផុតទៅ រាត្រីទាំងឡាយ តែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ កាលបើបុគ្គលបាន សម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់ហើយ ជាអ្នកសម្លឹងយកសេចក្តីស្ងប់ គួរតែលះបង់អាមិសៈ ក្នុងលោកចេញ ។

# កតិច្ឆិន្ទិសូត្រ ទី ៥

[១១] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោល គាថាសួរព្រះមានព្រះភាគថា

ជនត្រូវកាត់បង់ធម៌ប៉ុន្មាន ត្រូវលះបង់ធម៌ប៉ុន្មាន ត្រូវអប់រំ ធម៌ប៉ុន្មានតទៅ ភិក្ខុកន្លងបង់ នូវធម៌ជាគ្រឿងចំពាក់ប៉ុន្មាន ទើបហៅថា អ្នកឆ្លងឱឃៈបាន ។

[១២] ព្រះមានព្រះភាគ ត្រាស់តបថា ជនត្រូវកាត់ សំយោជនៈជាចំណែកខាងក្រោម ៥ ត្រូវលះបង់សំយោជនៈ ជាចំណែកខាងលើ ៥ ត្រូវអប់រំនូវឥន្ទ្រិយទាំង ៥ តទៅ ភិក្ខុកន្លងបង់នូវសង្គៈគឺធម៌ជាគ្រឿងចំពាក់[១] ទាំង ៥ យ៉ាង ទើបហៅថា អ្នកឆ្លងអន្លង់បាន ។

---

១ សំដៅយក រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ។

## ឆដ្ឋំ ជាគរសុត្តំ

[១៣] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

កតិ ជាគរតំ សុត្តា
កតិ សុត្តេសុ ជាគរា[១]
កតិភិ[២] រជមាទេតិ
កតិភិ បរិសុជ្ឈតីតិ ។

[១៤] បញ្ច ជាគរតំ សុត្តា
បញ្ច សុត្តេសុ ជាគរា
បញ្ចភិ រជមាទេតិ
បញ្ចភិ បរិសុជ្ឈតីតិ ។

## សត្តមំ អប្បដិវិទិតសុត្តំ

[១៥] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

---

១ ម. ជាគរោ ។ ២ ឱ. កតីហិ ។

# ជាគរសូត្រ ទី ៦

[១៣] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ធម៌ជាគ្រឿងលក់របស់ពួកបុគ្គលដែលកំពុងភ្ញាក់ មានប៉ុន្មាន
ធម៌ជាគ្រឿងភ្ញាក់ ក្នុងពួកបុគ្គលដែលលក់ មានប៉ុន្មាន
បុគ្គលប្រឡាក់ធូលីគឺកិលេស ព្រោះធម៌ប៉ុន្មាន បុគ្គលស្អាត
បាន ព្រោះធម៌ប៉ុន្មាន ។

[១៤] ព្រះមានព្រះភាគ ត្រាស់តបថា នីវរណៈទាំង ៥
ជាគ្រឿងលក់របស់ពួកបុគ្គលដែលកំពុងភ្ញាក់ ឥន្ទ្រិយទាំង ៥
ជាគ្រឿងភ្ញាក់ក្នុងពួកបុគ្គលដែលលក់ បុគ្គលតែងប្រឡាក់
ធូលីព្រោះនីវរណធម៌ ៥ តែងស្អាត ព្រោះឥន្ទ្រិយ ៥ ។

# អប្បដិវិទិតសូត្រ ទី ៧

[១៥] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

យេសំ ធម្មា អប្បដិវិទិតា
បរវាទេសុ នីយរេ[១]
សុត្តា តេ នប្បពុជ្ឈន្តិ
កាលោ តេសំ បពុជ្ឈិតុន្តិ ។

[១៦] យេសំ ធម្មា សុប្បដិវិទិតា
បរវាទេសុ ន នីយរេ
សម្ពុទ្ធា សម្មទញ្ញាយ[២]
ចរន្តិ វិសមេ សមន្តិ ។

## អដ្ឋមំ សុសម្មុដ្ឋសុត្តំ

[១៧] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

យេសំ ធម្មា សុសម្មុដ្ឋា
បរវាទេសុ នីយរេ
សុត្តា តេ នប្បពុជ្ឈន្តិ
កាលោ តេសំ បពុជ្ឈិតុន្តិ ។

១ ម. និយ្យរេ ។ ២ ឱ. ម. តេ សម្ពុទ្ធា សម្មទញ្ញា ។

ពួកជនណា មិនទាន់យល់ធម៌ច្បាស់ទេ ពួកជននោះតែង ជឿ ក្នុងលទ្ធិជាខាងក្រៅ ទុកជាកាលគួរពួកជនទាំងនោះ ភ្ញាក់រឭក ពួកជននោះ ក៏នៅតែលក់មិនភ្ញាក់រឭកសោះ ។

[១៦] ព្រះមានព្រះភាគត្រាស់ថា ពួកជនណា បានយល់ធម៌ ច្បាស់លាស់ល្អ ពួកជននោះ មិនជឿក្នុងលទ្ធិជាខាងក្រៅ ទេ ពួកជននោះ ឈ្មោះថាភ្ញាក់ខ្លួនឯង ឈ្មោះថា បាន ត្រាស់ដឹងតាមហេតុ រមែងប្រព្រឹត្តធម៌ស្មើ ក្នុងលោក-សន្និវាសដែលមិនស្មើ ។

# សុសម្មុដ្ឋសូត្រ ទី ៨

[១៧] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ បានពោល គាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ពួកជនណា ភាន់ច្រឡំធម៌ ពួកជននោះ តែងជឿក្នុងលទ្ធិ ជាខាងក្រៅ ទុកជាកាលគួរពួកជននោះភ្ញាក់រឭក ពួកជន នោះ ក៏នៅតែលក់មិនភ្ញាក់រឭកសោះ ។

៩



[១៨] យេសំ ធម្មា អសម្មុដ្ឋា
បរវាទេសុ ន នីយរេ
សម្ពុទ្ធា សម្មទញ្ញាយ
ចរន្តិ វិសមេ សមន្តិ ។

## នវមំ មានកាមសុត្តំ

[១៩] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ន មានកាមស្ស ទមោ ឥធត្ថិ
ន មោនមត្ថិ អសមាហិតស្ស
ឯកោ អរញ្ញេ វិហរម្បមត្តោ
ន មច្ចុធេយ្យស្ស តរេយ្យ បារន្តិ ។

[២០] មានំ បហាយ សុសមាហិតត្តោ
សុចេតសោ សព្វធិ វិប្បមុត្តោ[១]
ឯកោ អរញ្ញេ វិហរំ អប្បមត្តោ
ស មច្ចុធេយ្យស្ស តរេយ្យ បារន្តិ ។

---
១ ម. វិប្បយុត្តោ ។

[១៨] ពួកជនណា មិនភាន់ប្រទ្បំធម៌ ពួកជននោះ មិនជឿក្នុង
លទ្ធិជាខាងក្រៅទេ ពួកជននោះឈ្មោះថា ភ្ញាក់ខ្លួនឯង
ឈ្មោះថា បានត្រាស់ដឹងតាមហេតុ រមែងប្រព្រឹត្តធម៌ស្មើ
ក្នុងលោកសន្និវាសដែលមិនស្មើ ។

# មានកាមសូត្រ ទី ៩

[១៩] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ បានពោល
គាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា
ក្នុងលោកនេះ អ្នកប្រាថ្នាមានះ ប្រដៅចិត្តមិនបាន អ្នក
មានចិត្តមិនតាំងមាំ ឈ្មោះថា មិនមានញាណជាគ្រឿងដឹង
អ្នកនៅក្នុងព្រៃតែម្នាក់ឯង ប្រហែសធ្វេស ក៏មិនគប្បីឆ្លង
ត្រើយនៃវដ្ដៈដែលជាចំណងនៃមច្ចុបានឡើយ ។

[២០] ព្រះមានព្រះភាគត្រាស់ថា បុគ្គលលះមានះបាន តាំងចិត្ត
ប្រពៃដោយឧបចារសមាធិ មានចិត្តផូរផង់ រួចស្រឡះចាក
ធម៌ជាគ្រឿងសៅហ្មងគ្រប់យ៉ាង នៅក្នុងព្រៃតែម្នាក់ឯង មិន
បានប្រហែសធ្វេស បុគ្គលនោះ គប្បីឆ្លងត្រើយនៃវដ្ដៈដែល
ជាចំណងនៃមច្ចុបាន ។

# ទសមំ អរញ្ញសុត្តំ

[២១] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ

អរញ្ញេ វិហរន្តានំ
សន្តានំ ព្រហ្មចារិនំ
ឯកភត្តំ ភុញ្ជមានានំ
កេន វណ្ណោ បសីទតីតិ[១] ។

[២២] អតីតំ នានុសោចន្តិ
នប្បជប្បន្តិ នាគតំ
បច្ចុប្បន្នេន យាបេន្តិ
តេន វណ្ណោ បសីទតិ
អនាគតប្បជប្បាយ
អតីតស្សានុសោចនា
ឯតេន ពាលា សុស្សន្តិ
នឡោវ ហរិតោ លុតោតិ ។

នឡវគ្គោ បឋមោ ។

១ ម. បសីទតិ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# អរញ្ញសូត្រ ទី ១០

[២១] *លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថាសួរព្រះមានព្រះភាគថា*

*ពួកភិក្ខុជាព្រហ្មចារី នៅក្នុងព្រៃ មានចិត្តស្ងប់រម្ងាប់ ឆាន់អាហារតែម្តង ហេតុអ្វីបានជា ពណ៌សម្បុរកាយ នៅតែផូរផង់បាន ។*

[២២] *ព្រះមានព្រះភាគត្រាស់តបថា ពួកភិក្ខុនោះមិនសោកស្តាយរបស់ ដែលកន្លងទៅហើយ ទាំងមិនប្រាថ្នារបស់ដែលមិនទាន់មកដល់ គ្រាន់តែចិញ្ចឹមជីវិត ដោយរបស់ជាបច្ចុប្បន្ន ហេតុនោះបានជាពណ៌សម្បុរកាយនៅតែផូរផង់បាន ពួកជនពាលតែងស្រពោនស្រពាប់ ដោយហេតុទាំងពីរនោះ ព្រោះសេចក្តីប្រាថ្នានូវរបស់ដែលមិនទាន់មកដល់ និងសេចក្តីអាឡោះអាល័យ ចំពោះរបស់ ដែលកន្លងទៅហើយ ដូចដើមបបុសខៀវស្រស់ដែលត្រូវគេច្រូតចោល ។*

ចប់ នឡវគ្គ ទី ១ ។

១១

ទេវតាសំយុត្តស្ស នឡវគ្គេ ឧទ្ទានំ

# តត្រុទ្ទានំ

ឱឃំ និមោក្ខោ ឧបនេយ្យំ

អច្ចេន្តិ កតិច្ឆិន្ទិ ច

ជាគរំ អប្បដិវិទិតា

សុសម្មុដ្ឋា មានកាមិនា

អរញ្ញេ ទសមោ វុត្តោ

វគ្គោ តេន បវុច្ចតីតិ ។

# ឧទ្ទាននៃនឡវគ្គនោះ គឺ

*ឱឃតរណសូត្រ ១ និមោក្ខសូត្រ ១ ឧបនេយ្យសូត្រ ១ អច្ចេន្តិសូត្រ ១ កតិច្ឆិន្ទិសូត្រ ១ ជាគរសូត្រ ១ អប្បដិ-វិទិតសូត្រ ១ សុសម្មុដ្ឋសូត្រ ១ មានកាមសូត្រ ១ ជាគម្រប់ ១០ និងអរញ្ញសូត្រ ១ ព្រះមានព្រះភាគទ្រង់សំដែងហើយ លោកចាត់ថា ១ វគ្គ ដោយហេតុនោះ ។*

# ទុតិយោ នន្ទវគ្គោ

## បឋមំ នន្ទសុត្តំ

[២៣][១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២៤] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ អញ្ញតរា តាវតឹសកាយិកា ទេវតា នន្ទនវនេ អច្ឆរាសង្ឃបរិវុតា ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតា ស-មង្គីភូតា បរិចារិយមានា តាយំ វេលាយំ ឥមំ គាថំ អភាសិ

ន តេ សុខំ បជានន្តិ
យេ ន បស្សន្តិ នន្ទនំ
អាវាសំ នរទេវានំ
តិទសានំ យសស្សិនន្តិ ។

---

១. ឱ. ឯវម្មេ សុតន្តិ ទិស្សតិ ។

# នន្ទនវគ្គ ទី ២

## នន្ទនសូត្រ ទី ១

[២៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[២៤] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពីព្រេងនាយមក មានទេវតាមួយអង្គ ជាពួកទេវតាជាន់តាវត្តិង្ស មានពួកស្រីអប្សរចោមរោម ឆ្អែតស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ក្នុងនន្ទនវនឧទ្យាន បានពោលគាថានេះ ក្នុងវេលានោះថា

ពួកជនណា មិនបានឃើញនន្ទនវនឧទ្យាន ដែលជាទីនៅ
របស់ពួកនរទេវតា នៅក្នុងឋានត្រៃត្រិង្ស មានយសស័ក្តិ
ពួកជននោះ ឈ្មោះថា មិនស្គាល់ច្បាស់នូវសេចក្តីសុខទេ

១៣



[២៥] ឯវំ វុត្តេ ភិក្ខវេ អញ្ញតរា ទេវតា តំ ទេវតំ គាថាយ បច្ចភាសិ

ន ត្វំ ពាលេ បជានាសិ

យថា អរហតំ វចោ

អនិច្ចា សព្វេ សង្ខារា

ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ

តេសំ វូបសមោ សុខោតិ ។

## ទុតិយំ នន្ទិសុត្តំ

[២៦] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[២៥] ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ពោលយ៉ាងនេះហើយ មានទេវតាមួយអង្គទៀត (ជាអរិយសាវិកា) ពោលគាថាតបនឹងទេវតានោះវិញថា

ម្នាលទេវតាពាល អ្នកឯងមិនបានដឹងច្បាស់នូវពាក្យរបស់ព្រះអរហន្តទាំងឡាយថា សង្ខារទាំងពួង មិនទៀងទេ មានកិរិយាកើតឡើង និងកិរិយារលត់ទៅវិញជាធម្មតា កើតឡើងហើយ តែងរលត់ទៅវិញ លុះតែរម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ។

# នន្ទិសូត្រ ទី ២

[២៦] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ឆន្ទតិ បុត្តេហិ បុត្តិមា
គោមិកោ[១] គោហិ តថេវ ឆន្ទតិ ។
ឧបធី ហិ នរស្ស ឆន្ទនា
ន ហិ សោ ឆន្ទតិ យោ និរុបធីតិ ។

[២៧] សោចតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ សោចតិ
ឧបធី ហិ នរស្ស សោចនា
ន ហិ សោ សោចតិ យោ និរុបធីតិ ។

## តតិយំ នត្ថិបុត្តសមសុត្តំ

[២៨] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

នត្ថិ បុត្តសមំ បេមំ
នត្ថិ គោសមិតំ ធនំ
នត្ថិ សុរិយសមា អាភា
សមុទ្ទបរមា សរាតិ ។

១ ម. គោបិកោ ។

អ្នកមានកូន រមែងត្រេកអរនឹងកូនទាំងឡាយ អ្នកមានគោ រមែងត្រេកអរនឹងគោទាំងឡាយ ដូច្នោះដែរ ឧបធិ[១] ទាំងឡាយ ជាគ្រឿងត្រេកអរ (នឹងគេបាន) ។

[២៧] ព្រះអង្គត្រាស់ថា អ្នកមានកូន រមែងសោកសៅនឹងកូនទាំងឡាយ អ្នកមានគោ ក៏សោកសៅនឹងគោទាំងឡាយ ដូច្នោះដែរ ដ្បិតឧបធិទាំងឡាយ ជាគ្រឿងសោកសៅរបស់ជន លុះតែអ្នកណា មិនមានឧបធិ ទើបអ្នកនោះ មិនសោកសៅ ។

## នត្ថិបុត្តសមសូត្រ ទី ៣

[២៨] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

សេចក្តីស្រឡាញ់ស្មើនឹងកូនមិនមាន ទ្រព្យស្មើនឹងគោមិនមាន ពន្លឺស្មើនឹងព្រះអាទិត្យមិនមាន ស្រះទាំងឡាយប្រសើរជាងសមុទ្រ ។

---

១ ឧបធិ មាន ៤ យ៉ាងគឺ កាមូបធិ ១ ខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១ តែក្នុងទីនេះ លោកសំដៅយកកាមូបធិ គឺទេវតានោះ សំដៅយកអ្នកខ្សត់សម្បត្តិកាមគុណ រមែងរកអ្វីត្រេកអរនឹងគេគ្មានទេ ។

[២៩] នត្ថិ អត្តសមំ បេមំ
នត្ថិ ធញ្ញសមំ ធនំ
នត្ថិ បញ្ញាសមា អាភា
វុដ្ឋិ វេ បរមា សរាតិ ។

## ចតុត្ថំ ខត្តិយសុត្តំ

[៣០] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ខត្តិយោ ទិបទំ[១] សេដ្ឋោ
ពលិពទ្ទោ[២] ចតុប្បទំ
កោមារី[៣] សេដ្ឋា ភរិយានំ
យោ ច បុត្តាន បុព្វជោតិ ។

[៣១] សម្ពុទ្ធោ ទិបទំ សេដ្ឋោ
អាជានិយោ ចតុប្បទំ
សុស្សូសា សេដ្ឋា ភរិយានំ
យោ ច បុត្តានមស្សវោតិ ។

១ ឱ. ទ្វិបទំ ។ ២ ឱ. ពលិវទ្ទោ ។ ពលិពទ្ទោតិប្បត្តិ ។ ៣ ឱ. កុមារី ។

[២៩] ព្រះអង្គត្រាស់ថា សេចក្តីស្រឡាញ់ស្មើនឹងខ្លួនមិនមាន ទ្រព្យស្មើនឹងស្រូវមិនមាន ពន្លឺស្មើនឹងប្រាជ្ញាមិនមាន ទឹកភ្លៀងហ្នឹងឯង ទុកជាស្រះប្រសើរជាង ។

# ខត្តិយសូត្រ ទី ៤

[៣០] លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ក្សត្រិយ៍ប្រសើរជាងពួកសត្វជើង ២ គោប្រសើរជាងពួកសត្វជើង ៤ ប្រពន្ធក្មេងប្រសើរជាងប្រពន្ធទាំងឡាយ កូនច្បងប្រសើរជាងកូនទាំងឡាយ ។

[៣១] ព្រះអង្គត្រាស់ថា ព្រះសម្ពុទ្ធប្រសើរជាងពួកសត្វជើង ២ អាជានេយ្យ[១] ប្រសើរជាងពួកសត្វជើង ៤ ប្រពន្ធស្តាប់បង្គាប់ ប្រសើរជាងប្រពន្ធទាំងឡាយ កូនដែលស្តាប់ឱវាទប្រសើរជាងកូនទាំងឡាយ ។

---

១ អដ្ឋកថា ដំរីក្តី សេះក្តី គោក្តី ដែលចេះដឹងយល់ហេតុឆាប់បាន ហៅថា អាជានេយ្យ ។

## បញ្ចមំ សកមានសុត្តំ

[៣២] ឋិតេ មជ្ឈន្ហិកេ កាលេ
សន្និសិន្នេសុ(១) បក្ខិសុ
បលាតេវ(២) មហារញ្ញំ
តំ ភយំ បដិភាតិ មន្តិ ។

[៣៣] ឋិតេ មជ្ឈន្ហិកេ កាលេ
សន្និសិន្នេសុ បក្ខិសុ
បលាតេវ មហារញ្ញំ
សា រតី បដិភាតិ មន្តិ ។

## ឆដ្ឋំ និទ្ទាតន្ទិសុត្តំ

[៣៤] និទ្ទា តន្ទី វិជម្ភិតា
អរតី(៣) ភត្តសម្មទោ
ឯតេន នប្បកាសតិ
អរិយមគ្គោ ឥធ បាណិនន្តិ ។

---

១ ម. សន្និសីវេសុ ។ ២ ឱ. ម. សណាតេវ ។ ៣ ឱ. វិជម្ភិកា អរតី ។ ម. វិជម្ភិតា... ។ អ. វិជម្ភិតា ។

# សកមានសូត្រ ទី ៥

[៣២] *ទេវតាទូលថា ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងសត្វបក្សីទំសម្រាក ព្រៃធំហាក់ដូចជាឮសូររំពងខ្លាំង សូរសន្ធឹកនោះឯង ជាភ័យប្រាកដជាក់ស្តែង ដល់ខ្ញុំព្រះអង្គ ។*

[៣៣] *ព្រះអង្គត្រាស់ថា ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងបក្សីទំសម្រាក ព្រៃធំហាក់ដូចជាឮសូររំពងខ្លាំង ការអង្គុយម្នាក់ឯងនោះ ជាសេចក្តីត្រេកអរប្រាកដ ដល់តថាគត ។*

# និទ្ទាតន្ទិសូត្រ ទី ៦

[៣៤] *ទេវតាទូលថា ការល្មោភលក់ សេចក្តីខ្ជិលច្រអូស ការមឹតពត់កាយ សេចក្តីមិនរីករាយ សេចក្តីស្រវឹងអាហារ ព្រោះទោសទាំងនេះ បានជាអរិយមគ្គមិនជាក់ច្បាស់ ដល់ពួកសត្វក្នុងលោកនេះឡើយ ។*

ទេវតាសំយុត្តស្ស  នន្ទនវគ្គេ  ទុក្ករព្យាករណំ

[៣៨] និទ្ទំ  តន្ទឹ  វិជម្ភិតំ
អរតឹ  ភត្តសម្មទំ
វីរិយេន  នំ  បណាមេត្វា
អរិយមគ្គោ  វិសុជ្ឈតីតិ  ។

សត្តមំ  ទុក្ករសុត្តំ

[៣៦] ទុក្ករំ  ទុត្តិតិក្ខញ្ច
អព្យត្តេន  ច  សាមញ្ញំ
ពហូ  ហិ  តត្ថ  សម្ពាធា
យត្ថ  ពាលោ  វិសីទតីតិ  ។

[៣៧] កតិហំ  ចរេយ្យ  សាមញ្ញំ
ចិត្តំ  ចេ  ន  និវារយេ
បទេ  បទេ  វិសីទេយ្យ
សង្កប្បានំ  វសានុគោ
កុម្មោវ  អង្គានិ  សកេ  កចាលេ
សមោទហំ  ភិក្ខុ  មនោវិតក្កេ

[៣៥] ព្រះអង្គត្រាស់ថា លុះតែលះបង់ការល្មោភលក់ សេចក្តីខ្ជិលច្រអូស ការមឹតពត់កាយ សេចក្តីមិនរីករាយ និងសេចក្តីស្រវឹងក្នុងអាហារនោះ ដោយសេចក្តីព្យាយាមបានហើយ ទើបអរិយមគ្គ ស្អាតបាន ។

## ទុក្ករសូត្រ ទី ៧

[៣៦] ទេវតាទូលថា សមណធម៌ ជាធម៌ដែលបុគ្គលពាលធ្វើបានដោយក្រផង អត់ទ្រាំបានដោយក្រផង ព្រោះថា បុគ្គលពាល រមែងលិចចុះ ក្នុងសមណធម៌ណា សេចក្តីចង្អៀតចង្អល់ជាច្រើន (រមែងមាន) ក្នុងសមណធម៌នោះ ។

[៣៧] ព្រះអង្គត្រាស់ថា បើបុគ្គលឃាត់ចិត្តមិនបានទេ តើគួរប្រព្រឹត្តសមណធម៌បានប៉ុន្មានថ្ងៃ ព្រោះថា បុគ្គលអ្នកលុះក្នុងអំណាចសង្កប្បៈទាំងឡាយ រមែងលិចចុះគ្រប់ ៗ អារម្មណ៍ ភិក្ខុកាលរីករាយក្នុងសេចក្តីត្រិះរិះដែលកើតឡើងក្នុងចិត្ត ដូចអណ្តើកកាលរីករាយនឹងអវយវៈទាំងឡាយ ក្នុងស្នូករបស់ខ្លួន

អនិស្សិតោ អញ្ញមហោបយានោ
បរិនិព្វុតោ ឆុបរវេយ្យ កញ្ចីតិ ។

## អដ្ឋមំ ហិរិសុត្តំ

[៣៨] ហិរិនិសេធោ បុរិសោ
កោចិ លោកស្មិំ វិជ្ជតិ
យោ និន្ទំ[១] អបពោធេតិ
អស្សោ ភទ្រោ កសាមិវាតិ ។

[៣៩] ហិរិនិសេធា តនុយា
យេ ចរន្តិ សទា សតា
អន្តំ ទុក្ខស្ស បប្បុយ្យ[២]
ចរន្តិ វិសមេ សមន្តិ ។

## នវមំ កុដិកាសុត្តំ

[៤០] កច្ចិ តេ កុដិកា នត្ថិ
កច្ចិ នត្ថិ កុលាវកា
កច្ចិ សន្តានកា នត្ថិ
កច្ចិ មុត្តោសិ ពន្ធនាតិ ។

---

១ អដ្ឋកថាយំ និន្ទន្តិ ទិស្សតិ ។ ២ ម. អប្បេយ្យ ។

ជាបុគ្គលមិនបានអាស្រ័យ មិនបៀតបៀនអ្នកដទៃ ដោយតណ្ហានិងទិដ្ឋិ ជាអ្នករំលត់កិលេស មិនបានពោលតិះដៀលបុគ្គលណាមួយឡើយ ។

# ហិរិសូត្រ ទី ៨

[៣៨] ទេវតាទូលថា បុរសដែលបន្ទោបង់អំពើអាក្រក់ ដោយសេចក្តីអៀនខ្មាសបាន សឹងមានតិចក្នុងលោក អ្នកដែលបន្ទោបង់ការល្មោភលក់ ហើយភ្ញាក់រឭកបាន ដូចជាសេះល្អ (ដែលតក់ស្លុត) ដោយរំពាត់ ក៏មានតិចក្នុងលោកដែរ ។ [៣៩] ព្រះអង្គត្រាស់ថា ពួកជនដែលមានស្មារតីរាល់វេលាប្រព្រឹត្តទៅ ដើម្បីការពារអំពើអាក្រក់ ដោយសេចក្តីអៀនខ្មាស សឹងមានស្តួចស្តើង លុះតែពួកជនដែលដល់នូវទីបំផុតទុក្ខ ទើបប្រព្រឹត្តធម៌ស្មើក្នុងលោកសន្និវាសដែលមិនស្មើបាន ។

# កុដិកាសូត្រ ទី ៩

[៤០] ទេវតាទូលសួរថា ខ្ទមរបស់ព្រះអង្គ មិនមានទេឬ សំបុករបស់ព្រះអង្គ មិនមានទេឬ តំណវង្សរបស់ព្រះអង្គ មិនមានទេឬ ព្រះអង្គរួចចាកចំណងហើយឬ ។

១៩

ទេវតាសំយុត្តស្ស  នន្ទនវគ្គេ  កុដិកានត្ថិព្យាករណំ

[៤១] តគ្ឃ មេ កុដិកា នត្ថិ
តគ្ឃ នត្ថិ កុលាវកា
តគ្ឃ សន្តានកា នត្ថិ
តគ្ឃ មុត្តោម្ហិ ពន្ធនាតិ ។

[៤២] កិន្តាហំ កុដិកំ ព្រូមិ
កិន្តេ ព្រូមិ កុលាវកំ
កិន្តេ សន្តានកំ ព្រូមិ
កិន្តាហំ ព្រូមិ ពន្ធនន្តិ ។

[៤៣] មាតរំ កុដិកំ ព្រូសិ
ភរិយំ ព្រូសិ កុលាវកំ
បុត្តេ សន្តានកេ ព្រូសិ
តណ្ហំ មេ ព្រូសិ ពន្ធនន្តិ ។

[៤៤] សាហុ តេ កុដិកា នត្ថិ ។
សាហុ នត្ថិ កុលាវកា
សាហុ សន្តានកា នត្ថិ
សាហុ មុត្តោសិ ពន្ធនាតិ ។

[៤១] ព្រះអង្គត្រាស់ថា អើខ្នមរបស់តថាគត គ្មានសោះទេ អើសំបុកក៏គ្មានសោះទេ អើតំណវង្ស ក៏គ្មានសោះដែរ អើតថាគតរួចចាកចំណងជាប្រាកដហើយ ។

[៤២] ទេវតាទូលសួរថា ចុះខ្ញុំពោលសំដៅអ្វីថាជាខ្នម របស់ព្រះអង្គ ខ្ញុំពោលសំដៅអ្វីថាជាសំបុក របស់ព្រះអង្គ ខ្ញុំពោលសំដៅអ្វីថាជាតំណវង្ស របស់ព្រះអង្គ ខ្ញុំពោលសំដៅអ្វីថាជាចំណង របស់ព្រះអង្គ ។

[៤៣] ព្រះអង្គត្រាស់តបថា អ្នកពោលសំដៅមាតា ទុកជាខ្នម អ្នកពោលសំដៅភរិយា ទុកជាសំបុក អ្នកពោលសំដៅពួកបុត្រ ទុកជាតំណវង្ស អ្នកពោលសំដៅតណ្ហា ទុកជាចំណងរបស់តថាគត ។

[៤៤] ទេវតាទូលថា ព្រះអង្គគ្មានខ្នមមែនហើយ គ្មានសំបុកមែនហើយ គ្មានតំណវង្សមែនហើយ ព្រះអង្គរួចចាកចំណងពិតមែនហើយ ។

# ទសមំ សមិទ្ធិសុត្តំ

[៤៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ តបោទារាមេ ។ អថខោ អាយស្មា សមិទ្ធិ រត្តិយា បច្ចូសសមយំ(១) បច្ចុដ្ឋាយ យេន តបោទា តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ តបោទេ គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ សុក្ខាបយមានោ(២) ។

[៤៦] អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ តបោទំ ឱភាសេត្វា យេន អាយស្មា សមិទ្ធិ តេនុបសង្កមិ ឧបសង្កមិត្វា វេហាសំ ឋិតា(៣) អាយស្មន្តំ សមិទ្ធឹ គាថាយ អជ្ឈភាសិ

អភុត្វា ភិក្ខសិ ភិក្ខុ
ន ហិ ភុត្វាន ភិក្ខសិ
ភុត្វាន ភិក្ខុ ភិក្ខស្សុ
មា តំ កាលោ ឧបច្ចគាតិ ។

---

១ បច្ចូសសមយេតិបិ បាឋោ ។ ២ ម. បុព្វាបយមានោ ។ ៣ ម. វេហាសំ បត្វា ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# សមិទ្ធិសូត្រ ទី ១០

[៤៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងតបោទារាម ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯងព្រះសមិទ្ធិមានអាយុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ចូលទៅឯស្ទឹងតបោទា ដើម្បីស្រោចស្រប់ខ្លួន លុះស្រោចស្រប់ខ្លួន ក្នុងអន្ទង់ដែលមានទឹកក្តៅរួចហើយឡើងមក មានតែចីវរ ១ ឈរសំដិលខ្លួន ។

[៤៦] លុះរាត្រីបឋមយាមកន្លងហើយ កាលនោះទេវតា ១ អង្គមានរស្មីដ៏រុងរឿង ញ៉ាំងស្ទឹងតបោទាទាំងមូលឲ្យរុងរឿង ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ក៏ឋិតនៅនាអាកាស ពោលគាថានឹងព្រះសមិទ្ធិមានអាយុថា

នៃភិក្ខុ លោកមិនទៅបរិភោគ (កាមគុណ) មកដើរបិណ្ឌ-
បាត ម្តេចក៏លោកមិនបរិភោគ ហើយសឹមត្រាច់បិណ្ឌបាត
នៃភិក្ខុ ចូរលោកបរិភោគកាមហើយសឹមត្រាច់បិណ្ឌបាតចុះ
កុំឲ្យកាល (នៅក្មេង) កន្លងហួសលោកឡើយ ។

២១

ទេវតាសំយុត្តស្ស នន្ទនវគ្គេ សមិទ្ធូបសង្កមនំ

[៤៧] កាលំ វោហំ ន ជានាមិ
ឆន្នោ កាលោ ន ទិស្សតិ
តស្មា អភុត្វា ភិក្ខាមិ
មា មំ កាលោ ឧបច្ចគាតិ ។

[៤៨] អថខោ សា ទេវតា បថវិយំ បតិដ្ឋហិត្វា អាយស្មន្តំ សមិទ្ធឹ ឯតទវោច ទហរោ ត្វំ ភិក្ខុ បព្វជិតោ សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អនិក្កីឡិតាវី កាមេសុ ភុញ្ជ ភិក្ខុ មានុសកេ កាមេ មា សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវីតិ ។

ទេវតាសំយុត្ត នន្ទនវគ្គ ទេវតាចូលទៅរកព្រះសមិទ្ធិ

[៤៧] *អាត្មាមិនដឹងកាល (ដែលត្រូវស្លាប់) ទេ ព្រោះកាល (ត្រូវស្លាប់) កំបាំងជិតមិនប្រាកដសោះ ហេតុនោះបានជាអាត្មា មិននៅបរិភោគកាម មកត្រាច់បិណ្ឌបាត កុំឲ្យកាល (ធ្វើសមណធម៌) កន្លងហួសអាត្មាឡើយ ។*

[៤៨] *គ្រានោះឯង ទេវតាអង្គនោះ ត្រឡប់មកឈរលើប្រឹថពីវិញ ហើយនិយាយនឹងព្រះសមិទ្ធិមានអាយុ យ៉ាងនេះថា នែភិក្ខុលោកនៅកំលោះ មកបួសទាំងនៅក្មេងកំពុងមានសក់ខ្មៅស្រិល ទើបតែពេញវ័យ កំពុងចម្រើន គឺបឋមវ័យ មិនទាន់បានលេងក្នុងកាមទាំងឡាយឡើយ នែភិក្ខុ ចូរលោកបរិភោគកាម ជារបស់មនុស្សវិញ លោកកុំលះបង់នូវសន្ទិដ្ឋិកកាម*[១] *ហើយស្ទុះទៅរកកាលិកកាម*[២] *ឡើយ ។*

១ សន្ទិដ្ឋិកកាម សំដៅយកកាមរបស់មនុស្ស ។ ២ កាលិកកាម សំដៅយកកាមរបស់ទេវតា ។

[៤៩] ន ខ្វាហំ អាវុសោ សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវាមិ កាលិកញ្ច ខ្វាហំ អាវុសោ ហិត្វា សន្ទិដ្ឋិកំ អនុធាវាមិ កាលិកា ហិ អាវុសោ កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ[១] សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

[៥០] កថញ្ច ភិក្ខុ កាលិកា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ[២] កថំ សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

[៥១] អហំ ខោ អាវុសោ នវោ អចិរបព្វជិតោ អធុនាគតោ ឥមំ ធម្មវិនយំ ន តាហំ[៣] សក្កោមិ វិត្ថារេន អាចិក្ខិតុំ អយំ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

---
១-២ ភីយោតិបិ បាឋោ ។ ៣ ឱ. ខ្វាហំ ។

[៤៩] ម្នាលអាវុសោ អាត្មាលះបង់សន្ទិដ្ឋិកកាមហើយ មិនមែនស្ទុះទៅរកកាលិកកាមទេ ម្នាលអាវុសោ តែអាត្មាលះបង់កាលិកកាម[១] ហើយប្រាថ្នាយកសន្ទិដ្ឋិកលោកុត្តរធម៌វិញ ម្នាលអាវុសោ ព្រោះថា កាលិកកាម[២] ទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាលិកកាមនុ៎ះខ្លាំងពន់ពេក ធម៌នេះ ជាសន្ទិដ្ឋិកៈ ជាអកាលិកៈ ជាឯហិបស្សិកៈ ជាឱបនយិកៈ ជាបច្ចត្តវេទិតព្វធម៌ ។

[៥០] នៃភិក្ខុ ចុះកាលិកកាមទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាលិកកាមនុ៎ះខ្លាំងពន់ពេក តើដូចម្តេច ធម៌នេះជាសន្ទិដ្ឋិកៈ ជាអកាលិកៈ ជាឯហិបស្សិកៈ ជាឱបនយិកៈ ជាបច្ចត្តវេទិតព្វធម៌ តើដូចម្តេច ។

[៥១] ម្នាលអាវុសោ អាត្មាជាភិក្ខុថ្មី បួសមិនទាន់បានយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះថ្មីៗ អាត្មាមិនអាចនឹងប្រាប់អ្នកដោយពិស្តារបានទេ ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។

---

១-២ សំដៅយកកាមរបស់មនុស្សនិងទេវតា ។

## ២៣



រាជគហេ វិហរតិ តបោទារាមេ តំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆ យថា តេ ភគវា ព្យាករោតិ តថា នំ ធារេយ្យាសីតិ ។ ន ខោ ភិក្ខុ សុករោ សោ ភគវា អម្ហេហិ ឧបសង្កមិតុំ អញ្ញាហិ មហេសក្ខាហិ ទេវតាហិ បរិវុតោ សចេ ខោ ត្វំ ភិក្ខុ តំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាសិ មយំបិ អាគច្ឆេយ្យាម ធម្មស្សវនាយាតិ ។ ឯវមាវុសោតិ ខោ អាយស្មា សមិទ្ធិ តស្សា ទេវតាយ បដិស្សុណិត្វា[១] យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៤២] ឯកមន្តំ និសិន្នោ ខោ អាយស្មា សមិទ្ធិ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ រត្តិយា បច្ចូស-សមយំ បច្ចុដ្ឋាយ យេន តបោទា តេនុបសង្កមឹ គត្តានិ បរិសិញ្ចិតុំ តបោទេ គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសឹ គត្តានិ សុក្ខាបយមានោ

១ ឱ. ម. បដិស្សុត្វា ។

ទ្រង់គង់នៅក្នុងតបោទារាម ទៀបក្រុងរាជគ្រឹះ ចូរអ្នកចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយទូលសួរសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគទ្រង់ដោះស្រាយដល់អ្នក យ៉ាងណា ត្រូវអ្នកចាំសេចក្តីនោះ យ៉ាងនោះចុះ ។ ទេវតានោះតបថា នែភិក្ខុ ព្រះមានព្រះភាគអង្គនោះ យើងមិនងាយនឹងចូលទៅគាល់បានទេ ដ្បិតមានពួកទេវតាដទៃ ដែលមានស័ក្តិធំ ចោមរោមជុំវិញព្រះអង្គ នែភិក្ខុ ប្រសិនបើលោកចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយសួរសេចក្តីនុ៎ះផង ឯខ្ញុំព្រះករុណាក៏មកដើម្បីស្តាប់ធម៌ដែរ ។ ព្រះសមិទ្ធិមានអាយុ ក៏ទទួលពាក្យរបស់ទេវតានោះថា ចម្រើនពរ អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[៥២] លុះព្រះសមិទ្ធិមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបានក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយក៏ចូលទៅកាន់ស្ទឹងតបោទាដើម្បីស្រោចស្រប់ខ្លួន លុះស្រោចស្រប់ខ្លួនក្នុងស្ទឹងតបោទារួចហើយ ឡើងមកវិញ មានតែចីវរមួយ ឈរសំដិលខ្លួន

អថខោ ភន្តេ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ តបោទំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា វេហាសំ ឋិតា ឥមាយ គាថាយ អជ្ឈភាសិ

អភុត្វា ភិក្ខសិ ភិក្ខុ
ន ហិ ភុត្វាន ភិក្ខសិ
ភុត្វាន ភិក្ខុ ភិក្ខស្សុ
មា តំ កាលោ ឧបច្ចគាតិ ។

ឯវំ វុត្តេ អហំ ភន្តេ តំ ទេវតំ គាថាយ អជ្ឈ-ភាសឹ[១]

កាលំ វោហំ ន ជានាមិ
ឆន្នោ កាលោ ន ទិស្សតិ
តស្មា អភុត្វា ភិក្ខាមិ
មា មំ កាលោ ឧបច្ចគាតិ ។

១ ឱ. បច្ចភាសិ ។

បពិត្រព្រះអង្គដ៏ចម្រើន នាកាលរាត្រីបឋមយាម កន្លងហើយ ស្រាប់តែទេវតាមួយអង្គ មានរស្មីរុងរឿង ញុំាងស្ទឹងតបោទាទាំងមូលឲ្យភ្លឺស្វាងរុងរឿង ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ឋិតនៅនាអាកាស ពោលគាថានេះថា

នែភិក្ខុ លោកមិននៅបរិភោគ (កាមគុណ) មកដើរបិណ្ឌបាត

ម្ដេចក៏លោកមិនបរិភោគ ហើយសឹមត្រាច់បិណ្ឌបាត នែភិក្ខុ

ចូរលោកបរិភោគ ហើយសឹមត្រាច់បិណ្ឌបាតចុះ កុំឲ្យកាល

(នៅក្មេង) កន្លងហួសលោកឡើយ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលទេវតានោះ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយតបនឹងទេវតានោះ ដោយគាថា ដូច្នេះថា

អាត្មាមិនដឹងកាល (ដែលត្រូវស្លាប់) ទេ ព្រោះកាល (ត្រូវ

ស្លាប់) កំបាំងជិតមិនប្រាកដសោះ ហេតុនោះបានជាអាត្មា

មិននៅបរិភោគ មកត្រាច់បិណ្ឌបាត កុំឲ្យកាល (ធ្វើ

សមណធម៌) កន្លងហួសអាត្មាឡើយ ។

អថខោ ភន្តេ សា ទេវតា បឋវិយំ បតិដ្ឋហិត្វា មំ ឯតទវោច ទហរោ ត្វំ ភិក្ខុ បព្វជិតោ សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អនិក្កីឡិតាវី កាមេសុ ភុញ្ជ ភិក្ខុ មានុសកេ កាមេ មា សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវីតិ ។ ឯវំ វុត្តាហំ[១] ភន្តេ តំ ទេវតំ ឯតទវោចំ ន ខ្វាហំ អាវុសោ សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវាមិ កាលិកញ្ច ខ្វាហំ អាវុសោ ហិត្វា សន្ទិដ្ឋិកំ អនុធាវាមិ កាលិកា ហិ អាវុសោ កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ឯវំ វុត្តេ ភន្តេ សា ទេវតា មំ ឯតទវោច កថញ្ច ភិក្ខុ កាលិកា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា

១ ឱ. វុត្តេហំ ។

ទេវតាសំយុត្ត នន្ទនវគ្គ ការដែលព្រះសមិទ្ធិក្រាបទូលដំណឹង

បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ទេវតានោះត្រឡប់មកឈរលើប្រឹថពីវិញ ហើយនិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា នៃភិក្ខុ លោកនៅកំលោះ មកបួសទាំងនៅក្មេងកំពុងមានសក់ខ្មៅស្រិល ទើបតែពេញវ័យកំពុងចម្រើន គឺបឋមវ័យ មិនទាន់បានលេងក្នុងកាមទាំងឡាយឡើយ នៃភិក្ខុ ចូរលោកបរិភោគកាមជារបស់មនុស្សវិញ លោកកុំលះបង់នូវសន្ទិដ្ឋិកកាម ហើយស្ទុះទៅរកកាលិកកាមឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើទេវតានោះ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏បាននិយាយនឹងទេវតានោះយ៉ាងនេះថា ម្នាលអាវុសោ អាត្មាលះបង់សន្ទិដ្ឋិកកាមហើយ មិនមែនស្ទុះទៅរកកាលិកកាមវិញទេ ម្នាលអាវុសោ តែអាត្មាលះបង់កាលិកកាម ប្រាថ្នាយកសន្ទិដ្ឋិកលោកុត្តរធម៌វិញ ម្នាលអាវុសោ ព្រោះថា កាលិកកាមទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាលិកកាមនុ៎ះ ខ្លាំងពន់ពេក ធម៌នេះជាសន្ទិដ្ឋិកៈ ជាអកាលិកៈ ជាឯហិបស្សិកៈ ជាឱបនយិកៈ ជាបច្ចត្តវេទិតព្វធម៌ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គ និយាយយ៉ាងនេះហើយ ទេវតានោះ ក៏និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា នៃភិក្ខុ ចុះកាលិកកាមទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន

អាទីនវោ ឯត្ថ ភិយ្យោ កថំ សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ឯវំ វុត្តាហំ ភន្តេ តំ ទេវតំ ឯតទវោចំ អហំ ខោ អាវុសោ នវោ អចិរបព្វជិតោ អធុនាគតោ ឥមំ ធម្មវិនយំ ន តាហំ សក្កោមិ វិត្ថារេន អាចិក្ខិតុំ អយំ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ រាជគហេ វិហរតិ តបោទារាមេ តំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆ យថា តេ ភគវា ព្យាករោតិ តថា នំ ធារេយ្យាសីតិ ។ ឯវំ វុត្តេ ភន្តេ សា ទេវតា មំ ឯតទវោច ន ខោ ភិក្ខុ សុករោ សោ ភគវា អម្ហេហិ ឧបសង្កមិតុំ អញ្ញាហិ មហេសក្ខាហិ ទេវតាហិ បរិវុតោ សចេ ខោ ត្វំ ភិក្ខុ តំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាសិ មយំបិ អាគច្ឆេយ្យាម ធម្មស្សវនាយាតិ ។

*ទោសក្នុងកាលិកកាមនុ៎ះខ្លាំងពន់ពេក តើដូចម្តេច ធម៌នេះ ជាសន្ទិដ្ឋិកៈ ជាអកាលិកៈ ជាឯហិបស្សិកៈ ជាឱបនយិកៈ ជាបច្ចត្តំវេទិតព្វធម៌ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើទេវតានិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏បានពោលនឹងទេវតានោះ យ៉ាងនេះថា ម្នាលអាវុសោ អាត្មាជាភិក្ខុថ្មី បួសមិនទាន់បានយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះថ្មីៗ អាត្មាមិនអាចនឹងសំដែងប្រាប់អ្នក ដោយពិស្តារបានទេ ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងតបោទារាម ទៀបក្រុងរាជគ្រឹះ ចូរអ្នកទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយសួរសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគទ្រង់ដោះស្រាយដល់អ្នកយ៉ាងណា អ្នកត្រូវចាំសេចក្តីនោះយ៉ាងនេះចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ ទេវតានោះនិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា នែភិក្ខុ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនងាយនឹងចូលទៅគាល់បានទេ ដ្បិតពួកទេវតាដទៃដែលមានស័ក្តិធំ ចោមរោមជុំវិញព្រះអង្គ នែភិក្ខុ ប្រសិនបើលោកចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយសួរសេចក្តីនុ៎ះផង ឯខ្ញុំព្រះករុណាក៏មកស្តាប់ធម៌ដែរ ។*

សចេ ភន្តេ តស្សា ទេវតាយ សច្ចំ វចនំ ឥទេវ សា ទេវតា អវិទូរេតិ ។ ឯវំ វុត្តេ សា ទេវតា អាយស្មន្តំ សមិទ្ធឹ ឯតទវោច បុច្ឆ ភិក្ខុ បុច្ឆ ភិក្ខុ យមហំ អនុប្បត្តាតិ(១) ។

[៤៣] អថខោ ភគវា តំ ទេវតំ គាថាហិ(២) អជ្ឈភាសិ

អក្ខេយ្យសញ្ញិនោ សត្តា
អក្ខេយ្យស្មឹ បតិដ្ឋិតា
អក្ខេយ្យមបរិញ្ញាយ(៣)
យោគមាយន្តិ មច្ចុនោ
អក្ខេយ្យញ្ច បរិញ្ញាយ
អក្ខាតារំ ន មញ្ញតិ
តញ្ហិ តស្ស ន ហោតីតិ
យេន នំ វជ្ជា ន តស្ស អត្ថិ
សចេ វិជានាសិ វទេហិ យក្ខាតិ(៤) ។

---

១ ឱ. អនុប្បត្តោតិ ។ ២ ឱ. ម. គាថាយ ។ ៣ ម. អក្ខេយ្យំ អបរិញ្ញាយ ។ ៤ ឱ. ម. យក្ខីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពាក្យរបស់ទេវតានេះ ជាពាក្យពិត ទេវតានោះឋិតនៅក្នុងទីនេះមិនឆ្ងាយប៉ុន្មានទេ ។ កាលព្រះសមិទ្ធិមានអាយុ និយាយយ៉ាងនេះហើយ ទេវតានោះ ក៏និយាយនឹងព្រះសមិទ្ធិមានអាយុថា នែភិក្ខុ ចូរលោកសួរចុះ នែភិក្ខុ ចូរលោកសួរចុះ ខ្ញុំមកដល់ហើយ ។

[៥៣] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ នឹងទេវតានោះ ដោយគាថា ដូច្នេះថា

ពួកសត្វ ដែលមានសេចក្តីសំគាល់ក្នុងបញ្ញក្ខន្ធ ប្រកាន់ស្អិតក្នុងបញ្ញក្ខន្ធ មិនកំណត់យល់ច្បាស់នូវបញ្ញក្ខន្ធ រមែងលុះក្នុងអំណាច នៃសេចក្តីស្លាប់ បុគ្គល ដែលកំណត់យល់ច្បាស់នូវបញ្ញក្ខន្ធហើយ រមែងមិនត្រូវការបុគ្គលអ្នកប្រាប់ទេ ព្រោះការនោះ មិនមានដល់បុគ្គលនោះឡើយ ហេតុនោះ ជនណាមួយ គប្បីជៀលបុគ្គលនោះ ដោយហេតុណា ហេតុនោះ មិនមានដល់បុគ្គលនោះទេ ម្នាលទេវតា បើអ្នកដឹងច្បាស់ អ្នកត្រូវនិយាយមកចុះ ។

ន ខ្វាហំ ភន្តេ ឥមស្ស ភគវតា សង្ខិត្តេន ភាសិ-
តស្ស វិត្ថារេន អត្ថំ អាជានាមិ សាធុ មេ ភន្តេ
ភគវា តថា ភាសតុ យថាហំ ឥមស្ស ភគវតា
សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។

[៥៤] សមោ វិសេសី ឧទវា[១] និហីនោ
យោ មញ្ញតី សោ វិវទេថ តេន
តីសុ វិធាសុ អវិកម្បមានោ
សមោ វិសេសីតិ ន តស្ស ហោតិ
សចេ វិជានាសិ វទេហិ យក្ខាតិ ។

១ ឱ. អថ វា ។

ទេវតានោះតបថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសេចក្តីសង្ខេបនេះ ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីដោយពិស្តារទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ដោយសេចក្តីសង្ខេបនេះ ឲ្យខ្ញុំព្រះអង្គបានយល់សេចក្តីដោយពិស្តារ ។

[៤៤] ព្រះមានព្រះភាគត្រាស់ថា បុគ្គលណា សំគាល់ខ្លួន
ថាស្មើនឹងគេ ថាវិសេសជាងគេ ឬថាថោកទាបជាងគេ
បុគ្គលនោះ រមែងទាស់ទែង ដោយសេចក្តីសំគាល់នោះ
បុគ្គលណា មិនបានញាប់ញ័រក្នុងសេចក្តីប្រកាន់ទាំង ៣
ប្រការទេ សេចក្តីប្រកាន់ថាស្មើនឹងគេ ថាវិសេសជាងគេ
រមែងមិនមានដល់បុគ្គលនោះឡើយ ម្នាលទេវតា បើអ្នក
ដឹងច្បាស់ អ្នកចូរនិយាយមកចុះ ។

ឥមស្សបិ ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ ន អាជានាមិ សាធុ មេ ភន្តេ ភគវា តថា ភាសតុ យថាហំ ឥមស្ស ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។

[៥៥] បហាសិ កង្ខំ[១] ន វិមានមាគា[២]
អច្ឆេច្ឆិ តណ្ហំ ឥធ នាមរូបេ
តំ ឆិន្នគន្ថំ អនិឃំ និរាសំ
បរិយេសមានា នាជ្ឈគមុំ
ទេវា មនុស្សា ឥធ វា ហុរំ វា
សគ្គេសុ វា[៣] សព្វនិវេសនេសុ
សចេ វិជានាសិ វទេហិ យក្ខាតិ ។

---

១ ឱ. ម. សង្ខំ ។ ២ ឱ. ន វិមានមជ្ឈគា ។ ៣ ឱ. ឥទំ បាឋទ្វយំ ទិស្សតិ ។

ទេវតាសំយុត្ត នន្ទនវគ្គ សេចក្តីអធិប្បាយនៃភាសិត

ទេវតាតបថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ដោយសេចក្តីសង្ខេបនេះ ខ្ញុំព្រះអង្គមិនយល់សេចក្តី ដោយពិស្តារទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ ដោយសេចក្តីសង្ខេបនេះ ឲ្យខ្ញុំព្រះអង្គយល់ដោយពិស្តារ ។

[៥៥] ព្រះមានព្រះភាគត្រាស់ថា បុគ្គលបានលះបង់នូវកង្វល់ហើយ រមែងមិនមករកវិមាន (ផ្ទៃនៃមាតាទៀត) ទេ បុគ្គលបានផ្តាច់បង់ចំណង់ក្នុងនាមរូបនេះហើយ ពួកទេវតានិងមនុស្សទាំងឡាយ រកមើល នូវបុគ្គលដែលផ្តាច់ធម៌ជាគ្រឿងចាក់ស្រែះ ដែលមិនមានទុក្ខ មិនមានសេចក្តីអាឡោះអាល័យនោះ ក្នុងលោកនេះ ឬក្នុងលោកខាងមុខ ក្នុងឋានសួគ៌ ឬ ក្នុងលំនៅរបស់សត្វ[១] គ្រប់កន្លែងមិនឃើញទេ ម្នាលទេវតា បើអ្នកដឹងច្បាស់ អ្នកចូរនិយាយមកចុះ ។

---

១ ទីលំនៅរបស់សត្វក្នុងទីនេះ បានដល់ភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ លំនៅរបស់សត្វទាំង ៩ ។

[៤៦] ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ

ចាបំ ន ករេយ្យ វចសា មនសា
កាយេន វា កិញ្ចនំ សព្វលោកេ
កាមេ បហាយ សតិមា សម្បជានោ
ទុក្ខំ ន សេវេថ អនត្ថសញ្ហិតន្តិ ។

នន្ទនវគ្គោ ទុតិយោ ។

[៥៦] បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ ដោយសេចក្តីសង្ខេបនេះ ខ្ញុំព្រះអង្គបានយល់សេចក្តី ដោយពិស្តារយ៉ាងនេះថា

បុគ្គលមិនត្រូវធ្វើកង្វល់ដ៏លាមក ដោយវាចា ដោយចិត្ត ឬ
ដោយកាយ ក្នុងលោកទាំងអស់ បុគ្គលមានសតិ និងសម្ប-
ជញ្ញៈ បានលះបង់កាមទាំងឡាយហើយ មិនគួរសេពគប់
នូវសេចក្តីទុក្ខ ដែលមិនប្រកបដោយប្រយោជន៍ទេ ។

ចប់ នន្ទនវគ្គ ទី ២ ។

៣១

ទេវតាសំយុត្តស្ស នន្ទនវគ្គេ ឧទ្ទានំ

# តត្រុទ្ទានំ

នន្ទនា នន្ទតិ ចេវ
នត្ថិបុត្តសមេន ច
ខត្តិយោ សកមានោ ច
និទ្ទាតន្ទិ ច ទុក្ករំ
ហិរិ កុដិកា នវមោ
ទសមោ វុត្តោ សមិទ្ធិនាតិ ។

## ឧទ្ទាននៃនន្ទនវគ្គនោះ គឺ

*នន្ទនសូត្រ ១ នន្ទិសូត្រ ១ នត្ថិបុត្តសមសូត្រ ១ ខត្តិយសូត្រ ១ សកមានសូត្រ ១ និទ្ទាតន្ទិសូត្រ ១ ទុក្ករសូត្រ ១ ហិរិសូត្រ ១ មានកុដិកាសូត្រជាគម្រប់ ៩ និងសមិទ្ធិសូត្រជាគម្រប់ ១០ ដែលបានពោលមកហើយ ។*

# តតិយោ សត្តិវគ្គោ

## បឋមំ សត្តិសុត្តំ

[៨៧] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សត្តិយា វិយ ឱមដ្ឋោ
ឌយ្ហមានេវ មត្ថកេ
កាមរាគប្បហានាយ
សតោ ភិក្ខុ បរិព្វជេតិ ។

[៨៨] សត្តិយា វិយ ឱមដ្ឋោ
ឌយ្ហមានេវ មត្ថកេ
សក្កាយទិដ្ឋិប្បហានាយ
សតោ ភិក្ខុ បរិព្វជេតិ ។

## ទុតិយំ ផុសតិសុត្តំ

[៨៩] នាផុសន្តំ ផុសតិ ច
ផុសន្តញ្ច តតោ ផុសេ

# សត្តិវគ្គ ទី ៣

## សត្តិសូត្រ ទី ១

[៩៧] ទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ភិក្ខុអ្នកមានស្មារតី គប្បីប្រញាប់[១] វៀរ ដើម្បីលះបង់នូវកាមរាគ ដូចជាបុរសដែលគេប្រហារដោយលំពែង ឬដូចជាបុគ្គលដែលភ្លើងឆេះលើក្បាល ។

[៩៨] ព្រះមានព្រះភាគត្រាស់ថា ភិក្ខុអ្នកមានស្មារតី គប្បីប្រញាប់វៀរ ដើម្បីលះបង់នូវសក្កាយទិដ្ឋិ ដូចជាបុរសដែលត្រូវគេប្រហារដោយលំពែង ឬដូចជាបុគ្គលដែលភ្លើងឆេះលើក្បាល ។

## ផុសតិសូត្រ ទី ២

[៩៩] វិបាក រមែងមិនប៉ះពាល់បុគ្គលដែលមិនបានប៉ះពាល់កម្ម វិបាកប៉ះពាល់តែបុគ្គលដែលប៉ះពាល់កម្មប៉ុណ្ណោះ

---

១ តាមន័យក្នុងអដ្ឋកថា ឲ្យប្រែថា គប្បីនៅ គឺថា គប្បីសម្រេចឥរិយាបថទាំង ៤ ។

តស្មា ផុសន្តំ ផុសតិ
អប្បទុដ្ឋប្បទោសិនន្តិ ។

[៦០] យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោតិ ។

## តតិយំ ជដាសុត្តំ

[៦១] អន្តោជដា ពហិជដា
ជដាយ ជដិតា បជា
តំ តំ គោតម បុច្ឆាមិ
កោ ឥមំ វិជដយេ ជដន្តិ ។

ហេតុនោះ បានជាវិបាក រមែងប៉ះពាល់បុគ្គលដែលប៉ះពាល់កម្ម ជាអ្នកប្រទូស្តដល់បុគ្គលដែលមិនប្រទូស្ត ។

[៦០] បុគ្គលណា ប្រទូស្តចំពោះជនដែលមិនប្រទូស្ត ជាសត្វបរិសុទ្ធស្អាត ឥតមានទីទួលគឺកិលេស អំពើអាក្រក់រមែងត្រឡប់ឲ្យផលដល់បុគ្គលពាលនោះវិញ ដូចជាបុគ្គលបាចធូលីល្អិតច្រាសខ្យល់ ។

# ជដាសូត្រ ទី ៣

[៦១] តណ្ហាជាគ្រឿងចាក់ស្រែះខាងក្នុងក៏មាន តណ្ហាជាគ្រឿងចាក់ស្រែះខាងក្រៅក៏មាន ពពួកសត្វត្រូវតណ្ហា ជាគ្រឿងចាក់ស្រែះរួបរឹតហើយ បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គថា អ្នកណាអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះគឺតណ្ហានេះបាន ។

[៦២] សីលេ បតិដ្ឋាយ នរោ សបញ្ញោ
ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ
សោ ឥមំ វិជដយេ ជដំ[១]
យេសំ រាគោ ច ទោសោ ច
អវិជ្ជា ច វិរាជិតា
ខីណាសវា អរហន្តោ
តេសំ វិជដិតា ជដា
យត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតិ
បដិឃរូបសញ្ញា ច
ឯត្ថ សា ឆិជ្ជតេ[២] ជដាតិ ។

## ចតុត្ថំ មនោនិវារណសុត្តំ

[៦៣] យតោ យតោ មនោ និវារយេ
ន ទុក្ខមេតិ នំ តតោ តតោ

១ ឱ. ម. ជដន្តិ ។ ២ ឱ. ឯវំ ។ ម. ឯត្ថេសា វិជ្ជតេ ។

[៦២] នរជន មានប្រាជ្ញា បានតាំងមាំ ក្នុងសីលហើយ ចម្រើននូវសមាធិចិត្តនិងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាម ដុតកម្តៅកិលេស ប្រកបដោយបារិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះ ទើបកាប់ក្តារនូវតណ្ហាជាគ្រឿងចាក់ស្រែះនេះបាន ពួកបុគ្គលណា កម្ចាត់បង់រាគៈ ទោសៈនិងអវិជ្ជាបាន ជាអ្នកអស់អាសវៈ ឆ្ងាយចាកកិលេស ពួកបុគ្គលនោះ ឈ្មោះថា កាប់ក្តារនូវតណ្ហាជាគ្រឿងចាក់ស្រែះហើយ នាមនិងរូប ទាំងបដិឃសញ្ញា និងរូបសញ្ញា រលត់ទៅឥតមានសេសសល់ ក្នុងទីណា តណ្ហាជាគ្រឿងចាក់ស្រែះនោះ រមែងរលត់ទៅ ក្នុងទីនុ៎ះ ។

# មនោនិវារណាសូត្រ ទី ៤

[៦៣] បុគ្គលគួរឃាត់ហាមចិត្ត ចាកអំពើអាក្រក់ ឬល្អណា ៗ ទុក្ខរមែងមិនមកដល់បុគ្គលនោះ ព្រោះអំពើនោះ ៗ

ស សព្វតោ មនោ និវារយេ
ស សព្វតោ ទុក្ខា បមុច្ចតីតិ[១] ។

[៦៤] ន សព្វតោ មនោ និវារយេ
មនោ យតត្តមាគតំ[២]
យតោ យតោ ច បាបកំ
តតោ តតោ មនោ និវារយេតិ ។

## បញ្ចមំ អរហន្តសុត្តំ

[៦៥] យោ ហោតិ ភិក្ខុ អរហំ កតាវី
ខីណាសវោ អន្តិមទេហធារី
អហំ វទាមីតិបិ សោ វទេយ្យ
មមំ វទន្តីតិបិ សោ វទេយ្យាតិ ។

---

១ ម. ឥតិសទ្ទោ នត្ថិ ។ ២ អ. ឯវំ ។ ម. ន មនោ សំយតត្តមាគតំ ។

បុគ្គលនោះ គួរហាមឃាត់ចិត្តសព្វអន្លើ បុគ្គលនោះ រមែងរួចចាកទុក្ខសព្វគ្រប់ ។

[៦៤] បុគ្គល មិនគួរហាមឃាត់ចិត្តសព្វអន្លើ និងចិត្ត ដែលដល់នូវសេចក្តីសង្រួមទេ លុះតែចិត្តអាក្រក់ កើតឡើង ក្នុងកាលណា ៗ ទើបត្រូវបុគ្គលហាមឃាត់ចិត្ត ក្នុងកាលនោះ ។

## អរហន្តសូត្រ ទី ៥

[៦៥] ភិក្ខុណាជាព្រះអរហន្ត មានកិច្ចធ្វើស្រេចហើយ អស់អាសវៈហើយ ទ្រទ្រង់រាងកាយ តែក្នុងជាតិជាទីបំផុត ភិក្ខុនោះនៅតែនិយាយថា អាត្មានិយាយដូច្នេះក៏មាន ភិក្ខុនោះនៅតែនិយាយថា ជនទាំងឡាយនិយាយនឹងអាត្មាថាដូច្នេះក៏មាន ។

[៦៦] យោ ហោតិ ភិក្ខុ អរហំ កតាវី

ខីណាសវោ អន្តិមទេហធារី

អហំ វទាមីតិបិ សោ វទេយ្យ

មមំ វទន្តីតិបិ សោ វទេយ្យ

លោកេ សមញ្ញំ កុសលោ វិទិត្វា

វោហារមត្តេន សោ វោហរេយ្យាតិ ។

[៦៧] យោ ហោតិ ភិក្ខុ អរហំ កតាវី

ខីណាសវោ អន្តិមទេហធារី

មានំ នុ ខោ សោ ឧបាគម្ម ភិក្ខុ

អហំ វទាមីតិបិ សោ វទេយ្យ

មមំ វទន្តីតិបិ សោ វទេយ្យាតិ ។

[៦៦] ភិក្ខុណាជាអរហន្ត មានកិច្ចធ្វើស្រេចហើយ អស់អាសវៈហើយ ទ្រទ្រង់រាងកាយតែក្នុងជាតិជាទីបំផុត ភិក្ខុនោះ នៅតែនិយាយថា អាត្មានិយាយដូច្នេះក្តី ភិក្ខុនោះនៅតែនិយាយថា ជនទាំងឡាយនិយាយនឹងអាត្មាដូច្នេះក្តី ភិក្ខុនោះ គ្រាន់តែឈ្មោះថា ជាអ្នកឈ្លាស បានយល់ច្បាស់នូវវោហារក្នុងលោក ហើយនិយាយតាមតែវោហារប៉ុណ្ណោះ ។

[៦៧] ភិក្ខុណាជាព្រះអរហន្ត មានកិច្ចធ្វើស្រេចហើយ ជាព្រះខីណាស្រព ទ្រទ្រង់រាងកាយតែក្នុងជាតិជាទីបំផុត ភិក្ខុនោះ អាស្រ័យនូវមានះដែរឬ បានជាភិក្ខុនោះនៅនិយាយថា អាត្មានិយាយដូច្នេះក៏មាន ភិក្ខុនោះ នៅនិយាយថា ជនទាំងឡាយនិយាយនឹងអាត្មាដូច្នេះក៏មាន ។

៣៧

ទេវតាសំយុត្តស្ស សត្តិវគ្គេ បជ្ជោតបុច្ឆនំ

[៦៨] បហីនមានស្ស ន សន្តិ គន្ថា
វិធូបិតា មានគន្ថស្ស[១] សព្វេ
ស វីតិវត្តោ យមតំ[២] សុមេធោ
អហំ វទាមីតិបិ សោ វទេយ្យ
មមំ វទន្តីតិបិ សោ វទេយ្យ
លោកេ សមញ្ញំ កុសលោ វិទិត្វា
វោហារមត្តេន សោ វោហរេយ្យាតិ ។

## ឆដ្ឋំ បជ្ជោតសុត្តំ

[៦៩] កតិ លោកស្មឹ បជ្ជោតា
យេហិ លោកោ បកាសតិ
ភគវន្តំ បុដ្ឋុមាគម្ម
កថំ ជានេមុ តំ មយន្តិ ។

---

១ ឱ. ឯវំ ។ ២ អដ្ឋកថាយំ មញ្ញតន្តិ ទិស្សតិ ។

[៦៨] ភិក្ខុដែលបានលះមានះចោលហើយ មិនមានធម៌ជាគ្រឿងចាក់ស្រេះទេ ដ្បិតមានះនិងធម៌ជាគ្រឿងចាក់ស្រេះ ភិក្ខុនោះកម្ចាត់ចោលទាំងអស់ហើយ ភិក្ខុនោះមានប្រាជ្ញាល្អផុតសេចក្តីសំគាល់ហើយ ទោះភិក្ខុនោះ នៅតែនិយាយថាអាត្មានិយាយដូច្នេះក្តី ភិក្ខុនោះ នៅតែនិយាយថា ពួកជននិយាយនឹងអាត្មាដូច្នេះក្តី ភិក្ខុនោះ គ្រាន់តែឈ្មោះថា ជាអ្នកឈ្លាស បានយល់ច្បាស់នូវវោហារក្នុងលោក ហើយនិយាយតាមតែវោហារប៉ុណ្ណោះ ។

# បជ្ជោតសូត្រ ទី ៦

[៦៩] លោកតែងភ្លឺច្បាស់ ដោយពន្លឺទាំងឡាយណា ពន្លឺទាំងឡាយនោះ មានប៉ុន្មានយ៉ាង ក្នុងលោក យើងខ្ញុំមកទូលសួរព្រះមានព្រះភាគ តើដូចម្តេចហ្ន៎ យើងខ្ញុំនឹងដឹងនូវពន្លឺនោះបាន ។

[៧០] ចត្តារោ លោកេ បជ្ជោតា
បញ្ចមេត្ថ ន វិជ្ជតិ
ទិវា តបតិ អាទិច្ចោ
រត្តិមាភាតិ ចន្ទិមា
អថ អគ្គិ ទិវារត្តឹ
តត្ថ តត្ថ បភាសតិ
សម្ពុទ្ធោ តបតំ សេដ្ឋោ
ឯសា អាភា អនុត្តរាតិ ។

## សត្តមំ សរសុត្តំ

[៧១] កុតោ សរា និវត្តន្តិ
កត្ថ វដ្ដំ ន វត្តតិ[១]
កត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតីតិ ។

១ ឱ. វដ្ដតិ ។

[៧០] ព្រះមានព្រះភាគត្រាស់ថា ពន្លឺ ក្នុងលោកនេះ មាន ៤ យ៉ាង មិនមានដល់ ៥ ទេ ព្រះអាទិត្យរមែងភ្លឺបាន ក្នុងវេលាថ្ងៃ ព្រះចន្ទ្រភ្លឺបាន ក្នុងវេលាយប់ ភ្លើងភ្លឺបានទាំងថ្ងៃទាំងយប់គ្រប់វេលា ព្រះសម្ពុទ្ធ ប្រសើរជាងពួកដែលមានពន្លឺរុងរឿង នេះ ជាពន្លឺប្រសើរបំផុត ។

# សរសូត្រ ទី ៧

[៧១] ទេវតាទូលសួរថា ស្រះគឺសង្សារ ប្រព្រឹត្តទៅមិនបាន ក្នុងទីណា វដ្តៈវិលទៅមិនបាន ក្នុងទីណា នាមនិងរូប រលត់ឥតមានសេសសល់ ក្នុងទីណា ។

៣៩

ទេវតាសំយុត្តស្ស សត្តិវគ្គេ អនុស្សុកបុច្ឆនំ

[៧២] យត្ថ អាបោ ច បឋវី
តេជោ វាយោ ន គាធតិ
អតោ សរា និវត្តន្តិ
ឯត្ថ វដ្តំ ន វត្តតិ
ឯត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតីតិ ។

## អដ្ឋមំ មហាទ្ធនសុត្តំ

[៧៣] មហទ្ធនា មហាភោគា
រដ្ឋវន្តោបិ ខត្តិយា
អញ្ញមញ្ញាភិគិជ្ឈន្តិ
កាមេសុ អនលង្កតា
តេសុ ឧស្សុកជាតេសុ
ភវសោតានុសារិសុ
កេធតណ្ហំ[១] បជហឹសុ
កេ លោកស្មឹ អនុស្សុកាតិ ។

១ ឱ. ម. គេធតណ្ហំ បជ្ជហឹសុ ។

[៧២] *ព្រះមានព្រះភាគត្រាស់ថា ទឹក ដី ភ្លើង ខ្យល់ មិនតាំងនៅ ក្នុងទីណា ស្រះគឺសង្សារប្រព្រឹត្តទៅមិនបាន ក្នុងទីនុ៎ះ វដ្ដៈវិលទៅមិនបាន ក្នុងទីនុ៎ះដែរ នាមនិងរូប ក៏រលត់ឥតមានសេសសល់ ក្នុងទីនុ៎ះដែរ ។*

## មហទ្ធនសូត្រ ទី ៨

[៧៣] *ទេវតាទូលសួរថា ពួកក្សត្រិយ៍ ទុកជាមានទ្រព្យច្រើន មានភោគៈច្រើន មានទាំងដែន ក៏នៅតែមិនចេះឆ្អែត ក្នុងកាមទាំងឡាយទេ តែងប្រាថ្នារបស់ដទៃ ៗ ទៀត កាលបើពួកក្សត្រិយ៍ទាំងនោះ កើតសេចក្ដីខ្វល់ខ្វាយ រសាត់ទៅតាមខ្សែនៃការមានបាន ចុះជនពួកណា ទើបអស់សេចក្ដីខ្វល់ខ្វាយ បន្សាត់នូវសេចក្ដីត្រេកអរ និងសេចក្ដីប្រាថ្នាចោល ក្នុងលោកបាន ។*

[៧៤] ហិត្វា អគារំ បព្វជិតោ
ហិត្វា បុត្តំ បសុម្បិយំ
ហិត្វា រាគញ្ច ទោសញ្ច
អវិជ្ជញ្ច វិរាជិយ
ខីណាសវា អរហន្តោ
តេ លោកស្មឹ អនុស្សុកាតិ ។

## នវមំ ចតុច្ចក្កសុត្តំ

[៧៥] ចតុច្ចក្កំ នវទ្វារំ
បុណ្ណំ លោភេន សំយុត្តំ
បង្កជាតំ មហាវីរ
កថំ យាត្រា ភវិស្សតីតិ ។

[៧៦] ឆេត្វា នន្ទឹ[១] វរត្តញ្ច
ឥច្ឆាលោភញ្ច បាបកំ
សមូលំ តណ្ហំ អព្ពុយ្ហ[២]
ឯវំ យាត្រា ភវិស្សតីតិ ។

១ ឱ. ម. នន្ទី ។ ២ អព្ពុឡ្ហាតិបិ បាឋោ ។

[៧៤] ព្រះមានព្រះភាគត្រាស់ថា ជនពួកណា លះបង់ផ្ទះ លះបង់បុត្រ លះបង់សត្វចិញ្ចឹម ជាទីស្រឡាញ់ ហើយបួស បានកម្ចាត់បង់នូវរាគៈផង ទោសៈផង អវិជ្ជាផង អស់អាសវៈ ជាអរហន្ត ជនពួកនោះ ទើបឈ្មោះថា អស់សេចក្តីខ្វល់ខ្វាយ ក្នុងលោក ។

## ចតុច្ចក្កសូត្រ ទី ៩

[៧៥] ទេវតាទូលសួរថា បពិត្រព្រះអង្គអ្នកមានព្យាយាមធំ សរីរៈមានចក្ក ៤ មានទ្វារ ៩ ពេញដោយសេចក្តីលោភ ប្រកបដោយ (តណ្ហា) កើតក្នុងភក់ល្បាប់ តើនឹងយាត្រាដូចម្តេចបាន ។

[៧៦] ព្រះមានព្រះភាគត្រាស់ថា បុគ្គលត្រូវកាត់នូវកូនកំព្រាផង ព្រ័ត្រផង សេចក្តីប្រាថ្នានិងលោភៈដ៏លាមកផង ហើយដកតណ្ហាឲ្យរលើងទាំងឫស ត្រូវយាត្រាតាមលំអាននេះឯង ។

ទេវតាសំយុត្តស្ស សត្តិវគ្គេ ទុក្ខមុញ្ចនព្យាករណំ

# ទសមំ ឯណិជង្ឃសុត្តំ

[៧៧] ឯណិជង្ឃំ កិសំ វីរំ
អប្បាហារំ អលោលុបំ
សីហំវេកចរំ នាគំ
កាមេសុ អនបេក្ខិនំ
ឧបសង្កម្ម បុច្ឆាម
កថំ ទុក្ខា បមុច្ចតីតិ ។

[៧៨] បញ្ច កាមគុណា លោកេ
មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជិត្វា
ឯវំ ទុក្ខា បមុច្ចតីតិ ។

សត្តិវគ្គោ តតិយោ ។

# ឯណិជង្ឃសូត្រ ទី ១០

[៧៧] *ទេវតាទូលសួរថា ខ្ញុំព្រះអង្គទាំងឡាយ បានចូលទៅសួរបុគ្គល ដែលមានស្នែងដូចជាទ្រាយ មានរូបរាងស្គម មានព្យាយាម មានអាហារតិច មិនលោភលន់ ហើយមិនអាឡោះអាល័យ ក្នុងកាមទាំងឡាយ ត្រាច់ទៅតែម្នាក់ឯង ដូចជាសត្វសីហៈ ឬដំរីដ៏ប្រសើរ សួរថា បុគ្គលរួចចាកទុក្ខ តើដោយប្រការដូចម្តេច ។*

[៧៨] *កាមគុណទាំង ៥ មានចិត្តជាគម្រប់ ៦ អ្នកប្រាជ្ញបានប្រកាសហើយ ក្នុងលោក បុគ្គលកម្ចាត់សេចក្តីប្រាថ្នាក្នុងកាមរូបនោះបានហើយ យ៉ាងនេះ ទើបរួចចាកទុក្ខ ។*

ចប់ សត្តិវគ្គ ទី ៣ ។

៤២

សុត្តន្តបិដកេ សំយុត្តនិកាយស្ស សគាថវគ្គោ

# តត្រុទ្ទានំ

សត្តិយា ផុសតិ ចេវ
ជដា មនោនិវារណា
អរហន្តេន បជ្ជោតោ
សរា មហទ្ធនេន ច
ចតុចក្កេន នវមំ
ឯណិជង្ឃេន តេ ទសាតិ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# ឧទ្ទានក្នុងសត្តិវគ្គនោះ គឺ

*សត្តិសូត្រ ១ ផុសតិសូត្រ ១ ជដាសូត្រ ១ មនោនិវារណ-សូត្រ ១ អរហន្តសូត្រ ១ បជ្ជោតសូត្រ ១ សរសូត្រ ១ មហទ្ធនសូត្រ ១ ជាគម្រប់ ៩ និងចតុច្ចក្កសូត្រ ១ ជាគម្រប់ ១០ និងឯណិជង្ឃសូត្រ ១ ។*

# ចតុត្ថោ សតុល្លប្បកាយិកវគ្គោ

## បឋមំ សព្ភិសុត្តំ

[៧៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា សតុល្លប្បកាយិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[៨០] ឯកមន្តំ ឋិតា ខោ ឯកា[១] ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

១ ម. សា ឯកា ។

# សតុល្លប្បកាយិកវគ្គ ទី ៤

## សព្ភិសូត្រ ទី ១

[៧៩] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង កាលរាត្រីបឋមយាម កន្លងហើយ មានពួកសតុល្លប្បកាយិកាទេវតា[១] ជាច្រើន មានរស្មីដ៏រុងរឿង ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺរុងរឿង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរ ក្នុងទីដ៏សមគួរ ។

[៨០] លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

---

១ សតៈ ប្រែថាសប្បុរស ឧល្លប្បកា ប្រែថាពោល កាយិកា ប្រែថាពួក គឺ ទេវតាពួកនេះ កាលនៅជាពាណិជ លិចសំពៅក្នុងសមុទ្រ បានពោលសមាទានធម៌របស់សប្បុរស និច្ច-សីល អំពីបុរសម្នាក់ ហើយបានទៅកើតក្នុងឋានសួគ៌ បានជាឈ្មោះថា សតុល្លប្បកាយិកា ។ អដ្ឋកថា ។

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ[១] សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សេយ្យោ ហោតិ ន បាបិយោ ។

[៨១] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
បញ្ញំ[២] លភតិ នាញ្ញតោតិ ។

[៨២] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សោកមជ្ឈេ ន សោចតីតិ ។

---

១ ម. ក្រុព្វេថ ។ ២ ឱ. បញ្ញា ។

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងបានជាបុគ្គលប្រសើរ មិនអាក្រក់ឡើយ ។

[៨១] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលបានប្រាជ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនបានអំពីទីដទៃឡើយ ។

[៨២] លំដាប់នោះឯង ទេវតាមួយអង្គទៀត ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលបានដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងមិនសោកសៅក្នុងកណ្ដាលពួកជនអ្នកសោកសៅឡើយ ។

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ សព្ភិសមាសនំ

[៨៣] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
ញាតិមជ្ឈេ វិរោចតីតិ ។

[៨៤] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សត្តា គច្ឆន្តិ សុគតិន្តិ ។

[៨៣] លំដាប់នោះ ទេវតាមួយអង្គទៀត ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើ
សេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលបានដឹងច្បាស់
នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរុងរឿងក្នុងកណ្តាល
នៃញាតិ ។

[៨៤] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គលគួរតែអង្គុយរួមជាមួយនឹងសប្បុរសប៉ុណ្ណោះ គួរធ្វើ
សេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស សត្វទាំងឡាយបាន
ដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងទៅ
កាន់សុគតិបាន ។

[៨៥] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សត្តា តិដ្ឋន្តិ សាតតន្តិ ។

អថខោ អបរា ទេវតា ភគវន្តំ ឯតទវោច កស្ស នុ ខោ ភគវា សុភាសិតន្តិ ។

[៨៦] សព្វាសំ វោ សុភាសិតំ បរិយាយេន អបិច មមាបិ(១) សុណាថ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សព្វទុក្ខា បមុច្ចតីតិ ។

---

១ ឱ. មមម្បិ ។ ម. មមំបិ ។

[៨៥] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលនឹងពួកសប្បុរស សត្វទាំងឡាយ ដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងឋិតនៅជាសុខអស់កាលយូរ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភាសិតអ្នកណាហ្ន៎ ជាសុភាសិត ។

[៨៦] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ភាសិតរបស់អ្នកទាំងអស់ ជាសុភាសិត ដោយបរិយាយដែរហើយ តែអ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់តថាគតវិញថា

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរួចចាកទុក្ខទាំងអស់បាន ។

# ទុតិយំ មច្ឆរិសុត្តំ

[៨៧] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា សតុល្លប្បកាយិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[៨៨] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

មច្ឆេរា ច បមាទា ច
ឯវំ ទានំ ន ទីយតិ
បុញ្ញមាកង្ខមានេន
ទេយ្យំ ហោតិ វិជានតាតិ ។

[៨៩] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

# មច្ឆរិសូត្រ ទី ២

[៨៧] សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង កាលរាត្រីបឋមយាម កន្លងហើយ មានពួកសតុល្លប្បកាយិកាទេវតាជាច្រើន មានរស្មីរុងរឿង ញុាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរ ក្នុងទីដ៏សមគួរ ។

[៨៨] លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ព្រោះសេចក្តីកំណាញ់និងសេចក្តីប្រមាទ បានជានរជនឲ្យ
ទានមិនកើតយ៉ាងនេះ ទាន កាលបើបុគ្គលដឹងច្បាស់ ជា
អ្នកប្រាថ្នានូវបុណ្យ គួរតែឲ្យ ។

[៨៩] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

យស្សេវ ភីតោ ន ទទាតិ មច្ឆរី
តទេវ អទទតោ ភយំ
ជិឃច្ឆា ច បិបាសា ច
យស្ស ភាយតិ មច្ឆរី
តមេវ ពាលំ ផុសតិ
អស្មឹ លោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ
ទជ្ជា ទានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

[៩០] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

តេ មតេសុ ន មិយ្យន្តិ
អទ្ធានំវ[១] សហាវជំ
អប្បស្មឹ យេ បវេច្ឆន្តិ

១ អ. ឯវំ ។ ឱ. បន្ថានំ វ ។ ម. បថានំ ។

មនុស្សកំណាញ់ ភ័យចំពោះហេតុណា ហើយមិនឲ្យទាន ហេតុនោះឯង ជាភ័យរបស់អ្នកមិនឲ្យ បុគ្គលកំណាញ់ខ្លាចចំពោះហេតុណា គ្រោះសេចក្តីឃ្លាននិងស្រេក ហេតុនោះឯង តែងពាល់ត្រូវបុគ្គលពាល ក្នុងលោកនេះ និងលោកខាងមុខ ព្រោះហេតុនោះ សាធុជន គួរតែកម្ចាត់បង់នូវសេចក្តីកំណាញ់ ជាអ្នកគ្របសង្កត់នូវមន្ទិល ហើយត្រូវឲ្យទាន (ព្រោះថា) បុណ្យទាំងឡាយ ជាទីពឹងរបស់ពួកសត្វក្នុងលោកខាងមុខ ។

[៩០] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ពួកជនណា កាលទ្រព្យមានតិច ក៏នៅតែឲ្យទានបាន ដូចជាអ្នកដើរផ្លូវឆ្ងាយ (ចែកស្បៀងដែលមានតិចតួចដល់គ្នាបាន) កាលបើគេស្លាប់រាល់គ្នា ជននោះឈ្មោះថាមិនស្លាប់

ឯស ធម្មោ សនន្តនោ
អប្បស្មេកេ បវេច្ឆន្តិ
ពហុនេកេ ន ទិច្ឆរេ
អប្បស្មា ទក្ខិណា ទិន្នា
សហស្សេន សមំ មិតាតិ ។

[៩១] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

ទុទ្ទទំ ទទមានានំ
ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ
សតំ ធម្មោ ទុរន្វយោ[១]
តស្មា សតញ្ច អសតញ្ច
នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ
សន្តោ សគ្គបរាយនាតិ ។

អថខោ អបរា ទេវតា ភគវន្តំ ឯតទវោច កស្ស នុ ខោ ភគវា សុភាសិតន្តិ ។

---
១ ឱ. ទុរន្នយោ ។

ធម៌នេះ ជាធម៌របស់បុរាណាចារ្យ ជនពួកខ្លះ កាលទ្រព្យ
មានតិចក៏នៅតែឲ្យទានបាន ជនពួកខ្លះសូម្បីសម្បូណ៌ទ្រព្យ
ច្រើន ក៏ឲ្យទានមិនកើត ទក្ខិណាទាន ដែលគេបែងអំពី
ទ្រព្យតិចហើយឲ្យ រមែងមានផលស្មើគ្នានឹងទានរាប់ពាន់ ។

[៩១] លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

កាលបើពួកសប្បុរស កំពុងឲ្យរបស់ដែលឲ្យបានដោយកម្រ
កំពុងធ្វើអំពើដែលធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាម
មិនបាន (ព្រោះ) ធម៌របស់ពួកសប្បុរស គឺពួកអសប្បុរស
ប្រព្រឹត្តតាមបានដោយកម្រ ព្រោះហេតុនោះ គតិរបស់ពួក
សប្បុរសនិងអសប្បុរស រមែងផ្សេងគ្នា អំពីលោកនេះទៅ
គឺពួកអសប្បុរស ទៅកាន់នរក ពួកសប្បុរស ទៅកាន់
ឋានសួគ៌ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភាសិតរបស់អ្នកណាហ្ន៎ ជាសុភាសិត ។

[៩២] សញ្ញាសំ ហ៊ៃ សុភាសិតំ បរិយាយេន អបិច មមាបិ សុណាថ

ជម្មំ ចរេ យោបិ សមុញ្ជកំ[១] ចរេ
ជារំ ច ចោសំ ឧជំ អប្បកស្មឹ
សតំ សហស្សានំ សហស្សយាគិនំ
កលំបិ ជាគ្ឃន្តិ តថាវិជស្ស តេតិ ។

[៩៣] អថខោ អបរា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ

កោនេស[២] យញ្ញោ វិបុលោ មហគ្គតោ
សមេន ទិន្នស្ស ន អគ្ឃមេតិ
កាជំ[៣] សហស្សានំ សហស្សយាគិនំ
កលំបិ ជាគ្ឃន្តិ តថាវិជស្ស តេតិ ។

១ ម. អ. ឯវំ ។ ឱ. យោ សមុច្ឆកំ ។ ២ ឱ. កេនេសំ ។ ៣ ឱ. ម. សហស្សានំ ។

[៩២] ភាសិតរបស់អ្នកគ្រប់គ្នា ជាសុភាសិត ដោយបរិយាយដែរហើយ តែអ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់តថាគតវិញថា

ជនណា ចិញ្ចឹមភរិយាផង កាលបើទ្រព្យមានតិច នៅតែឲ្យទានបានផង ប្រព្រឹត្តធម៌បានផង ប្រព្រឹត្តនូវសេចក្តីខ្វល់ខ្វាយ (ក្នុងការងារ) ផង ពួកជនដែលមានការបូជារាប់ពាន់ដល់បុគ្គលមួយសែននាក់ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះបាន ។

[៩៣] លំដាប់នោះ ទេវតាមួយអង្គទៀត បានពោលគាថាចំពោះព្រះមានព្រះភាគថា

យ័ញ្ញនុ៎ះ មានផលដ៏ទូលាយច្រើនដែរ នៅតែមិនដល់ទានដែលបុគ្គលឲ្យហើយ ដោយធម៌ដ៏ស្មើ តើដោយហេតុដូចម្តេច បុគ្គល មានការបូជារាប់ពាន់ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះ តើដូចម្តេច ។

[៩៤] អថខោ ភគវា តំ ទេវតំ គាថាយ អជ្ឈភាសិ

ទទន្តិ ហេកេ[១] វិសមេ និវិដ្ឋា

ឃត្វា[២] វធិត្វា អថ សោចយិត្វា

សា ទក្ខិណា អស្សុមុខា សទណ្ឌា

សមេន ទិន្នស្ស ន អគ្ឃមេតិ

ឯវំ សហស្សាន[២] សហស្សយាគិនំ

កាលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

# តតិយំ សាធុសុត្តំ

[៩៥] អថខោ សម្ពហុលា សតុល្លប្បកាយិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវ-លកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុ-បសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-មន្តំ អដ្ឋំសុ ។

១ ឱ. ឯកេ ។ ២ ឱ. ឆេត្វា ។ ៣ ម. ឯវំ សតំ សហស្សានំ ។

[៩៤] លំដាប់នោះឯង ព្រះមានព្រះភាគ បានត្រាស់នឹងទេវតា នោះ ដោយគាថា ថា

បុគ្គលពួកមួយ បានឋិតនៅស៊ប់ក្នុងធម៌មិនស្មើ ហើយបៀត បៀន សម្លាប់ ពុំនោះសោត ធ្វើបុគ្គលដទៃឲ្យសោកសៅ ទើបឲ្យទាន ទក្ខិណាទាននោះ ឈ្មោះថា មានមុខទទឹក ដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិនដល់នូវតម្លៃនៃទាន ដែលបុគ្គលឲ្យហើយដោយធម៌ដ៏ស្មើទេ បុគ្គលមានការបូជា រាប់ពាន់ ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយ ចំណិតរបស់បុគ្គលយ៉ាងនោះ ដូច្នេះឯង ។

## សាធុសូត្រ ទី ៣

[៩៥] លំដាប់នោះឯង កាលរាត្រីបឋមយាម កន្លងទៅហើយ ពួកសតុល្លប្បកាយិកាទេវតាជាច្រើន មានរស្មីដ៏រុងរឿង ញុំាំងវត្តជេត-ពនទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅ ដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។

[៩៦] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សាធុ[១] ខោ មារិស ទានំ
មច្ឆេរា ច បមាទា ច
ឯវំ ទានំ ន ទីយតិ
បុញ្ញមាកង្ខមានេន
ទេយ្យំ ហោតិ វិជានតាតិ ។

[៩៧] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សាធុ ខោ មារិស ទានំ
អបិច អប្បកស្មឹបិ សាហុ[២] ទានំ
អប្បស្មេកេ បវេច្ឆន្តិ
ពហុនេកេ ន ទិច្ឆរេ
អប្បស្មា ទក្ខិណា ទិន្នា
សហស្សេន សមំ មិតាតិ ។

១ ម. សាហុ ។ ២ ឱ. អប្បស្មឹបិ សាធូតិ ទិស្សតិ ។

[៩៦] ទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរ បន្លឺនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទានជាការប្រពៃណាស់ បុគ្គលឲ្យ
ទានមិនបាន យ៉ាងនេះ ព្រោះសេចក្តីកំណាញ់ផង ព្រោះ
សេចក្តីប្រហែសផង ទាន កាលបើបុគ្គលដឹងច្បាស់ ជា
អ្នកប្រាថ្នានូវបុណ្យ គួរតែឲ្យ ។

[៩៧] លំដាប់នោះ ទេវតាមួយអង្គទៀត បន្លឺនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទាន ជាការប្រពៃណាស់ កាល
ដែលទ្រព្យមានតិច នៅតែឲ្យបាន ជាការប្រពៃ ជនពួក
ខ្លះ សូម្បីមានទ្រព្យបន្តិចបន្តួច ក៏ឲ្យបាន ជនពួកខ្លះមាន
ទ្រព្យច្រើនតែឲ្យមិនកើត ទក្ខិណាទានដែលគេចែករំលែក
អំពីទ្រព្យតិច ហើយឲ្យ មានផលស្មើគ្នានឹងទានដទៃរាប់
ពាន់ ។

៤៣

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ ទានប្បញ្ញា

[៩៨] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សាធុ ខោ មារិស ទានំ

អប្បកស្មឹបិ សាធុ ទានំ

អបិច សទ្ធាយបិ សាធុ ទានំ

ទានញ្ច យុទ្ធញ្ច សមានមាហុ

អប្បាបិ សន្តា ពហុកេ ជិនន្តិ

អប្បម្បិ ចេ សទ្ទហានោ ទទាតិ

តេនេវ សោ ហោតិ សុខី បរត្ថាតិ ។

[៩៩] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ទេវតាសំយុត្ត សតុល្លប្បកាយិកវគ្គ ទានប្បញ្ញា

[៩៨] លំដាប់នោះ ទេវតាដទៃទៀត បានបន្ទឹនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បពិត្រព្រះអង្គអ្នកនិទុក្ខ ទាន ជាការប្រពៃណាស់ កាល ដែលទ្រព្យមានតិច នៅតែឲ្យបាន ជាការប្រពៃ មួយទៀត ការឲ្យដោយសទ្ធា ជាការប្រពៃ ពួកអ្នកប្រាជ្ញ ពោលថា ទាននិងចម្បាំង មានកម្លាំងស្មើគ្នា ពួកសប្បុរស សូម្បី មានគ្នាតិច រមែងឈ្នះពួកអសប្បុរសដែលមានគ្នាច្រើនបាន កាលបើបុគ្គលណាជឿ (កម្មផល) ហើយឲ្យទានសូម្បីបន្តិច បន្តួច បុគ្គលនោះ រមែងបានសេចក្តីសុខក្នុងលោកខាងមុខ ព្រោះតែទាននោះឯង ។

[៩៩] លំដាប់នោះ ទេវតាដទៃទៀត បានបន្ទឹនូវឧទាន នេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

សាធុ ខោ មារិស ធានំ
អប្បកស្មឹបិ សាហុ ធានំ
សទ្ធាយបិ សាហុ ធានំ
អបិច ធម្មលទ្ធស្សាបិ សាហុ ធានំ
យោ ធម្មលទ្ធស្ស ទធាតិ ធានំ
ឧដ្ឋានវីរិយាធិគតស្ស ជន្តុ[១]
អតិក្កម្ម[២] វេតរណឹ យមស្ស
ទិព្វានិ ឋានានិ ឧបេតិ មច្ចោតិ ។

[១០០] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧធានំ ឧធានេសិ

១ ជន្តុនោតិប្បត្តិ ។ ២ ឱ. ម. ឯត្ថន្តរេ សោតិ ទិស្សតិ ។

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទាន ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិច នៅតែឲ្យបាន ជាការប្រពៃ ការឲ្យដោយសទ្ធា ជាការប្រពៃ មួយទៀត ការឲ្យនូវរបស់ដែលបានមកដោយធម៌ ជាការប្រពៃ ជនណាឲ្យទានដល់បុគ្គលអ្នកបានធម៌ អ្នកត្រាស់ដឹងដោយសេចក្តីសង្វាតនិងសេចក្តីព្យាយាម ជន (នោះ) កន្លងបង់នូវវេតរណិនរក[១] របស់ស្តេចយមៈ ហើយដល់នូវឋានទាំងឡាយ ជាទិព្វបាន ។

[១០០] លំដាប់នោះ ទេវតាដទៃទៀត បានបន្ទឹនូវឧទាននេះក្នុងសំណាក់នៃព្រះមានព្រះភាគថា

១ អដ្ឋកថា ថា មិនមែនត្រឹមតែវេតរណិនរកទេ រាប់បញ្ចូលទាំងនរកឯទៀត មានសញ្ជីវនរកនិងកាឡសុត្តនរកជាដើម ។

សាធុ ខោ មារិស ទានំ
អប្បកស្មឹបិ សាហុ ទានំ
សទ្ធាយបិ សាហុ ទានំ
ធម្មលទ្ធស្សបិ សាហុ ទានំ
អបិច វិចេយ្យទានំបិ សាធុ
វិចេយ្យទានំ សុគតប្បសត្ថំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
ពីជានិ វុត្តានិ យថា សុខេត្តេតិ ។

[១០១] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ

សាធុ ខោ មារិស ទានំ
អប្បកស្មឹបិ សាហុ ទានំ
សទ្ធាយបិ សាហុ ទានំ
ធម្មលទ្ធស្សបិ សាហុ ទានំ
វិចេយ្យទានំបិ សាធុ

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទាន ជាការប្រពៃណាស់ កាលដែលមានទ្រព្យតិច នៅតែឲ្យបាន ជាការប្រពៃ មួយទៀត ការឲ្យដោយសទ្ធា ជាការប្រពៃ ទាំងឲ្យរបស់ដែលបានមកដោយធម៌ ជាការប្រពៃ ប៉ុន្តែការពិចារណាហើយឲ្យ ទើបជាការប្រពៃពិត ព្រោះទានដែលបុគ្គលពិចារណាហើយឲ្យ ព្រះសុគតទ្រង់សរសើរ ពួកទក្ខិណេយ្យបុគ្គលណាមានក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យ ចំពោះពួកទក្ខិណេយ្យ-បុគ្គលនុ៎ះ មានផលច្រើន ដូចជាពូជដែលបុគ្គលសាបព្រោះក្នុងស្រែល្អ ។

[១០១] លំដាប់នោះ ទេវតាដទៃទៀត បានបន្ទឹនូវឧទាននេះក្នុងសំណាក់នៃព្រះមានព្រះភាគថា

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទាន ជាការប្រពៃណាស់ កាលដែលមានទ្រព្យតិច នៅតែឲ្យបាន ជាការប្រពៃ ការឲ្យទានដោយសទ្ធា ជាការប្រពៃ ការឲ្យរបស់ដែលបានមកដោយធម៌ជាការប្រពៃ ការពិចារណាហើយឲ្យ ក៏ជាការប្រពៃហើយ

អបិច ចាណោសុបិ សាធុ សំយមោ
យោ ចាណភូតានិ[១] អហេឋយំ ចរំ
បរូបវាទា ន ករោតិ[២] ចាបំ
ភីរុំ បសំសន្តិ ន ហិ តត្ថ សូរំ
ភយា ហិ សន្តោ ន ករោន្តិ ចាបន្តិ ។

[១០២] អថខោ អបរា ទេវតា ភគវន្តំ ឯតទវោច
កស្ស នុ ខោ ភគវា សុភាសិតន្តិ ។

[១០៣] សព្វាសំ វោ សុភាសិតំ បរិយាយេន
អបិច មមាបិ[៣] សុណាថ

សទ្ធាហិ[៤] ទានំ ពហុធា បសត្ថំ
ទានា ច[៥] ខោ ធម្មបទំ វ សេយ្យោ
បុព្វេវ ហិ បុព្វតរេវ សន្តោ
និព្វានមេវជ្ឈគមុំ សបញ្ញាតិ ។

---

១ ឱ. បាណភូតេសុ ។ ២ ម. ន ករោន្តិ ។ ៣ ឱ. មមំបីតិ ទិស្សតិ ។ ៤ ឱ. អទ្ធាហីតិ វា បាឋោ ។ ៥ ឱ. ម. អ. ឯវំ ។

ប៉ុន្តែការសង្រួម គឺការមិនបៀតបៀនក្នុងសត្វទាំងឡាយ ក៏រឹតតែជាការប្រពៃណាស់ បុគ្គលណាមិនប្រព្រឹត្តបៀតបៀននូវសត្វទាំងឡាយ មិនធ្វើបាប ព្រោះខ្លាចការតិះដៀលអំពីអ្នកដទៃ ជនទាំងឡាយ តែងសរសើរបុគ្គលខ្លាចបាប មិនសរសើរបុគ្គលក្លៀវក្លា ក្នុងបាបនោះទេ ឯពួកសប្បុរសមិនធ្វើបាប ព្រោះខ្លាចបាប ។

[១០២] លំដាប់នោះ ទេវតាដទៃទៀត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភាសិតរបស់អ្នកណាហ្ន៎ ជាសុភាសិត ។

[១០៣] ព្រះមានព្រះភាគត្រាស់ថា ភាសិត របស់អ្នកទាំងឡាយគ្រប់គ្នា ជាសុភាសិត ដោយបរិយាយដែរហើយ តែអ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់តថាគតវិញថា

ការឲ្យដោយសទ្ធា អ្នកប្រាជ្ញសរសើរ ដោយចំណែកច្រើនប្រការ តែថាធម៌ជាឧបាយដើម្បីព្រះនិព្វាន ត្រឹមតែ ១ បទ ក៏ប្រសើរក្រៃលែងជាងទានទៅទៀត ព្រោះសប្បុរសទាំងឡាយជាន់ដើម ឬជាន់ដើមទៅទៀត ដែលជាអ្នកប្រកបដោយប្រាជ្ញា ក៏បានដល់ព្រះនិព្វានមែនពិត ។

## ៤៧

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ មនុជេសុ អនិច្ចា កាមា

# ចតុត្ថំ នសន្តិសុត្តំ

[១០៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា សតុល្លប្បកាយិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[១០៥] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ន សន្តិ កាមា មនុជេសុ និច្ចា
សន្តីធ កមនីយានិ យេសុ ពទ្ធោ[១]
យេសុ បមត្តោ អបុនាគមនំ
អនាគន្ត្វា បុរិសោ មច្ចុធេយ្យាតិ ។

---

១ ម. កាមេសុ ពន្ធោ ។

# នសន្តិសូត្រ ទី ៤

[១០៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯងកាលរាត្រីបឋមយាមកន្លងហើយ ពួកសតុល្លប្បកាយិកាទេវតា មានប្រមាណច្រើនអង្គ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាងនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

[១០៥] ទេវតាមួយអង្គ ឈរក្នុងទីសមគួរហើយ ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

កាមទាំងឡាយ ក្នុងពួកមនុស្ស រកទៀងគ្មានទេ បុរស
ដែលជាប់ចំពាក់ក្នុងឥដ្ឋារម្មណ៍ទាំងឡាយ ស្រវឹងក្នុងឥដ្ឋា-
រម្មណ៍ទាំងឡាយ ចេញចាកវដ្ដៈ ដែលជាលំនៅនៃមារ
ទៅកាន់ព្រះនិព្វាន ជាស្ថានមិនត្រឡប់មកវិញទៀត មិន
បានទេ ឥដ្ឋារម្មណ៍ទាំងនោះ រមែងមានក្នុងលោកនេះ ។

ឆន្ទជំ អឃំ ឆន្ទជំ ទុក្ខំ
ឆន្ទវិនយា អឃវិនយោ
អឃវិនយា ទុក្ខវិនយោតិ ។
ន តេ កាមា យានិ ចិត្រានិ លោកេ
សង្កប្បរាគោ បុរិសស្ស កាមោ
តិដ្ឋន្តិ ចិត្រានិ តថេវ លោកេ
អថេត្ថ ធីរា វិនយន្តិ ឆន្ទំ ។
កោធំ ជហេ វិប្បជហេយ្យ មានំ
សញ្ញោជនំ សព្វមតិក្កមេយ្យ
តំ នាមរូបស្មឹមសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ ទុក្ខា ។
បហាសិ សង្ខំ ន វិមានមាគា[១]
អច្ឆេជ្ជិ[២] តណ្ហំ ឥធ នាមរូបេ

១ ឱ. ម. ន វិមានមជ្ឈគា ។ ២ ឱ. អច្ឆេច្ឆិ ។

បញ្ចក្ខន្ធកើតអំពីតណ្ហា សេចក្តីទុក្ខក៏កើតអំពីតណ្ហា ការកម្ចាត់បង់បញ្ចក្ខន្ធ ព្រោះកម្ចាត់បង់តណ្ហាបាន ការកម្ចាត់បង់វដ្តទុក្ខ ក៏ព្រោះកម្ចាត់បង់បញ្ចក្ខន្ធបាន ។ អារម្មណ៍ដ៏វិចិត្រទាំងឡាយក្នុងលោក ហៅថាកាមនោះ មិនបានទេ តម្រេកដែលបុគ្គលត្រិះរិះ ទើបហៅថា កាមរបស់បុរស អារម្មណ៍ដ៏វិចិត្រទាំងឡាយ តែងឋិតនៅក្នុងលោក តាមធម្មតា តែថាពួកអ្នកប្រាជ្ញ តែងកម្ចាត់បង់នូវសេចក្តីប្រាថ្នាក្នុងអារម្មណ៍ទាំងនុ៎ះ ។ បុគ្គលត្រូវលះបង់សេចក្តីក្រោធ ត្រូវរំសាយសេចក្តីប្រកាន់ ត្រូវឆ្លងឲ្យផុតសញ្ញោជនៈទាំងអស់ ព្រោះថា ទុក្ខទាំងឡាយ មិនធ្លាក់លើបុគ្គលដែលមិនជាប់ចំពាក់ក្នុងនាមរូប ជាអ្នកឥតមានកង្វល់នោះទេ ។ បុគ្គលលះសេចក្តីបញ្ញត្តបានហើយ នឹងមិនបានមកកាន់វិមាន គឺផ្ទៃនៃមាតាទេ បុគ្គលកាត់បង់តណ្ហា ក្នុងនាមរូបនេះបានហើយ

៤៩



តំ ឆិន្នគន្ថំ អនិឃំ និរាសំ
បរិយេសមានា នាជ្ឈគមុំ[១]
ទេវា មនុស្សា ឥធ វា ហុរំ វា
សគ្គេសុ វា សព្វនិវេសនេសូតិ ។

[១០៦] តញ្ចេ ហិ នាទ្ទក្ខុំ[២] តថា វិមុត្តំ
(ឥច្ចាយស្មា មោឃរាជា)
ទេវា មនុស្សា ឥធ វា ហុរំ វា
នរុត្តមំ អត្ថចរំ នរានំ
យេ តំ នមស្សន្តិ បសំសិយា តេតិ ។

[១០៧] បសំសិយា តេបិ ភវន្តិ ភិក្ខុ
មោឃរាជាតិ ភគវា
យេ តំ នមស្សន្តិ តថា វិមុត្តំ
អញ្ញាយ ធម្មំ វិចិកិច្ឆំ បហាយ
សង្គាតិគា[៣] តេបិ ភវន្តិ ភិក្ខូតិ ។

---

១ ឱ. ម. ន ច អជ្ឈគមុំ ។ ២ ម. តំ វេ ទុក្ខំ ។ ៣ សង្គាតិគាតិ វា សង្ខាតិគាតិ វា បាឋោ ។

ពួកទេវតានិងពួកមនុស្ស ស្វែងរកបុគ្គលដែលផ្តាច់បង់ធម៌ជាគ្រឿងចាក់ស្រែះ ជាបុគ្គលឥតមានទុក្ខ ឥតមានតណ្ហានោះ មិនប្រទះក្នុងលោកនេះ ក្នុងលោកខាងមុខ ឬក្នុងឋានសួគ៌ ឬក៏ក្នុងលំនៅរបស់សត្វគ្រប់កន្លែង ។

[១០៦] (ព្រះមោឃរាជ មានអាយុ បានទូលសួរថា) បើពួកទេវតានិងមនុស្ស មើលមិនឃើញនូវបុគ្គលនោះ ដែលមានចិត្តរួចស្រឡះ យ៉ាងនោះហើយ ពួកទេវតានិងមនុស្សណា ក្នុងលោកនេះ ឬ លោកខាងមុខ នមស្ការព្រះអង្គដ៏ប្រសើរជាងជន ជាអ្នកប្រព្រឹត្តប្រយោជន៍ដល់នរជនទាំង-ឡាយ ពួកទេវតានិងមនុស្សនោះ គួរគេសរសើរឬទេ ។

[១០៧] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ នឹងមោឃរាជថា) ម្នាលភិក្ខុ ពួកទេវតានិងមនុស្សនោះ ឈ្មោះថាជាបុគ្គលគួរបុគ្គលសរសើរបានផង ម្នាលភិក្ខុ ពួកបុគ្គលណានមស្ការបុគ្គលដែលរួចចាកតណ្ហា ដោយប្រការដូច្នោះនោះ ពួកបុគ្គលនោះឈ្មោះថាបានដឹងច្បាស់នូវធម៌ លះបង់នូវវិចិកិច្ឆាជាបុគ្គលកន្លងបង់នូវធម៌ជាគ្រឿងជាប់ចំពាក់បានផង ។

# បញ្ចមំ ឧជ្ឈានសញ្ញិសុត្តំ

[១០៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា ឧជ្ឈានសញ្ញិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភា-សេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា វេហាសំ អដ្ឋំសុ ។

[១០៩] វេហាសំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

អញ្ញថា សន្តមត្តានំ
អញ្ញថា យោ បវេទយេ
និកច្ច កិតវស្សេវ
ភុត្តំ ថេយ្យេន តស្ស តំ
យញ្ហិ កយិរា តញ្ហិ វទេ
យំ ន កយិរា ន តំ វទេ
អករោន្តំ ភាសមានំ[១]
បរិជានន្តិ បណ្ឌិតាតិ ។

---

១ ម. អករោន្តំ អភាសមានំ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# ឧជ្ឈានសញ្ញិសូត្រ ទី ៥

[១០៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង កាលរាត្រីបឋមយាម កន្លងទៅហើយ ពួកទេវតាច្រើនអង្គ ជាអ្នកមានសេចក្តីសំគាល់ក្នុងការពោលទោស មានរស្មីដ៏រុងរឿង ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឋិតនៅនាអាកាស ។

[១០៩] ទេវតាមួយអង្គ ឋិតនៅនាអាកាសហើយ ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គលណា ប្រកាសសេចក្តីស្ងប់ដោយអាការផ្សេង ប្រកាសខ្លួនដោយអាការផ្សេង ការបរិភោគរបស់បុគ្គលនោះ ឈ្មោះថា បរិភោគ ដោយការលួចលាក់ ដូចជាព្រានសត្វស្ទាបបញ្ឆោតបាញ់សត្វយកសាច់មកបរិភោគ ព្រោះថា បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ ព្រោះពួកអ្នកប្រាជ្ញ តែងកំណត់ដឹងពួកបុគ្គលដែលបានតែខាងនិយាយ តែមិនធ្វើ ។

[១១០] ឧយិធំ ភាសិតមត្ថេន

ឯកាន្តសវនេន វា

អនុក្កមិតវេ(១) សក្ខា

យាយំ បដិបទា ឧទ្ធា

យាយ ធីរា បមុច្ចន្តិ

ឈាយិនោ មារពន្ធនា

ន វេ ធីរា បកុព្វន្តិ

វិទិត្វា លោកបរិយាយំ

អញ្ញាយ និព្វុតា ធីរា

តិណ្ណា លោកេ វិសត្តិកាន្តិ ។

[១១១] អថខោ តា ទេវតាយោ បបរិយំ បតិដ្ឋហិត្វា ភគវតោ ចាទេសុ សិរសា និបតិត្វា ភគវន្តំ ឯត-ឧវោចុំ អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលា យថាមូឡ្ហា យថាអកុសលា យា មយំ ភគវន្តំ អប្បសាទេតព្វំ(២) អមញ្ញិម្ហា តាសំ នោ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ អថខោ ភគវា សិតំ ចាត្វាកាសិ ។

១ ឱ. អនុក្កមិតុំ វេ ។ ម. អនុក្កមិតុំ យេ ។ ២ ឱ. ម. អសាទេតព្វំ ។

ទេវតាសំយុត្ត សគុលប្បកាយិកវគ្គ បដិបទាដ៏មាំនិងការសូមឲ្យព្រះសាស្តាអត់ទោស

[១១០] ព្រះមានព្រះភាគ ត្រាស់ថា បដិបទានេះឯង ជាបដិបទាដ៏មាំ ពួកអ្នកប្រាជ្ញមានឈានរមែងរួចចាកចំណង់មារ ដោយបដិបទាណា បុគ្គល មិនអាចប្រតិបត្តិបដិបទានេះ ដោយគ្រាន់តែចេះនិយាយ ឬគ្រាន់តែស្តាប់ ដោយចំណែកមួយទេ ពួកអ្នកប្រាជ្ញ ដឹងច្បាស់នូវហេតុក្នុងលោក បានដឹងនូវចតុសច្ចធម៌ ជាអ្នករំលត់កិលេស បានឆ្លងនូវតណ្ហាដែលផ្សាយទៅក្នុងលោក រមែងមិននិយាយអួតទេ ។

[១១១] គ្រានោះឯង ទេវតាទាំងឡាយនោះ ប្រតិស្ឋានលើប្រឹថពី ហើយក្រាបសិរ្សទៀបព្រះបាទនៃព្រះមានព្រះភាគ ទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះអង្គទាំងឡាយ តាមដោយខ្ញុំព្រះអង្គទាំងឡាយជាអ្នកល្ងង់ខ្លៅ ជាអ្នកវង្វេង ជាអ្នកមិនឈ្លាស ខ្ញុំព្រះអង្គទាំងឡាយណា បានមើលងាយព្រះមានព្រះភាគ ដែលជាបុគ្គលមិនគួរបៀតបៀន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អត់នូវទោសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយ ដល់ខ្ញុំព្រះអង្គទាំងឡាយនោះ ដើម្បីនឹងសង្រួមតទៅ ។ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើការញញឹមឲ្យប្រាកដឡើង ។

[១១២] អថខោ តា ទេវតាយោ ភិយ្យោសោ មត្តាយ[១] ឧជ្ឈាយន្តិយោ វេហាសំ អព្ភុគ្គច្ឆុំ ។ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ[២]

អច្ចយំ ទេសយន្តីនំ
យោ ចេ[៣] នប្បដិគ្គណ្ហាតិ
កោបន្តរោ ទោសគរុ
ស វេរំ បដិមុច្ចតីតិ ។
អច្ចយោ ចេ ន វិជ្ជេថ
នោ ចីធ អបហតំ[៤] សិយា
វេរានិ ន ច សម្មេយ្យុំ
កេនីធ កុសលោ សិយាតិ ។
កស្សច្ចយា ន វិជ្ជន្តិ
កស្ស នត្ថិ អចាហតំ[៥]
កោ ន សម្មោហមាបាទិ
កោធ[៦] ធីរោ សទា សតោតិ ។

---

១ ភិយោសោ មត្តាយាតិបិ បាឋោ ។ ២ ឱ. គាថមភាច ។ ៣ ឱ. វេ ។ ៤-៥ ឱ. ម. អបគតំ ។ ៦ ឱ. កោច ។

[១១២] លំដាប់នោះឯង ទេវតាទាំងនោះក៏ពោលទោសច្រើនហួសប្រមាណ ហើយហោះទៅឯអាកាស ។ ទេវតាមួយអង្គ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បើអ្នកណា មិនអត់ទោសឲ្យ ដល់បុគ្គលអ្នកសំដែងទោស អ្នកនោះឈ្មោះថា មានសេចក្ដីក្រោធនៅខាងក្នុង ធ្វើទោសឲ្យកាន់តែធ្ងន់ឡើង ឈ្មោះថាឱបក្រសោបពៀរទុក (ដូចជាបុគ្គលពាក់ឡេវក្ដុំ) ។ បើទោសមិនមានទេ កំហុសក្នុងលោកនេះក៏មិនមានដែរ បើពៀរទាំងឡាយមិនរម្ងាប់ទេ ក្នុងលោកនេះនឹងមានអ្នកឈ្លាសដូចម្ដេចបាន ។ បុគ្គលណាមិនមានទោសប្រព្រឹត្តកន្លង (ដោយវាចា) បុគ្គលណាមិនមានកំហុស បុគ្គលណា មិនដល់នូវសេចក្ដីភាន់ច្រឡំ បុគ្គលណា ជាអ្នកប្រាជ្ញ មានសតិសព្វកាលក្នុងលោកនេះ ។

[១១៣] តថាគតស្ស ពុទ្ធស្ស
សព្វភូតានុកម្បិនោ
តស្សច្ចយា ន វិជ្ជន្តិ
តស្ស នត្ថិ អបាហតំ
សោ ន សម្មោហមាបាទិ
សោធ ធីរោ សទា សតោតិ ។
អច្ចយំ ទេសយន្តីនំ
យោ ចេ នប្បដិគណ្ហតិ
កោបន្តរោ ទោសគរុ
ស[១] វេរំ បដិមុច្ចតិ
តំ វេរំ នាភិនន្ទាមិ
បដិគ្គណ្ហាមិ វោច្ចយន្តិ ។

## ឆដ្ឋំ សទ្ធាសុត្តំ

[១១៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ

១ ឱ. យំ ។

[១១៣] ព្រះមានព្រះភាគ ត្រាស់ថា ព្រះតថាគតនោះ ជាព្រះពុទ្ធ ជាអ្នកមានសេចក្តីអនុគ្រោះ ដល់សព្វសត្វ មិនមានទោសប្រព្រឹត្តកន្លងទេ ព្រះតថាគតនោះ មិនមានកំហុសទេ ព្រះតថាគតនោះ មិនដល់នូវសេចក្តីភាន់ច្រឡំទេ ព្រះតថាគតនោះ ជាអ្នកមានប្រាជ្ញាមានសតិសព្វកាលក្នុងលោកនេះ ។ បើអ្នកណាមិនអត់ទោសដែលប្រព្រឹត្តកន្លងដល់បុគ្គលអ្នកសំដែងទោស អ្នកនោះឈ្មោះថា មានសេចក្តីក្រោធនៅខាងក្នុង ធ្វើទោសឲ្យកាន់តែធ្ងន់ឡើង ឈ្មោះថាឱបក្រសោបពៀរទុក តថាគតមិនត្រេកអរនឹងពៀរនោះទេ តថាគតអត់ទោសដែលប្រព្រឹត្តកន្លង ដល់អ្នកទាំងឡាយហើយ ។

# សទ្ធាសូត្រ ទី ៦

[១១៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង

សម្ពហុលា សតុល្លបកាយិកា ទេវតាយោ អ-
ភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ
ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[១១៨] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ
សន្តិកេ ឥមំ គាថំ អភាសិ

សទ្ធា ទុតិយា បុរិសស្ស ហោតិ
នោ ចេ អស្សទ្ធិយមវតិដ្ឋតិ
យសោ ច កិត្តី ច តត្វស្ស ហោតិ[១]
សគ្គញ្ច សោ គច្ឆតិ សរីរំ បហាយាតិ ។
កោធំ ជហេ វិប្បជហេយ្យ មានំ
សញ្ញោជនំ សព្វមតិក្កមេយ្យ
តំ នាមរូបស្មឹមសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ សង្គាតិ ។

១ ឱ. ម. អ. ឯវំ ។

កាលវេលារាត្រីបឋមយាម កន្លងទៅហើយ ពួកសតុល្លប្បកាយិកាទេវតា[១] ជាច្រើន មានរស្មីល្អ ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

[១១៥] លុះទេវតាមួយអង្គ ឋិតនៅ ក្នុងទីសមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

សទ្ធាជាទីពីរ របស់បុរស បើបុគ្គលមិនឋិតនៅក្នុងភាពជាអ្នកមិនមានសទ្ធាទេ យសបរិវារក្តី កិត្តិសព្ទក្តី តែងមានដល់បុរសនោះ ព្រោះតែការមិនឋិតនៅក្នុងភាពជាបុគ្គល មិនមានសទ្ធានោះ លុះបុគ្គលនោះ លះសរីរៈហើយ រមែងទៅកាន់ឋានសួគ៌ ។ បុគ្គលគប្បីលះបង់សេចក្តីក្រោធ គប្បីលះបង់មានះ គប្បីលះបង់សំយោជនៈទាំងពួង សង្គធម៌ទាំងឡាយ[២] មិនធ្លាក់សង្កត់នូវបុគ្គលនោះ ដែលមិនជាប់ចំពាក់នៅក្នុងនាមនិងរូប មិនមានសេចក្តីក្រវល់ក្រវាយឡើយ ។

១ ទេវតាដែលបានអណ្តែតទៅកើតក្នុងឋានសួគ៌ ដោយអំណាចកាន់ធម៌ របស់សប្បុរស ។
២ សង្គៈប្រាំប្រការ មានកិលេសសង្គៈជាដើម ។ អដ្ឋកថា ។

[១១៦] បមាទមនុយុញ្ជន្តិ
ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី
ធនំ សេដ្ឋំវ រក្ខតិ
មា បមាទមនុយុញ្ជេថ
មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ
បប្បោតិ បរមំ សុខន្តិ ។

# សត្តមំ សមយសុត្តំ

[១១៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ ទសហិ ច លោកធាតូហិ ទេវតា[១] យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច ។

---
១ ឱ. ម. ទេវតាយោ ។

[១១៦] ពួកជនពាល ឥតប្រាជ្ញា តែងប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ អ្នកប្រាជ្ញ រមែងរក្សានូវសេចក្ដីមិនប្រមាទ ដូចជាគេរក្សាទុក នូវទ្រព្យដ៏ប្រសើរ បុគ្គលកុំគប្បីប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ កុំប្រកបរឿយ ៗ នូវការមូលមិត្តដោយតម្រេកក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ អ្នកមានឈាន រមែងដល់នូវសេចក្ដីដ៏ឧត្ដម ។

# សមយសូត្រ ទី ៧

[១១៧] ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ នាដែនសក្កៈ មួយអន្លើដោយភិក្ខុសង្ឃ ជាច្រើន ចំនួនភិក្ខុប្រាំរយរូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។ ក៏ពួកទេវតាមកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាដោយច្រើន ដើម្បីឃើញ ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។

[១១៨] អថខោ ចតុន្នំ សុទ្ធាវាសកាយិកានំ ទេវានំ ឯតទហោសិ អយំ ខោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ទសហិ ច លោកធាតូហិ ទេវតា[១] យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច យន្នូន មយម្បិ យេន ភគវា តេនុបសង្កមេយ្យាម ឧបសង្កមិត្វា ភគវតោ សន្តិកេ បច្ចេកគាថា ភាសេយ្យាមាតិ ។

[១១៩] អថខោ តា ទេវតា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា ភគវតោ បុរតោ បាតុរហំសុ[២] ។ អថខោ តា ទេវតា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[១២០] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

---

១ ឱ. ម. ទេវតាយោ ។ ២ ឱ. ម. បាតុរហេសុំ ។

[១១៨] លំដាប់នោះឯង ពួកសុទ្ធាវាសទេវតា ទាំងបួនអង្គ ត្រិះរិះ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ គង់នៅក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ នាដែនសក្កៈ មួយអន្លើដោយភិក្ខុសង្ឃ ជាច្រើន ចំនួនភិក្ខុប្រាំរយរូប សុទ្ធតែជាអរហន្តទាំងអស់ ក៏ពួកទេវតាមកអំពី លោកធាតុទាំង ១០ ប្រជុំគ្នាដោយច្រើន ដើម្បីឃើញ ព្រះមានព្រះ ភាគនិងភិក្ខុសង្ឃ បើដូច្នោះ គួរតែពួកយើង ចូលទៅគាល់ព្រះមាន ព្រះភាគដែរ លុះចូលទៅដល់ហើយ ពួកយើងគប្បីសំដែងនូវគាថាមួយ ម្នាក់ ៗ ក្នុងសំណាក់នៃព្រះមានព្រះភាគ ។

[១១៩] លំដាប់នោះឯង ទេវតាទាំងនោះ ក៏បាត់អំពីសុទ្ធា-វាសទេវលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ដូចជាបុរសមានកម្លាំង លាដៃដែលអង្កុញ ឬអង្កុញដៃដែលលា ដូច្នោះឯង ។ ទេវតាទាំងនោះ ក៏ថ្វាយបង្គំដោយគោរព ចំពោះព្រះ មានព្រះភាគហើយ ឋិតនៅក្នុងទីដ៏សមគួរ ។

[១២០] លុះទេវតាមួយអង្គ ឋិតនៅ ក្នុងទីសមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

## ៦៧



មហាសមយោ បវនស្មឹ
ទេវកាយា សមាគតា
អាគតម្ហ ឥមំ ធម្មសមយំ
ទក្ខិតាយេវ អបរាជិតសង្ឃន្តិ ។

[១២១] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

តត្រ ភិក្ខវោ សមាទហំសុ
ចិត្តំ អត្តនោ ឧជុកមកំសុ
សារថីវ នេត្តានិ គហេត្វា
ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតាតិ ។

[១២២] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ឆេត្វា ខីលំ ឆេត្វា បលីឃំ
ឥន្ទខីលំ ឱហច្ច[១] មនេជា
តេ ចរន្តិ សុទ្ធា វិមលា
ចក្ខុមតា សុទន្តា សុសូ នាគាតិ ។

---

១ ម. ឧហច្ច ។

*សម័យនេះ ជាសម័យប្រជុំធំក្នុងដងព្រៃ ពួកទេវតាក៏មកប្រជុំគ្នាហើយ យើងទាំងឡាយ មកកាន់ទីប្រជុំ ប្រកបដោយធម៌នេះ ដើម្បីឃើញអបរាជិតសង្ឃ គឺសង្ឃដែលមារផ្ចាញ់មិនបាន ។*

[១២១] *លំដាប់នោះ ទេវតាមួយអង្គទៀត ពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា*

*ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិ ធ្វើចិត្តរបស់ខ្លួន (ដែលវៀចកោង) ឲ្យជាចិត្តស្លូតត្រង់ ភិក្ខុជាបណ្ឌិតទាំងឡាយ តែងរក្សានូវឥន្ទ្រិយទាំងឡាយដោយល្អ ដូចជាសារថីកាន់ទប់នូវខ្សែបរទុកដូច្នោះឯង ។*

[១២២] *លំដាប់នោះ ទេវតាមួយអង្គទៀត ពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា*

*ភិក្ខុទាំងនោះ កាត់បង់នូវបង្គោល គឺរាគៈ ទោសៈ មោហៈ កាត់បង់នូវរនុកទ្វារ គឺរាគៈ ទោសៈ មោហៈ គាស់រំលើងនូវសសរគោល គឺរាគៈ ទោសៈ មោហៈ ហើយជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ជាអ្នកបរិសុទ្ធស្អាត ប្រាសចាកមន្ទិល ជានាគកម្លោះ មានចក្ខុ មានឥន្ទ្រិយទូន្មានល្អហើយ តែងត្រាច់ទៅ (ក្នុងទីទាំងពួងបានតាមប្រាថ្នា) ។*

[១៦៣] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

យេ កេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

# អដ្ឋមំ សកលិកសុត្តំ

[១៦៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ មទ្ទកុច្ឆិស្មឹ មិគទាយេ ។ តេន ខោ បន សមយេន ភគវតោ បាទោ[១] សកលិកា-យ[២] ខតោ ហោតិ ។ ភុសា សុទំ ភគវតោ វេទ-នា វត្តន្តិ សារីរិកា ទុក្ខា តិព្វា ខរា កដុកា អ-សាតា អមនាបា ។ តា សុទំ ភគវា សតោ សម្ប-ជានោ អធិវាសេតិ អវិហញ្ញមានោ ។ អថខោ ភគវា

១ ឱ. ឯវំ ។ ២ ម. សក្ខលិកាយ ។

[១២៣] លំដាប់នោះ ទេវតាមួយអង្គទៀត ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធ ជាទីរឭក
ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះ
បង់រាងកាយជារបស់មនុស្សហើយ នឹងទៅបំពេញក្នុងពួក
នៃទេវតាមិនខាន ។

# សកលិកសូត្រ ទី ៨

[១២៤] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងឱទ្យានឈ្មោះមទ្ទកុច្ឆិ ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះបាទនៃព្រះមានព្រះភាគទង្គិចដោយបំណែកថ្ម (ដែលទេវទត្តប្រមៀលមក) ។ វេទនាដ៏មានកម្លាំង ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត ក៏ប្រព្រឹត្តទៅក្នុងព្រះសរីរៈ នៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់មានព្រះសតិសម្បជញ្ញៈ ទ្រង់អត់សង្កត់ នូវវេទនាទាំងនោះបាន មិនលំបាកឡើយ ។ គ្រានោះ ព្រះមានព្រះភាគ

ចតុក្កុណ្ឌិំ សង្ឃាដិំ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេ(១) បាទំ អច្ចាធាយ សតោ សម្បជានោ ។

[១២៥] អថខោ សត្តសតា សតុល្លប្បកាយិកា ទេវតាយោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ មទ្ទកុច្ឆឹ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[១២៦] ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ នាគោ វត ភោ សមណោ គោតមោ នាគវតា ច បនុប្បន្នា(២) សារីរិកា វេទនា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា សតោ សម្បជានោ អធិវាសេតិ អវិហញ្ញមានោតិ ។

---

១ បាទេនាតិបិ បាឋោ ។ ២ ឱ. សមុប្បន្នា ។

ត្រាស់បង្គាប់ភិក្ខុ ឲ្យក្រាលសង្ឃាដី មានជាន់បួន ទ្រង់សម្រេចព្រះសីហសេយ្យាខាងស្តាំ តម្រួតព្រះបាទខាងឆ្វេង លើព្រះបាទខាងស្តាំ ទ្រង់មានព្រះសតិសម្បជញ្ញៈ ។

[១២៥] លំដាប់នោះ កាលវេលារាត្រីបឋមយាម កន្លងទៅហើយ ពួកសតុល្លប្បកាយិកាទេវតា ៧០០ អង្គ មានរស្មីដ៏ល្អ ញុំាងមទ្ទកុច្ឆិឱទ្យានទាំងមូលឲ្យភ្លឺ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។

[១២៦] លុះទេវតាមួយអង្គ ឋិតនៅ ក្នុងទីសមគួរហើយ ក៏បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា យីអើ ព្រះសមណគោតម ជានាគមែនហ្ន៎ ព្រោះព្រះអង្គ ជាបុគ្គលមានព្រះពលានុភាព ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

[១២៧] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ សីហោ វត ភោ សមណោ គោតមោ សីហវតា ច បនុប្បន្នា សារីកា វេធជា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា សតោ សម្បជានោ អធិវាសេតិ អវិហញ្ញមានោតិ ។

[១២៨] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ អាជានីយោ វត ភោ ស-មណោ គោតមោ អាជានីយវតា ច បនុប្បន្នា សា-រីកា វេធជា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា សតោ សម្បជានោ អធិវាសេតិ អវិ-ហញ្ញមានោតិ ។

[១២៧] លំដាប់នោះ ទេវតាមួយអង្គទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ ដូច្នេះថា យីអើ ព្រះសមណគោតម ជាសីហៈមែនហ្ន៎ ព្រោះព្រះអង្គជាអ្នកមិនតក់ស្លុត ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

[១២៨] លំដាប់នោះ ទេវតាមួយអង្គទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា យីអើ ព្រះសមណគោតមជាអាជា-នេយ្យមែនហ្ន៎ ព្រោះព្រះអង្គទ្រង់ជ្រាបនូវហេតុ ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

ទេវតាសំយុត្តស្ស  សតុល្លប្បកាយិកវគ្គោ  ទេវតោទានំ

[១២៩] អថខោ អបរា ទេវតា ភគវតោ សន្តិ-
កេ ឥមំ ឧទានំ ឧទានេសិ និសភោ វត ភោ
សមណោ គោតមោ និសភវតា ច បទុប្បន្នា សា-
រីរិកា វេទនា ទុក្ខា តិព្វា ខរា កដុកា អសាតា
អមនាបា សតោ សម្បជានោ អធិវាសេតិ អវិ-
ហញ្ញមានោតិ ។

[១៣០] អថខោ អបរា ទេវតា ភគវតោ សន្តិកេ
ឥមំ ឧទានំ ឧទានេសិ ធោរយ្ហោ វត ភោ សម-
ណោ គោតមោ ធោរយ្ហវតា ច បទុប្បន្នា សារីរិកា
វេទនា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា
សតោ សម្បជានោ អធិវាសេតិ អវិហញ្ញមានោតិ ។

[១២៩] លំដាប់នោះ ទេវតាមួយអង្គទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា យីអើ ព្រះសមណគោតម ជានិសភៈ[១] មែនហ្ន៎ ព្រោះព្រះអង្គជាបុគ្គលឥតមានអ្នកណាស្មើ ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

[១៣០] លំដាប់នោះ ទេវតាមួយអង្គទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា យីអើហ្ន៎ ព្រះសមណគោតម ព្រះអង្គជាធោរយ្ហបុគ្គលមែន ព្រោះព្រះអង្គជាអ្នកនាំទៅនូវធុរៈ ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

---

១ អដ្ឋកថា ថា គោឈ្មោលដែលជាធំជាងគោ ១ រយ ហៅថា ឧសភៈ ជាធំជាងគោ ១ ពាន់ ហៅថា អាសភៈ ជាធំជាងគោ ១ ម៉ឺន ហៅថា និសភៈ ។ ព្រះមានព្រះភាគទ្រង់ប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់ព្រះនាមថា និសភៈ ។

[១៣១] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ ទន្តោ វត ភោ សមណោ គោតមោ ទន្ធវតា ច បទុប្បន្នា សារីកា វេទនា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា សតោ សម្បជានោ អធិវាសេតិ អវិហញ្ញមានោតិ ។

[១៣២] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ ឧទានំ ឧទានេសិ បស្ស សមាធឹ សុភាវិតំ ចិត្តញ្ច សុវិមុត្តំ ន ចាភិណតំ[១] ន ចាបណតំ[២] ន ច សសង្ខារនិគ្គយ្ហ ចារិតវតំ[៣] យោ ឯវរូបំ បុរិសនាគំ បុរិសសីហំ បុរិសអាជានីយំ បុរិសនិសភំ បុរិសធោរយ្ហំ បុរិសទន្តំ អតិក្កាមិតព្វំ មញ្ញេយ្យ កិមញ្ញត្រ អទស្សនាតិ ។

១ អ. អភិណតំ ។ ២ អ. អបណតំ ។ ៣ ម. វារិវាវតំ ។ វារិតវតន្តិ អដ្ឋកថាយំ ទិស្សតិ ។

[១៣១] លំដាប់នោះ ទេវតាដទៃទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ ដូច្នេះថា យីអើហ្ន៎ ព្រះសមណគោតម ជាទន្តបុគ្គល (អ្នកប្រដៅព្រះហឫទ័យបាន) មែន ព្រោះព្រះអង្គជាអ្នកមិនមានពុតត្បុត ទោះបីវេទនា ជាទុក្ខ ក្លាខ្លាំង ក្រហល់ក្រហាយ មិនសប្បាយ មិនជាទីពេញចិត្ត កើតឡើង ប្រព្រឹត្តទៅក្នុងព្រះសរីរៈ ក៏ព្រះអង្គមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំបាន មិនលំបាកឡើយ ។

[១៣២] លំដាប់នោះ ទេវតាដទៃទៀត បន្លឺឧទានវាចានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគដូច្នេះថា សូមព្រះអង្គទតចំពោះតែអរហត្តផលសមាធិដែលចម្រើនល្អហើយ និងចិត្តដែលរួចស្រឡះដោយផលវិមុត្តិហើយ សូមកុំទតនូវចិត្តដែលប្រព្រឹត្តទៅតាមរាគៈ ប្រព្រឹត្តទៅតាមទោសៈ និងចិត្តដែលសង្កត់សង្កិននូវកិលេសដោយសេចក្តីព្យាយាមរបស់ខ្លួនហើយប្រព្រឹត្តទៅ អ្នកណាឡើយនឹងរាប់អានបុគ្គលដែលបៀតបៀននូវនាគបុរស សីហបុរស អាជានីយបុរស និសភបុរស ធោរយ្ហបុរស ទន្តបុរស មានសភាពយ៉ាងនេះដូចម្តេចបាន វៀរលែងតែបុគ្គលជាអន្ធពាលចេញ ។

៧៣

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ ទេវតោទានំ

បញ្ចវេទា សតំ សមំ

តបស្សី ព្រាហ្មណា ចរំ

ចិត្តញ្ច នេសំ ន សម្មា វិមុត្តំ

ហីនត្ថរូបា ន បារង្គមា តេតិ[១] ។

តណ្ហាធិបន្នា វតសីលពទ្ធា

លូខំ តបំ វស្សសតំ ចរន្តា

ចិត្តញ្ច នេសំ ន សម្មា វិមុត្តំ

ហីនត្ថរូបា ន បារង្គមា តេតិ ។

---

១ ឱ. ម. ឥតិសទ្ទោ នត្ថិ ។

ទេវតាសំយុត្ត សតុល្លប្បកាយិកវគ្គ ឧទានរបស់ទេវតា

ពួកព្រាហ្មណ៍ អ្នកទ្រទ្រង់នូវវេទទាំង ៤ ជាអ្នកប្រព្រឹត្ត អាស្រ័យនូវតបៈ អស់មួយរយឆ្នាំគត់ ក៏ចិត្តរបស់ពួកព្រាហ្មណ៍នោះ នៅតែមិនរួចស្រឡះដោយប្រពៃនៅឡើយ ព្រាហ្មណ៍ទាំងនោះ មានសភាពជាអ្នកធ្វើខ្លួនឲ្យថោកទាប មិនដល់នូវព្រះនិព្វានឡើយ ។ បុគ្គលអ្នកជាប់ចំពាក់ដោយសីលពត្ត[១] ព្រោះតណ្ហាគ្របសង្កត់ ទោះប្រព្រឹត្តនូវតបៈដ៏សៅហ្មង អស់មួយរយឆ្នាំ ក៏ចិត្តរបស់បុគ្គលទាំងនោះ មិនរួចស្រឡះដោយប្រពៃឡើយ បុគ្គលទាំងនោះ មានសភាពជាអ្នកធ្វើខ្លួនឲ្យថោកទាប មិនដល់នូវព្រះនិព្វានឡើយ ។

១ អដ្ឋកថា ថា ជាប់ចំពាក់ដោយទំនៀមនិងប្រក្រតីទាំងឡាយ មានទំនៀមនិងប្រក្រតីនៃពពែ និងឆ្កែជាដើម ។

ន មានកាមស្ស ទមោ ឥធត្ថិ
ន មោនមត្ថិ អសមាហិតស្ស
ឯកោ អរញ្ញេ វិហរម្បមត្តោ
ន មច្ចុធេយ្យស្ស តរេយ្យ បារន្តិ ។
មានំ បហាយ សុសមាហិតត្តោ
សុចេតសោ សព្វធិ វិប្បមុត្តោ
ឯកោ អរញ្ញេ វិហរំ អប្បមត្តោ
ស មច្ចុធេយ្យស្ស តរេយ្យ បារន្តិ ។

## នវមំ បឋមបជ្ជុន្នធីតុសុត្តំ

[១៣៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ កោកនទា[១] បជ្ជុន្នស្ស ធីតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ មហាវនំ ឱភា-សេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

១ ម. កោកនុទា ។

ក្នុងលោកនេះ បុគ្គល អ្នកប្រាថ្នានូវមានះ រមែងមិនមានការទូន្មានឥន្ទ្រិយ បុគ្គលអ្នកមានចិត្តមិនតាំងមាំ រមែងមិនមានបញ្ញា បុគ្គល ជាអ្នកប្រមាទ ទុកជានៅក្នុងព្រៃតែម្នាក់ឯង ក៏ឆ្លងនូវទីនៅរបស់មារទៅព្រះនិព្វាន ពុំបានឡើយ ។ បុគ្គលណា លះមានះបានហើយ មានចិត្តតម្កល់នៅដោយប្រពៃ មានចិត្តផូរផង់ រួចស្រឡះចាកធម៌ជាគ្រឿងសៅហ្មងទាំងពួង នៅក្នុងព្រៃតែម្នាក់ឯង ជាអ្នកមិនប្រមាទ បុគ្គលនោះ ទើបឆ្លងនូវទីនៅរបស់មារទៅព្រះនិព្វានបាន ។

# បឋមបជ្ជុន្នធីតុសូត្រ ទី ៩

[១៣៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ ទេវតាឈ្មោះកោកនទា ជាធីតានៃបជ្ជុន្នទេវរាជ មានរស្មីដ៏ល្អ ញុំាងមហាវ័នទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏អភិវាទព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ រតនត្តយប្បសំសា

[១៣៤] ឯកមន្តំ ឋិតា ខោ(១) កោកនទា បជ្ជុន្នស្ស ធីតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

វេសាលិវនេ វិហរន្តំ
អគ្គំ សត្តស្ស សម្ពុទ្ធំ
កោកនទាហមស្មិ អភិវន្ទេ
កោកនទា បជ្ជុន្នស្ស ធីតា
សុតមេវ បុរេ(២) អាសិ
ធម្មោ ចក្ខុមតានុពុទ្ធោ
សាហំ ទានិ សក្ខិ ជានាមិ
មុនិនោ ទេសយតោ សុគតស្ស
យេ កេចិ អរិយំ ធម្មំ
វិគរហន្តា ចរន្តិ ទុម្មេធា
ឧបេន្តិ រោរុវំ ឃោរំ
ចិររត្តំ ទុក្ខមនុភវន្តិ

១ ឱ. សា ទេវតាតិ បាឋទ្វយំ បញ្ញាយតិ ។ ២ ឱ. សុតមេវ មេ បុរេ ។

ទេវតាសំយុត្ត សតុល្លប្បកាយិកវគ្គ សេចក្តីសរសើរព្រះរត្នត្រ័យ

[១៣៤] លុះទេវតាឈ្មោះកោកនទា ជាធីតានៃបជ្ជុន្នទេវរាជ ឋិត នៅក្នុងទីដ៏សមគួរហើយ បានពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃ ព្រះមានព្រះភាគថា

ខ្ញុំម្ចាស់ឈ្មោះកោកនទា ខ្ញុំម្ចាស់ឈ្មោះកោកនទា ជាធីតានៃ បជ្ជុន្នទេវរាជ សូមថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គជាកំពូលរបស់ សត្វ ទ្រង់គង់នៅក្នុងមហាវ័ន ជិតក្រុងវេសាលី ក្នុងកាល មុន ខ្ញុំម្ចាស់បានឮថា ព្រះធម៌ គឺព្រះតថាគត អ្នកមាន ចក្ខុ ត្រាស់ដឹងហើយ ឥឡូវនេះ ខ្ញុំម្ចាស់ដឹងច្បាស់លាស់ (នូវធម៌) ដែលព្រះសុគតជាមុនីសម្តែងហើយ ពួកបុគ្គល អាប់ប្រាជ្ញាណាមួយ ប្រព្រឹត្តតិះដៀល នូវព្រះធម៌ដ៏ប្រសើរ នឹងចូលទៅដល់រោរុវនរក រងទុក្ខដ៏ក្លា អស់រាត្រីយូរអង្វែង

យេ ច ខោ អរិយេ ធម្មេ
ខន្តិយា ឧបសមេន ឧបេតា
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

## ទសមំ ទុតិយបជ្ជុន្នធីតុសុត្តំ

[១៣៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ចុល្លកោកនទា បជ្ជុន្នស្ស ធីតា អភិក្កន្តា-យ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ មហាវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[១៣៦] ឯកមន្តំ ឋិតា ខោ ចុល្លកោកនទា បជ្ជុន្នស្ស ធីតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

លុះតែបុគ្គលពួកណា មានខន្តី ចូលទៅរម្ងាប់កិលេសមានរាគៈជាដើម ក្នុងអរិយធម៌ ទើបបុគ្គលពួកនោះ លះបង់នូវរាងកាយ ជារបស់មនុស្ស ហើយនឹងចូលទៅបំពេញនូវកាយជារបស់ទេវតាបាន ។

## ទុតិយបជ្ជុន្នធីតុសូត្រ ទី ១០

[១៣៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ ទេវតា ឈ្មោះចុល្លកោកនទា ជាធីតានៃបជ្ជុន្នទេវរាជ មានរស្មីដ៏ល្អញុំាំងមហាវ័នទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏អភិវាទព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

[១៣៦] លុះទេវតាឈ្មោះចុល្លកោកនទា ជាធីតានៃបជ្ជុន្នទេវរាជ ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

៧៧

ទេវតាសំយុត្តស្ស សតុល្លប្បកាយិកវគ្គេ ឧទ្ទានំ

ឥធាគមា វិជ្ជុបភាសវណ្ណា
កោកនទា បជ្ជុន្នស្ស ធីតា
ពុទ្ធញ្ច ធម្មញ្ច នមស្សមានា
គាថាវិមា[១] អត្ថវតី អភាសិ

ពហុនាបិ ខោ នំ វិភជេយ្យំ បរិយាយេន តាទិសោ ធម្មោ
សង្ខិត្តមត្ថំ លបយិស្សាមិ យាវតា មេ មនសា បរិយត្តំ

បាបំ ន កយិរា វចសា មនសា
កាយេន វា កិញ្ចន សព្វលោកេ
កាមេ បហាយ សតិមា សម្បជានោ
ទុក្ខំ ន សេវេថ អនត្ថសញ្ហិតន្តិ ។

សតុល្លប្បកាយិកវគ្គោ ចតុត្ថោ ។

## តត្រុទ្ទានំ

សព្ភិ មច្ឆរិនា សាធុ
នសន្តុជ្ឈានសញ្ញិនោ
សទ្ធា សមយោ សកលិកំ
ឧភោ បជ្ជុន្នធីតរោតិ ។

---

១ គាថា ចិមាតិបិ បាឋោ ។

ទេវតាឈ្មោះកោកនទា ជាធីតានៃបជ្ជុន្នទេវរាជ មានរស្មីដ៏ភ្លឺដូចជាផ្ទៃកបន្ទោរ មកហើយក្នុងទីនេះ កាលនមស្ការព្រះពុទ្ធ ព្រះធម៌ (និងព្រះសង្ឃ) បានពោលនូវគាថានេះ ដ៏ប្រកបដោយអត្ថថា

ខ្ញុំម្ចាស់ក៏ត្រូវចែកនូវគាថានោះ ដោយបរិយាយដ៏ច្រើនប្រការ ធម៌បែបនោះ ខ្ញុំម្ចាស់នឹងសំដែងនូវសេចក្តីយ៉ាងសង្ខេប ធម៌ទាំងប៉ុន្មាននោះ ខ្ញុំម្ចាស់បានរៀនដោយចិត្ត (ជ្រះថ្លា) បុគ្គលមិនគប្បីធ្វើបាប ដោយកាយវាចាចិត្ត បុគ្គលគប្បីលះបង់នូវកង្វល់ក្នុងលោកទាំងពួង គប្បីលះបង់នូវកាមទាំង-ឡាយ គប្បីជាអ្នកមានសតិនិងសម្បជញ្ញៈ មិនគប្បីសេពអំពើឥតប្រយោជន៍ ដែលនាំមកនូវសេចក្តីទុក្ខ ។

ចប់ សតុល្លប្បកាយិកវគ្គ ទី ៤ ។

# បញ្ជីរឿងក្នុងសតុល្លប្បកាយិកវគ្គនោះ គឺ

សព្ភិសូត្រ ១ មច្ឆរិសូត្រ ១ សាធុសូត្រ ១ នសន្តិសូត្រ ១ ឧជ្ឈានសញ្ញិសូត្រ ១ សទ្ធាសូត្រ ១ សមយសូត្រ ១ សក-លិកសូត្រ ១ បជ្ជុន្នធីតុសូត្រ ២ ។

# បញ្ចមោ អាទិត្តវគ្គោ

## បឋមំ អាទិត្តសុត្តំ

[១៣៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា-មេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[១៣៨] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

អាទិត្តស្មឹ អគារស្មឹ
យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ
នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ[១]

១ ឱ. ឯវមាទីបិតោ លោកោ ។ ម. ឯវំ ។

# អាទិត្តវគ្គ ទី ៥

## អាទិត្តសូត្រ ទី ១

[១៣៧] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះឯង កាលដែលវេលារាត្រីបឋមយាម កន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏អភិវាទព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

[១៣៨] លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ បានពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គល ជញ្ជូននូវភាជន៍ណា អំពីផ្ទះដែលភ្លើងកំពុងឆេះ ពុំ
នោះសោត ភ្លើងមិនទាន់ឆេះនូវវត្ថុណាក្នុងផ្ទះនោះ ភាជន៍
និងវត្ថុនោះជាប្រយោជន៍នៃបុគ្គលនោះឯង សត្វលោកដែល

៧៩



ជរាយ មរណេន ច
នីហរេថេវ ទានេន
ទិន្នំ ហោតិ សុនិព្ភតំ[១]
ទិន្នំ សុខផលំ ហោតិ
នាទិន្នំ ហោតិ តំ តថា
ចោរា ហរន្តិ រាជានោ
អគ្គិ ឌយ្ហតិ នស្សតិ
អថ អន្តេន ជហាតិ
សរីរំ សបរិគ្គហំ
ឯតទញ្ញាយ មេធាវី
ភុញ្ជេថ ច ទទេថ ច
ទត្វា ច[២] ភុត្វា ច យថានុភាវំ
អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

---

១ ឱ. សុនីហតំ ។ ២ ឱ. ច- ការោ នត្ថិ ។

ទេវតាសំយុត្ត អាទិត្តវគ្គ ផលរបស់ទាន

ជរានិងមរណៈឆេះយ៉ាងនេះ ត្រូវតែនាំទ្រព្យចេញ ដោយទានកុំខាន ទានដែលបុគ្គលឲ្យហើយ ឈ្មោះថានាំចេញដោយល្អ វត្ថុដែលបុគ្គលឲ្យហើយ ជាវត្ថុមានសុខជាផល វត្ថុដែលបុគ្គល មិនឲ្យហើយ ជាវត្ថុមិនមានសុខជាផលទេ ពួកចោរតែងនាំទៅ ពួករាជការតែងរឹបយក ភ្លើងតែងឆេះវិនាសទៅ ពុំនោះសោត វេលាស្លាប់ទៅ ក៏រមែងលះបង់នូវសរីរៈនិងរបស់ដែលបុគ្គលធ្លាប់ហួងហែង អ្នកប្រាជ្ញដឹងនូវសេចក្ដីនេះហើយ គប្បីបរិភោគផង ឲ្យទានផង បុគ្គលឲ្យទានទាំងបរិភោគ ឲ្យសមគួរតាមសភាពហើយ គេមិនដែលនិន្ទាទេ តែងបានទៅកើតក្នុងឋានសួគ៌ ។

# ទុតិយំ កិន្ទទសុត្តំ

[១៣៩] កឹនទោ ពលទោ ហោតិ
កឹនទោ ហោតិ វណ្ណទោ
កឹនទោ សុខទោ ហោតិ
កឹនទោ ហោតិ ចក្ខុទោ
យោ ច[១] សព្វទទោ ហោតិ
តំ មេ អក្ខាហិ បុច្ឆិតោតិ ។

[១៤០] អន្នទោ ពលទោ ហោតិ
វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ
ទីបទោ ហោតិ ចក្ខុទោ
សោ ច សព្វទទោ ហោតិ
យោ ទទាតិ ឧបស្សយំ
អមតន្ទទោ ច សោ ហោតិ
យោ ធម្មមនុសាសតីតិ ។

១ ឱ. ម. កោ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# កិន្ទទសូត្រ ទី ២

[១៧៩] ទេវតាក្រាបបង្គំសួរថា បុគ្គលឲ្យអ្វី ឈ្មោះថាឲ្យកម្លាំង ឲ្យអ្វី ឈ្មោះថាឲ្យពណ៌សម្បុរ ឲ្យអ្វី ឈ្មោះថាឲ្យសេចក្ដីសុខ ឲ្យអ្វី ឈ្មោះថាឲ្យចក្ខុ មួយទៀត បុគ្គលណា ឲ្យរបស់អ្វី ឈ្មោះថាឲ្យគ្រប់យ៉ាង សូមព្រះអង្គសំដែងប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គជាអ្នកសួរ ។

[១៨០] ព្រះមានព្រះភាគត្រាស់ថា បុគ្គលឲ្យបាយ ឈ្មោះថាឲ្យកម្លាំង ឲ្យសំពត់ ឈ្មោះថាឲ្យពណ៌សម្បុរ ឲ្យយានជំនិះ ឈ្មោះថាឲ្យសេចក្ដីសុខ ឲ្យប្រទីប ឈ្មោះថាឲ្យចក្ខុ មួយទៀត បុគ្គលណា ឲ្យទីនៅអាស្រ័យ បុគ្គលនោះ ឈ្មោះថាឲ្យវត្ថុគ្រប់យ៉ាង បុគ្គលណា ប្រៀនប្រដៅធម៌ បុគ្គលនោះ ឈ្មោះថាឲ្យព្រះនិព្វាន ។

ទេវតាសំយុត្តស្ស  អាទិត្តវគ្គេ  បុញ្ញប្បសំសា

# តតិយំ  អន្នសុត្តំ

[១៤១] អន្នមេវាភិនន្ទន្តិ
ឧភយេ[១] ទេវមានុសា
អថ ខោ[២] នាម សោ យក្ខោ
យំ អន្នំ នាភិនន្ទតីតិ ។

[១៤២] យេ នំ ទទន្តិ សទ្ធាយ
វិប្បសន្នេន ចេតសា
តមេវ អន្នំ ភជតិ
អស្មឹ លោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ
ទជ្ជា ទានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

១ ម. ឯវំ ។ ឱ. ឧភយោ ។ ២ ឱ. អថ កោ ។

ទេវតាសំយុត្ត អាទិត្តវគ្គ សេចក្តីសរសើរបុណ្យ

# អន្នសូត្រ ទី ៣

[១៨១] ទ.[១] ជនទាំងពីរពួកគឺទេវតានិងមនុស្ស រមែងប្រាថ្នានូវបាយតែម្យ៉ាង អ្នកណា មិនប្រាថ្នានូវបាយ អ្នកនោះ ឈ្មោះថាយក្ខដោយពិត ។

[១៨២] ព.[២] ជនទាំងឡាយណា មានចិត្តជ្រះថ្លាឲ្យបាយនោះដោយសទ្ធា បាយនោះ រមែងចូលទៅរកជនទាំងនោះវិញ ក្នុងលោកនេះនិងលោកខាងមុខ ព្រោះហេតុនោះ សាធុជន គប្បីកម្ចាត់បង់នូវសេចក្តីកំណាញ់ចេញគ្របសង្កត់នូវមន្ទិលហើយឲ្យទានចុះ (ព្រោះថា) បុណ្យទាំងឡាយ ជាទីពឹងនៃពួកសត្វក្នុងបរលោក ។

១ ទ. គឺទេវតាទូលថា ។ ២ ព. គឺព្រះមានព្រះភាគត្រាស់ថា ។

# ចតុត្ថំ ឯកមូលសុត្តំ

[១៤៣] ឯកមូលំ ទ្វិអាវដ្ដំ[១]
តិមលំ បញ្ចបត្ថរំ
សមុទ្ទំ ទ្វាទសាវដ្ដំ
បាតាលំ អតរី ឥសីតិ ។

# បញ្ចមំ អនោមិយសុត្តំ

[១៤៤] អនោមនាមំ និបុណត្ថទស្សឹ
បញ្ញាទទំ កាមាលយេ អសត្តំ
តំ បស្សថ សព្វវិទុំ សុមេធំ
អរិយេ បថេ កមមានំ មហេសិន្តិ ។

១ ឱ. ម. ទ្វិរាវដ្ដំ ។

# ឯកមូលសូត្រ ទី ៤

[១៨៣] ទ. ឥសី បានឆ្លងហើយ នូវសមុទ្របាតាល ដែលមានមូលមួយគឺតណ្ហា មានអន្ទង់ពីរគឺសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ មានមន្ទិលបីគឺរាគៈ ទោសៈ មោហៈ មាន គ្រឿងផ្សាយចេញ ៥ យ៉ាងគឺបញ្ចកាមគុណ មានកំនួចទឹក ១២ គឺ អាយតនៈទាំង ១២ ។

# អនោមិយសូត្រ ទី ៥

[១៨៤] ទ. អ្នកទាំងឡាយ ចូរមើលនូវព្រះមានព្រះភាគ នោះ ព្រះអង្គមានព្រះនាមបរិបូណ៌ ព្រោះទ្រង់ប្រកបដោយ គុណទាំងពួង ព្រះអង្គឃើញនូវប្រយោជន៍ដ៏ល្អិតល្អ ជាអ្នក ឲ្យនូវបញ្ញា ព្រះអង្គមិនជាប់នៅក្នុងអាល័យគឺកាម ព្រះអង្គ ត្រាស់ដឹងសព្វ ព្រះអង្គមានប្រាជ្ញល្អ ព្រះអង្គស្តេចទៅក្នុង ផ្លូវដ៏ប្រសើរគឺអរិយមគ្គ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។

៨៣



# ឆដ្ឋំ អច្ឆរាសុត្តំ

[១៤៨] អច្ឆរាគណសង្ឃុដ្ឋំ
បិសាចគណសេវិតំ
វនន្តំ មោហនំ នាម
កថំ យាត្រា ភវិស្សតីតិ ។

[១៤៦] ឧជុកោ នាម សោ មគ្គោ
អភយា នាម សា ទិសា
រថោ អកុជ្ជនោ នាម
ធម្មចក្កេហិ សំយុត្តោ
ហិរិ តស្ស អបាលម្ពោ
សតស្ស[១] បរិវារណំ
ធម្មាហំ សារថឹ ព្រូមិ
សម្មាទិដ្ឋិបុរេជវំ
យស្ស ឯតាទិសំ យានំ
ឥត្ថិយា បុរិសស្ស វា
ស វេ ឯតេន យានេន
និព្វានស្សេវ សន្តិកេ ។

១ ឱ. សត្យស្សាតិ ទិស្សតិ ។

ទេវតាសំយុត្ត អាទិត្តវគ្គ សេចក្តីព្យាករនូវមគ្គ

# អច្ឆរាសូត្រ ទី ៦

[១៨៥] សមណទេវបុត្តពោលថា(១) ព្រៃឈ្មោះមោហនៈ នោះ ជាព្រៃគឹកកង់ដោយពួកនៃស្រីអប្សរ ជាទីសេពគប់នៃពួកបិសាច(២) ធ្វើដូចម្តេចនឹងយាត្រា (ចេញអំពីព្រៃនេះ) ទៅបាន ។

[១៨៦] ព. ផ្លូវគឺអដ្ឋង្គិកមគ្គនោះ ឈ្មោះថាជាផ្លូវត្រង់ ទិសគឺព្រះនិព្វាននោះ ឈ្មោះថាជាទិសគ្មានភ័យ រថគឺអដ្ឋង្គិកមគ្គ ឈ្មោះថាជារថមិនឮសូរ ប្រកបដោយកង់គឺធម៌បានដល់សេចក្តីព្យាយាមដោយកាយនិងចិត្ត ហិរិនិងឱត្តប្បៈជាទ្រពង់នៃរថនោះ សតិជាព្រ័ត្រជ្រាមនៃរថនោះ តថាគតពោលថា ធម៌គឺលោកុត្តរមគ្គជាសារថី មានសម្មាទិដ្ឋិជាសន្ទុះទៅខាងមុខ ជនណា ទោះស្រី ឬ ប្រុស បានយានបែបនោះហើយ ជននោះឯង នឹងដល់នូវទីជិតនៃព្រះនិព្វានដោយយាននុ៎ះមិនខាន ។

---

១-២ សមណទេវបុត្តនោះ ហៅព្រៃនន្ទវ័ន ថាព្រៃមោហនៈ ហៅពួកទេវតា ថាពួកបិសាច ព្រោះមិនមានសេចក្តីគាប់ចិត្តចំពោះព្រៃនន្ទវ័ននិងពួកទេវតានោះសោះ ។

## សត្តមំ  វនរោបសុត្តំ

[១៤៧]  កេសំ  ទិវា  ច  រត្តោ  ច
សទា  បុញ្ញំ  បវឌ្ឍតិ
ធម្មដ្ឋា  សីលសម្បន្នា
កេ  ជនា  សគ្គគាមិនោតិ  ។

[១៤៨]  អារាមរោបា  វនរោបា
យេ  ជនា  សេតុការកា
បបញ្ច  ឧទបានញ្ច
យេ  ទទន្តិ  ឧបស្សយំ
តេសំ  ទិវា  ច  រត្តោ  ច
សទា  បុញ្ញំ  បវឌ្ឍតិ
ធម្មដ្ឋា  សីលសម្បន្នា
តេ  ជនា  សគ្គគាមិនោតិ  ។

## អដ្ឋមំ  ជេតវនសុត្តំ

[១៤៩]  ឥទំ  ហិតំ  ជេតវនំ
ឥសិសង្ឃនិសេវិតំ

# វនរោបសូត្រ ទី ៧

[១៨៧] ទេ. បុណ្យ រមែងចម្រើនមិនដាច់ ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនពួកណា ជនពួកណា ឈ្មោះថាតាំងនៅក្នុងធម៌ ឈ្មោះថាបរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

[១៨៨] ព. ជនណា ដាំច្បារឈើមានផ្កាផ្លែ ដាំច្បារឈើមានម្លប់ សាងស្ពាន សាងរោង ឲ្យទានទឹកទាំងជីកស្រះ ជនទាំងឡាយណា ឲ្យនូវទីសំណាក់អាស្រ័យ បុណ្យ រមែងចម្រើនមិនដាច់ ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនទាំងឡាយនោះ ជនទាំងនោះ ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ឈ្មោះថាបរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

# ជេតវនសូត្រ ទី ៨

[១៨៩] អនាថបិណ្ឌិកទេវបុត្តពោលថា វត្តជេតពននេះជាវត្តមានប្រយោជន៍ ដែលពួកឥសីគឺភិក្ខុសង្ឃគង់នៅមិនដាច់

៨៤

ទេវតាសំយុត្តស្ស អាទិត្តវគ្គេ ជេតវនប្បសំសា

អាវុត្តំ ធម្មរាជេន
បីតិសញ្ជននំ មម
កម្មំ វិជ្ជា ច ធម្មោ ច
សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ
ន គោត្តេន ធនេន វា
តស្មា ហិ បណ្ឌិតោ ពោសោ
សម្បស្សំ អត្ថមត្តនោ
យោនិសោ វិចិនេ ធម្មំ
ឯវំ តត្ថ វិសុជ្ឈតិ
សារីបុត្តោ វ បញ្ញាយ
សីលេន ឧបសមេន ច
យោបិ ពារគតោ ភិក្ខុ
ឯតាវបរមោ សិយាតិ ។

ជាវត្តដែលព្រះសម្ពុទ្ធជាធម្មរាជ ទ្រង់គង់នៅ ជាទីញ៉ាំងបីតិឲ្យកើតដល់ខ្ញុំព្រះអង្គ សត្វទាំងឡាយ រមែងបរិសុទ្ធដោយអដ្ឋង្គិកមគ្គនេះ គឺកម្ម បានដល់មគ្គចេតនា វិជ្ជា បានដល់សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ធម្មៈ បានដល់សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ សីលៈ បានដល់សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ឈ្មោះថាជីវិតដ៏ឧត្តម មិនមែនបរិសុទ្ធ ដោយគោត្រ ឬ ដោយទ្រព្យទេ ព្រោះហេតុនោះឯង បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន គួរតែពិចារណានូវធម៌ ដោយឧបាយនៃប្រាជ្ញា រមែងបរិសុទ្ធ ក្នុងអរិយមគ្គនោះ យ៉ាងនេះឯងព្រះសារីបុត្ត ទើបជាបុគ្គល (ប្រសើរ) ដោយបញ្ញាផង ដោយសីលផង ដោយការស្ងប់រម្ងាប់ផង ភិក្ខុដែលប្រសើរដោយគុណធម៌ប៉ុណ្ណោះ ទើបគួរជាអ្នកដល់នូវព្រះនិព្វាន ។

# នវមំ មច្ឆរិសុត្តំ

[១៨០] យេធ មច្ឆរិនោ លោកេ
កទរិយា បរិភាសកា
អញ្ញេសំ ទទមានានំ
អន្តរាយករា នរា
កីទិសោ តេសំ វិបាកោ
សម្បរាយោ ច កីទិសោ
ភគវន្តំ បុដ្ឋុមាគម្ម
កថំ ជានេមុ តំ មយន្តិ ។

[១៨១] យេធ មច្ឆរិនោ លោកេ
កទរិយា បរិភាសកា
អញ្ញេសំ ទទមានានំ
អន្តរាយករា នរា
និរយំ តិរច្ឆានយោនឹ

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# មច្ឆរិសូត្រ ទី ៩

[១៥០] ១. ក្នុងលោកនេះ ជនទាំងឡាយណា ជាអ្នកកំណាញ់ស្វិតស្វាញ ជាអ្នកពោលពាក្យទ្រគោះ ជាអ្នកធ្វើសេចក្តីអន្តរាយ[១] ដល់ជនដទៃដែលកំពុងឲ្យទាន ផលវិបាករបស់ជនទាំងឡាយនោះដូចម្តេច សម្បរាយភពរបស់ជនទាំងឡាយនោះដូចម្តេច យើងខ្ញុំមកដើម្បីក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូចម្តេចហ្ន៎ នឹងដឹងនូវសេចក្តីនោះបាន ។

[១៥១] ព. ក្នុងលោកនេះ ជនទាំងឡាយណា ជាអ្នកកំណាញ់ស្វិតស្វាញ ជាអ្នកពោលពាក្យទ្រគោះ ជាអ្នកធ្វើសេចក្តីអន្តរាយ ដល់ជនដទៃដែលកំពុងឲ្យទាន ជនទាំង-ឡាយនោះ តែងទៅកើតក្នុងនរក ក្នុងកំណើតសត្វតិរច្ឆាន

---

១ ធ្វើសេចក្តីអន្តរាយឋានសួគ៌របស់ទាយក ធ្វើនូវសេចក្តីអន្តរាយលាភរបស់បដិគ្គាហកៈ ។ អដ្ឋកថា ។

## ៨៧

ទេវតាសំយុត្តស្ស អាទិត្តវគ្គេ វីតមច្ឆរព្យាករណំ

យមលោកូបបជ្ជរេ[១]
សចេ ឯន្តិ[២] មនុស្សត្តំ
ឧឡ្សិទ្ធេ ជាយរេ កុលេ
ចោឡំ បិណ្ឌោ រតី ខិឌ្ឌា
យត្ថ កិច្ឆេន លព្ភតិ
បរតោ អាសីសរេ ពាលា
តំបិ តេសំ ន លព្ភតិ
ឯវ្ចេ កម្មស វិបាកោ
សម្បរាយោ ច ទុគ្គតីតិ ។
[១៨២] ឥតិ ហេតំ វិជានាម
អញ្ញំ បុច្ឆាម គោតមំ
យេន លទ្ធា មនុស្សត្តំ
វទញ្ញូ វីតមច្ឆរា
ពុទ្ធេ បសន្នា ធម្មេ ច
សង្ឃេ ច តិព្វគារវា
ការិសោ តេសំ វិបាកោ

---

១ ឱ. យមលោកមុប្បជ្ជរេតិ ទិស្សតិ ។ ២ ម. ជន្តិ ។

និងក្នុងយមលោក ប្រសិនបើដល់នូវភាពជាមនុស្ស រមែងកើតក្នុងត្រកូលកំសត់ ស្វែងរកតែសំពត់ និងអាហារ និងសេចក្តីត្រេកអរក្នុងបញ្ចកាមគុណ និងល្បែង ក៏បានដោយកម្រ ពួកពាលតែងនឹកប៉ងនូវទ្រព្យណាអំពីទីដទៃ ទ្រព្យនោះ មិនដែលបានដល់ពួកពាលនោះឡើយ នេះជាផលវិបាក ក្នុងទិដ្ឋធម៌គឺក្នុងទីដែលកើត ចំណែកសម្បរាយភព រមែងមានទុគ្គតិជាផល ។

[១៥២] ទ. យើងខ្ញុំ ដឹងសេចក្តីនេះជាក់ច្បាស់ដូច្នេះហើយ យើងខ្ញុំ សូមក្រាបបង្គំទូលសួរនូវសេចក្តីដទៃនឹងព្រះគោតមជាម្ចាស់ (តទៅទៀត) ក្នុងលោកនេះ ជនទាំងឡាយណា បាននូវអត្តភាពជាមនុស្សហើយ ជាអ្នកដឹងនូវពាក្យពោល ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ជាអ្នកជ្រះថ្លា ទាំងមានសេចក្តីគោរពយ៉ាងខ្លាំង ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ផលវិបាករបស់ជនទាំងឡាយនោះដូចម្តេច

សម្បរាយោ ច ឦទិសោ
ភគវន្តំ ពុទ្ធមាគម្ម
កថំ ជានេមុ តំ មយន្តិ ។
[១៨៣] យេច លទ្ធា មនុស្សត្តំ
វទញ្ញូ វីតមច្ឆរា
ពុទ្ធេ បសន្នា ធម្មេ ច
សង្ឃេ ច តិព្វគារវា
ឯតេ សគ្គេ បកាសេន្តិ
យត្ថ តេ ឧបបជ្ជរេ
សចេ ឯន្តិ មនុស្សត្តំ
អឌ្ឍេ អាជាយរេ កុលេ
ចោឡំ បិណ្ឌោ រតី ខិឌ្ឌា
យត្ថាកិច្ឆេន លព្ភតិ
បរសម្ភតេសុ ភោគេសុ
វសវត្តីវ មោទរេ
ទិដ្ឋេ ធម្មេស វិបាកោ
សម្បរាយោ ច សុគតីតិ ។

សម្បរាយភពរបស់ជនទាំងឡាយនោះដូចម្ដេច យើងខ្ញុំមកដើម្បីក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូចម្ដេចហ្ន៎ នឹងដឹងនូវសេចក្ដីនោះបាន ។

[១៩៣] ៣. ក្នុងលោកនេះ ជនទាំងឡាយណា បានអត្តភាពជាមនុស្សហើយ ជាអ្នកដឹងនូវពាក្យពោល ជាអ្នកប្រាសចាកសេចក្ដីកំណាញ់ ជាអ្នកជ្រះថ្លា ទាំងមានសេចក្ដីគោរពយ៉ាងខ្លាំង ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជនទាំងឡាយនោះ រមែងរុងរឿងក្នុងឋានសួគ៌ ជនទាំងឡាយនោះ ទោះទៅកើតក្នុងទីណា បើដល់នូវអត្តភាពជាមនុស្ស រមែងកើតក្នុងត្រកូលដ៏ស្ដុកស្ដម្ភ ស្វែងរកសំពត់ និងអាហារ និងសេចក្ដីត្រេកអរក្នុងបញ្ចកាមគុណ និងល្បែងបានដោយងាយ ទាំងមានអំណាច ផ្សាយទៅក្នុងភោគៈទាំងឡាយដែលអ្នកដទៃសន្សំបានមក សប្បាយរីករាយក្នុងចិត្ត នេះជាផលវិបាក ក្នុងទិដ្ឋធម៌ គឺក្នុងទីដែលកើត ចំណែកសម្បរាយភព រមែងមានសុគតិជាផល ។

# ទសមំ ឃដិករសុត្តំ

[១៨៤] អវិហំ ឧបបន្នាសេ
វិមុត្តា សត្ត ភិក្ខវោ
រាគទោសបរិក្ខីណា
តិណ្ណា លោកេ វិសត្តិកន្តិ ។
យេ ច តេ[១] អតរុំ សង្គំ[២]
មច្ចុធេយ្យំ សុទុត្តរំ
តេ ហិត្វា មានុសំ ទេហំ
ទិព្វយោគំ ឧបច្ចគុន្តិ ។
ឧបកោ ផលគណ្ឌោ[៣] ច
បុក្កុសាតិ ច តេ តយោ
ភទ្ទិយោ ខណ្ឌទេវោ ច
ពហុទន្តី[៤] ច សិង្គិយោ[៥]
តេ ហិត្វា មានុសំ ទេហំ
ទិព្វយោគំ ឧបច្ចគុន្តិ ។

១ ឱ. កេ ច តេ ។ ២. ឱ. ម. បង្កំ ។ ៣ ម. បលគណ្ឌោ ។ ៤ ឱ. ពាហុរគ្គិ ។ ៥ ឱ. បិង្គិយោ ។

# ឃដិករសូត្រ ទី ១០

[១៩៤] ទ. ភិក្ខុទាំង ៧រូប បានទៅកើតក្នុងព្រហ្មលោកឈ្មោះអវិហា មានចិត្តរួចស្រឡះហើយ[១] មានរាគៈទោសៈអស់ហើយ ឆ្លងនូវតណ្ហាក្នុងលោករួចហើយ ។ ភិក្ខុទាំងឡាយណា បានឆ្លងនូវកិលេសជាគ្រឿងចំពាក់ ជាទីតាំងនៃមច្ចុដែលឆ្លងបានដោយកម្រក្រៃពេក ភិក្ខុទាំងឡាយនោះ លុះលះបង់នូវរាងកាយជារបស់មនុស្សហើយ កន្លងនូវទិព្វយោគគឺសំយោជនៈទាំង ៥ ជាចំណែកខាងលើ ។ ភិក្ខុទាំងនោះគឺ ព្រះឧបកៈ ១ ព្រះផលគណ្ឌៈ ១ ព្រះបុក្កុសាតិ ១ ជា ៣ រូប និងព្រះភទ្ទិយៈ ១ ព្រះខណ្ឌទេវៈ ១ ព្រះពាហុទន្តី ១ ព្រះសិង្គិយៈ ១ (៤ រូបនេះទៀតជា ៧) ភិក្ខុទាំងនោះ បានលះបង់នូវរាងកាយជារបស់មនុស្សហើយ ទើបកន្លងនូវទិព្វយោគបាន ។

---

១ រួចស្រឡះដោយអរហត្តផលវិមុត្តិ បន្ទាប់អំពីកាលដែលកើតក្នុងព្រហ្មលោកឈ្មោះអវិហា ។ អដ្ឋកថា ។

[១៩៥] កុសលី[១] ភាសសី តេសំ
មារធាសប្បហាយិនំ
កស្ស តេ ជម្មញ្ញាយ
អច្ឆិជ្ជំ ភវពន្ធនច្ឆិត្ត ។

[១៩៦] ន អញ្ញត្រ ភគវតា
ជានាត្រ តវ សាសនា
យស្ស តេ ជម្មញ្ញាយ
អច្ឆិជ្ជំ ភវពន្ធនំ
យត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតិ
តំ តេ ជម្មមិជញ្ញាយ
អច្ឆិជ្ជំ ភវពន្ធនច្ឆិត្ត ។

[១៩៧] គម្ភីរំ ភាសសី វាចំ
ទុព្វិជានំ សុទុព្ពុធំ

១ កុសលន្តិបិ បាឋោ ។

[១៥៥] ព. អ្នកឯង ជាបុគ្គលមានកុសល បានពោលសរសើរនូវភិក្ខុទាំងនោះ ដែលជាអ្នកលះបង់នូវអន្ទាក់នៃមារ ភិក្ខុទាំងនោះ បានកាត់នូវបំណង់គឺភព ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលណា ។

[១៥៦] ទ. ព្រះថេរៈទាំងនោះ បានកាត់នូវបំណង់គឺភព ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលណា បុគ្គលនោះ វៀរតែព្រះមានព្រះភាគចេញ មិនមានទេ វៀរតែសាសនារបស់ព្រះអង្គចេញ មិនមានទេ នាមនិងរូប រលត់ទៅឥតមានសេសសល់ក្នុងសាសនាណា ព្រះថេរៈទាំងនោះ បានកាត់នូវបំណង់គឺភព ព្រោះដឹងច្បាស់នូវធម៌នោះ ក្នុងសាសនានេះ ។

[១៥៧] ព. អ្នកឯង ជាបុគ្គលពោលវាចាមានអត្ថដ៏ជ្រៅ ដែលដឹងបានដោយកម្រ យល់បានដោយកម្រក្រៃពេក

ទេវតាសំយុត្តស្ស អាទិត្តវគ្គេ ភូតបុព្វប្បកាសនំ

កស្ស ត្វំ ធម្មមញ្ញាយ
វាចំ ភាសសិ ឦទិសន្តិ ។
[១៨៨] កុម្ភការោ បុរេ អាសឹ
វេភឡិង្គេ[១] ឃដីករោ
មាតាបេត្តិភរោ អាសឹ
កស្សបស្ស ឧបាសកោ
វិរតោ មេថុនា ធម្មា
ព្រហ្មចារី និរាមិសោ
អហុវា តេ សគាមេយ្យោ
អហុវា តេ បុរេ សខា
សោហមេតេ បជានាមិ
វិមុត្តេ សត្ត ភិក្ខវោ
រាគទោសបរិក្ខីណេ
តិណ្ណេ លោកេ វិសត្តិកន្តិ ។

១ វេហឡិង្គេតិ វា បាឋោ ។ ម. វេកឡិង្គេ ។

អ្នកឯង ពោលវាចាបែបនេះ ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលដូចម្តេច ។

[១៥៨] ទ. ខ្ញុំព្រះអង្គ ជាស្មូនឆ្នាំងឈ្មោះឃដិការ កើតក្នុងបុរីឈ្មោះវេភឡិង្គ ជាអ្នកចិញ្ចឹមមាតាបិតា ជាឧបាសករបស់ព្រះពុទ្ធទ្រង់ព្រះនាមកស្សប ជាអ្នកវៀរចាកមេថុនធម្មប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រាសចាកអាមិសៈ បាននៅក្នុងស្រុកជាមួយនឹងព្រះអង្គ ជាសំឡាញ់នឹងព្រះអង្គក្នុងកាលមុន ខ្ញុំព្រះអង្គស្គាល់នូវភិក្ខុទាំង ៧ រូបនុ៎ះ ដែលមានចិត្តរួចស្រឡះហើយ មានរាគៈនិងទោសៈអស់ហើយ បានឆ្លងហើយនូវតណ្ហាក្នុងលោក ។

[១៨៩] ឯវមេតំ តទា អាសិ
យថា ភាសសិ ភគ្គវ
កុម្ភការោ បុរេ អាសិ
វេកឡិង្គេ ឃដីការោ
មាតាបេត្តិភរោ អាសិ
កស្សបស្ស ឧចាសកោ
វិរតោ មេថុនា ធម្មា
ព្រហ្មចារី និរាមិសោ
អហុវា មេ សគាមេយ្យោ
អហុវា មេ បុរេ សខាតិ ។
ឯវមេតំ បុរាណានំ
សហាយានមហុ សង្គមោ
ឧភិន្នំ ភាវិតត្តានំ
សរីរន្តិមធារិនន្តិ ។

អាទិត្តវគ្គោ បញ្ចមោ ។

[១៥៩] ៣. ម្នាលភគវៈ អ្នកឯង និយាយយ៉ាងណា រឿងនុ៎ះ ក៏មានយ៉ាងនោះមែន ក្នុងកាលនោះ អ្នកឯង ជាស្មូនឆ្នាំងឈ្មោះឃដិការ កើតក្នុងបុរីឈ្មោះវេកឡិង្គ ជាអ្នកចិញ្ចឹមមាតាបិតា ជាឧបាសករបស់ព្រះពុទ្ធកស្សប ជាអ្នកវៀរចាកមេថុនធម្ម ប្រព្រឹត្តធម៌ដ៏ប្រសើរ (ជាអនាគាមី) ប្រាសចាកអាមិសៈ បាននៅក្នុងស្រុកជាមួយនឹងតថាគត ជាសម្លាញ់របស់តថាគត ក្នុងកាលមុន ។ ការចួបជុំនឹងសម្លាញ់ពីបុរាណនេះ របស់យើងទាំងពីរនាក់ ដែលមានខ្លួនចម្រើនហើយ ជាអ្នកទ្រទ្រង់នូវសរីរៈជាទីបំផុត យ៉ាងនេះឯង ។

ចប់ អាទិត្តវគ្គ ទី ៥ ។

៩៣

ទេវតាសំយុត្តស្ស អាទិត្តវគ្គេ ឧទ្ទានំ

# តត្រុទ្ទានំ

អាជិត្តំ ភិក្ខុជំ អត្ថំ

ឯកមូលំ អនោមិយំ

អច្ឆរា វនរោបជេតំ[១]

មច្ឆេរេន ឃដីករោតិ ។

១ ឱ. វនរោបេតំ ។ ម. វនបេតបេតំ ។

# បញ្ជីរឿងក្នុងអាទិត្តវគ្គនោះ គឺ

*អាទិត្តសូត្រ ១ កិន្ទទសូត្រ ១ អន្នសូត្រ ១ ឯកមូលសូត្រ ១ អនោមិយសូត្រ ១ អច្ឆរាសូត្រ ១ វនរោបសូត្រ ១ ជេតវនសូត្រ ១ មច្ឆរិសូត្រ ១ ឃដិករសូត្រ ១ ។*

# ឆដ្ឋោ ជរាវគ្គោ

## បឋមំ ជរាសុត្តំ

[១៦០] កឹសុ យាវ ជរា សាធុ
កឹសុ សាធុ បតិដ្ឋិតំ
កឹសុ នរានំ រតនំ
កឹសុ ចោរេហិ ទូហរន្តិ ។

[១៦១] សីលំ យាវ ជរា សាធុ
សទ្ធា សាធុ បតិដ្ឋិតា
បញ្ញា នរានំ រតនំ
បុញ្ញំ ចោរេហិ ទូហរន្តិ ។

## ទុតិយំ អជរសាសុត្តំ

[១៦២] កឹសុ អជរសា សាធុ
កឹសុ សាធុ អធិដ្ឋិតំ
កឹសុ នរានំ រតនំ
កឹសុ ចោរេហិ ហារិយន្តិ ។

# ជរាវគ្គ ទី ៦

## ជរាសូត្រ ទី ១

[១៦០] ១. អ្វីហ្ន៎ ជាគុណជាតញុំាងប្រយោជន៍ឲ្យសម្រេច ដរាបដល់ជរា អ្វីហ្ន៎ ដែលបុគ្គលតម្កល់ទុកហើយ ញុំាងប្រយោជន៍ឲ្យសម្រេចបាន អ្វីហ្ន៎ ជាកែវរបស់ជនទាំង-ឡាយ អ្វីហ្ន៎ ដែលពួកចោរនាំទៅមិនបាន ។

[១៦១] ៣. សីល ជាគុណជាតញុំាងប្រយោជន៍ឲ្យសម្រេចដរាបដល់ជរា សទ្ធា ដែលបុគ្គលតម្កល់ទុកហើយ ញុំាងប្រយោជន៍ឲ្យសម្រេចបាន បញ្ញា ជាកែវរបស់ជនទាំងឡាយ បុណ្យ ពួកចោរនាំទៅមិនបាន ។

## អជរសាសូត្រ ទី ២

[១៦២] ១. អ្វីហ្ន៎ ជាគុណជាតដ៏ចម្រើនដោយមិនប្រែប្រួលទៅ អ្វីហ្ន៎ ដែលគេអធិដ្ឋានហើយញុំាងប្រយោជន៍ឲ្យសម្រេច អ្វីហ្ន៎ ជាកែវរបស់ជនទាំងឡាយ អ្វីហ្ន៎ ដែលពួកចោរនាំទៅមិនបាន ។

[១៦៣] សីលំ អជរសា សាធុ
សទ្ធា សាធុ អធិដ្ឋិតា
បញ្ញា នរានំ រតនំ
បុញ្ញំ ចោរេហិ ហារិយន្តិ ។

## តតិយំ មិត្តសុត្តំ

[១៦៤] កឹសុ បសវតោ[១] មិត្តំ
កឹសុ មិត្តំ សកេ ឃរេ
កឹ មិត្តំ អត្ថជាតស្ស
កឹ មិត្តំ សម្បរាយិកន្តិ ។

[១៦៥] សត្ថោ បសវតោ មិត្តំ
មាតា មិត្តំ សកេ ឃរេ
សហាយោ អត្ថជាតស្ស
ហោតិ មិត្តំ បុនប្បុនំ
សយំ កតានិ បុញ្ញានិ
តំ មិត្តំ សម្បរាយិកន្តិ ។

១ ឱ. បថវតោ ។ ២ ឱ. ឯវំ ។

[១៦៣] ព. *សីល ជាគុណជាតដ៏ចម្រើនដោយមិនប្រែប្រួលទៅ សទ្ធា ដែលគេអធិដ្ឋានហើយញ៉ាំងប្រយោជន៍ឲ្យសម្រេច បញ្ញាជាកែវរបស់ជនទាំងឡាយ បុណ្យ ពួកចោរនាំទៅមិនបាន ។*

# មិត្តសូត្រ ទី ៣

[១៦៤] ទ. *អ្វីហ្ន៎ ជាមិត្តរបស់អ្នកដើរផ្លូវ អ្វីហ្ន៎ ជាមិត្តក្នុងផ្ទះរបស់ខ្លួន អ្វីហ្ន៎ ជាមិត្តរបស់អ្នកមានធុរៈកើតឡើង អ្វីហ្ន៎ ជាមិត្តតាមទៅក្នុងភពខាងមុខ ។*

[១៦៥] ព. *បក្ខពួក ជាមិត្តរបស់អ្នកដើរផ្លូវ មាតាជាមិត្តក្នុងផ្ទះរបស់ខ្លួន អ្នកដែលមានចិត្តប្រព្រឹត្តទៅស្មើគ្នា ជាមិត្តរបស់អ្នកដែលមានធុរៈកើតឡើងរឿយ ៗ បុណ្យទាំងឡាយដែលគេធ្វើហើយដោយខ្លួនឯង ជាមិត្តជាប់តាមទៅក្នុងភពខាងមុខ ។*

## ចតុត្ថំ វត្ថុសុត្តំ

[១៦៦] កឹសុ វត្ថុ មនុស្សានំ
កឹស្វីធ បរមា សខា
កឹសុ ភូតា ឧបជីវន្តិ
យេ បាណា បថវឹ សិតាតិ ។

[១៦៧] បុត្តា វត្ថុ មនុស្សានំ
ភរិយា បរមា សខា
វុដ្ឋី ភូតា ឧបជីវន្តិ
យេ បាណា បថវឹ សិតាតិ ។

## បញ្ចមំ បឋមជនសុត្តំ

[១៦៨] កឹសុ ជនេតិ បុរិសំ
កឹសុ តស្ស វិធាវតិ
កឹសុ សំសារមាបាទិ
កឹសុ តស្ស មហព្ភយន្តិ ។

# វត្ថុសូត្រ ទី ៤

[១៦៦] អ្វី ជាទីពំនាក់របស់មនុស្សទាំងឡាយ អ្វី ជាសំឡាញ់ដ៏ប្រសើរ របស់មនុស្សទាំងឡាយ ក្នុងលោកនេះ ពួកសត្វមានជីវិត ដែលអាស្រ័យផែនដី រស់នៅនឹងអ្វី ។

[១៦៧] ព. កូន ជាទីពំនាក់របស់មនុស្សទាំងឡាយ ភរិយាជាសំឡាញ់ដ៏ប្រសើររបស់មនុស្សទាំងឡាយ (ក្នុងលោកនេះ) ពួកសត្វមានជីវិតដែលអាស្រ័យផែនដី រស់នៅនឹងទឹកភ្លៀង ។

# បឋមជនសូត្រ ទី ៥

[១៦៨] ទ. អ្វីហ្ន៎ តែងញុំាងបុរសឲ្យកើត អ្វីហ្ន៎ របស់បុរសនោះតែងស្ទុះទៅ អ្វីហ្ន៎ តែងអន្ទោលទៅក្នុងសង្សារ អ្វីហ្ន៎ ជាមហាភ័យរបស់សត្វនោះ ។

ទេវតាសំយុត្តស្ស ជរាវគ្គេ ជននាទិព្យាករណំ

[១៦៩] តណ្ហា ជនេតិ បុរិសំ
ចិត្តមស្ស វិធាវតិ
សត្តោ សំសារមាបាទិ
ទុក្ខមស្ស មហព្ភយន្តិ ។

ឆដ្ឋំ ទុតិយជនសុត្តំ

[១៧០] កឹសុ ជនេតិ បុរិសំ
កឹសុ តស្ស វិធាវតិ
កឹសុ សំសារមាបាទិ
កិស្មា ន បរិមុច្ចតីតិ ។

[១៧១] តណ្ហា ជនេតិ បុរិសំ
ចិត្តមស្ស វិធាវតិ
សត្តោ សំសារមាបាទិ
ទុក្ខា ន បរិមុច្ចតីតិ ។

[១៦៩] ព. តណ្ហា តែងញុំាងបុរសឲ្យកើត ចិត្តរបស់បុរសនោះ តែងស្ទុះទៅ សត្វលោក តែងអន្ទោលទៅក្នុងសង្សារ សេចក្តីទុក្ខ ជាមហាភ័យរបស់សត្វនោះ ។

# ទុតិយជនសូត្រ ទី ៦

[១៧០] ទ. អ្វីហ្ន៎ តែងញុំាងបុរសឲ្យកើត អ្វីហ្ន៎ របស់បុរសនោះ តែងស្ទុះទៅ អ្វីហ្ន៎ តែងអន្ទោលទៅក្នុងសង្សារ សត្វលោក តែងគេចមិនរួចអំពីអ្វី ។

[១៧១] ព. តណ្ហា តែងញុំាងបុរសឲ្យកើត ចិត្តរបស់បុរសនោះ តែងស្ទុះទៅ សត្វលោក តែងអន្ទោលទៅក្នុងសង្សារ សត្វនោះឯង តែងគេចមិនរួចអំពីសេចក្តីទុក្ខ ។

# សត្តមំ តតិយជនសុត្តំ

[១៧២] កឹសុ ជនេតិ បុរិសំ
កឹសុ តស្ស វិធាវតិ
កឹសុ សំសារមាបាទិ
កឹសុ តស្ស បរាយនន្តិ ។

[១៧៣] តណ្ហា ជនេតិ បុរិសំ
ចិត្តមស្ស វិធាវតិ
សត្តោ សំសារមាបាទិ
កម្មំ តស្ស បរាយនន្តិ ។

# អដ្ឋមំ ឧប្បថសុត្តំ

[១៧៤] កឹសុ ឧប្បថោ អក្ខាតិ[១]
កឹសុ រត្តិន្ទិវក្ខយោ
កឹ មលំ ព្រហ្មចរិយស្ស
កឹ សិណានមនោទកន្តិ ។

១ ឱ. ឯវំ ។

# តតិយជនសូត្រ ទី ៧

[១៧២] ទ. អ្វីហ្ន៎ តែងញុំាងបុរសឲ្យកើត អ្វីហ្ន៎ របស់បុរសនោះ តែងស្ទុះទៅ អ្វីហ្ន៎ តែងអន្ទោលទៅកាន់សង្សារ អ្វីហ្ន៎ ជាទីប្រព្រឹត្តទៅខាងមុខរបស់សត្វនោះ ។

[១៧៣] ព. តណ្ហា តែងញុំាងបុរសឲ្យកើត ចិត្តរបស់បុរសនោះ តែងស្ទុះទៅ សត្វលោក តែងអន្ទោលទៅកាន់សង្សារ កម្ម ជាទីប្រព្រឹត្តទៅខាងមុខរបស់សត្វនោះ ។

# ឧប្បថសូត្រ ទី ៨

[១៧៤] ទ. អ្វីហ្ន៎ ជាផ្លូវខុស អ្វីហ្ន៎ ដែលអស់ទៅតាមយប់និងថ្ងៃ អ្វី ជាមន្ទិលរបស់ព្រហ្មចរិយៈ អ្វី ជាគ្រឿងសម្រាប់លាងសេចក្តីសៅហ្មងបាន ដែលមិនចាំបាច់មានទឹក ។

[១៧៥] រាគោ ឧប្បថោ អក្ខាតិ
វយោ រត្តិន្ទិវក្ខយោ
ឥត្ថី មលំ ព្រហ្មចរិយស្ស
ឯត្ថាយំ សជ្ជតេ បជា
តបោ ច[១] ព្រហ្មចរិយញ្ច
តំ សិនានមនោទកន្តិ ។

## នវមំ ទុតិយសុត្តំ

[១៧៦] កឹសុ ទុតិយំ បុរិសស្ស ហោតិ
កឹសុ ចេនំ បសាសតិ
កិស្ស ចាភិរតោ មច្ចោ
សព្វទុក្ខា បមុច្ចតីតិ ។

[១៧៧] សទ្ធា ទុតិយា បុរិសស្ស ហោតិ
បញ្ញា ចេនំ បសាសតិ
និព្វានាភិរតោ មច្ចោ
សព្វទុក្ខា បមុច្ចតីតិ ។

---
១ ឱ. ម. ចការោ ន បញ្ញាយតិ ។

[១៧៥] ព. *រាគៈ ជាផ្លូវខុស វ័យ តែងអស់ទៅតាមយប់និងថ្ងៃ ស្ត្រី ជាមន្ទិលរបស់ព្រហ្មចរិយៈ ពួកសត្វនេះរមែងជាប់នៅនឹងស្ត្រីនុ៎ះ តបៈនិងព្រហ្មចរិយៈ ជាធម៌សម្រាប់លាងសេចក្តីសៅហ្មងនោះ មិនចាំបាច់មានទឹកឡើយ ។*

## ទុតិយសូត្រ ទី ៩

[១៧៦] ទ. *អ្វីហ្ន៎ ជាទីពីររបស់បុរស អ្វីហ្ន៎ តែងគ្រប់គ្រងបុរសនោះ មួយទៀត សត្វត្រេកអរនឹងធម៌អ្វី ទើបរួចចាកទុក្ខទាំងពួងបាន ។*

[១៧៧] ព. *សទ្ធា ជាទីពីររបស់បុរស បញ្ញា រមែងគ្រប់គ្រងនូវបុរសនោះ មួយទៀត សត្វត្រេកអរនឹងព្រះនិព្វាន ទើបរួចចាកទុក្ខទាំងពួងបាន ។*

## ទសមំ កវិសុត្តំ

[១៧៨] កឹសុ និទានំ គាថានំ
កឹសុ តាសំ វិយញ្ជនំ
កឹសុ សន្និស្សិតា គាថា
កឹសុ គាថានមាសយោតិ ។

[១៧៩] ឆន្ទោ និទានំ គាថានំ
អក្ខរា តាសំ[១] វិយញ្ជនំ
នាមសន្និស្សិតា គាថា
កវិ គាថានមាសយោតិ ។

ជរាវគ្គោ ឆដ្ឋោ

### តស្សុទ្ទានំ

ជរា អជរសា មិត្តំ
វត្ថុ តីណិ ជនានិ ច
ឧប្បថោ ច ទុតិយោ ច
កវិនា បូរិតោ វគ្គោតិ ។

១ ម. អក្ខរានំ ។

# កវិសូត្រ ទី ១០

[១៧៨] ៥. អ្វីហ្ន៎ ជាដើមហេតុនៃគាថាទាំងឡាយ អ្វីហ្ន៎ ជាគ្រឿងបង្កើតគាថាទាំងឡាយនោះ គាថា អាស្រ័យនឹង អ្វី អ្វី ជាទីអាស្រ័យរបស់គាថាទាំងឡាយ ។

[១៧៩] ព. ឆន្ទ ជាដើមហេតុនៃគាថាទាំងឡាយ អក្ខរៈ ជាគ្រឿងបង្កើតគាថាទាំងឡាយនោះ គាថា អាស្រ័យនឹង នាម ចិន្តកវី ជាទីអាស្រ័យរបស់គាថាទាំងឡាយ ។

ចប់ ជរាវគ្គ ទី ៦ ។

## បញ្ជីរឿងនៃជរាវគ្គនោះ គឺ

ជរាសូត្រ ១ អជរសាសូត្រ ១ មិត្តសូត្រ ១ វត្ថុសូត្រ ១ ជនសូត្រ ៣ ឧប្បជសូត្រ ១ ទុតិយសូត្រ ១ បំពេញវគ្គ ដោយកវិសូត្រ ១ ។

# សត្តមោ អន្នវគ្គោ

## បឋមំ នាមសុត្តំ

[១៨០] កឹសុ សព្វំ អទ្ធភវិ[១]
កិស្មា ភិយ្យោ[២] ន វិជ្ជតិ
កិស្សស្សុ ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

[១៨១] នាមំ សព្វំ អទ្ធភវិ
នាមា ភិយ្យោ ន វិជ្ជតិ
នាមស្ស ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

## ទុតិយំ ចិត្តសុត្តំ

[១៨២] កេនស្សុ នីយតិ លោកោ
កេនស្សុ បរិកិស្សតិ
កិស្សស្សុ ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

---

១ ឱ. ម. អទ្ធភវិ ។ អ. អន្វភវីតិបិ អន្ធភវីតិបិ បាឋោ ។ ២ ភីយោតិបិ បាឋោ ។

# អន្ទវគ្គ ទី ៧

## នាមសូត្រ ទី ១

[១៨០] ១. អ្វីហ្ន៎ តែងធ្លាក់ចុះលើសត្វនិងសង្ខារទាំងពួង ដែលមិនមានអ្វីក្រៃលែងជាង សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺធម៌អ្វី ។

[១៨១] ២. នាម (ឈ្មោះ) តែងធ្លាក់ចុះលើសត្វនិងសង្ខារទាំងពួង មិនមានអ្វីក្រៃលែងជាងនាមឡើយ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺនាម ។

## ចិត្តសូត្រ ទី ២

[១៨២] ១. អ្វី តែងនាំសត្វលោកទៅ អ្វី តែងកើចកន្ត្រាក់សត្វលោកទៅ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺធម៌អ្វី ។

[១៨៣] ចិត្តេន នីយតិ លោកោ
ចិត្តេន បរិកិស្សតិ
ចិត្តស្ស ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

## តតិយំ តណ្ហាសុត្តំ

[១៨៤] កេនស្សុ នីយតិ លោកោ
កេនស្សុ បរិកិស្សតិ
កិស្សស្ស ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

[១៨៥] តណ្ហាយ នីយតិ លោកោ
តណ្ហាយ បរិកិស្សតិ
តណ្ហាយ ឯកធម្មស្ស
សព្វេវ វសមន្វគូតិ ។

[១៨៣] ៣. ចិត្ត តែងនាំសត្វលោកទៅ ចិត្ត តែងកើចកន្ត្រាក់សត្វលោកទៅ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺចិត្ត ។

# តណ្ហាសូត្រ ទី ៣

[១៨៤] ទ. អ្វីហ្ន៎ តែងនាំសត្វលោកទៅ អ្វីហ្ន៎ តែងកើចកន្ត្រាក់សត្វលោកទៅ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺធម៌អ្វី ។

[១៨៥] ព. តណ្ហា តែងនាំសត្វលោកទៅ តណ្ហាតែងកើចកន្ទ្រាក់សត្វលោកទៅ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺតណ្ហា ។

## ចតុត្ថំ សញ្ញោជនសុត្តំ

[១៨៦] កឹសុ សញ្ញោជនោ លោកោ
កឹសុ តស្ស វិចារណំ
កិស្សស្ស វិប្បហានេន
និព្វានំ ឥតិ វុច្ចតីតិ ។

[១៨៧] នន្ទិសញ្ញោជនោ លោកោ
វិតក្កស្ស វិចារណំ
តណ្ហាយ វិប្បហានេន
និព្វានំ ឥតិ វុច្ចតីតិ ។

## បញ្ចមំ ពន្ធនសុត្តំ

[១៨៨] កឹសុ សម្ពន្ធនោ លោកោ
កឹសុ តស្ស វិចារណំ
កិស្សស្ស វិប្បហានេន
សព្វំ ឆិន្ទតិ ពន្ធនន្តិ ។

# សញ្ញោជនសូត្រ ទី ៤

[១៨៦] ទ. អ្វី ជាគ្រឿងចងសត្វលោកទុកនៅ អ្វី ជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ព្រោះលះបង់អ្វី ទើបហៅថា ព្រះនិព្វាន ។

[១៨៧] ព. សត្វលោក មានសេចក្តីរីករាយជាគ្រឿងចង វិតក្កៈ ជាគ្រឿងត្រាច់ទៅ (របស់សត្វលោក) ព្រោះលះបង់តណ្ហា ទើបហៅថា ព្រះនិព្វាន ។

# ពន្ធនសូត្រ ទី ៥

[១៨៨] ទ. អ្វី ជាគ្រឿងចងសត្វលោកទុកនៅ អ្វី ជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ព្រោះលះបង់អ្វី ទើបកាត់ចំណងទាំងពួងបាន ។

[១៨៩] ឆន្ទិសម្ពន្ធនោ លោកោ
វិតក្កស្ស វិចារណំ
តណ្ហាយ វិប្បហានេន
សព្វំ ឆិន្ទតិ ពន្ធនន្តិ ។

## ឆដ្ឋំ អព្ភាហតសុត្តំ

[១៩០] កេនស្សុព្ភាហតោ[១] លោកោ
កេនស្សុ បរិវារិតោ
កេន សល្លេន ឱតិណ្ណោ
កិស្ស ធូបាយិតោ សទាតិ ។

[១៩១] មច្ចុនាព្ភាហតោ លោកោ
ជរាយ បរិវារិតោ
តណ្ហាសល្លេន ឱតិណ្ណោ
ឥច្ឆាធូបាយិតោ សទាតិ ។

## សត្តមំ ឧឌ្ឌិតសុត្តំ

[១៩២] កេនស្សុ ឧឌ្ឌិតោ លោកោ
កេនស្សុ បរិវារិតោ

១ ឱ. កេនស្សុពាសតោ ។

[១៨៩] ព. សត្វលោក មានសេចក្តីរីករាយជាគ្រឿងចង វិតក្កៈ ជាគ្រឿងត្រាច់ទៅ (របស់សត្វលោក) ព្រោះលះបង់តណ្ហា ទើបកាត់ចំណងទាំងពួងបាន ។

## អព្ភាហតសូត្រ ទី ៦

[១៩០] ទ. អ្វី គ្របសង្កត់សត្វលោក អ្វី ចោមរោម (សត្វលោក) អ្វី ជាសរមុតចុះទៅ អ្វី ដែលឆេះសព្វកាលទាំងពួង ។

[១៩១] ព. មច្ចុ គ្របសង្កត់សត្វលោក ជរា ចោមរោម (សត្វលោក) តណ្ហា ជាសរមុតចុះទៅ ឥច្ឆា ឆេះសព្វកាលទាំងពួង ។

## ឧឌ្ឌិតសូត្រ ទី ៧

[១៩២] ទ. អ្វី បញ្ចើចសត្វលោក អ្វី ចោមរោមសត្វលោក

កេនស្សុ បិហិតោ លោកោ
កិស្មឹ លោកោ បតិដ្ឋិតោតិ ។

[១៩៣] តណ្ហាយ ឧឌ្ឌិតោ លោកោ
ជរាយ បរិវារិតោ
មច្ចុនា បិហិតោ លោកោ
ទុក្ខេ លោកោ បតិដ្ឋិតោតិ ។

## អដ្ឋមំ បិហិតសុត្តំ

[១៩៤] កេនស្សុ បិហិតោ លោកោ
កិស្មឹ លោកោ បតិដ្ឋិតោ
កេនស្សុ ឧឌ្ឌិតោ លោកោ
កេនស្សុ បរិវារិតោតិ ។

[១៩៥] មច្ចុនា បិហិតោ លោកោ
ទុក្ខេ លោកោ បតិដ្ឋិតោ
តណ្ហាយ ឧឌ្ឌិតោ លោកោ
ជរាយ បរិវារិតោតិ ។

អ្វី បិទសត្វលោក សត្វលោក តែងឋិតនៅក្នុងអ្វី ។

[១៩៣] ព. តណ្ហា បញ្ឆេចសត្វលោក ជរា ចោមរោមសត្វលោក មច្ចុ បិទសត្វលោក សត្វលោក ឋិតនៅក្នុងសេចក្តីទុក្ខ ។

## បិហិតសូត្រ ទី ៨

[១៩៤] ទ. អ្វី បិទសត្វលោក សត្វលោក ឋិតនៅក្នុងអ្វី អ្វី បញ្ឆេចសត្វលោក អ្វី ចោមរោមសត្វលោក ។

[១៩៥] ព. មច្ចុ បិទសត្វលោក សត្វលោក ឋិតនៅក្នុងសេចក្តីទុក្ខ តណ្ហា បញ្ឆេចសត្វលោក ជរា ចោមរោមសត្វលោក ។

## នវមំ ឥច្ឆាសុត្តំ

[១៩៦] កេនស្សុ ពជ្ឈតិ លោកោ
កិស្ស វិនយាយ មុច្ចតិ
កិស្សស្ស វិប្បហានេន
សព្វំ ឆិន្ទតិ ពន្ធនន្តិ ។

[១៩៧] ឥច្ឆាយ ពជ្ឈតិ លោកោ
ឥច្ឆាវិនយាយ មុច្ចតិ
ឥច្ឆាយ វិប្បហានេន
សព្វំ ឆិន្ទតិ ពន្ធនន្តិ ។

## ទសមំ លោកសុត្តំ

[១៩៨] កិស្មឹ លោកោ សមុប្បន្នោ
កិស្មឹ កុព្វតិ សន្ថវំ
កិស្ស[១] លោកោ ឧបាទាយ
កិស្មឹ លោកោ វិហញ្ញតីតិ ។

[១៩៩] ឆសុ លោកោ សមុប្បន្នោ
ឆសុ កុព្វតិ សន្ថវំ

១ ឱ. កិស្សា ។ ម. កិស្មឹ ។

# ឥច្ឆាសូត្រ ទី ៩

[១៩៦] ១. អ្វី ចងទាក់សត្វលោកទុក សត្វលោក របូតរួចទៅ ព្រោះកម្ចាត់បង់នូវធម៌អ្វី សត្វលោក កាត់ផ្តាច់នូវចំណងទាំងពួងបាន ព្រោះលះបង់នូវអ្វី ។

[១៩៧] ២. សេចក្តីប្រាថ្នា ចងទាក់សត្វលោកទុក សត្វលោក របូតរួចទៅបាន ព្រោះកម្ចាត់បង់សេចក្តីប្រាថ្នា សត្វលោក កាត់ផ្តាច់នូវចំណងទាំងពួងបាន ព្រោះលះបង់សេចក្តីប្រាថ្នា ។

# លោកសូត្រ ទី ១០

[១៩៨] ១. លុះតែអ្វី កើតឡើង ទើបសត្វលោកកើតឡើងបាន សត្វលោក រមែងធ្វើនូវសេចក្តីស្និទ្ធស្នាលក្នុងអ្វី សត្វលោកប្រកាន់មាំនូវអ្វី សត្វលោក លំបាកព្រោះអ្វី ។

[១៩៩] ២. លុះតែអាយតនៈខាងក្នុងទាំង ៦ កើតឡើង ទើបសត្វលោកកើតឡើងបាន សត្វលោករមែងធ្វើនូវសេចក្តីស្និទ្ធស្នាល ក្នុងអាយតនៈខាងក្រៅទាំង ៦ សត្វលោក

១០៧

ទេវតាសំយុត្តស្ស អន្ធវគ្គេ ឧទ្ទានំ

ឆន្ទមេវ ឧចាជាយ

ឆសុ លោកោ វិហញ្ញតីតិ ។

អន្ធវគ្គោ សត្តមោ ។

តស្សុទ្ទានំ

ជាមំ ចិត្តញ្ច តណ្ហា ច

សញ្ញោជនញ្ច ពន្ធនា

អព្ភាហតុឌ្ឌិតោ បិហិតោ

ឥច្ឆា លោកេន តេ ឧសាតិ ។

ប្រកាន់មាំ នូវអាយតនៈខាងក្នុងទាំង ៦ សត្វលោក លំ-
បាក ព្រោះអាយតនៈខាងក្រៅទាំង ៦ ។

ចប់ អន្នវគ្គ ទី ៧ ។

## បញ្ជីរឿងនៃអន្នវគ្គនោះ គឺ

សូត្រទាំងឡាយ ១០ នោះគឺ នាមសូត្រ ១ ចិត្តសូត្រ ១ តណ្ហាសូត្រ ១ សញ្ញោជនសូត្រ ១ ពន្ធនសូត្រ ១ អត្តា-ហតសូត្រ ១ ឧឌ្ឌិតសូត្រ ១ បិហិតសូត្រ ១ ឥច្ឆាសូត្រ ១ លោកសូត្រ ១ ។

# អដ្ឋមោ យត្វាវគ្គោ

## បឋមំ យត្វាសុត្តំ

[២០០] ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ

គាថាយ អជ្ឈភាសិ

កឹសុ យត្វា[១] សុខំ សេតិ

កឹសុ យត្វា ន សោចតិ

កិស្សស្ស ឯកធម្មស្ស

វធំ រោចេសិ គោតមាតិ ។

[២០១] កោធំ យត្វា សុខំ សេតិ

កោធំ យត្វា ន សោចតិ

កោធស្ស វិសមូលស្ស

មធុរគ្គស្ស ទេវតេ

វធំ អរិយា បសំសន្តិ

តញ្ហិ យត្វា ន សោចតីតិ ។

១ ឱ. ម. ឆេត្វា ។ អ. យត្វា ។

# ឃត្វាវគ្គ ទី ៨

## ឃត្វាសូត្រ ទី ១

[២០០] ទេវតានោះ ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលគាថា ចំពោះព្រះមានព្រះភាគថា

បុគ្គលសម្លាប់អ្វីបាន ទើបដេកនៅជាសុខ សម្លាប់អ្វីបាន ទើបមិនសោក បពិត្រព្រះគោតម ព្រះអង្គគាប់ព្រះហឫទ័យ ចំពោះការសម្លាប់ធម៌ឯក តើធម៌អ្វី ។

[២០១] ព. បុគ្គលសម្លាប់សេចក្តីក្រោធបាន ទើបដេកនៅជាសុខ សម្លាប់សេចក្តីក្រោធបាន ទើបមិនសោក ម្នាលទេវតា ព្រះអរិយៈទាំងឡាយ តែងសរសើរការសម្លាប់សេចក្តីក្រោធ ដែលមានគល់ជាពិស មានចុងដ៏ផ្អែម លុះតែសម្លាប់សេចក្តីក្រោធនោះបាន ទើបមិនសោក ។

# ទុតិយំ វេថសុត្តំ

[២០២] កឹសុ វេថស្ស បញ្ញាណំ

កឹសុ បញ្ញាណមគ្គិនោ

កឹសុ រដ្ឋស្ស បញ្ញាណំ

កឹសុ បញ្ញាណមិត្ថិយាតិ ។

[២០៣] ធជោ វេថស្ស បញ្ញាណំ

ធូមោ បញ្ញាណមគ្គិនោ

រាជា វេថស្ស បញ្ញាណំ

ភត្តា បញ្ញាណមិត្ថិយាតិ ។

# តតិយំ វិត្តសុត្តំ

[២០៤] កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ

កឹសុ សុចិណ្ណោ[១] សុខមាវហាតិ

កឹសុ ហវេ សាធុតរំ រសានំ

កថំជីវឹ[២] ជីវិតមាហុ សេដ្ឋន្តិ ។

---

១ សុចិណ្ណន្តិបិ បាឋេន ភវិតព្វំ ។ ២ ម. កឹសុ ជីវឹ ។ កថំជីវឹ ឥតិបិ ទិស្សតិ ។

ទេវតាសំយុត្ត យក្ខាវគ្គ ការសួរនូវទ្រព្យ

# រថសូត្រ ទី ២

[២០២] ទ. អ្វី ជាគ្រឿងប្រាកដរបស់រថ អ្វី ជាគ្រឿងប្រាកដរបស់ភ្លើង អ្វី ជាគ្រឿងប្រាកដរបស់ដែន អ្វី ជាគ្រឿងប្រាកដរបស់ស្រី ។

[២០៣] ព. ទង់ ជាគ្រឿងប្រាកដរបស់រថ ផ្សែង ជាគ្រឿងប្រាកដរបស់ភ្លើង ព្រះរាជា ជាគ្រឿងប្រាកដរបស់ដែន ភស្តាជាគ្រឿងប្រាកដរបស់ស្រី ។

# វិត្តសូត្រ ទី ៣

[២០៤] ទ. ក្នុងលោកនេះ អ្វី ជាទ្រព្យដ៏ប្រសើររបស់បុរស អ្វី ដែលគេសន្សំល្អហើយ តែងនាំសេចក្តីសុខមកឲ្យ អ្វី មានរសឆ្ងាញ់ពិសាលើសលុបជាងរសទាំងឡាយ បណ្ឌិត ទាំងឡាយពោលថា អ្នករស់នៅបែបណា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ។

[២០៨] សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាធុតរំ រសានំ
បញ្ញាជីវឹ(១) ជីវិតមាហុ សេដ្ឋន្តិ ។

## ចតុត្ថំ វុដ្ឋិសុត្តំ

[២០៦] កឹសុ ឧប្បតតំ សេដ្ឋំ
កឹសុ និបតតំ វរំ
កឹសុ បវជមានានំ
កឹសុ បវទតំ វរន្តិ ។

[២០៧] ពីជំ ឧប្បតតំ សេដ្ឋំ
វុដ្ឋិ និបតតំ វរា
គាវោ បវជមានានំ
បុត្តោ បវទតំ វរោតិ ។

---

១ បញ្ញាជីវី ឥតិបិ ។

[២០៥] ៣. ក្នុងលោកនេះ សទ្ធា ជាទ្រព្យដ៏ប្រសើររបស់បុរស ធម៌ ដែលគេសន្សំល្អហើយ តែងនាំសេចក្តីសុខមកឲ្យ ពាក្យសត្យ មានរសឆ្ងាញ់ពីសាលើសរសទាំង-ឡាយ បណ្ឌិតទាំងឡាយពោលថា អ្នករស់នៅដោយបញ្ញា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ។

## វុដ្ឋិសូត្រ ទី ៤

[២០៦] ទ. បណ្តារបស់ដែលកើតមានឡើង អ្វី ជារបស់ប្រសើរ បណ្តារបស់ដែលធ្លាក់ចុះ អ្វី ជារបស់ប្រសើរ បណ្តាសត្វដើរទៅដោយជើង សត្វពួកណា ជាសត្វប្រសើរ បណ្តាអ្នកចេះនិយាយពីរោះ មនុស្សបែបណាប្រសើរ ។

[២០៧] ទេវតាអង្គ ១ ពោលកាត់ថា បណ្តារបស់ដែលកើតមានឡើង ពូជស្រូវ ជារបស់ប្រសើរ បណ្តារបស់ដែលធ្លាក់ចុះ ទឹកភ្លៀង ជារបស់ប្រសើរ បណ្តាសត្វ ដើរទៅដោយជើង គោ ជាសត្វប្រសើរ បណ្តាអ្នកចេះនិយាយពីរោះ កូន ជាមនុស្សប្រសើរ ។

[២០៨] វិជ្ជា ឧប្បតតំ សេដ្ឋា
អវិជ្ជា និបតតំ វរា
សង្ឃោ បវជមានានំ
ពុទ្ធោ បវទតំ វរោតិ ។

## បញ្ចមំ ភីតសុត្តំ

[២០៩] កឹសូធ ភីតា ជនតា អនេកា
មគ្គោវនេកាយតនប្បវុត្តោ
បុច្ឆាមិ តំ គោតម ភូរិបញ្ញ
កិស្មឹ ឋិតោ បរលោកំ ន ភាយេតិ ។

[២១០] វាចំ មនញ្ច បណិធាយ សម្មា
កាយេន បាបានិ អកុព្វមានោ
ពហុន្នបានំ ឃរមាវសន្តោ
សទ្ធោ មុទូ សំវិភាគី វទញ្ញូ
ឯតេសុ ធម្មេសុ ឋិតោ ចតូសុ
ធម្មេ[១] ឋិតោ បរលោកំ ន ភាយេតិ ។

---

១ ម. ធម្មេសុ ។

[២០៨] ៣. បណ្ដារបស់ដែលកើតមានឡើង វិជ្ជា ជាធម្មជាតិប្រសើរ បណ្ដារបស់ដែលធ្លាក់ចុះ អវិជ្ជា ដែលធ្លាក់ចុះប្រសើរ បណ្ដាសត្វដើរទៅដោយជើង ព្រះសង្ឃជាបុគ្គលប្រសើរ បណ្ដាអ្នកចេះនិយាយពីរោះ ព្រះពុទ្ធជាបុគ្គលប្រសើរ ។

# ភីតសូត្រ ទី ៥

[២០៩] ទ. ក្នុងលោកនេះ អ្វី ដែលប្រជុំជនច្រើនគ្នាតែងខ្លាច ហើយព្រះអង្គ សំដែងថា ជាផ្លូវមានមែកបែកច្រើនណាស់ បពិត្រព្រះគោតមជាម្ចាស់ ព្រះអង្គមានបញ្ញាក្រាស់ ខ្ញុំព្រះអង្គសូមសួរថា នរជនតាំងនៅក្នុងធម៌ដូចម្ដេច រមែងមិនភ័យទៅក្នុងលោក ។

[២១០] ៣. សាធុជនតម្កល់វាចានិងចិត្ត ដោយប្រពៃមិនធ្វើបាបដោយកាយ គ្រប់គ្រងនូវផ្ទះដែលមានបាយនិងទឹកច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករលែក ជាអ្នកដឹងនូវពាក្យពោល ជនដែលតាំងនៅក្នុងធម៌ទាំង ៤ ប្រការនេះ ឈ្មោះថា ជាអ្នកឋិតនៅក្នុងធម៌ រមែងមិនភ័យទៅក្នុងបរលោកទេ ។

# ឆដ្ឋំ នជីរតិសុត្តំ

[២១១] កឹសុ[១] ជីរតិ កឹ ន ជីរតិ
កឹសុ ឧប្បថោតិ វុច្ចតិ
កឹសុ ធម្មានំ បរិបន្ថោ
កឹសុ រត្តិន្ទិវក្ខយោ
កឹ មលំ ព្រហ្មចរិយស្ស
កឹ សិនានមនោទកំ
កតិ លោកស្មិំ ឆិទ្ទានិ
យត្ថ ចិត្តំ ន តិដ្ឋតិ
ភគវន្តំ បុដ្ឋុមាគម្ម
កថំ ជានេមុ តំ មយន្តិ ។
[២១២] រូបំ ជីរតិ មច្ចានំ
នាមគោត្តំ ន ជីរតិ
រាគោ ឧប្បថោតិ វុច្ចតិ
លោភោ ធម្មានំ បរិបន្ថោ
វយោ រត្តិន្ទិវក្ខយោ

១ ឱ. ម. ក ។

# នជីរតិសូត្រ ទី ៦

[២១១] ទ. អ្វី រមែងចាស់ជរា អ្វី រមែងមិនចាស់ជរា អ្វី ហៅថាផ្លូវខុស អ្វី ជាសេចក្ដីអន្តរាយនៃធម៌ទាំងឡាយ អ្វី អស់ទៅតាមយប់និងថ្ងៃ អ្វី ជាមន្ទិលនៃព្រហ្មចរិយៈ អ្វី ជាជម្មជាតិសម្រាប់លាងជម្រះ មិនចាំបាច់មានទឹក ចិត្តរមែងមិនឋិតនៅក្នុងច្រកទាំងឡាយណា ច្រកទាំងនោះ តើមានប៉ុន្មានក្នុងលោក យើងខ្ញុំព្រះអង្គនាំគ្នាមកគាល់ព្រះមានព្រះភាគ ធ្វើម្ដេចហ្ន៎ នឹងដឹងនូវសេចក្ដីនោះបាន ។

[២១២] ព. រូបរបស់សត្វទាំងឡាយ រមែងចាស់ជរា នាមនិងគោត្រមិនចាស់ជរាឡើយ រាគៈហៅថាផ្លូវខុស លោភៈជាសេចក្ដីអន្តរាយនៃធម៌ទាំងឡាយ វ័យអស់ទៅតាមយប់និងថ្ងៃ

១១៣

ទេវតាសំយុត្តស្ស យត្វាវគ្គេ ព្រហ្មចរិយមលាទិ

ឥត្ថី មលំ ព្រហ្មចរិយស្ស

ឯត្ថាយំ សជ្ជតេ បជា

តបោ ច ព្រហ្មចរិយញ្ច

តំ សិនានមនោទកំ

ឆ លោកស្មិ ឆិទ្ទានិ(១)

យត្ថ ចិត្តំ ន តិដ្ឋតិ

អាលស្សញ្ច បមាទោ ច

អនុដ្ឋានមសំយមោ

និទ្ទា តន្ទី ច តេ ឆិទ្ទេ

សព្វសោ តំ វវជ្ជយេតិ ។

១ ម. ឆិទ្ទេ លោកស្មឹ ឆ ឆិទ្ទានិ ។

ស្ត្រី ជាមន្ទិលរបស់ព្រហ្មចរិយៈ ប្រជាជនទាំងនោះ រមែង ជាប់ចំពាក់នៅនឹងស្ត្រីទាំងនោះ តបធម៌ឬព្រហ្មចរិយធម៌ ជាធម្មជាតសម្រាប់លាងជម្រះនូវមន្ទិលនោះ មិនចាំបាច់មានទឹកឡើយ ចិត្តរមែងមិនឋិតនៅ ក្នុងប្រកទាំងឡាយណា ប្រកទាំងនោះមាន ៦ យ៉ាង ក្នុងលោក គឺសេចក្ដីខ្ជិលច្រអូស ១ សេចក្ដីធ្វេសប្រហែស ១ សេចក្ដីមិនព្យាយាម ១ ការមិនសង្រួម ១ ការលក់ ១ សេចក្ដីខ្ជិល ១ ជនគប្បីវៀរបង់នូវប្រកទាំងនោះ ដោយប្រការទាំងពួងចុះ ។

# សត្តមំ ឥស្សរសុត្តំ

[២១៣] កឹសុ ឥស្សរិយំ លោកេ
កឹសុ ភណ្ឌានមុត្តមំ
កឹសុ សត្ថមលំ[១] លោកេ
កឹសុ លោកស្មិមព្ពុទំ
កឹសុ ហរន្តំ វារេន្តិ
ហរន្តោ បន កោ បិយោ
កឹសុ បុនប្បុនាយន្តំ
អភិនន្ទន្តិ បណ្ឌិតាតិ ។

[២១៤] វសោ ឥស្សរិយំ លោកេ
ឥត្ថី ភណ្ឌានមុត្តមំ
កោធោ សត្ថមលំ លោកេ
ចោរា លោកស្មិមព្ពុទា
ចោរំ ហរន្តំ វារេន្តិ
ហរន្តោ សមណោ បិយោ
សមណំ បុនប្បុនាយន្តំ
អភិនន្ទន្តិ បណ្ឌិតាតិ ។

១ ម. សត្ថមលំ ។

# ឥស្សរសូត្រ ទី ៧

[២១៣] ទ. អ្វី ជាធំក្នុងលោក អ្វី ឧត្តមជាងទ្រព្យទាំងឡាយក្នុងលោក អ្វី ដូចជាច្រែះចាប់សស្ត្រាក្នុងលោក អ្វី ជាសេចក្តីអន្តរាយក្នុងលោក អ្នកផងតែងឃាត់ខាំងទុកនូវជនដូចម្តេច កាលដែលនាំយកទ្រព្យទៅ មួយទៀត អ្នកផងតែងពេញចិត្ត ចំពោះជនដូចម្តេច កាលនាំយកទ្រព្យទៅ ពួកជនជាបណ្ឌិត តែងត្រេកអរ ចំពោះជនដូចម្តេចដែលមករឿយៗ ។

[២១៤] ព. អំណាច ជាធំក្នុងលោក ស្ត្រី ឧត្តមជាងទ្រព្យទាំងឡាយក្នុងលោក សេចក្តីក្រោធ ដូចជាច្រែះចាប់សស្ត្រាក្នុងលោក ពួកចោរ ជាសេចក្តីអន្តរាយក្នុងលោក អ្នកផងតែងឃាត់ខាំងទុក នូវចោរកាលដែលនាំយកទ្រព្យទៅ អ្នកផងតែងពេញចិត្ត ចំពោះសមណៈកាលនាំយកទ្រព្យទៅ ពួកជនជាបណ្ឌិត តែងត្រេកអរចំពោះសមណៈ ដែលមករឿយ ៗ ។

## អដ្ឋមំ កាមសុត្តំ

[២១៥] កិមត្ថកាមោ ន ទទេ
កឹ មច្ចោ ន បរិច្ចជេ
កឹសុ មុច្ចេយ្យ កល្យាណឹ
បាបិកញ្ច[១] ន មោចយេតិ ។

[២១៦] អត្តានំ ន ទទេ បោសោ
អត្តានំ ន បរិច្ចជេ
វាចំ មុច្ចេយ្យ កល្យាណឹ
បាបិកញ្ច ន មោចយេតិ ។

## នវមំ បាវេយ្យសុត្តំ

[២១៧] កឹសុ ពន្ធតិ បាវេយ្យំ
កឹសុ ភោគានមាសយោ
កឹសុ នរំ បរិកស្សតិ
កឹសុ លោកស្មិ ទុជ្ជហំ
កិស្មឹ ពទ្ធា បុថូ សត្តា
បាសេន សកុណី យថាតិ ។

---

១ ឱ. បាបិយញ្ច ។

# កាមសូត្រ ទី ៨

[២១៥] ទ. របស់អ្វី ដែលអ្នកប្រាថ្នានូវប្រយោជន៍ មិនគប្បីប្រគល់ឲ្យគេ របស់អ្វី ដែលសត្វមិនគប្បីលះបង់ចោល វត្ថុអ្វី ជារបស់ល្អ ដែលបុគ្គលគួរបញ្ចេញ តែបើអាក្រក់វិញ បុគ្គលមិនគួរបញ្ចេញ ។

[២១៦] ព. បុរសមិនគប្បីប្រគល់ខ្លួនឲ្យគេទេ មិនគប្បីលះបង់ខ្លួនចោលទេ គួរបញ្ចេញវាចាពីរោះ មិនគួរបញ្ចេញវាចាអាក្រក់សោះឡើយ ។

# បាថេយ្យសូត្រ ទី ៩

[២១៧] ទ. អ្វី រមែងចងទុកនូវស្បៀងគឺកុសល អ្វី ជាទីនៅអាស្រ័យនៃភោគៈទាំងឡាយ អ្វី រមែងកើចកន្ត្រាក់នរជនយកទៅ អ្វី ដែលបុគ្គលលះបង់បានដោយកម្រក្នុងលោក សត្វមានកិលេសគ្រាស់ ជាប់ចំពាក់នៅ ក្នុងរបស់អ្វី ដែលដូចជាបក្សីជាប់អន្ទាក់ ។

[២១៨] សទ្ធា ពន្ធតិ ចាបេយ្យំ
សិរិ ភោគានមាសយោ
ឥច្ឆា នរំ បរិកស្សតិ
ឥច្ឆា លោកស្មិ ទុជ្ជហា
ឥច្ឆាពន្ធា បុថូ សត្តា
ចាសេន សកុណី យថាតិ ។

## ទសមំ បជ្ជោតសុត្តំ

[២១៩] កឹសុ លោកស្មិ បជ្ជោតោ
កឹសុ លោកស្មិ ជាគរោ
កឹសុ កម្មេ សជីវានំ
កឹសុ ចស្ស[១] ឥរិយាបថោ
កឹសុ អលសំ អនលសញ្ច
មាតា បុត្តំវ បោសតិ
កឹសុ ភូតា ឧបជីវន្តិ
យេ បាណា បថវឹ សិតាតិ ។

---
១ ឱ. ម. កិមស្ស ។

[២១៨] ៣. សទ្ធា រមែងចងទុកនូវស្បៀងគឺកុសល សិរី ជាទីនៅអាស្រ័យនៃភោគៈទាំងឡាយ សេចក្តីប្រាថ្នា រមែងកើចកន្ទ្រាក់នរជនទៅ សេចក្តីប្រាថ្នាកម្របុគ្គលលះបង់បាន ក្នុងលោក សត្វមានកិលេសក្រាស់ រមែងជាប់នៅ ក្នុងសេចក្តីប្រាថ្នា ដូចជាបក្សីជាប់អន្ទាក់ ។

# បជ្ជោតសូត្រ ទី ១០

[២១៩] ទ. អ្វី ជាគ្រឿងបំភ្លឺក្នុងលោក អ្វី ជាគ្រឿងភ្ញាក់រឭកក្នុងលោក អ្វី ជាសម្លាញ់ក្នុងការងារ របស់ពួកជនអ្នកចិញ្ចឹមជីវិត អ្វី ជាគ្រឿងចិញ្ចឹមជីវិតរបស់ពួកសត្វនោះ អ្វី តែងចិញ្ចឹមនូវបុគ្គលខ្ជិលនិងមិនខ្ជិល ដូចជាមាតាចិញ្ចឹមបុត្ត ពួកសត្វណា ដែលអាស្រ័យផែនដី សត្វទាំងនោះ តែងរស់នៅនឹងអ្វី ។

[២២០] បញ្ញា លោកស្មិ បជ្ជោតោ
សតិ លោកស្មិ ជាគរោ
គាវោ កម្មេ សជីវានំ
សីតស្ស ឥរិយាបថោ
វុដ្ឋិ អាលសំ អនលសញ្ច
មាតា បុត្តំវ ចោសតិ
វុដ្ឋី ភូតា ឧបជីវន្តិ
យេ ចាណា បឋវី សិតាតិ ។

ឯកាទសមំ អរណាសុត្តំ

[២២១] កេសូធ អរណា លោកេ
កេសំ វុសិតំ ន នស្សតិ
កេធ ឥច្ឆំ(១) បរិជានន្តិ
កេសំ ភោជិសិយំ សទា
កឹសុ មាតា បិតា ភាតា
វន្ទន្តិ នំ បតិដ្ឋិតំ
កឹសុ ឥធ ជាតិហីនំ
អភិវាទេន្តិ ខត្តិយាតិ ។

១ ឥច្ឆាតិ វា បាឋោ ។

[២២០] ពា. បញ្ញា ជាគ្រឿងបំភ្លឺក្នុងលោក សតិ ជាគ្រឿងភ្ញាក់រឭកក្នុងលោក គោ ជាសម្ភារញ់ក្នុងការងាររបស់ពួកជនអ្នកចិញ្ចឹមជីវិត នង្គ័ល ជាគ្រឿងចិញ្ចឹមជីវិត របស់ពួកសត្វនោះ ទឹកភ្លៀង តែងចិញ្ចឹមនូវបុគ្គលខ្ជិលនិងមិនខ្ជិល ដូចជាមាតាចិញ្ចឹមបុត្ត ពួកសត្វដែលអាស្រ័យផែនដី តែងរស់នៅនឹងទឹកភ្លៀង ។

# អរណាសូត្រ ទី ១១

[២២១] ទេ. ក្នុងលោកនេះ មនុស្សពួកណា ជាបុគ្គលមិនមានកិលេស ព្រហ្មចរិយៈគឺមនុស្សពួកណា រក្សាហើយរមែងមិនខូចខាតទៅវិញ ក្នុងលោកនេះ មនុស្សពួកណារមែងស្គាល់ច្បាស់នូវសេចក្តីប្រាថ្នា មនុស្សពួកណា រួចខ្លួនជាអ្នកជា ក្នុងកាលទាំងពួង មាតាបិតាបងប្អូន រមែងក្រាបសំពះនូវបុគ្គលណា បុគ្គលនោះតាំងនៅក្នុងគុណធម៌ដូចម្តេច ក្នុងលោកនេះ ក្សត្រិយ៍ទាំងឡាយ រមែងទ្រង់សំពះដោយគោរពនូវជនមានជាតិថោកទាប តើមនុស្សពួកណា ។

[២២២] សមណីឌ អរណា លោកេ
សមណានំ វុសិតំ ន នស្សតិ
សមណា ឥច្ឆំ បរិជានន្តិ
សមណានំ កោជិសិយំ សទា
សមណំ មាតា បិតា ភាតា
វន្ទន្តិ នំ បតិដ្ឋិតំ
សមណីឌ ជាតិហីនំ
អភិវាទេន្តិ ខត្តិយាតិ ។

យត្វាវគ្គោ អដ្ឋមោ ។

## តស្សុទ្ទានំ

យត្វា រថញ្ច វិត្តញ្ច
វុឌ្ឍិ ភីតា នជីរតិ
ឥស្សរំ កាមចាបេយ្យំ
បជ្ជោតោ អរណេន ចាតិ ។

ទេវតាសំយុត្តំ សមត្តំ ។

[២២២] ៣. ក្នុងលោកនេះ ពួកខីណាសវសមណៈ ជាបុគ្គលមិនមានកិលេស ព្រហ្មចរិយៈ ដែលពួកព្រះខីណាស្រពរក្សាហើយ រមែងមិនខូចខាតទៅវិញ ពួកខិណាសវសមណៈ រមែងស្គាល់ច្បាស់ នូវសេចក្តីប្រាថ្នា ពួកខីណាសវសមណៈ រួចខ្លួនជាអ្នកជា ក្នុងកាលទាំងពួងមាតាបិតាបងប្អូន រមែងក្រាបសំពះ នូវខីណាសវសមណៈនោះ ដែលជាអ្នកមានសីលដ៏ខ្ជាប់ខ្ជួន ក្នុងលោកនេះក្សត្រិយ៍ទាំងឡាយ រមែងទ្រង់សំពះ ដោយគោរពនូវជនមានជាតិថោកទាប ដែលជាសមណៈ ។

ចប់ យត្វាវគ្គ ទី ៨ ។

# បញ្ជីរឿងនៃយត្វាវគ្គនោះគឺ

យត្វាសូត្រ ១ រថសូត្រ ១ វិត្តសូត្រ ១ វុដ្ឋិសូត្រ ១ ភីតសូត្រ ១ នជីរតិសូត្រ ១ ឥស្សរសូត្រ ១ កាមសូត្រ ១ បាថេយ្យសូត្រ ១ បជ្ជោតសូត្រ ១ អរណោសូត្រ ១ ។

ចប់ ទេតាសំយុត្ត

# ទេវបុត្តសំយុត្តំ

## បឋមោ កស្សបវគ្គោ

### បឋមំ បឋមកស្សបសុត្តំ

[២២៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ កស្សបោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ កស្សបោ ទេវបុត្តោ ភគវន្តំ ឯតទវោច ភិក្ខុំ ភគវា បកាសេសិ នោ ច ភិក្ខុនោ អនុសាសន្តិ ។ តេន ហិ កស្សប តញ្ញេវេត្ថ បដិភាតូតិ ។

# ទេវបុត្តសំយុត្ត

## កស្សបវគ្គ ទី ១

### បឋមកស្សបសូត្រ ទី ១

[២២៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះឯង កាលវេលារាត្រី បឋមយាមកន្លងទៅហើយ ទេវបុត្តឈ្មោះកស្សបមានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំដោយគោរព ចំពោះព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីសមគួរ ។ លុះកស្សបទេវបុត្តឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា ព្រះមានព្រះភាគទ្រង់ទូន្មានភិក្ខុ ឯខ្ញុំព្រះអង្គមិនបានប្រៀនប្រដៅភិក្ខុទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលកស្សប បើដូច្នោះ ពាក្យប្រៀនប្រដៅនិងដំបូន្មាន (នុ៎ះ) ចូរតាំងឡើងប្រាកដក្នុងទីនេះចុះ ។

[២២៨] សុភាសិតស្ស សិក្ខេថ
សមណុបាសនស្ស ច
ឯកាសនស្ស ច រហោ
ចិត្តវូបសមស្ស ចាតិ

ឥទមវោច កស្សបោ ទេវបុត្តោ ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ កស្សបោ ទេវបុត្តោ សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

## ទុតិយំ ទុតិយកស្សបសុត្តំ

[២២៩] សាវត្ថិយំ អារាមេ... ឯកមន្តំ ឋិតោ ខោ កស្សបោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ភិក្ខុ សិយា ឈាយិ វិមុត្តចិត្តោ
អាកង្ខេ វេ[១] ហទយស្សានុបត្តឹ
លោកស្ស ញត្វា ឧទយព្វយញ្ច
សុចេតសោ អនិស្សិតោ[២] តទានិសំសោតិ ។

១ ឱ. ច ។ ម. ចេ ។២ ម. អ. ឯវំ ។ ឱ. អសិតោ ។

[២២៤] កស្សបទេវបុត្ត ក្រាបបង្គំទូលថា

បុគ្គលគួរសិក្សានូវពាក្យសុភាសិត នូវការចូលទៅគប់ប្រសព្វនឹងសមណៈ នូវអាសនៈតែមួយក្នុងទីស្ងាត់ នូវធម៌ជាគ្រឿងញ៉ាំងចិត្តឲ្យស្ងប់រម្ងាប់ ។

ព្រះសាស្ដាក៏ទ្រង់មានព្រះហឫទ័យរីករាយ ។ លុះកស្សបទេវបុត្តដឹងថា ព្រះសាស្ដា ទ្រង់មានព្រះហឫទ័យរីករាយនឹងពាក្យអាត្មាហើយ ក៏ថ្វាយបង្គំដោយគោរព ចំពោះព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះឯង ។

# ទុតិយកស្សបសូត្រ ទី ២

[២២៥] ព្រះមានព្រះភាគ ទ្រង់គង់ក្នុងអារាម ជិតក្រុងសាវត្ថី... កស្សបទេវបុត្ត ឋិតនៅក្នុងទីសមគួរ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ភិក្ខុដែលជាអ្នកមានអានិសង្សក្នុងព្រះអរហត្តនោះ កាលបើចង់បានព្រះអរហត្ត គប្បីជាអ្នកមានឈាន ជាអ្នកមានចិត្តរួចស្រឡះ ដឹងនូវសេចក្ដីអស់ទៅនិងសូន្យទៅនៃលោក ជាអ្នកមានចិត្តល្អ មិនគប្បីអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ឡើយ ។

# តតិយំ មាឃសុត្តំ

[២២៦] សាវត្ថិយំ អារាមេ... អថខោ មាឃោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[២២៧] ឯកមន្តំ ឋិតោ ខោ មាឃោ ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

កឹសុ ឆេត្វា សុខំ សេតិ
កឹសុ ឆេត្វា ន សោចតិ
កិស្សស្ស ឯកធម្មស្ស
វធំ រោចេសិ គោតមាតិ ។

ទេវបុត្តសំយុត្ត កស្សបវគ្គ សូររកការសម្លាប់

# មាឃសូត្រទី ៣

[២២៦] ព្រះមានព្រះភាគទ្រង់គង់ក្នុងអារាម ជិតក្រុងសាវត្ថី... កាលវេលារាត្រីបឋមយាមកន្លងទៅហើយ មាឃទេវបុត្ត[១] មានរស្មីដ៏ល្អ ក៏ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំដោយគោរព ចំពោះព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីសមគួរ ។

[២២៧] លុះមាឃទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលគាថានឹងព្រះមានព្រះភាគថា

បុគ្គលសម្លាប់អ្វី ទើបដេកជាសុខ សម្លាប់អ្វី ទើបមិនសោក
បពិត្រព្រះគោតម ព្រះអង្គគាប់ព្រះហឫទ័យនឹងការសម្លាប់
ធម៌មួយ តើគឺធម៌អ្វី ។

១ ព្រះឥន្ទ ។

[២២៨] កោធំ ឃត្វា សុខំ សេតិ
កោធំ ឃត្វា ន សោចតិ
កោធស្ស វិសមូលស្ស
មធុរគ្គស្ស វត្រភូ
វធំ អរិយា បសំសន្តិ
តញ្ហិ ឃត្វា ន សោចតីតិ ។

## ចតុត្ថំ មាគធសុត្តំ

[២២៩] ឯកមន្តំ ឋិតោ ខោ មាគធោ ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

កតិ លោកស្មិំ បជ្ជោតា
យេហិ លោកោ បកាសតិ
ភគវន្តំ បុដ្ឋុមាគម្ម
កថំ ជានេមុ តំ មយន្តិ ។

[២២៨] ព្រះមានព្រះភាគត្រាស់ថា បុគ្គលសម្លាប់សេចក្តីក្រោធបាន ទើបដេកជាសុខ សម្លាប់សេចក្តីក្រោធបាន ទើបមិនសោក ម្នាលវត្រភូ[១] ព្រះអរិយៈទាំងឡាយតែងសរសើរការសម្លាប់សេចក្តីក្រោធ ដែលមានឫសជាពិស មានចុងដ៏ផ្អែម ជនសម្លាប់សេចក្តីក្រោធនោះឯង ទើបមិនសោក ។

## មាគធសូត្រ ទី ៤

[២២៩] មាគធទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ពោលនឹងព្រះមានព្រះភាគ ដោយគាថាថា

ពន្លឺក្នុងលោក មានប៉ុន្មានយ៉ាង លោកភ្លឺច្បាស់ដោយពន្លឺទាំងឡាយណា យើងខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ ធ្វើដូចម្តេចហ្ន៎ នឹងដឹងនូវពន្លឺនោះបាន។

១ ជាឈ្មោះនៃព្រះឥន្ទ្រ ។ ព្រះឥន្ទ្រនោះបានជាឈ្មោះថាវត្រភូ ព្រោះគ្របសង្កត់នូវជនដទៃដោយវត្ត ( ៧ យ៉ាងមានចិញ្ចឹមមាតាបិតាជាដើម) ហើយដល់នូវភាពជាធំជាងទេវតា ។

[២៣០] ចត្តារោ លោកេ បជ្ជោតា
បញ្ចមេត្ថ ន វិជ្ជតិ
ទិវា តបតិ អាទិច្ចោ
រត្តិមាភាតិ ចន្ទិមា
អថ អគ្គិ ទិវារត្តឹ
តត្ថ តត្ថ បកាសតិ
សម្ពុទ្ធោ តបតំ សេដ្ឋោ
ឯសា អាភា អនុត្តរាតិ ។

## បញ្ចមំ ទាមលិសុត្តំ

[២៣១] សាវត្ថិយំ អារាមេ... អថខោ ទាមលិ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[២៣២] ឯកមន្តំ ឋិតោ ខោ ទាមលិ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[២៣០] *ព្រះមានព្រះភាគទ្រង់ត្រាស់ថា ពន្លឺក្នុងលោកនេះមានតែ ៤ យ៉ាង មិនមានដល់ ៥ យ៉ាងទេ គឺព្រះអាទិត្យភ្លឺក្នុងវេលាថ្ងៃ ព្រះចន្ទភ្លឺក្នុងវេលាយប់ ឯភ្លើងភ្លឺក្នុងទីនោះ ៗ ទាំងយប់ទាំងថ្ងៃ ព្រះសម្ពុទ្ធប្រសើរលើសពន្លឺទាំងឡាយ ពន្លឺនេះមិនមានពន្លឺដទៃលើសលុបឡើយ ។*

## ទាមលិសូត្រ ទី ៥

[២៣១] *ព្រះមានព្រះភាគទ្រង់គង់ក្នុងអារាម ជិតក្រុងសាវត្ថី... គ្រានោះ កាលវេលារាត្រីបឋមយាម កន្លងហើយ ទាមលិទេវបុត្តមានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។*

[២៣២] *លុះទាមលិទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា*

ករណីយមេតំ[១] ព្រាហ្មណេន
បធានមក្កិលាសុនា
ការានំ វិប្បហានេន
ន តេនាសីសតេ ភវន្តិ ។

[២៣៣] នត្ថិ កិច្ចំ ព្រាហ្មណស្ស (ឧាមលីតិ ភគវា)
កតកិច្ចោ ហិ[២] ព្រាហ្មណោ
យាវ ន គាធំ លភតិ នទីសុ
អាយូហតិ សព្វគត្តេភិ ជន្តុ
គាធញ្ច លទ្ធាន ថលេ ឋិតោ សោ
នាយូហតិ បារគតោ ហិ ហោតិ[៣]
ឯសូបមា ឧាមលិ ព្រាហ្មណស្ស
ខីណាសវស្ស និបកស្ស ឈាយិនោ
បប្បុយ្យ ជាតិមរណស្ស អន្តំ
នាយូហតិ បារគតោ ហិ ហោតីតិ ។

១ ឱ. ករណីយមេត្ថ ។ ២ ម. តិ ។ ៣ ឱ. ម. សោតិ ។

សេចក្តីព្យាយាមនុ៎ះ ព្រាហ្មណ៍អ្នកមិនខ្ជិលច្រអូស គួរធ្វើដោយកិរិយាលះបង់នូវកាមទាំងឡាយ ព្រាហ្មណ៍មិនប្រាថ្នានូវភព ដោយហេតុនោះទេ ។

[២៣៣] (ព្រះមានព្រះភាគត្រាស់ថា ម្នាលទាមលិ) កិច្ចរបស់ព្រាហ្មណ៍ មិនមានទេ ព្រោះថាព្រាហ្មណ៍មានកិច្ចធ្វើរួចហើយ សត្វមិនបាននូវទីពឹង ក្នុងស្ទឹងទាំងឡាយដរាបណា រមែងឃ្លាងចាកដំណើរទាំងពួងដរាបនោះ លុះតែសត្វនោះបាននូវទីពឹងផង បិតនៅលើគោកផង ទើបមិនឃ្លាង ជាអ្នកដល់នូវត្រើយមែនពិត ម្នាលទាមលិ នេះឧបមាដូចជាព្រាហ្មណ៍ ជាខីណាស្រព មានប្រាជ្ញាចាស់ ជាអ្នកមានឈាន ដល់ហើយនូវទីបំផុតនៃជាតិនិងមរណៈ ជាអ្នកដល់នូវត្រើយមែនពិត ឥតឃ្លាង ដូច្នោះឯង ។

ទេវបុត្តសំយុត្តស្ស កស្សបវគ្គេ តុដ្ឋិព្យាករណំ

# ឆដ្ឋំ កាមទសុត្តំ

[២៣៤] ឯកមន្តំ ឋិតោ ខោ កាមទោ ទេវបុត្តោ ភគវន្តំ ឯតទវោច ទុក្ករំ ភគវា សុទុក្ករំ ភគវាតិ ។

ទុក្ករំ វាបិ ករោន្តិ (កាមទាតិ ភគវា)
សេក្ខសីលសមាហិតា ឋិតត្តា
អនគារិយុបេតស្ស
តុដ្ឋិ ហោតិ សុខាវហាតិ ។

[២៣៥] ទុល្លភា ភគវា យទិទំ តុដ្ឋីតិ ។

ទុល្លភំ វាបិ លភន្តិ (កាមទាតិ ភគវា)
ចិត្តវូបសមេ រតា
យេសំ ទិវា ច រត្តោ ច
ភាវនាយ រតោ មនោតិ ។

# កាមទសូត្រ ទី ៦

[២៣៤] *កាមទទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលនឹងព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគ កាលធ្វើសមណធម៌ បុគ្គលធ្វើបានដោយកម្រ បពិត្រព្រះមានព្រះភាគ ការធ្វើសមណធម៌ បុគ្គលធ្វើបានដោយកម្រក្រៃពេក ។*

*(ព្រះមានព្រះភាគត្រាស់ថា ម្នាលកាមទៈ) លុះតែជន*
*ទាំងឡាយប្រកបដោយសេក្ខសីល មានសភាពជាអ្នកខ្ជាប់*
*ខ្ជួន ទើបធ្វើសមណធម៌ ដែលបុគ្គលធ្វើបានដោយកម្រ*
*សេចក្ដីសន្ដោសរបស់បុគ្គលចូលដល់នូវភាពជាបុគ្គលគ្មានផ្ទះ*
*ជាគុណជាតិនាំមកនូវសេចក្ដីសុខ ។*

[២៣៥] *កាមទទេវបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ សេចក្ដីសន្ដោសនេះ បុគ្គលបានដោយកម្រ ។*

*(ព្រះមានព្រះភាគត្រាស់ថា ម្នាលកាមទៈ) លុះតែចិត្ត*
*របស់ពួកជនដែលត្រេកអរក្នុងភាវនាទាំងយប់ទាំងថ្ងៃ ត្រេក-*
*អរក្នុងធម៌ជាគ្រឿងចូលទៅជិតញុំាងចិត្តឲ្យស្ងប់ ទើបបាននូវ*
*សេចក្ដីសន្ដោសដែលបុគ្គលបានដោយកម្រ ។*

[២៣៦] ទុស្សមាទហំ ភគវា យទិទំ ចិត្តន្តិ ។

ទុស្សមាទហំ វាបិ សមាទហន្តិ

(កាមទាតិ ភគវា) ឥន្ទ្រិយូបសមេ រតា

តេ ឆេត្វា មច្ចុនោ ជាលំ

អរិយា គច្ឆន្តិ កាមទាតិ ។

[២៣៧] ទុគ្គមោ ភគវា វិសមោ មគ្គោតិ ។

ទុគ្គមេ វិសមេ វាបិ

អរិយា គច្ឆន្តិ កាមទ

អនរិយា វិសមេ មគ្គេ

បបតន្តិ អវំសិរា

អរិយានំ សមោ មគ្គោ

អរិយា ហិ វិសមេ សមាតិ ។

[២៣៦] កាមទទេវបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ចិត្តនេះបុគ្គលតម្កល់បានដោយកម្រ ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលកាមទៈ) លុះតែពួកជនណាជាអរិយៈ ត្រេកអរក្នុងការរម្ងាប់នូវឥន្ទ្រិយ កាត់នូវបណ្ដាញនៃមច្ចុបាន ម្នាលកាមទៈ ពួកជននោះ ទើបតម្កល់នូវចិត្តដែលបុគ្គលតម្កល់បានដោយកម្រ ។

[២៣៧] កាមទទេវបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ផ្លូវមិនរាបស្មើ បុគ្គលទៅបានដោយកម្រ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលកាមទៈ លុះតែពួកអរិយៈជន ទើបទៅក្នុងផ្លូវមិនរាបស្មើដែលបុគ្គលទៅបានដោយកម្រ ពួកជនមិនមែនជាអរិយៈ តែងមានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងផ្លូវដ៏មិនរាបស្មើ ឯផ្លូវដ៏រាបស្មើជាផ្លូវសម្រាប់តែពួកអរិយជន ព្រោះថា ពួកអរិយជន តែងប្រព្រឹត្តស្មើក្នុងផ្លូវដ៏មិនរាបស្មើបាន ។

# សត្តមំ  បញ្ចាលចណ្ឌសុត្តំ

[២៣៨] ឯកមន្តំ ឋិតោ ខោ បញ្ចាលចណ្ឌោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សម្ពាធេ វត ឱកាសំ
អវិន្ទិ ភូរិមេធសោ
យោ ឈានមពុជ្ឈិ ពុទ្ធោ
បដិលីននិសភោ មុនីតិ ។

[២៣៩] សម្ពាធេបិ ច វិន្ទន្តិ[១] (បញ្ចាលចណ្ឌាតិ ភគវា) ធម្មំ និព្វានបត្តិយា
យេ សតឹ បច្ចលត្ថំសុ
សម្មា តេ សុសមាហិតាតិ ។

# អដ្ឋមំ  តាយនសុត្តំ

[២៤០] អថខោ តាយនោ ទេវបុត្តោ បុរាណតិត្ថ-ករោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

១ ឱ. វាបិ វន្ទន្តិ ។

# បញ្ចាលចណ្ឌសូត្រ ទី ៧

[២៣៨] *បញ្ចាលចណ្ឌទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បាន ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា*

*ឱហ្ន៎ បុគ្គលជាអ្នកមានប្រាជ្ញាក្រាស់ ជាអ្នកដឹងនូវ*
*ឈាន ជាអ្នកត្រាស់ដឹង ជាអ្នកប្រសើរដោយការលះអស្មិ-*
*មានះ ជាមុនី បានហើយនូវឱកាសគឺឈានក្នុងទីចង្អៀត ។*

[២៣៩] *(ព្រះមានព្រះភាគត្រាស់ថា ម្នាលបញ្ចាល-*
*ចណ្ឌៈ) ជនទាំងឡាយណា ទោះបីឋិតនៅក្នុងទីចង្អៀត*
*ក៏បាននូវសតិ ព្រោះដល់នូវការរំលត់នូវអកុសលធម៌ ជន*
*ទាំងនោះ ឈ្មោះថាតម្កល់នៅដោយល្អប្រពៃ ។*

# តាយនសូត្រ ទី ៨

[២៤០] *គ្រានោះ កាលរាត្រីបឋមយាមកន្លងទៅហើយ តាយ- នទេវបុត្ត ជាបុរាណតិត្ថករ[១] មានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូល ឲ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះ មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។*

---
១ ពីដើមធ្លាប់ជាមេលទ្ធិ ជាអ្នកបង្កើតទិដ្ឋិ ៦២ ។

[២៤១] ឯកមន្តំ ឋិតោ ខោ តាយនោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

ឆិន្ទ សោតំ បរក្កម្ម
កាមេ បនូទ ព្រាហ្មណ
នប្បហាយ មុនិ កាមេ
នេកត្តមុបបជ្ជតិ(១)
កយិរា ចេ(២) កយិរាថេនំ
ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ
ភិយ្យោ អាកិរតេ រជំ
អកតំ ទុក្កដំ សេយ្យោ
បច្ឆា តប្បតិ ទុក្កដំ
កតញ្ច សុកតំ សេយ្យោ
យំ កត្វា នានុតប្បតិ

១ ឱ. នេកត្តមុបបជ្ជតីតិ ។ ២ ឱ. កយិរញ្ចេ ។

[២៤១] លុះតាយនទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ទើបពោលគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា បពិត្រព្រាហ្មណ៍ ចូរអ្នកកាត់ខ្សែតណ្ហា ចូរអ្នកបន្ទោបង់កាមទាំងឡាយ មុនី (បើ) មិនលះបង់កាមទាំងឡាយទេ ក៏មិនបាននូវឈាន បុគ្គលបើបានជាធ្វើព្យាយាម កុំគប្បីបន្ធូរបន្ថយព្យាយាមនោះឡើយ គប្បីធ្វើព្យាយាមនោះ ឲ្យមាំមួនឡើង ព្រោះថាបព្វជ្ជាដែលបុគ្គលកាន់ធូរ ៗ រមែងរោយធូលីគឺកិលេសដ៏ក្រៃលែង អំពើអាក្រក់ដែលបុគ្គលមិនធ្វើហើយជាអំពើប្រសើរ អំពើអាក្រក់ តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ មួយទៀត បុគ្គលធ្វើអំពើណា តែងមិនក្តៅតាម អំពើនោះ ដែលបុគ្គលធ្វើហើយ ជាអំពើល្អប្រសើរ

កុសោ យថា ទុគ្គហិតោ
ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ
និរយាយូបកឌ្ឍតិ
យង្កិញ្ចិ សិថិលំ កម្មំ
សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ
ន តំ ហោតិ មហប្ផលន្តិ ។

ឥទមវោច តាយនោ ទេវបុត្តោ ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

[២៤២] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ តាយនោ នាម ទេវបុត្តោ បុរាណតិត្ថករោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ តាយនោ ទេវបុត្តោ មម សន្តិកេ ឥមា គាថាយោ អភាសិ

ភាពជាសមណៈដែលអ្នកបួសកាន់មិនល្អ តែងប្រទាញចូលទៅក្នុងនរក ដូចជាស្បូវដែលបុគ្គលកាន់មិនល្អ តែងមុតដៃដូច្នោះឯង ការងារណាមួយដ៏ធូរ ៗ ក្តី វត្តណាមួយដ៏សៅហ្មងក្តី ព្រហ្មចរិយធម៌ណាមួយ ដែលបុគ្គលប្រព្រឹត្តដោយសេចក្តីរង្កៀសក្តី កិច្ចនោះ ជាកិច្ចមិនមានផលធំឡើយ ។

តាយនទេវបុត្ត បានពោលពាក្យនេះ លុះពោលពាក្យនេះរួច ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ បាត់ក្នុងទីនោះឯង ។

[២៤២] កាលរាត្រីនោះកន្លងទៅ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ កាលរាត្រីបឋមយាមកន្លងទៅហើយ តាយនទេវបុត្ត ជាបុរាណតិត្ថករ មានរស្មីដ៏ល្អញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ចូលមករកតថាគត លុះចូលមកដល់ហើយថ្វាយបង្គំតថាគត ឋិតនៅក្នុងទីសមគួរ ។ លុះតាយនទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលគាថាទាំងនេះ ក្នុងសំណាក់តថាគតថា

ឆិន្ទ  សោតំ  បរក្កម្ម
កាមេ  បនូទ  ព្រាហ្មណ
នប្បហាយ  មុនិ  កាមេ
នេកត្តមុបបជ្ជតិ
កយិរា  ចេ  កយិរាថេនំ
ទឡ្ហមេនំ  បរក្កមេ
សិថិលោ  ហិ  បរិព្វាជោ
ភិយ្យោ  អាកិរតេ  រជំ
អកតំ  ទុក្កដំ  សេយ្យោ
បច្ឆា  តប្បតិ  ទុក្កដំ
កតញ្ច  សុកតំ  សេយ្យោ
យំ  កត្វា  នានុតប្បតិ
កុសោ  យថា  ទុគ្គហិតោ
ហត្ថមេវានុកន្តតិ
សាមញ្ញំ  ទុប្បរាមដ្ឋំ
និរយាយុបកឌ្ឍតិ
យំ  កិញ្ចិ  សិថិលំ  កម្មំ

បពិត្រព្រាហ្មណ៍ ចូរអ្នកព្យាយាមកាត់ខ្សែតណ្ហា ចូរអ្នកបន្ទោបង់នូវកាមទាំងឡាយ មុនី (បើ) មិនលះបង់នូវកាមទាំងឡាយទេ ក៏មិនបាននូវឈាន បុគ្គលបើបានជាធ្វើព្យាយាម កុំគប្បីបន្ធូរបន្ថយព្យាយាមនោះឡើយ គប្បីធ្វើព្យាយាមនោះឲ្យមាំមួនឡើង ព្រោះថាបព្វជ្ជាដែលបុគ្គលកាន់ធូរ ៗ រមែងរោយនូវធូលីគឺកិលេសដ៏ក្រៃលែង អំពើអាក្រក់ដែលបុគ្គលមិនធ្វើហើយ ជាអំពើប្រសើរ អំពើអាក្រក់ តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ មួយទៀត បុគ្គលធ្វើនូវអំពើណា តែងមិនក្តៅតាម អំពើនោះដែលបុគ្គលធ្វើហើយជាអំពើល្អប្រសើរ ភាពជាសមណៈដែលអ្នកបួសកាន់មិនល្អតែងប្រទាញចូលទៅក្នុងនរក ដូចជាស្បូវដែលបុគ្គលកាន់មិនល្អ តែងមុតដៃដូច្នោះឯង ការងារណាមួយដ៏ធូរ ៗ ក្តី

សង្ក៏លិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ
ន តំ ហោតិ មហប្ផលន្តិ ។

ឥទមវោច ភិក្ខវេ តាយនោ ទេវបុត្តោ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ឧគ្គណ្ហាថ ភិក្ខវេ តាយនគាថា បរិយាបុណាថ ភិក្ខវេ តាយ-នគាថា ធារេថ ភិក្ខវេ តាយនគាថា អត្ថសញ្ហិតា ភិក្ខវេ តាយនគាថា អាទិព្រហ្មចរិយកាតិ ។

## នវមំ ចន្ទិមសុត្តំ

[២៤៣] សាវត្ថិយំ វិហរតិ... តេន ខោ បន សមយេន ចន្ទិមា ទេវបុត្តោ រាហុនា អសុរិន្ទេន គហិ-តោ ហោតិ ។ អថខោ ចន្ទិមា ទេវបុត្តោ ភគវន្តំ អនុស្សរមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

វត្តណាមួយដ៏សៅហ្មងក្តី ព្រហ្មចរិយធម៌ណាមួយ ដែល បុគ្គលប្រព្រឹត្តដោយសេចក្តីរង្កៀសក្តី កិច្ចនោះ ជាកិច្ចមិន មានផលធំឡើយ ។

ម្នាលភិក្ខុទាំងឡាយ តាយនទេវបុត្ត បានពោលពាក្យនេះ លុះ ពោលពាក្យនេះរួច ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ បាត់ ក្នុងទីនោះឯង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូលរៀននូវតាយន-គាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទន្ទេញនូវតាយនគាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទ្រទ្រង់នូវតាយនគាថា ម្នាល ភិក្ខុទាំងឡាយ តាយនគាថា ប្រកបដោយប្រយោជន៍ ជាខាងដើមនៃ ព្រហ្មចរិយៈ ។

# ចន្ទិមសូត្រ ទី ៩

[២៤៣] ព្រះមានព្រះភាគទ្រង់គង់ជិតក្រុងសាវត្ថី... សម័យ នោះឯង រាហុអសុរិន្ទ ចាប់ចន្ទិមទេវបុត្ត ។ លំដាប់នោះ ចន្ទិមទេវបុត្ត រឭកដល់ព្រះមានព្រះភាគ បានពោលគាថានេះ ក្នុងវេលានោះថា

ជមោ  តេ  ពុទ្ធវីរត្ថុ
វិប្បមុត្តោសិ  សព្វធិ
សម្ពាធប្បដិបន្នោស្មិ
តស្ស  មេ  សរណំ  ភវាតិ  ។

[២៤៤]  អថខោ  ភគវា  ចន្ទិមំ  ទេវបុត្តំ  អារព្ភ រាហុំ  អសុរិន្ទំ  គាថាយ  អជ្ឈភាសិ

តថាគតំ  អរហន្តំ
ចន្ទិមា  សរណំ  គតោ
រាហុ  ចន្ទំ  បមុញ្ចស្សុ
ពុទ្ធា  លោកានុកម្បកាតិ  ។

[២៤៥]  អថខោ  រាហុ  អសុរិន្ទោ  ចន្ទិមំ  ទេវបុត្តំ មុញ្ចិត្វា  តរមានរូបោ  យេន  វេបចិត្តិ  អសុរិន្ទោ  តេនុប-សង្កមិ  ឧបសង្កមិត្វា  សំវិគ្គោ  លោមហដ្ឋជាតោ  ឯក-មន្តំ  អដ្ឋាសិ  ។

[២៤៦]  ឯកមន្តំ  ឋិតំ  ខោ  រាហុំ  អសុរិន្ទំ  វេប-ចិត្តិ  អសុរិន្ទោ  គាថាយ  អជ្ឈភាសិ

បពិត្រព្រះពុទ្ធអ្នកមានព្យាយាម កិរិយានមស្ការថ្វាយបង្គំ (របស់ខ្ញុំ) ចូរមានដល់ព្រះអង្គ ព្រះអង្គរួចស្រឡះចាក ធម៌ទាំងពួងមានខន្ធ និង អាយតនៈជាដើម ខ្ញុំព្រះអង្គដល់ នូវគ្រោះថ្នាក់ដ៏ចង្អៀតហើយ សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ ។

[២៨៤] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ប្រារព្ធ ចន្ទិមទេវបុត្ត ក៏ត្រាស់នឹងរាហុអសុរិន្ទ ដោយគាថា ថា ចន្ទិមទេវបុត្ត ដល់នូវតថាគតជាអរហន្ត ជាទីពឹងហើយ ម្នាលរាហុ អ្នកចូរលែងចន្ទទេវបុត្តចេញ ព្រះពុទ្ធទាំងឡាយ តែងទ្រង់អនុគ្រោះសត្វលោក ។

[២៨៥] គ្រានោះឯង រាហុអសុរិន្ទលែងចន្ទិមទេវបុត្តហើយ ក៏ប្រញាប់ប្រញាល់ចូលទៅរកវេបចិត្តិអសុរិន្ទ លុះចូលទៅដល់ ក៏មានសេចក្ដីសង្វេគព្រឺរោមព្រឺស្បែក ឋិតនៅក្នុងទីសមគួរ ។

[២៨៦] វេបចិត្តិអសុរិន្ទ បានពោលនឹងរាហុអសុរិន្ទ ដែលឋិតនៅក្នុងទីសមគួរដោយគាថា ថា

កិន្នុ  សន្តរមានោវ
រាហុ  ចន្ទំ  បមុញ្ចសិ
សំវិគ្គរូបោ  អាគម្ម
កិន្នុ  ភីតោវ  តិដ្ឋសីតិ ។

[២៤៧] សត្តធា  មេ  ផលេ  មុទ្ធា
ជីវន្តោ  ន  សុខំ  លភេ
ពុទ្ធគាថាភិគីតោម្ហិ
នោ  ចេ  មុញ្ចេយ្យ  ចន្ទិមន្តិ ។

## ទសមំ  សុរិយសុត្តំ

[២៤៨] តេន  ខោ  បន  សមយេន  សុរិយោ  ទេវបុត្តោ  រាហុនា  អសុរិន្ទេន  គហិតោ  ហោតិ ។ អថខោ  សុរិយោ  ទេវបុត្តោ  ភគវន្តំ  អនុស្សរមានោ  តាយំ  វេលាយំ  ឥមំ  គាថំ  អភាសិ

នមោ  តេ  ពុទ្ធវីរត្ថុ
វិប្បមុត្តោសិ  សព្វធិ
សម្ពាធប្បដិបន្នោស្មិ
តស្ស  មេ  សរណំ  ភវាតិ ។

ម្នាលរាហុ ហេតុដូចម្តេចបានជាអ្នកប្រញាប់លែងចន្ទទេវបុត្ត ហើយមានសភាពស្រពោនស្រពាប់ ហេតុដូចម្តេចបានជាអ្នកភ័យដល់ម្ល៉េះ ។

[២៤៧] រាហុអសុរិន្ទ បានពោលគាថា ថា

ខ្ញុំជាបុគ្គលត្រូវ ចន្ទិមទេវបុត្តពោលគាថាចំពោះព្រះពុទ្ធហើយ បើខ្ញុំមិនលែងចន្ទិមទេវបុត្តទេ ក្បាលខ្ញុំ មុខជានឹងបែកជា ៧ ភាគ ទោះបើខ្ញុំរស់នៅ ក៏មិនបានសេចក្តីសុខ ។

# សុរិយសូត្រ ទី ១០

[២៤៨] សម័យនោះឯង រាហុអសុរិន្ទ ចាប់សុរិយទេវបុត្ត ។ លំដាប់នោះ សុរិយទេវបុត្តរឭកដល់ព្រះមានព្រះភាគ បានពោលគាថានេះ ក្នុងវេលានោះថា

បពិត្រព្រះពុទ្ធអ្នកមានព្យាយាម កិរិយានមស្ការ របស់ខ្ញុំ ចូរមានដល់ព្រះអង្គនោះ ព្រះអង្គរួចស្រឡះចាកធម៌ទាំងពួង មានខន្ធនិងអាយតនៈជាដើម ខ្ញុំព្រះអង្គដល់នូវគ្រោះថ្នាក់ដ៏ចង្អៀតហើយ សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ ។

[២៤៩] អថខោ ភគវា សុរិយំ ទេវបុត្តំ អារព្ភ រាហុំ អសុរិន្ទំ គាថាយ អជ្ឈភាសិ

តថាគតំ អរហន្តំ
សុរិយោ សរណំ គតោ
រាហុ សុរិយំ បមុញ្ចស្សុ
ពុទ្ធា លោកានុកម្បកា
យោ អន្ធការេ តបសី បភង្ករោ
វេរោចនោ មណ្ឌលិ ឧគ្គតេជោ
មា រាហុ គិលី ចរមន្តលិក្ខេ
បជំ មម រាហុ បមុញ្ច សុរិយន្តិ ។

[២៥០] អថខោ រាហុ អសុរិន្ទោ សុរិយំ ទេវបុត្តំ មុញ្ចិត្វា តរមានរូបោ យេន វេបចិត្តិ អសុរិន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា សំវិគ្គោ លោមហដ្ឋជាតោ ឯកមន្តំ អដ្ឋាសិ

[២៥១] ឯកមន្តំ ឋិតំ ខោ រាហុំ អសុរិន្ទំ វេបចិត្តិ អសុរិន្ទោ គាថាយ អជ្ឈភាសិ

[២៤៩] លំដាប់នោះឯង ព្រះមានព្រះភាគ ប្រារព្ធសុរិយទេវបុត្ត ក៏ត្រាស់នឹងរាហុអសុរិន្ទ ដោយគាថា ថា

សុរិយទេវបុត្ត ដល់នូវតថាគតជាអរហន្ត ជាទីពឹងហើយ
ម្នាលរាហុ អ្នកចូរលែងសុរិយទេវបុត្តចេញ ព្រះពុទ្ធទាំងឡាយ តែងទ្រង់អនុគ្រោះសត្វលោក អ្នកណាមានកម្តៅ
មានពន្លឺភ្លឺផ្លេក ៗ ដ៏រុងរឿងក្នុងទីងងឹត មានសណ្ឋានមូល
មានតេជៈខ្ពង់ខ្ពស់ ម្នាលរាហុ អ្នកកុំលេបនូវអ្នកនោះ ដែល
កំពុងតែចរទៅឰដ៏អាកាសឡើយ ម្នាលរាហុ អ្នកចូរលែង
សុរិយទេវបុត្ត ជាកូនតថាគតចេញ ។

[២៥០] លំដាប់នោះឯង រាហុអសុរិន្ទ បានលែងសុរិយទេវបុត្តហើយ ប្រញាប់ចូលទៅរកវេបចិត្តិអសុរិន្ទ លុះចូលទៅដល់ហើយ មានសេចក្តីសង្វេគព្រឺរោមព្រឺស្បែក ឋិតនៅក្នុងទីសមគួរ ។

[២៥១] វេបចិត្តិអសុរិន្ទ បានពោលនឹងរាហុអសុរិន្ទ ដែលឋិតនៅក្នុងទីសមគួរ ដោយគាថា ថា

កិន្នុ សន្ធរមានោ វ
រាហុ សុរិយំ បមុញ្ចសិ
សំវិគ្គរូបោ អាគម្ម
កិន្នុ ភីតោ វ តិដ្ឋសីតិ ។

[២៥២] សត្តធា មេ ផលេ មុទ្ធា
ជីវន្តោ ន សុខំ លភេ
ពុទ្ធគាថាភិគីតោម្ហិ
នោ ចេ មុញ្ចេយ្យ សុរិយន្តិ ។

កស្សបវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ទ្វេ កស្សបា ច មាឃោ ច
មាគធោ ទាមលិ កាមទោ
បញ្ចាលចណ្ឌោ ច តាយនោ
ចន្ទិមសុរិយេន តេ ទសាតិ

ម្នាលរាហុ ហេតុដូចម្ដេច បានជាអ្នកប្រញាប់លែងសុរិយ-ទេវបុត្ត ហើយមានសភាពស្រពោនស្រពាប់ ហេតុដូចម្ដេច បានជាអ្នកភ័យដល់ម្ល៉េះ ។

[២៩២] រាហុអសុរិន្ទ បានពោលគាថា ថា

ខ្ញុំជាបុគ្គលត្រូវសុរិយទេវបុត្ត បានពោលគាថាចំពោះព្រះពុទ្ធហើយ បើខ្ញុំមិនលែងសុរិយទេវបុត្តទេ ក្បាលរបស់ខ្ញុំមុខជានឹងបែកជា ៧ ភាគ ទោះបីខ្ញុំរស់នៅ ក៏មិនបានសុខដែរ ។

ចប់ កស្សបវគ្គ ទី ១ ។

## បញ្ជីរឿងនៃកស្សបវគ្គនោះ គឺ

សូត្រទាំង ១០ នោះគឺ កស្សបសូត្រ ២ មាឃសូត្រ ១ មាគ-ធសូត្រ ១ ទាមលិសូត្រ ១ កាមទសូត្រ ១ បញ្ចាលចណ្ឌ-សូត្រ ១ តាយនសូត្រ ១ ចន្ទិមសូត្រ ១ សុរិយសូត្រ ១ ។

# ទុតិយោ អនាថបិណ្ឌិកវគ្គោ

## បឋមំ ចន្ទិមសសុត្តំ

[២៤៣] សាវត្ថិយំ អារាមេ... អថខោ ចន្ទិមសោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[២៤៤] ឯកមន្តំ ឋិតោ ខោ ចន្ទិមសោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

តេ ហិ សោត្ថឹ គមិស្សន្តិ
កច្ឆេវាមកសេ មិគា
ឈានានិ ឧបសម្បជ្ជ
ឯកោទិនិបកា សតា ។

# អនាថបិណ្ឌិកវគ្គ ទី ២

## ចន្ទិមសសូត្រ ទី ១

[២៥៣] ក្នុងអារាមជិតក្រុងសាវត្ថី... គ្រាកាលដែលរាត្រីបឋម-យាមកន្លងទៅហើយ ទេវបុត្តឈ្មោះចន្ទិមសៈ មានរស្មីរុងរឿង ញុំាង វត្តជេតពនទាំងមូល ឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះ ចូលទៅដល់ ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ ហើយឋិតនៅក្នុង ទីសមគួរ ។

[២៥៤] ចន្ទិមសទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ពោល នូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ជនទាំងឡាយណា បានដល់នូវឈាន មានចិត្តតាំងនៅក្នុង
អារម្មណ៍តែមួយ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានសតិ
ជនទាំងឡាយនោះ នឹងដល់នូវសួស្តី ដូចជាម្រឹគនៅក្នុង
កៀន[១] ដែលមិនមានសត្វមូស ។

---

១ កៀនភ្នំឬកៀនទន្លេ ។

[២៥៥] តេ ហិ ចារំ គមិស្សន្តិ
ឆេត្វា ជាលំវ[១] អម្ពុជោ
ឈានានិ ឧបសម្បជ្ជ
អប្បមត្តា រណញ្ជហាតិ ។

## ទុតិយំ វេណ្ឌុសុត្តំ

[២៥៦] ឯកមន្តំ ឋិតោ ខោ វេណ្ឌុ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សុខិតា វត តេ មនុជា
សុគតំ បយិរុបាសិយ
យុញ្ជ គោតមសាសនេ
អប្បមត្តានុសិក្ខរេតិ ។

[២៥៧] យេ មេ វុត្តេ សត្ថុបទេ[២] (វេណ្ឌូតិ ភគវា)
អនុសិក្ខន្តិ ឈាយិនោ
កាលេ តេ អប្បមជ្ជន្តា
ន មច្ចុវសគា សិយុន្តិ ។

---

១ ឱ. ម. អយមេវ បាឋោ ។ ជាលញ្ហាតិប្បត្តិ ។ ២ ឱ. បវុត្តេ សត្ថិបទេ ។ ម. ច វុត្តេ សិត្ថិបទេ ។

[២៥៥] ព្រះមានព្រះភាគ ត្រាស់ថា ជនទាំងឡាយ ណា បានដល់នូវឈាន ជាអ្នកមិនប្រមាទ បានលះបង់នូវកិលេស ជនទាំងឡាយនោះ នឹងដល់នូវត្រើយគឺព្រះនិព្វានដូចជាត្រីកាត់នូវសំណាញ់បាន ។

# វេណ្ឌុសូត្រ ទី ២

[២៥៦] វេណ្ឌុទេវបុត្ត បិតនៅក្នុងទីសមគួរហើយ ក៏ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

មនុស្សទាំងឡាយ ណា បានចូលទៅអង្គុយជិតព្រះសុគត ហើយជាអ្នកប្រកបព្យាយាម មិនប្រមាទ តែងសិក្សាតាមក្នុងសាសនាព្រះគោតម មនុស្សទាំងនោះ ដល់នូវសេចក្តីសុខមែនពិត ។

[២៥៧] (ព្រះមានបុណ្យត្រាស់ថា នៃវេណ្ឌុទេវបុត្ត) មនុស្សទាំងឡាយ ណា មានឈាន បានសិក្សាតាម ក្នុងចំណែកនៃពាក្យប្រៀនប្រដៅ ដែលតថាគត បានពោលហើយ មនុស្សទាំងឡាយនោះ កាលបើមិនប្រមាទ ក្នុងកាលគួរ មិនគប្បីលុះក្នុងអំណាចនៃមច្ចុបានឡើយ ។

# តតិយំ ទីឃលដ្ឋិសុត្តំ

[២៥៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជ-គហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ ទីឃលដ្ឋិ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ វេឡុវនំ ឱភាសេត្វា យេន ភគវា តេនុ-បសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[២៥៩] ឯកមន្តំ ឋិតោ ខោ ទីឃលដ្ឋិ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ភិក្ខុ សិយា ឈាយិ វិមុត្តចិត្តោ
អាកង្ខេ វេ[១] ហទយស្សានុបត្តឹ
លោកស្ស ញត្វា ឧទយព្វយញ្ច
សុចេតសោ អនិស្សិតោ តទានិសំសោតិ ។

# ចតុត្ថំ នន្ទនសុត្តំ

[២៦០] ឯកមន្តំ ឋិតោ ខោ នន្ទនោ ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

# ទីឃលដ្ឋិសូត្រ ទី ៣

[២៥៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រាកាលដែលរាត្រីបឋមយាមកន្លងទៅហើយ ទេវបុត្តឈ្មោះទីឃលដ្ឋិ មានរស្មីរុងរឿង ញុំាងវត្តវេឡុវ័នទាំងមូល ឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីសមគួរ ។

[២៥៩] លុះទីឃលដ្ឋិទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ភិក្ខុ ដែលមានព្រះអរហត្តជាអានិសង្ស គប្បីជាអ្នកមាន
ឈាន មានចិត្តរួចស្រឡះ គប្បីប្រាថ្នានូវសេចក្តីសម្រេច
នៃហឫទ័យ គឺព្រះអរហត្ត ដឹងច្បាស់នូវកិរិយាកើតឡើង
និងការសូន្យទៅ នៃសង្ខារលោក មានចិត្តល្អ មិនអា-
ស្រ័យ (នូវតណ្ហានិងទិដ្ឋិ) ។

# នន្ទនសូត្រ ទី ៤

[២៦០] នន្ទនទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគ ដោយគាថា ថា

បុច្ឆាមិ តំ គោតម ភូរិបញ្ញ
អជាវជំ ភគវតោ ញាណទស្សនំ
កថំវិធំ សីលវន្តំ វទន្តិ
កថំវិធំ បញ្ញវន្តំ វទន្តិ
កថំវិធោ ទុក្ខមតិច្ច ឥរីយតិ
កថំវិធំ ទេវតា បូជយន្តីតិ ។

[២៦១] យោ សីលវា បញ្ញវា ភាវិតត្តោ
សមាហិតោ ឈានរតោ សតីមា
សព្វស្ស សោកា វិគតា បហីនា
ខីណាសវោ អន្តិមទេហធារី
តថាវិធំ សីលវន្តំ វទន្តិ
តថាវិធំ បញ្ញវន្តំ វទន្តិ
តថាវិធោ ទុក្ខមតិច្ច ឥរីយតិ
តថាវិធំ ទេវតា បូជយន្តីតិ ។

បពិត្រព្រះគោតម អ្នកមានបញ្ញាក្រាស់ ដូចជាផែនដី ញាណទស្សនៈ របស់ព្រះមានព្រះភាគ មិនមានអ្វីរារាំង បានទេ ព្រោះហេតុនោះ ខ្ញុំសូមសួរព្រះអង្គ អ្នកប្រាជ្ញ ទាំងឡាយ ហៅបុគ្គលដូចម្តេចថា ជាអ្នកមានសីល ហៅ បុគ្គលដូចម្តេចថា ជាអ្នកមានបញ្ញា បុគ្គលដូចម្តេច ដែល អ្នកប្រាជ្ញ តែងហៅថា ជាអ្នកកន្លង នូវសេចក្តីទុក្ខបាន ទេវតាទាំងឡាយ តែងបូជានូវបុគ្គលដូចម្តេច ។

[២៦១] ព្រះអង្គត្រាស់ថា បុគ្គលណាមានសីល មាន បញ្ញា មានខ្លួនចម្រើនហើយ មានចិត្តតាំងខ្ជាប់ ត្រេកអរ ក្នុងឈាន មានស្មារតី ប្រាសចាកសេចក្តីសោក លះបង់ នូវកិលេសទាំងពួង មានអាសវៈអស់ហើយ ទ្រទ្រង់នូវរាង កាយជាទីបំផុត អ្នកប្រាជ្ញទាំងឡាយ តែងហៅបុគ្គល នោះថា ជាអ្នកមានសីល តែងហៅបុគ្គលនោះថា ជា អ្នកមានបញ្ញា បុគ្គលនោះ ដែលអ្នកប្រាជ្ញ តែងហៅថា ជាអ្នកកន្លង នូវសេចក្តីទុក្ខបាន ទេវតាទាំងឡាយ តែង បូជានូវបុគ្គលនោះ ។

# បញ្ចមំ ចន្ទនសុត្តំ

[២៦២] ឯកមន្តំ ឋិតោ ខោ ចន្ទនោ ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

កថំសុ តរតិ ឱឃំ
រត្តិន្ទិវមតន្ទិតោ
អប្បតិដ្ឋេ អនាលម្ពេ
កោ គម្ភីរេ ន សីទតីតិ ។

[២៦៣] សព្វទា សីលសម្បន្នោ
បញ្ញវា សុសមាហិតោ
អារទ្ធវិរិយោ បហិតត្តោ
ឱឃំ តរតិ ទុត្តរំ
វិរតោ កាមសញ្ញាយ
រូបសញ្ញោជណាតិតោ[១]
នន្ទិភវបរិក្ខីណោ[២]
សោ គម្ភីរេ ន សីទតីតិ ។

---

១ រូបសញ្ញោជនាតិគោតិ វា បាឋោ ។ ២ ឱ. អ. ឯវំ ។ ម. នន្ទិរាគបរិក្ខីណោ ។

# ចន្ទនសូត្រ ទី ៥

[២៦២] ចន្ទនទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគ ដោយគាថា ថា

បុគ្គលដូចម្តេចហ្ន៎ ដែលមិនខ្ជិលទាំងយប់ទាំងថ្ងៃ តែងឆ្លងនូវ
អន្លង់បាន បុគ្គលដូចម្តេច មិនលិចចុះក្នុងអន្លង់ជ្រៅ ដែល
មិនមានទីឋិតនៅខាងក្រោម មិនមានទីតោងក្នុងខាងលើ ។

[២៦៣] ព្រះអង្គត្រាស់ថា បុគ្គលបរិបូណ៌ ដោយសីល
មានបញ្ញា មានចិត្តតាំងខ្ជាប់ មានព្យាយាមប្រារព្ធហើយ
មានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វានសព្វកាល រមែងឆ្លងនូវ
អន្លង់ដែលឆ្លងបានដោយកម្រ បុគ្គលណាប្រាសចាកកាម-
សញ្ញា កន្លងនូវរូបសញ្ញោជនៈ មានភពជាទីត្រេកអរ[១] អស់
ហើយ បុគ្គលនោះ រមែងមិនលិចចុះក្នុងអន្លង់ជ្រៅឡើយ ។

---

១ បានដល់កម្មាភិសង្ខារ ៣ ។

## ឆដ្ឋំ វាសុទត្តសុត្តំ

[២៦៤] ឯកមន្តំ ឋិតោ ខោ វាសុទត្តោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សត្តិយា វិយ ឱមដ្ឋោ
ឌយ្ហមានេវ(១) មត្ថកេ
កាមរាគប្បហានាយ
សតោ ភិក្ខុ បរិព្វជេតិ ។

[២៦៥] សត្តិយា វិយ ឱមដ្ឋោ
ឌយ្ហមានេវ មត្ថកេ
សក្កាយទិដ្ឋិប្បហានាយ
សតោ ភិក្ខុ បរិព្វជេតិ ។

## សត្តមំ សុព្រហ្មសុត្តំ

[២៦៦] ឯកមន្តំ ឋិតោ ខោ សុព្រហ្មា ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

---

១ ឱ. ឌយ្ហមានោ វ ។

# វាសុទត្តសូត្រ ទី ៦

[២៦៤] វាសុទត្តទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

*ភិក្ខុមានស្មារតី គប្បីនៅដើម្បីលះបង់កាមរាគ (ដោយរហ័ស) ដូចជាបុរសដែលគេប្រហារដោយលំពែង ឬ ដូចជាបុរស ដែលភ្លើងកំពុងឆេះលើក្បាល ។*

[២៦៥] ព្រះមានព្រះភាគ ត្រាស់ថា *ភិក្ខុមានស្មារតី គប្បីនៅដើម្បីលះបង់សក្កាយទិដ្ឋិ (ដោយរហ័ស) ដូចជាបុរសដែលគេប្រហារដោយលំពែង ឬ ដូចជាបុរស ដែលភ្លើងកំពុងឆេះលើក្បាល ។*

# សុព្រហ្មសូត្រ ទី ៧

[២៦៦] សុព្រហ្មទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគ ដោយគាថា ថា

និច្ចមុត្រស្តមិទំ ចិត្តំ
និច្ចមុព្វិគ្គមិទំ មនោ
អនុប្បន្នេសុ កិច្ចេសុ
អថោ ឧប្បត្តិតេសុ ច
សចេ អត្ថិ អនុត្រស្តំ
តំ មេ អក្ខាហិ បុច្ឆិតោតិ ។

[២៦៧] នាញ្ញត្រ ពោជ្ឈង្គតបសា
នាញ្ញត្រ ឥន្ទ្រិយសំវរា
នាញ្ញត្រ សព្វនិស្សគ្គា
សោត្ថឹ បស្សាមិ បាណិនន្តិ ។

ឥទមវោច ។ បេ ។ តត្ថេវន្តរធាយីតិ ។

# អដ្ឋមំ កកុធសុត្តំ

[២៦៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាកេតេ វិហរតិ អញ្ជនវនេ មិគទាយេ ។ អថខោ កកុធោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ អញ្ជនវនំ ឱភាសេត្វា

កាលបើកិច្ច គឺសេចក្តីទុក្ខទាំងឡាយមិនទាន់កើតឡើងក្តី ឬកើតឡើងហើយក្តី ចិត្ត (របស់ខ្ញុំព្រះអង្គ) នេះតក់ស្លុតជានិច្ច ចិត្ត (របស់ខ្ញុំព្រះអង្គ) នេះរន្ធត់ជានិច្ច បើចិត្តដែលមិនតក់ស្លុត មាន ខ្ញុំព្រះអង្គសូមសួរឲ្យព្រះអង្គប្រាប់ នូវចិត្តនោះ ដល់ខ្ញុំព្រះអង្គ ។

[២៦៧] ព្រះអង្គត្រាស់ថា តថាគតមិនឃើញសួស្តីរបស់ពួកសត្វ ក្រៅអំពីពោជ្ឈង្គ និងតបោគុណទេ ក្រៅអំពីការសង្រួមនូវឥន្ទ្រិយទេ ក្រៅអំពីការលះបង់ នូវកិលេសទាំងអស់ទេ ។

លុះព្រះមានព្រះភាគ ពោលគាថានេះរួចហើយ ។ បេ ។ ទេវបុត្តនោះ ក៏បាត់អំពីទីនោះទៅ ។

# កកុធសូត្រ ទី ៨

[២៦៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងព្រៃអញ្ជ័ន ជាទីឲ្យអភ័យដល់សត្វម្រឹគ ជិតក្រុងសាកេត ។ គ្រាកាលដែលរាត្រីបឋមយាម កន្លងទៅហើយ ទេវបុត្តឈ្មោះកកុធៈមានរស្មីរុងរឿង ញុំាងព្រៃអញ្ជ័នជុំវិញទាំងអស់ ឲ្យភ្លឺស្វាង

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ

[២៦៩] ឯកមន្តំ ឋិតោ ខោ កកុធោ ទេវបុត្តោ ភគវន្តំ ឯតទវោច នន្ទសិ សមណាតិ ។ កឹ លទ្ធា អាវុសោតិ ។ តេន ហិ សមណ សោចសីតិ ។ កឹ ជីយិត្ថ អាវុសោតិ ។ តេន ហិ សមណ នេវ នន្ទសិ នេវ សោចសីតិ ។ ឯវមាវុសោតិ ។

[២៧០] កច្ចិ ត្វំ អឃិយោ ភិក្ខុ
កច្ចិ នន្ទិ ន វិជ្ជតិ
កច្ចិ តមេកមាសីនំ
អរតី នាភិកីរតីតិ ។

[២៧១] អឃិយោ វេ អហំ យក្ខ
អថោ នន្ទិ ន វិជ្ជតិ
អថោ មមេកមាសីនំ
អរតី នាភិកីរតីតិ ។

ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

[២៦៩] លុះកកុធទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះសមណៈ ព្រះអង្គត្រេកអរដែរឬ ។ ព្រះអង្គត្រាស់ថា ម្នាលអាវុសោ ត្រេកអរ ព្រោះបានអ្វី ។ បពិត្រព្រះសមណៈ បើដូច្នោះ ព្រះអង្គសោយសោកដែរឬ ។ ម្នាលអាវុសោ ចុះនរណាផ្ទាញ់អ្វី (បានជាសោយសោក) ។ បពិត្រព្រះសមណៈ បើដូច្នោះ ព្រះអង្គមិនត្រេកអរ មិនសោយសោកទេឬ ។ អើអាវុសោ ។

[២៧០] ក. ទ.[១] ព្រះអង្គជាភិក្ខុ មិនមានទុក្ខទេឬ
សេចក្តីត្រេកអរមិនមានទេឬ សេចក្តីអផ្សុកមិនគ្របសង្កត់
ព្រះអង្គ ដែលគង់នៅម្នាក់ឯងទេឬ ។

[២៧១] ព. ម្នាលយក្ស តថាគតមិនមានទុក្ខទេ ទាំង
សេចក្តីត្រេកអរក៏មិនមាន ទាំងសេចក្តីអផ្សុកក៏មិនគ្របសង្កត់
តថាគត ដែលអង្គុយនៅតែម្នាក់ឯងឡើយ ។

១ កកុធទេវបុត្ត ។

[២៧២] កចំ ត្វំ អនិឃោ ភិក្ខុ
កចំ នន្ទិ ន វិជ្ជតិ
កចំ តមេកមាសីនំ
អរតី នាភិកីរតីតិ ។

[២៧៣] អឃជាតស្ស វេ នន្ទិ
នន្ទិជាតស្ស វេ អឃំ
អនន្ទី អនិឃោ ភិក្ខុ
ឯវំ ជានាហិ អាវុសោតិ ។

[២៧៤] ចិរស្សំ វត បស្សាមិ
ព្រាហ្មណំ បរិនិព្វុតំ
អនន្ទី អនិឃំ ភិក្ខុំ
តិណ្ណំ លោកេ វិសត្តិកន្តិ ។

## នវមំ ឧត្តរសុត្តំ

[២៧៥] រាជគហនិទានំ ។ ឯកមន្តំ ឋិតោ ខោ ឧត្តរោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[២៧២] ក. ទ. ដូចម្តេចក៏ព្រះអង្គជាភិក្ខុមិនមានទុក្ខ ដូចម្តេចក៏មិនមានសេចក្តីត្រេកអរ ដូចម្តេចក៏សេចក្តីអផ្សុក មិនគ្របសង្កត់ព្រះអង្គ ដែលគង់នៅតែម្នាក់ឯង ។

[២៧៣] ព. សេចក្តីត្រេកអរ រមែងមានដល់សត្វ ដែលមានសេចក្តីទុក្ខ[១] សេចក្តីទុក្ខ រមែងមានដល់សត្វ ដែលមានសេចក្តីត្រេកអរ[២] ម្នាលអាវុសោ អ្នកឯងចូរដឹងថា ភិក្ខុមិនមានសេចក្តីត្រេកអរ សេចក្តីទុក្ខក៏មិនមានដែរ ។

[២៧៤] ក. ទ. ខ្ញុំព្រះអង្គបានឃើញភិក្ខុជាព្រាហ្មណ៍ ដែលរលត់កិលេស មិនមានសេចក្តីត្រេកអរ មិនមានទុក្ខ ឆ្លងនូវតណ្ហា ដែលជាគ្រឿងផ្សាយទៅក្នុងលោក អស់កាលយូរហើយ ។

# ឧត្តរសូត្រ ទី ៩

[២៧៥] រាជគហនិទាន ។ ឧត្តរទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

១ សំដៅយកវដ្តទុក្ខ ។ ២ សំដៅយកតណ្ហា ។

ឧបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានីតិ ។

[២៧៦] ឧបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
លោកាមិសំ បជហេ សន្តិបេក្ខោតិ ។

## ទសមំ អនាថបិណ្ឌិកសុត្តំ

[២៧៧] ឯកមន្តំ ឋិតោ ខោ អនាថបិណ្ឌិកោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

*ជីវិតគឺអាយុ មានប្រមាណតិចណាស់ តែងត្រូវជរានាំចូលទៅរក (សេចក្តីស្លាប់) សត្វដែលត្រូវជរានាំចូលទៅហើយ មិនមានទីជ្រកកោនឡើយ កាលបើបុគ្គលបានសំឡឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសេចក្តីសុខមកឲ្យ ។*

[២៧៦] ៣. *ជីវិតគឺអាយុ មានប្រមាណតិចណាស់ ដែលជរា តែងនាំចូលទៅរក (សេចក្តីស្លាប់) សត្វដែលត្រូវជរានាំចូលទៅហើយ មិនមានទីជ្រកកោនឡើយ កាលបើបុគ្គលបានសំឡឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះហើយ គប្បីជាអ្នកប្រាថ្នា នូវសន្តិភាពគឺព្រះនិព្វាន ហើយលះបង់នូវអាមិសៈក្នុងលោកចោលចេញ ។*

## អនាថបិណ្ឌិកសូត្រ ទី ១០

[២៧៧] *អនាថបិណ្ឌិកទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា*

ឥទំ ហិតំ ជេតវនំ
ឥសិសង្ឃនិសេវិតំ
អាវុត្ថំ ធម្មរាជេន
បីតិសញ្ជននំ មម
កម្មំ វិជ្ជា ច ធម្មោ ច
សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ
ន គោត្តេន ធនេន វា
តស្មា ហិ បណ្ឌិតោ បោសោ
សម្បស្សំ អត្ថមត្តនោ[១]
យោនិសោ វិចិនេ ធម្មំ
ឯវំ តត្ថ វិសុជ្ឈតិ
សារីបុត្តោវ បញ្ញាយ
សីលេន ឧបសមេន ច
យោបិ បារគតោ ភិក្ខុ
ឯតាវបរមោ សិយាតិ ។

១ អត្ថមត្តនោតិបិ បាឋោ ។

វត្ថុជេតពននេះ ជាវត្ថុមានប្រយោជន៍ ដែលពួកឥសី គឺភិក្ខុសង្ឃគង់នៅមិនដាច់ ជាវត្ថុដែលព្រះសម្ពុទ្ធ ជាធម្មរាជទ្រង់គង់នៅ ជាទីញុំាងបីតិឲ្យកើតដល់ខ្ញុំព្រះអង្គ សត្វទាំង-ឡាយរមែងបរិសុទ្ធដោយអដ្ឋង្គិកមគ្គនេះ គឺ កម្មៈ បានដល់មគ្គចេតនា វិជ្ជា បានដល់សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ធម្មៈ បានដល់សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ សីលៈ បានដល់សម្មាវាចា សម្មាកម្មន្តៈ និងសម្មា-អាជីវៈ ឈ្មោះថាជីវិតដ៏ឧត្តម មិនមែនបរិសុទ្ធដោយគោត្រ មិនមែនបរិសុទ្ធដោយទ្រព្យទេ ព្រោះហេតុនោះឯង បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍ របស់ខ្លួន គួរតែពិចារណានូវធម៌ដោយឧបាយនៃប្រាជ្ញា រមែងបរិសុទ្ធក្នុងអរិយមគ្គនោះ យ៉ាងនេះឯង ព្រះសារីបុត្ត ទើបជាបុគ្គល (ប្រសើរ) ដោយបញ្ញាផង ដោយសីលផង ដោយកាស្ងប់រម្ងាប់ផង ភិក្ខុដែលប្រសើរដោយគុណធម៌ប៉ុណ្ណោះ ទើបគួរជាអ្នកដល់នូវព្រះនិព្វាន ។

១៤៧

ទេវបុត្តសំយុត្តស្ស អនាថបិណ្ឌិកវគ្គេ ជេតវនប្បសំសាទិ

ឥទមវោច អនាថបិណ្ឌិកោ ទេវបុត្តោ ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

[២៧៨] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ អញ្ញតរោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេ-តវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្ក-មិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតោ ខោ សោ ទេវបុត្តោ មម សន្តិកេ ឥមា គាថាយោ អភាសិ

ឥទំ ហិ តំ ជេតវនំ
ឥសិសង្ឃនិសេវិតំ
អាវុត្ថំ ធម្មរាជេន
បីតិសញ្ជននំ មម
កម្មំ វិជ្ជា ច ធម្មោ ច

អនាថបិណ្ឌិកទេវបុត្ត បានពោលគាថានេះ លុះពោលដូច្នេះហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[២៧៨] លុះកន្លងរាត្រីនោះទៅ ទើបព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ កាលដែលរាត្រីបឋមយាម កន្លងទៅហើយ មានទេវបុត្តមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង ក៏ចូលមករកតថាគត លុះចូលមកដល់ ក្រាបថ្វាយបង្គំតថាគតហើយ ឋិតនៅក្នុងទីសមគួរ លុះទេវបុត្តនោះ ឋិតនៅក្នុងទីសមគួរហើយ បានពោលនូវគាថាទាំងនេះ ក្នុងសំណាក់តថាគតថា

វត្តជេតពននេះ ជាវត្តមានប្រយោជន៍ ដែលពួកឥសី គឺ
ភិក្ខុសង្ឃនៅមិនដាច់ ជាវត្តដែលព្រះសម្ពុទ្ធជាធម្មរាជ ទ្រង់
គង់នៅ ជាទីញុំាងបីតិឲ្យកើតដល់ខ្ញុំព្រះអង្គ សត្វទាំងឡាយ
រមែងបរិសុទ្ធ ដោយអដ្ឋង្គិកមគ្គនេះ គឺ កម្មៈ បានដល់
មគ្គចេតនា វិជ្ជា បានដល់សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ
ធម្មៈ បានដល់សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ

សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ
ន គោត្តេន ធនេន វា
តស្មា ហិ បណ្ឌិតោ ពោសោ
សម្បស្សំ អត្ថមត្តនោ
យោនិសោ វិចិនេ ធម្មំ
ឯវំ តត្ថ វិសុជ្ឈតិ
សារីបុត្តោ វ បញ្ញាយ
សីលេន ឧបសមេន ច
យោបិ ចារគតោ ភិក្ខុ
ឯតាវបរមោ សិយាតិ ។

ឥទមវោច ភិក្ខវេ សោ ទេវបុត្តោ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

[២៧៩] ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯត-ទវោច សោ ហិ នូន ភន្តេ អនាថបិណ្ឌិកោ ទេវបុត្តោ ភវិស្សតិ អនាថបិណ្ឌិកោ គហបតិ អាយស្មន្តេ សារី-បុត្តេ អភិប្បសន្នោ អហោសីតិ ។ សាធុ សាធុ អានន្ទ

សីលៈ បានដល់សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ឈ្មោះថាជីវិតដ៏ឧត្តម មិនមែនបរិសុទ្ធដោយគោត្រ មិនមែនបរិសុទ្ធដោយទ្រព្យ ព្រោះហេតុនោះឯង បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍ របស់ខ្លួន គួរតែពិចារណានូវធម៌ដោយឧបាយនៃប្រាជ្ញា រមែងបរិសុទ្ធក្នុងអរិយមគ្គនោះ យ៉ាងនេះឯង ព្រះសារីបុត្ត ទើបជាបុគ្គល (ប្រសើរ) ដោយបញ្ញាផង ដោយសីលផង ដោយការស្ងប់រម្ងាប់ផង ភិក្ខុដែលប្រសើរដោយគុណធម៌ប៉ុណ្ណោះ ទើបគួរជាអ្នកដល់នូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ទេវបុត្តនោះបានពោលគាថានេះ លុះពោលដូច្នេះហើយ ក្រាបថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[២៧៩] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្តនោះឯង ប្រាកដជាអនាថបិណ្ឌិក ព្រោះអនាថបិណ្ឌិកគហបតី ជ្រះថ្លាក្រៃពេក ក្នុងព្រះសារីបុត្តមានអាយុ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ មែនណាស់ហើយ

យាវតកំ ខោ អានន្ទ តក្កាយ បត្តព្វំ អនុប្បត្តំ តយា អនាថបិណ្ឌិកោ ហិ សោ អានន្ទ ទេវបុត្តោតិ ។

អនាថបិណ្ឌិកវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ចន្ទិមសោ ច វេណ្ហុ ច

ទីឃលដ្ឋិ ច នន្ទនោ

ចន្ទនោ វាសុទត្តោ ច

សុព្រហ្មា កកុធេន ច

ឧត្តរោ នវមោ វុត្តោ

ទសមោ អនាថបិណ្ឌិកោតិ ។

ម្នាលអានន្ទ ដ្បិតថាហេតុទាំងអម្បាលម៉ាន ដែលបុគ្គលគប្បីដល់ដោយសេចក្តីត្រិះរិះ ហេតុទាំងអម្បាលណោះ ខ្លួនអ្នកក៏បានសម្រេចហើយ ម្នាលអានន្ទ ទេវបុត្តនោះ គឺអនាថបិណ្ឌិកហ្នឹងឯង ។

ចប់ អនាថបិណ្ឌិកវគ្គ ទី ២ ។

## បញ្ជីរឿងនៃអនាថបិណ្ឌិកវគ្គនោះ គឺ

ចន្ទិមសសូត្រ ១ វេណ្ឌុសូត្រ ១ ទីឃលដ្ឋិសូត្រ ១ នន្ទនសូត្រ ១ ចន្ទនសូត្រ ១ វាសុទត្តសូត្រ ១ សុព្រហ្មសូត្រ ១ កកុធសូត្រ ១ ឧត្តរសូត្រជាគំរប់ប្រាំបួន ១ និងអនាថបិណ្ឌិកសូត្រ ជាគំរប់ដប់ ១ ។

# តតិយោ នានាតិត្ថិយវគ្គោ

## បឋមំ សិវសុត្តំ

[២៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សិវោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[២៨១] ឯកមន្តំ ឋិតោ ខោ សិវោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ[១] សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សេយ្យោ ហោតិ ន បាបិយោ
សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ

---
១ ម. ក្រុព្វេថ ។

# នានាតិត្ថិយវគ្គ ទី ៣

## សិវសូត្រ ទី ១

[២៨០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រាកាលដែលរាត្រីបឋមយាមកន្លងទៅហើយ ទេវបុត្តឈ្មោះសិវៈ មានរស្មីដ៏រុងរឿង ញុំាំងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។

[២៨១] លុះសិវទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ពោលគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ

បុគ្គលគួរទាក់ទង ជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើ
សេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស ព្រោះដឹងច្បាស់នូវ
ព្រះសទ្ធម្ម[១] របស់ពួកសប្បុរស រមែងបានសេចក្តីល្អ មិន
មានអាក្រក់ឡើយ បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុ-
រសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស

---

១ សំដៅយកសីល ៥ ។

១៤១

ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ សព្ភិវេរ សមាសនំ

សតំ សទ្ធម្មមញ្ញាយ
បញ្ញំ លភតិ ជាញ្ញតោ
សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សោកមជ្ឈេ ន សោចតិ ។
សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
ញាតិមជ្ឈេ វិរោចតិ
សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ
សត្តា គច្ឆន្តិ សុគ្គតឹ
សព្ភិរេវ សមាសេថ
សព្ភិ កុព្វេថ សន្ថវំ

បុគ្គល បានប្រាជ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្ម របស់ពួកសប្បុរស មិនមែនបានអំពីទីដទៃឡើយ បុគ្គលគួរទាក់ទង ជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស បុគ្គល បានដឹងព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងមិនសោកសៅ ក្នុងកណ្តាលពួកជនអ្នកសោកសៅឡើយ បុគ្គល គួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស បុគ្គល បានដឹងព្រះសទ្ធម្ម របស់ពួកសប្បុរសហើយ រមែងរុងរឿងក្នុងកណ្តាលពួកញាតិ បុគ្គល គួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស សត្វទាំងឡាយ បានដឹងព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងទៅកាន់សុគតិបាន បុគ្គល គួរទាក់ទងជាមួយនឹងពួកសប្បុរស ប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស

សតំ  សទ្ធម្មមញ្ញាយ

សត្តា  តិដ្ឋន្តិ  សាតតន្តិ  ។

[២៨២] អថខោ ភគវា សិវំ ទេវបុត្តំ គាថាយ អជ្ឈភាសិ[១]

សព្ភិរេវ  សមាសេថ

សព្ភិ  កុព្វេថ  សន្ថវំ

សតំ  សទ្ធម្មមញ្ញាយ

សព្វទុក្ខា  បមុច្ចតីតិ  ។

## ទុតិយំ  ខេមសុត្តំ

[២៨៣] ឯកមន្តំ ឋិតោ ខោ ខេមោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

១ ឱ. ម. បច្ចាភាសិ ។

សត្វទាំងឡាយ ដឹងព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងឋិត

នៅ (ជាសុខ) អស់កាលយូរ ។

[២៨២] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាតបទៅនឹងសិវទេវបុត្តវិញ ដោយគាថា ថា

បុគ្គល គួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើ

សេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលដឹងព្រះសទ្ធម្ម

របស់ពួកសប្បុរសហើយ រមែងរួចចាកទុក្ខទាំងអស់បាន ។

## ខេមសូត្រ ទី ២

[២៨៣] ខេមទេវបុត្ត ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ពោលគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

១៤៣

ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ អសាធុសាធុភាវោ

ចរន្តិ ពាលា ទុម្មេធា
អមិត្តេនេវ អត្តនា
ករោន្តិ បាបកំ កម្មំ
យំ ហោតិ កដុកប្ផលំ
ន តំ កម្មំ កតំ សាធុ
យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ
វិបាកំ បដិសេវតិ
តញ្ច កម្មំ កតំ សាធុ
យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ
វិបាកំ បដិសេវតិ
បដិកច្ចេវ តំ កយិរា
យំ ជញ្ញា ហិតមត្តនោ
ន សាកដិកចិន្តាយ
មន្តា ធីរោ បរក្កមេ
យថា សាកដិកោ បសត្ថំ[១]

---

១ ឱ. បន្ថំ ។ ម. សដ្ឋំ ។

កម្មដ៏លាមកណា មានផលក្តៅផ្សា ពួកជនពាល ឥតប្រាជ្ញា មានខ្លួនដូចជាសត្រូវ រមែងប្រព្រឹត្តធ្វើនូវកម្មដ៏លាមក (នោះ) បុគ្គល ធ្វើកម្មណាហើយ តែងក្តៅតាមក្នុងខាងក្រោយ (ឬ) បុគ្គល មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលបុគ្គលធ្វើហើយនោះ មិនប្រពៃទេ បុគ្គល ធ្វើកម្មណាហើយ មិនក្តៅតាមក្នុងខាងក្រោយ (ឬ) បុគ្គល មានសេចក្តីត្រេកអរ មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលបុគ្គលធ្វើហើយនោះ ជាកម្មប្រពៃ បុគ្គលដឹងនូវកម្មណា ដែលជាប្រយោជន៍ដល់ខ្លួន ត្រូវតែធ្វើកម្មនោះជាមុនឲ្យហើយ អ្នកប្រាជ្ញដែលមានប្រាជ្ញា មានសេចក្តីប្រឹងប្រែង មិនត្រូវធ្វើកម្មដោយគំនិតដូចជាអ្នកបររទេះឡើយ

សមំ ហិត្វា មហាបថំ
វិសមំ មគ្គមារុយ្ហ
អក្ខច្ឆិន្នោវ ឈាយតិ
ឯវំ ធម្មា អបក្កម្ម[១]
អធម្មមនុវត្តិយ
មន្ទោ មច្ចុមុខំ បត្តោ
អក្ខច្ឆិន្នោវ ឈាយតីតិ ។

## តតិយំ សេរីសុត្តំ

[២៨៤] ឯកមន្តំ ឋិតោ ខោ សេរី ទេវបុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

អន្នមេវាភិនន្ទន្តិ
ឧភយេ ទេវមានុសា
អថ ខោ នាម សោ យក្ខោ
យំ អន្នំ នាភិនន្ទតីតិ ។

១ ម. អវោក្កម្ម ។

អ្នកបររទេះ តែលះបង់ផ្លូវស្មើ លះបង់ផ្លូវធំចេញ ហើយបរឡើងលើផ្លូវមិនស្មើវិញ រមែងបាក់ភ្លៅរទេះ ហើយសញ្ជប់សញ្ជឹង យ៉ាងណាមិញ ឯបុគ្គលខ្លៅ តែគេចចេញអំពីកុសលធម៌ហើយ ប្រព្រឹត្តតាមអកុសលធម៌វិញ ក៏រមែងដល់នូវមាត់នៃមច្ចុ ហើយសញ្ជប់សញ្ជឹង ដូចជាអ្នកបររទេះបាក់ភ្លៅរទេះ យ៉ាងនោះឯង ។

## សេរីសូត្រ ទី ៣

[២៨២] សេរីទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ ដោយគាថា ថា

យក្សនោះឯង មិនត្រេកអរចំពោះបាយណា ឯទេវតានិង
មនុស្សទាំងពីរពួក រមែងត្រេកអរចំពោះបាយនោះ ។

ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ ទានប្បសំសា

[២៨៥] យេ នំ ទទន្តិ សទ្ធាយ

វិប្បសន្នេន ចេតសា

តមេវ អន្នំ ភជតិ

អស្មឹ លោកេ បរម្ហិ ច

តស្មា វិនេយ្យ មច្ឆេរំ

ទជ្ជា ទានំ មលាភិភូ

បុញ្ញានិ បរលោកស្មឹ

បតិដ្ឋា ហោន្តិ បាណិនន្តិ ។

[២៨៦] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភា-

សិតញ្ចិទំ ភន្តេ ភគវតា

[២៨៥] ព្រះមានព្រះភាគត្រាស់ថា ពួកជនណា មានចិត្តជ្រះថ្លា ឲ្យនូវបាយនោះ ដោយសទ្ធា បាយនោះឯងរមែងទៅតាមនូវពួកជននោះ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ព្រោះហេតុនោះ បុគ្គល គប្បីបន្ទោបង់នូវសេចក្តីកំណាញ់ គ្របសង្កត់នូវមន្ទិលគឺសេចក្តីកំណាញ់ហើយ ឲ្យនូវទាន (ព្រោះ) បុណ្យទាំងឡាយ រមែងជាទីពឹងរបស់ពួកសត្វ ក្នុងលោកខាងមុខ ។

[២៨៦] បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះពុទ្ធដីកាដែលព្រះមានព្រះភាគ សំដែងហើយ ដោយប្រពៃដូច្នេះថា

យេ នំ ទទន្តិ សទ្ធាយ
វិប្បសន្នេន ចេតសា
តមេវ អន្នំ ភជតិ
អស្មឹ លោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ
ទជ្ជា ទានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

[២៨៧] ភូតបុព្វាហំ ភន្តេ សេរី នាម រាជា អហោសឹ ទាយកោ ទានបតិ ទានស្ស វណ្ណវាទី ។ តស្ស មយ្ហំ ភន្តេ ចតូសុ ទ្វារេសុ ទានំ ទីយិត្ថ សមណព្រាហ្មណកបណទ្ធិកវណិព្វកយាចកានំ ។ អថខោ មំ ភន្តេ ឥត្ថាគារំ ឧបសង្កមិត្វា ឯតទវោច ទេវស្ស ខោ ទានំ ទីយតិ អម្ហាកំ ទានំ ន ទីយតិ សាធុ មយម្បិ ទេវំ និស្សាយ ទានានិ ទទេយ្យាម បុញ្ញានិ ករេយ្យាមាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហំ ខោស្មិ ទាយកោ ទានបតិ

ពួកជនណា មានចិត្តជ្រះថ្លា ឲ្យនូវបាយនោះ ដោយសទ្ធា បាយនោះឯង រមែងទៅតាមនូវពួកជននោះ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់ គ្របសង្កត់នូវមន្ទិលគឺសេចក្តីកំណាញ់ហើយ ឲ្យនូវទាន (ព្រោះ) បុណ្យទាំងឡាយរមែងជាទីពឹងរបស់ពួកសត្វ ក្នុងលោកខាងមុខ ។

[២៨៧] បពិត្រព្រះអង្គដ៏ចម្រើន ពីព្រេងនាយមក ខ្ញុំព្រះអង្គកើតជាស្តេច នាមថា សេរី ជាទាយក (អ្នកឲ្យទាន) ជាម្ចាស់នៃទាន ជាអ្នកពោលសរសើរទានជាប្រក្រតី ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យទាន ដល់សមណព្រាហ្មណ៍ អ្នកកំសត់ អ្នកដើរផ្លូវឆ្ងាយ អ្នកពណ៌នាហើយសូម និងស្មូមទាំងឡាយ ទៀបទ្វារទាំង ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ អគ្គមហេសីចូលមករកខ្ញុំព្រះអង្គ ហើយពោលពាក្យដូច្នេះថា ព្រះសម្មតិទេពបានឲ្យទានហើយ ពួកយើងមិនទាន់បានឲ្យទានទេ សូមព្រះរាជានុញ្ញាតឲ្យពួកយើងបានឲ្យទាន ធ្វើបុណ្យអាស្រ័យនឹងព្រះសម្មតិទេពផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញជាទាយក ជាម្ចាស់នៃទាន

១៤៧

## ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ ភូតបុព្វវត្ថុ

ជានស្ស វណ្ណាភាគី ជានំ ឧស្សាមាតិ វទន្តេ[១] កិន្តិ វទេយ្យន្តិ ។ សោ ខ្វាហំ ភន្តេ បឋមទ្វារំ ឥត្ថាគារស្ស អទាសឹ តត្ថ ឥត្ថាគារស្ស ជានំ ជីយិត្ថ មម ជានំ បដិក្កមិ ។ អថខោ មំ ភន្តេ ខត្តិយា អនុយុត្តា ឧបសង្កមិត្វា មំ ឯតទវោចុំ ទេវស្ស ខោ ជានំ ជីយតិ ឥត្ថាគារស្ស ជានំ ជីយតិ អម្ហាកំ ជានំ ន ជីយតិ សាធុ មយម្បិ ទេវំ និស្សាយ ជា-នានិ ទទេយ្យាម បុញ្ញានិ ករេយ្យាមាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហំ ខោស្មិ ជាយកោ ជានបតិ ជានស្ស វណ្ណាភាគី ជានំ ឧស្សាមាតិ វទន្តេ កិន្តិ វទេយ្យន្តិ ។ សោ ខ្វាហំ ភន្តេ ទុតិយទ្វារំ ខត្តិយានំ អនុយុត្តានំ អទាសឹ តត្ថ ខត្តិយានំ អនុយុត្តានំ ជានំ ជីយិត្ថ មម ជានំ បដិក្កមិ ។

១ ឱ. វទន្តានំ ។

ជាអ្នកពោលសរសើរទានជាប្រក្រតី កាលបើមានគេពោលថា យើងនឹងឲ្យទាន តើអាត្មាអញ គួរពោលដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏បានឲ្យទ្វារជាបឋម ដល់មហេសី មហេសីក៏បានឲ្យទាន ក្នុងទ្វារជាបឋមនោះ ឯទានរបស់ខ្ញុំព្រះអង្គក៏ថយចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកក្សត្រិយ៍ជាចំណុះ ចូលមករកខ្ញុំព្រះអង្គ ហើយពោលពាក្យនេះនឹងខ្ញុំព្រះអង្គថា ព្រះសម្មតិទេព បានឲ្យទានហើយ មហេសីក៏បានឲ្យទានដែរ ឯពួកយើងមិនទាន់បានឲ្យទានសោះ សូមព្រះរាជានុញ្ញាតឲ្យពួកយើងបានឲ្យទាន ធ្វើបុណ្យអាស្រ័យនឹងព្រះសម្មតិទេពផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ជាទាយក ជាម្ចាស់នៃទាន ជាអ្នកពោលសរសើរទានជាប្រក្រតី កាលបើមានគេពោលថា យើងនឹងឲ្យទាន តើអាត្មាអញ គួរពោលដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏បានឲ្យទ្វារទីពីរ ដល់ពួកក្សត្រិយ៍ចំណុះ ពួកក្សត្រិយ៍ចំណុះក៏បានឲ្យទានក្នុងទ្វារទីពីរនោះ ឯទានរបស់ខ្ញុំព្រះអង្គ ក៏ថយចុះ ។

អថខោ មំ ភន្តេ ពលកាយោ ឧបសង្កមិត្វា ឯតទវោច ទេវស្ស ខោ ទានំ ជីយតិ ឥត្ថាគារស្ស ទានំ ជីយតិ ខត្តិយានំ អនុយុត្តានំ ទានំ ជីយតិ អម្ហាកំ ទានំ ន ជីយតិ សាធុ មយម្បិ ទេវំ និស្សាយ ទានានិ ទទេយ្យាម បុញ្ញានិ ករេយ្យាមាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហំ ខោស្មិ ទាយកោ ទានបតិ ទានស្ស វណ្ណវាទី ទានំ ទស្សាមាតិ វទន្តិ កិន្តិ វទេយ្យន្តិ ។ សោ ខ្វាហំ ភន្តេ តតិយទ្វារំ ពលកា-យស្ស អទាសឹ តត្ថ ពលកាយស្ស ទានំ ជីយិត្ថ មម ទានំ បដិក្កមិ ។ អថខោ មំ ភន្តេ ព្រាហ្មណ-គហបតិកា ឧបសង្កមិត្វា ឯតទវោចុំ ទេវស្ស ខោ ទានំ ជីយតិ ឥត្ថាគារស្ស ទានំ ជីយតិ ខត្តិយានំ អនុយុត្តានំ ទានំ ជីយតិ ពលកាយស្ស ទានំ ជី-យតិ អម្ហាកំ ទានំ ន ជីយតិ សាធុ មយម្បិ ទេវំ និស្សាយ ទានានិ ទទេយ្យាម បុញ្ញានិ ករេយ្យាមាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកពលចូលមករកខ្ញុំព្រះអង្គ ហើយពោលពាក្យដូច្នេះថា ព្រះសម្មតិទេព បានឲ្យទានហើយ មហេសីបានឲ្យទានហើយ ពួកក្សត្រិយ៍ចំណុះក៏បានឲ្យទានដែរ ឯពួកយើងមិនទាន់បានឲ្យទានសោះ សូមព្រះរាជានុញ្ញាតឲ្យពួកយើងបានឲ្យទាន ធ្វើបុណ្យអាស្រ័យនឹងព្រះសម្មតិទេពផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ជាទាយក ជាម្ចាស់នៃទាន ជាអ្នកពោលសរសើរទានជាប្រក្រតី កាលបើមានគេពោលថា យើងនឹងឲ្យទាន តើអាត្មាអញ គួរពោលដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏បានឲ្យទ្វារទីបីដល់ពួកពល ពួកពលក៏បានឲ្យទានក្នុងទ្វារទីបីនោះ ឯទានរបស់ខ្ញុំព្រះអង្គក៏ថយចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកព្រាហ្មណ៍និងគហបតីចូលមករកខ្ញុំព្រះអង្គ ហើយពោលពាក្យដូច្នេះថា ព្រះសម្មតិទេព បានឲ្យទានហើយ មហេសីបានឲ្យទានហើយ ពួកក្សត្រិយ៍ជាចំណុះបានឲ្យទានហើយ ពួកពលក៏បានឲ្យទានដែរ ឯពួកយើងមិនទាន់បានឲ្យទានសោះ សូមព្រះរាជានុញ្ញាតឲ្យពួកយើងបានឲ្យទាន ធ្វើបុណ្យអាស្រ័យនឹងព្រះសម្មតិទេពផង ។

តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហំ ខោស្មិ ជាយ-
កោ ជានបតិ ជានស្ស វណ្ណាវាជី ជានំ ទស្សាមាតិ
វទន្តេ ភិន្តិ វទេយ្យន្តិ ។ សោ ខ្វាហំ ភន្តេ ចតុត្តទ្វារំ
ព្រាហ្មណគហបតិកានំ អជាសឹ តត្ថ ព្រាហ្មណគហ-
បតិកានំ ជានំ ជីយិត្ថ មម ជានំ បដិក្កមិ ។ អថខោ
មំ ភន្តេ បុរិសា ឧបសង្កមិត្វា ឯតទវោចុំ ន ខោជានិ
ទេវស្ស កោចិ ជានំ ជីយតីតិ ។ ឯវំ វុត្តាហំ ភន្តេ តេ
បុរិសេ ឯតទវោចំ តេនហិ ភណេ យោ ពាហិរេសុ
ជនបទេសុ អាយោ សញ្ជាយតិ តតោ ឧបឌ្ឍំ អន្តេបុរំ
បវេសេថ ឧបឌ្ឍំ តត្ថេវ ជានំ ទេថ សមណព្រាហ្មណ-
កបណទ្ធិកវណិព្វកយាចកានន្តិ ។ សោ ខ្វាហំ ភន្តេ

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញជាទាយក ជាម្ចាស់នៃទាន ជាអ្នកពោលសរសើរទានជាប្រក្រតី កាលបើមានគេពោលថា យើងនឹងឲ្យទាន តើអាត្មាអញ គួរពោលដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះក៏បានឲ្យទ្វារទីបួនដល់ពួកព្រាហ្មណ៍និងគហបតី ពួកព្រាហ្មណ៍និងគហបតីក៏បានឲ្យទាន ក្នុងទ្វារទីបួននោះ ឯទានរបស់ខ្ញុំព្រះអង្គក៏ថយចេញអស់ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួករាជបុរស ចូលមករកខ្ញុំព្រះអង្គ ហើយពោលពាក្យដូច្នេះថា ឥឡូវនេះ ព្រះសម្មតិទេព មិនដែលឲ្យទានក្នុងទីណាមួយឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួករាជបុរសក្រាបទូលយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏ពោលតបទៅនឹងពួករាជបុរសទាំងនោះដូច្នេះថា នៃព្រះស្ដេង បើដូច្នោះ សួយណា ដែលកើតឡើងក្នុងជនបទទាំង-ឡាយខាងក្រៅ អ្នកទាំងឡាយចូរញ៉ាំងសួយពាក់កណ្ដាលអំពីសួយនោះឲ្យចូលមកកាន់ព្រះរាជវាំង ហើយចូរឲ្យទានពាក់កណ្ដាល ដល់សមណ-ព្រាហ្មណ៍ អ្នកកំសត់ អ្នកដើរផ្លូវឆ្ងាយ អ្នកពណ៌នាហើយសូម និងស្មូមទាំងឡាយ ក្នុងជនបទនោះចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ

ឯវំ ជីយន្តំ កតានំ បុញ្ញានំ ឯវំ ជីយន្តំ កតានំ កុសលានំ បរិយន្តំ ជានិតុប្ចាមិ ឯត្តកាំ បុញ្ញន្តិ វា ឯត្តកោ បុញ្ញវិបាកោតិ វា ឯត្តកាំ សគ្គេ[1] ឋាតព្វន្តិ វាតិ ។

[២៨៨] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា

យេ ធំ ធនន្តិ សទ្ធាយ
វិប្បសន្នេន ចេតសា
តមេវ អន្នំ ភជតិ
អស្មឹ លោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ
ទជ្ជា ទានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

## ចតុត្ថំ ឃដិការសុត្តំ

[២៨៩] ឯកមន្តំ ឋិតោ ខោ ឃដិការោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

១ សមគ្គេតិបិ បាឋោ ។

មិនបានដឹងប្រាកដ នូវទីបំផុតរបស់បុណ្យ ដែលខ្ញុំព្រះអង្គបានធ្វើហើយអស់កាលយូរយ៉ាងនេះ និងទីបំផុតរបស់កុសល ដែលខ្ញុំព្រះអង្គបានធ្វើហើយអស់កាលយូរយ៉ាងនេះថា បុណ្យមានប្រមាណប៉ុណ្ណេះផង ផលនៃបុណ្យមានប្រមាណប៉ុណ្ណេះផង អាត្មាអញគប្បីឋិតនៅ ក្នុងឋានសួគ៌អស់កាលមានប្រមាណប៉ុណ្ណេះផង ។

[២៨៨] បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះពុទ្ធដីកាដែលព្រះមានព្រះភាគ សំដែងហើយដោយប្រពៃដូច្នេះ

ពួកជនណាមានចិត្តជ្រះថ្លា ឲ្យនូវបាយនោះ ដោយសទ្ធា
បាយនោះឯង រមែងទៅតាមនូវពួកជននោះវិញ ក្នុងលោក
នេះផង ក្នុងលោកខាងមុខផង ព្រោះហេតុនោះ បុគ្គល
គប្បីបន្ទោបង់នូវសេចក្តីកំណាញ់ គ្របសង្កត់នូវមន្ទិលគឺ
សេចក្តីកំណាញ់ហើយ ឲ្យនូវទាន (ព្រោះ) បុណ្យទាំង-
ឡាយ រមែងជាទីពឹងរបស់សត្វ ក្នុងលោកខាងមុខ ។

# ឃដិការសូត្រ ទី ៩

[២៨៩] ឃដិការទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

អវិហំ ឧបបន្នាសេ
វិមុត្តា សត្ត ភិក្ខវោ
រាគទោសបរិក្ខីណា
តិណ្ណា លោកេ វិសត្តិកន្តិ ។

[២៩០] យេ[១] ច តេ អតរុំ សង្គំ[២]
មច្ចុធេយ្យំ សុទុត្តរំ
តេ ហិត្វា មានុសំ ទេហំ
ទិព្វយោគមុបច្ចគុន្តិ ។

[២៩១] ឧបកោ ផលគណ្ឌោ ច
បុក្កុសាតិ ច តេ តយោ
ភទ្ទិយោ ខណ្ឌទេវោ ច
ពាហុរគ្គិ ច សិង្គិយោ[៣]
តេ ហិត្វា មានុសំ ទេហំ
ទិព្វយោគមុបច្ចគុន្តិ ។

---

១ ឱ. ម. កេ ។ ២ ឱ. អតរុំ បង្កំ ។ ម. អករុំ បង្កំ ។ ៣ ឱ. បិង្គិយោ ។

*ភិក្ខុទាំង ៧ រូប បានទៅកើតក្នុងជាន់អវិហាហើយ ជាអ្នកមានបិត្តផុតស្រឡះ មានរាគៈទោសៈអស់ហើយ ឆ្លងនូវតណ្ហា ក្នុងលោកបាន ។*

*[២៩០] ព្រះមានព្រះភាគត្រាស់ថា បុគ្គលទាំងឡាយណា បានឆ្លងនូវសង្គកិលេស ជាលំនៅនៃមច្ចុ ដែលឆ្លងបានដោយកម្រក្រៃពេក បុគ្គលទាំងនោះ បានលះបង់នូវរាងកាយ ជារបស់មនុស្សហើយ កន្លងនូវទិព្វយោគ គឺសំយោជនៈជាចំណែកខាងលើបាន ។*

*[២៩១]* **ទ.** *ព្រះថេរៈទាំង ៣ រូបនោះ គឺ ព្រះថេរៈឈ្មោះឧបកៈ ១ ផលគណ្ឌៈ ១ បុក្កុសាតិ ១ (និងព្រះថេរៈ ៤ រូបទៀត) គឺ ភទ្ទិយៈ ១ ខណ្ឌទេវៈ ១ ពាហុរគ្គិ ១ សិង្គិយៈ ១ ព្រះថេរៈទាំងនោះ បានលះបង់នូវរាងកាយជារបស់មនុស្ស ហើយកន្លងនូវទិព្វយោគបាន ។*

[២៩២] កុសលី(១) ភាសសី តេសំ
មារធាសប្បហាយិនំ
កស្ស តេ ធម្មមញ្ញាយ
អច្ឆិទ្ទំ ភវពន្ធនន្តិ ។
[២៩៣] ន អញ្ញត្រ ភគវតា
នាញ្ញត្រ តវ សាសនា
យស្ស តេ ធម្មមញ្ញាយ
អច្ឆិទ្ទំ ភវពន្ធនំ
យត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតិ
តំ តេ ធម្មមិធញ្ញាយ(២)
អច្ឆិទ្ទំ ភវពន្ធនន្តិ ។
[២៩៤] គម្ភីរំ ភាសសី វាចំ
ទុព្វិជានំ សុទុព្ពុធំ
កស្ស ត្វំ ធម្មមញ្ញាយ
វាចំ ភាសសិ ឦទិសន្តិ ។

១ ឱ. កុសលំ ។ ២ ម. តេ ច ធម្មំ ឥធញ្ញាយ ។

[២៩២] ព. អ្នកឯង ជាអ្នកមានកុសល ពោលសរសើរគុណនៃព្រះថេរៈទាំងនោះ ជាអ្នកលះបង់នូវអន្ទាក់នៃមារ ចុះព្រះថេរៈទាំងនោះ បានកាត់នូវចំណងគឺភព ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលណា ។

[២៩៣] ទ. ព្រះថេរៈទាំងនោះ បានកាត់នូវចំណងគឺភព ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលណា បុគ្គលនោះ វៀរតែព្រះមានព្រះភាគចេញ មិនមាន វៀរតែសាសនារបស់ព្រះអង្គចេញ មិនមាន នាមនិងរូបរលត់ទៅឥតមានសេសសល់ ក្នុងធម៌ណា ឯព្រះថេរៈទាំងនោះ បានកាត់នូវចំណងគឺភព ព្រោះដឹងច្បាស់នូវធម៌នោះ ក្នុងសាសនានេះ ។

[២៩៤] ព. អ្នកឯងបានជាពោលវាចាជ្រាលជ្រៅ កម្រដឹងបាន កម្រយល់បានក្រៃពេក តើអ្នកឯង ពោលវាចាប្រាកដដូច្នេះ ព្រោះដឹងច្បាស់នូវធម៌របស់បុគ្គលណា ។

[២៩៥] កុម្ភការោ បុរេ អាសឹ
វេភឡិង្គេ[១] ឃដីការោ
មាតាបេត្តិភរោ អាសឹ
កស្សបស្ស ឧបាសកោ
វិរតោ មេថុនា ធម្មា
ព្រហ្មចារី និរាមិសោ
អហុវា តេ សគាមេយ្យោ
អហុវា តេ បុរេ សខា
សោហមេតេ បជានាមិ
វិមុត្តេ សត្ត ភិក្ខវោ
រាគទោសបរិក្ខីណេ
តិណ្ណេ លោកេ វិសត្តិកន្តិ ។
[២៩៦] ឯវមេតំ តទា អាសិ
យថា ភាសសិ ភគ្គវ
កុម្ភការោ បុរេ អាសិ
វេភឡិង្គេ ឃដីការោ

---

១ ឱ. វេហឡិង្គេ ។ ម. វេកឡិង្គេ ។

ទេវបុត្តសំយុត្ត នានាតិត្ថិយវគ្គ រឿងស្មូនឆ្នាំងឈ្មោះឃដិការ

[២៩៥] ទ. ខ្ញុំព្រះអង្គពីដើមជាស្មូនឆ្នាំង ឈ្មោះឃដិការ កើតក្នុងនិគមឈ្មោះវេភឡិង្គ ជាអ្នកចិញ្ចឹមមាតាបិតា ជាឧបាសករបស់ព្រះពុទ្ធព្រះនាមកស្សប ជាអ្នកវៀរចាកមេ-ថុនធម្ម ប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រាសចាកអាមិសៈ បាននៅក្នុងស្រុកជាមួយនឹងព្រះអង្គ ជាសម្លាញ់នឹងព្រះអង្គក្នុងកាលមុន ខ្ញុំព្រះអង្គស្គាល់ច្បាស់នូវភិក្ខុទាំង ៧ រូបនុ៎ះ ដែលមានចិត្តផុតស្រឡះ មានរាគៈទោសៈអស់ហើយ បានឆ្លងនូវតណ្ហា ក្នុងលោក ។

[២៩៦] ព. ម្នាលភគ្គវៈ អ្នកឯង ពោលយ៉ាងណា ឯរឿងនុ៎ះ ក្នុងកាលនោះក៏មានយ៉ាងនោះមែន អ្នកឯងពីដើមជាស្មូនឆ្នាំងឈ្មោះឃដិការ កើតក្នុងនិគម ឈ្មោះវេភឡិង្គ

មាតាបេតិភរោ អាសិ
កស្សបស្ស ឧបាសកោ
វិរតោ មេថុនា ធម្មា
ព្រហ្មចារី និរាមិសោ
អហុវា មេ សគាមេយ្យោ
អហុវា មេ បុរេ សខាតិ ។
ឯវមេតំ បុរាណានំ
សហាយានមហុ សង្គមោ
ឧភិន្នំ ភាវិតត្តានំ
សរីរន្តិមធារិនន្តិ ។

## បញ្ចមំ ជន្តុសុត្តំ

[២៩៧] ឯវម្មេ សុតំ ។ ឯកំ សមយំ សម្ពហុលា ភិក្ខូ កោសលេសុ វិហរន្តិ ហិមវន្តបស្សេ អរញ្ញកុដិកាយំ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា[១] បាកតិន្ទ្រិយា ។

១ វិព្ភន្តចិត្តាតិបិ បាឋោ ។

ជាអ្នកចិញ្ចឹមមាតាបិតា ជាឧបាសករបស់ព្រះពុទ្ធព្រះនាម កស្សប ជាអ្នកវៀរចាកមេថុនធម្ម ប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រាសចាកអាមិសៈ បាននៅក្នុងស្រុកជាមួយនឹងតថាគត ជាសម្លាញ់នឹងតថាគតក្នុងកាលមុន ។ នេះជាការដែលបាន ចួបជុំសម្លាញ់ដែលមានក្នុងកាលមុនទាំងពីរនាក់ ដែលមាន ខ្លួនចម្រើនហើយបានទ្រទ្រង់នូវសរីរៈជាទីបំផុតយ៉ាងនេះឯង ។

# ជន្តុសូត្រ ទី ៥

[២៩៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ពួកភិក្ខុជាច្រើនរូប នៅក្នុងអរញ្ញកុដិ ខាងភ្នំហេមពាន្ត ក្នុងដែនកោសល ជាអ្នកមានចិត្តរាយមាយ[១] មានមានះដូចជាបបុសលើកឡើងហើយ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចារោយរាយ ភ្លេចសតិ មិនដឹងខ្លួន មានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តវិលទៅខុស មានឥន្ទ្រិយជាប្រក្រតី (ដូចជាគ្រហស្ថ) ។

១ បុគ្គលមានប្រក្រតីជាអ្នករាយមាយ ដោយសំគាល់ថា គួរក្នុងរបស់ដែលមិនគួរផង សំគាល់ថា មិនគួរក្នុងរបស់ដែលគួរផង សំគាល់ថា ជាទោសក្នុងរបស់ដែលមិនមានទោសផង សំគាល់ថា មិនមានទោសក្នុងរបស់ដែលជាទោសផង ។ អដ្ឋកថា ។

[២៩៨] អថខោ ជន្តុ ទេវបុត្តោ តទហុបោសថេ បណ្ណរសេ[១] យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ គាថាហិ អជ្ឈភាសិ

សុខជីវិនោ បុរេ អាសុំ
ភិក្ខូ គោតមសាវកា
អនិច្ឆា បិណ្ឌមេសនា
អនិច្ឆា សយនាសនំ
លោកេ អនិច្ចតំ ញត្វា
ទុក្ខស្សន្តមកំសុ តេ
ទុប្បោសំ កត្វា អត្តានំ
គាមេ គាមណិកា វិយ
ភុត្វា ភុត្វា និបជ្ជន្តិ
បរាគារេសុ មុច្ឆិតា
សង្ឃស្ស អញ្ជលឹ កត្វា
ឥធេកច្ចេ វទាមហំ
អបវិទ្ធា[២] អនាថា តេ
យថា បេតា តថេវ តេ

១ បន្នរសេតិ វា បាឋោ ។ ២ ឱ. អបវិទ្ធា ។

ទេវបុត្តសំយុត្ត នានាតិត្ថិយវគ្គ ជន្តុទេវបុត្តចូលទៅរកភិក្ខុច្រើនរូប

[២៩៨] គ្រានោះ ជន្តុទេវបុត្ត ក្នុងវេលាថ្ងៃឧបោសថទី ១៥ នោះ ក៏ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលនឹងភិក្ខុទាំងនោះ ដោយគាថាទាំងឡាយថា

កាលពីដើមមានពួកភិក្ខុជាសាវ័ករបស់ព្រះគោតម មានការរស់នៅជាសុខ ភិក្ខុទាំងនោះ ជាអ្នកមិនប្រាថ្នា ដោយការស្វែងរកបិណ្ឌបាត ជាអ្នកមិនប្រាថ្នា ដោយការស្វែងរកទីដេក ទីអង្គុយ ដឹងនូវសេចក្តីមិនទៀងក្នុងលោក ហើយក៏បានធ្វើនូវទីបំផុតនៃទុក្ខ ពួកភិក្ខុដែលធ្វើខ្លួន ឲ្យគេចិញ្ចឹមបានដោយកម្រ ស៊ីដេក ស៊ីដេក ដូចជាបុរសអ្នកធំក្នុងស្រុក ជជ្រកមមកនៅក្បែរផ្ទះនៃបុគ្គលដទៃ ខ្ញុំធ្វើអញ្ជលីចំពោះសង្ឃហើយ សូមពោលចំពោះភិក្ខុពួកខ្លះក្នុងសាសនានេះ ភិក្ខុទាំងនោះ ដែលគេបោះបង់ហើយ ក៏ឥតមានទីពឹងឡើយ ពួកប្រេតយ៉ាងណា ភិក្ខុទាំងនោះក៏យ៉ាងនោះដែរ

យេ ខោ បមត្តា វិហរន្តិ
តេ មេ សង្ខាយ ភាសិតំ
យេ អប្បមត្តា វិហរន្តិ
នមោ តេសំ ករោមហន្តិ ។

# ឆដ្ឋំ រោហិតស្សសុត្តំ

[២៩៩] សាវត្ថិយំ វិហរតិ... ឯកមន្តំ ឋិតោ ខោ រោហិតស្សោ ទេវបុត្តោ ភគវន្តំ ឯតទវោច យត្ថ នុ ខោ ភន្តេ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ សក្កា នុ ខោ សោ ភន្តេ គមនេន លោកស្ស អន្តោ ញាតុំ វា ទដ្ឋុំ វា បាបុណិតុំ វាតិ ។

[៣០០] យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នាហំ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមីតិ ។ អច្ឆរិយំ ភន្តេ អព្ភូតំ ភន្តេ

ភិក្ខុទាំងឡាយណាប្រមាទ ខ្ញុំក៏ពោលសំដៅភិក្ខុទាំងនោះ
ភិក្ខុទាំងឡាយណាមិនប្រមាទ ខ្ញុំសូមធ្វើនមស្ការចំពោះ
ភិក្ខុទាំងនោះ ។

# រោហិតស្សសូត្រ ទី ៦

[២៩៩] (ព្រះមានព្រះភាគ) ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... លុះរោហិតស្សទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា បពិត្រព្រះអង្គដ៏ចម្រើន ទីបំផុតនៃលោកនោះ បុគ្គលអាច ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដោយកិរិយាទៅដោយជើងបានដែរឬ ។

[៣០០] ព្រះអង្គត្រាស់ថា ម្នាលអាវុសោ សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា តថាគតមិនពោលថា ទីបំផុតនៃលោកនោះ បុគ្គលគប្បីដឹងបាន គប្បីឃើញបាន គប្បីដល់បាន ដោយការទៅដោយជើងដូច្នេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់

យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នាហន្តំ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមីតិ ។

[៣០១] ភូតបុព្វាហំ ភន្តេ រោហិតស្សោ នាម ឥសិ អហោសឹ ភោជបុត្តោ ឥទ្ធិមា វេហាសង្គមោ ។ តស្ស មយ្ហំ ភន្តេ ឯវរូបោ ជវោ អហោសិ សេយ្យថាបិ នាម ទឡ្ហធម្មោ ធនុគ្គហោ សុសិក្ខិតោ កតហត្ថោ កតយោគ្គោ[១] កតុបាសនោ លហុកេន អសនេន អប្បកសិរេនេវ តិរិយំ តាលច្ឆាយំ អតិបាតេយ្យ ។ តស្ស មយ្ហំ ភន្តេ ឯវរូបោ បទវីតិហារោ អហោសិ សេយ្យថាបិ បុរត្ថិមា សមុទ្ទា បច្ឆិមោ សមុទ្ទោ ។ តស្ស មយ្ហំ ភន្តេ ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ គមនេន លោកស្ស អន្តំ បាបុណិស្សាមីតិ ។ សោ ខ្វាហំ ភន្តេ

១ ម. បោត្ថកេ អយំ បាឋោ ន ហោតិ ។ អដ្ឋកថាយម្បិ នត្ថិ ។

ព្រោះព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគ ទ្រង់ពោលហើយ ដោយប្រពៃថា ម្នាលអាវុសោ សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា តថាគតមិនពោលថា ទីបំផុតនៃលោកនោះ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងឡើយ ។

[៣០១] បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយ ខ្ញុំព្រះអង្គបានកើតជាឫសីឈ្មោះរោហិតស្ស ជាកូននៃព្រាន មានឫទ្ធិហោះទៅក្នុងអាកាសបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសន្ទុះដូចខ្មាន់ធ្នូ ដែលមានធ្នូដ៏មាំបានសិក្សាដោយប្រពៃ មានដៃស្ទាត់ មានយានចាត់ចែងហើយ មានគ្រឿងក្រោះធ្វើហើយ អាចយកព្រួញដែលស្រាលបាញ់កាត់ទទឹងស្រមោលដើមត្នោត ដោយមិនលំបាកសោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានការឈានទៅនៃជំហាន មានសភាពដូចជាឈានអំពីសមុទ្រខាងកើត ទៅកាន់សមុទ្រខាងលិច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តីប្រាថ្នាមានសភាពដូច្នេះកើតឡើងថា អាត្មាអញនឹងដល់ នូវទីបំផុតនៃលោកដោយការទៅដោយជើង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ

ឯវរូបេន ជវេន សមន្នាគតោ ឯវរូបេន ច បទវីតិហា-វេន អញ្ញត្រេវ អសិតខាយិតសាយិតា អញ្ញត្រ ឧច្ចា-រប្បស្សាវកម្មា អញ្ញត្រ និទ្ទាកិលមថប្បដិវិនោទនា វស្សសតាយុកោ វស្សសតជីវី វស្សសតំ គន្ត្វា អប្បត្វា វ(១) លោកស្ស អន្តំ អន្តរា វ កាលកតោ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នាហន្តំ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមីតិ ។

[៣០២] យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នា-ហន្តំ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ(២) ន ច បនាហំ(៣) អាវុសោ

១ ឱ. ម. ច ។ ២ ឱ. យត្ថ ខោ អាវុសោ ន ជាយតិ... បត្តេយ្យន្តិ វទាមីតិ ន ទិស្សន្តិ ។ ៣ ឱ. ម. ន ខោ បនាហំ ។

ប្រកបដោយសន្ទុះមានសភាពដូច្នេះផង ប្រកបដោយការឈានទៅនៃជំហានមានសភាពដូច្នេះផង វៀរលែងតែវេលាស៊ី ទំពាស៊ី និងក្រេបជញ្ជក់ វៀរលែងតែការធ្វើនូវឧច្ចារៈបស្សាវៈ វៀរលែងតែការដេកលក់ និងការបន្ទោបង់នូវសេចក្តីនឿយហត់ មានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ដើរទៅអស់កំណត់ ១០០ ឆ្នាំ គង់មិនបានដល់នូវទីបំផុតនៃលោកសោះ ហើយក៏ធ្វើមរណកាល ក្នុងរវាងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគទ្រង់ពោលហើយដោយប្រពៃថា ម្នាលអាវុសោ សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា តថាគតមិនពោលថា ទីបំផុតនៃលោកនោះ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការទៅដោយជើងបានឡើយ ។

[៣០២] ម្នាលអាវុសោ សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា តថាគតមិនពោលថា ទីបំផុតនៃលោកនោះ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ដោយការទៅដោយជើងដូច្នេះឡើយ ម្នាលអាវុសោ មួយទៀត តថាគតមិនបាន

អប្បត្វា លោកស្ស អន្តំ ទុក្ខស្ស អន្តកិរិយំ វទាមិ អបិចាហំ[១] អាវុសោ ឥមស្មឹយេវ ព្យាមមត្តេ កឡេវរេ សសញ្ញម្ហិ សមនកេ លោកញ្ច បញ្ញបេមិ[២] លោក-សមុទយញ្ច លោកនិរោធញ្ច លោកនិរោធគាមិនិញ្ច បដិបទន្តិ ។

គមនេន ន បត្តព្វោ
លោកស្សន្តោ កុទាចនំ
ន ច អប្បត្វា លោកន្តំ
ទុក្ខា អត្ថិ បមោចនំ[៣]
តស្មា ហវេ លោកវិទូ សុមេធោ
លោកន្តគូ វុសិតព្រហ្មចរិយោ
លោកស្ស អន្តំ សមិតាវិ ញត្វា
នាសីសតិ លោកមិមំ បរញ្ចាតិ ។

១ ឱ. ម. អបិ ខ្វាហំ ។ ២ បញ្ញាបេមីតិ វា បាឋោ ។ ៣ អត្ថិប្បមោចនន្តិបិ លិខិតំ ។

ពោលនូវដំណើរដែលសត្វមិនបានដល់នូវទីបំផុតនៃសង្ខារលោក ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខទេ ម្នាលអាវុសោ ម្យ៉ាងទៀត តថាគតសំដែងនូវលោកគឺទុក្ខសច្ចផង នូវហេតុជាទីកើតឡើងនៃលោកគឺសមុទយសច្ចផង នូវទីរលត់នៃលោកគឺនិរោធសច្ចផង នូវបដិបទាជាហេតុទៅកាន់ទីរលត់នៃលោកគឺមគ្គសច្ចផង ក្នុងអត្តភាពប្រមាណមួយព្យាម ដែលប្រកបដោយសញ្ញា ប្រកបដោយចិត្តនេះទេតើ ។

ទីបំផុតនៃលោក បុគ្គល មិនគប្បីដល់ដោយការទៅដោយ
ជើងក្នុងកាលណា ៗ ឡើយ ឯការមិនបានដល់នូវទីបំផុតនៃ
លោកហើយរួចស្រឡះចាកទុក្ខ មិនមានទេ ព្រោះហេតុ
នោះ បុគ្គលអ្នកមានបញ្ញាល្អ ដឹងច្បាស់នូវលោក ដល់
នូវទីបំផុតនៃលោក មានព្រហ្មចរិយធម៌នៅស្រេចហើយ
មានបាបរម្ងាប់បង់ហើយ ដឹងនូវទីបំផុតនៃលោក រមែង
មិនប្រាថ្នា នូវលោកនេះផង នូវលោកខាងមុខផង ។

## សត្តមំ នន្ទសុត្តំ

[៣០៣] ឯកមន្តំ ឋិតោ ខោ នន្ទោ ទេវបុត្តោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ
វយោគុណា អនុបុព្វំ ជហន្តិ
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានីតិ ។

[៣០៤] អច្ចេន្តិ កាលា តរយន្តិ រត្តិយោ
វយោគុណា អនុបុព្វំ ជហន្តិ
ឯតំ ភយំ មរណេ បេក្ខមានោ
លោកាមិសំ បជហេ សន្តិបេក្ខោតិ ។

# នន្ទសូត្រ ទី ៧

[៣០៣] នន្ទទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

កាលទាំងឡាយ តែងកន្លងផុតទៅ រាត្រីទាំងឡាយ តែងញុំាងសត្វឲ្យឆ្លងទៅ (រកសេចក្តីស្លាប់) ជំនាន់របស់វ័យទាំងឡាយ តែងលះបង់ដោយលំដាប់ទៅ កាលបើបុគ្គលបានសម្លឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះ គួរតែខំធ្វើបុណ្យទាំងឡាយ ដែលជាគុណនាំសេចក្តីសុខមកឲ្យ ។

[៣០៤] កាលទាំងឡាយ តែងកន្លងផុតទៅ រាត្រីទាំង-ឡាយ តែងញុំាងសត្វឲ្យឆ្លងទៅ (រកសេចក្តីស្លាប់) ជំនាន់របស់វ័យទាំងឡាយ តែងលះបង់ដោយលំដាប់ទៅ កាលបើបុគ្គលបានសម្លឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះ សម្លឹងរំពឹងយកនូវសេចក្តីស្ងប់គឺព្រះនិព្វាន ហើយលះបង់នូវអាមិសៈក្នុងលោកចោលចេញ ។

១៧១



# អដ្ឋមំ នន្ទិវិសាលសុត្តំ

[៣០៥] ឯកមន្តំ ឋិតោ ខោ នន្ទិវិសាលោ ទេវ-
បុត្តោ ភគវន្តំ គាថាយ អជ្ឈភាសិ

ចតុចក្កំ នវទ្វារំ
បុណ្ណំ លោភេន សំយុត្តំ
បង្កជាតំ មហាវីរ
កថំ យាត្រា ភវិស្សតីតិ ។

[៣០៦] ឆេត្វា នទ្ធឹ វរត្តញ្ច
ឥច្ឆាលោភញ្ច បាបកំ
សមូលំ តណ្ហំ អព្ពុយ្ហ
ឯវំ យាត្រា ភវិស្សតីតិ ។

# នន្ទិវិសាលសូត្រ ទី ៨

[៣០៥] នន្ទិវិសាលទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដោយគាថា ថា

បពិត្រព្រះអង្គអ្នកមានព្យាយាមធំ (យន្តគឺសរីរៈនេះ) មានចក្រ ៤[១] មានទ្វារ ៩ ដ៏ពេញ (ដោយវត្ថុមិនស្អាត) ប្រកបដោយសេចក្តីលោភ ជាសរីរៈដូចជាភក់ បុគ្គលនឹងយាត្រា (ចេញចាកសរីរៈនោះ) ដោយប្រការដូចម្តេចបាន ។

[៣០៦] ព្រះមានព្រះភាគ ត្រាស់ថា បុគ្គល កាត់នូវចំណងគឺឧបនាហៈផង នូវព្រ័ត្រគឺកិលេសផង នូវសេចក្តីប្រាថ្នា និងការលោភដ៏លាមកផង ដកចេញនូវតណ្ហាព្រមទាំងឫសផង ទើបយាត្រា (ចេញចាកសរីរៈនោះបាន) ដោយប្រការយ៉ាងនេះឯង ។

១ សំដៅយកឥរិយាបថ ៤ ។

# នវមំ សុសិមសុត្តំ

[៣០៧] សាវត្ថីនិទានំ ។ អថខោ អាយស្មា អា-
នន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ
ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច តុយ្ហំបិ
នោ អានន្ទ សារីបុត្តោ រុច្ចតីតិ ។ កស្ស ហិ នាម
ភន្តេ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស អវិបល្លត្ថចិត្តស្ស
អាយស្មា សារីបុត្តោ ន រុច្ចេយ្យ បណ្ឌិតោ ភន្តេ
អាយស្មា សារីបុត្តោ មហាបញ្ញោ ភន្តេ អាយស្មា
សារីបុត្តោ បុថុបញ្ញោ ភន្តេ អាយស្មា សារីបុត្តោ
ហាសបញ្ញោ ភន្តេ អាយស្មា សារីបុត្តោ ជវនបញ្ញោ
ភន្តេ អាយស្មា សារីបុត្តោ តិក្ខបញ្ញោ ភន្តេ អាយស្មា
សារីបុត្តោ និព្វេធិកបញ្ញោ ភន្តេ អាយស្មា សារីបុត្តោ

# សុសិមសូត្រ ទី ៩

[៣០៧] សាវត្ថីនិទាន ។ គ្រានោះ ព្រះអានន្ទមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ សារីបុត្ត គាប់ចិត្តនឹងអ្នក ដែរឬ ។ ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនសមបើនឹងថា ព្រះសារីបុត្តមានអាយុ មិនគាប់ចិត្ត នឹងបុគ្គលមិនពាល មិនប្រទូស្ត មិនវង្វេង មិនមានចិត្តវិបល្លាសទេ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតព្រះសារីបុត្តមានអាយុ ជាបណ្ឌិត បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាច្រើន បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាក្រាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាជាគ្រឿងរីករាយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញារហ័ស បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាមុត បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាជាគ្រឿងទម្លាយនូវកិលេស

អប្បិច្ឆោ ភន្តេ អាយស្មា សារីបុត្តោ សន្តុដ្ឋោ ភន្តេ អាយស្មា សារីបុត្តោ បវិវិត្តោ ភន្តេ អាយស្មា សារីបុត្តោ អសំសដ្ឋោ ភន្តេ អាយស្មា សារីបុត្តោ អារទ្ធវិរិយោ ភន្តេ អាយស្មា សារីបុត្តោ វត្តា ភន្តេ អាយស្មា សារីបុត្តោ វចនក្ខមោ ភន្តេ អាយស្មា សារីបុត្តោ ចោទកោ ភន្តេ អាយស្មា សារីបុត្តោ ចាបគរហី ភន្តេ អាយស្មា សារីបុត្តោ កស្ស ហិ នាម ភន្តេ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស អវិបល្លត្ថចិត្តស្ស អាយស្មា សារីបុត្តោ ន រុច្ចេយ្យាតិ ។

[៣០៨] ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ កស្ស ហិ នាម អានន្ទ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស

បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ គ្មានសេចក្ដីប្រាថ្នា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកសន្ដោស បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកស្ងប់ស្ងាត់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកមិនច្រឡូកច្រឡំដោយគ្រហស្ថ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ មានព្យាយាមប្រារព្ធហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកប្រិនសំដី បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកអត់ទ្រាំនឹងពាក្យសំដី បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកដាស់តឿនគេ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកតិះដៀលបុគ្គលបាប បពិត្រព្រះអង្គដ៏ចម្រើន មិនសមបើនឹងថា ព្រះសារីបុត្តមានអាយុ មិនគាប់ចិត្តនឹងបុគ្គលមិនពាល មិនប្រទូស្ដ មិនវង្វេង មិនមានចិត្តវិបល្លាសទេ ។

[៣០៨] ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ហេតុនុ៎ះយ៉ាងនេះឯង ម្នាលអានន្ទ ហេតុនុ៎ះយ៉ាងនេះឯង ម្នាលអានន្ទ មិនសមបើនឹងថា សារីបុត្ត មិនគាប់ចិត្ត នឹងបុគ្គលមិនពាល មិនប្រទូស្ដ មិនវង្វេង

អវិបល្លត្ថចិត្តស្ស សារីបុត្តោ ន រុច្ចេយ្យ បណ្ឌិតោ
អានន្ទ សារីបុត្តោ មហាបញ្ញោ អានន្ទ សារីបុត្តោ
បុថុប្បញ្ញោ អានន្ទ សារីបុត្តោ ហាសប្បញ្ញោ អានន្ទ
សារីបុត្តោ ជវនប្បញ្ញោ អានន្ទ សារីបុត្តោ តិក្ខប្បញ្ញោ
អានន្ទ សារីបុត្តោ និព្វេធិកប្បញ្ញោ អានន្ទ សារីបុត្តោ
អប្បិច្ឆោ អានន្ទ សារីបុត្តោ សន្តុដ្ឋោ អានន្ទ សា-
រីបុត្តោ បវិវិត្តោ អានន្ទ សារីបុត្តោ អសំសដ្ឋោ អានន្ទ
សារីបុត្តោ អារទ្ធវីរិយោ អានន្ទ សារីបុត្តោ វត្តា
អានន្ទ សារីបុត្តោ វចនក្ខមោ អានន្ទ សារីបុត្តោ ចោទ-
កោ អានន្ទ សារីបុត្តោ បាបគរហី អានន្ទ សារីបុត្តោ
កស្ស ហិ នាម អានន្ទ អពាលស្ស អទុដ្ឋស្ស អ-
មូឡ្ហស្ស អវិបល្លត្ថចិត្តស្ស សារីបុត្តោ ន រុច្ចេយ្យាតិ ។

មិនមានចិត្តវិបល្លាសទេ ម្នាលអានន្ទ ដ្បិតសារីបុត្ត ជាបណ្ឌិត ម្នាលអានន្ទ សារីបុត្ត ជាអ្នកមានបញ្ញាច្រើន ម្នាលអានន្ទ សារីបុត្ត ជាអ្នកមានបញ្ញាក្រាស់ ម្នាលអានន្ទ សារីបុត្ត មានបញ្ញាជាគ្រឿងរីក-រាយ ម្នាលអានន្ទ សារីបុត្ត មានបញ្ញារហ័ស ម្នាលអានន្ទ សារីបុត្ត មានបញ្ញាមុត ម្នាលអានន្ទ សារីបុត្ត មានបញ្ញាជាគ្រឿងទម្លាយនូវកិលេស ម្នាលអានន្ទ សារីបុត្ត គ្មានសេចក្តីប្រាថ្នា ម្នាលអានន្ទ សារីបុត្ត ជាអ្នកសន្តោស ម្នាលអានន្ទ សារីបុត្ត ជាអ្នកស្ងប់ស្ងាត់ ម្នាលអានន្ទ សារីបុត្ត ជាអ្នកមិនច្រឡូកច្រឡំដោយគ្រហស្ថ ម្នាលអានន្ទ សារីបុត្ត ជាអ្នកមានព្យាយាមប្រារព្ធហើយ ម្នាលអានន្ទ សារី-បុត្ត ជាអ្នកប៉ិនសំដី ម្នាលអានន្ទ សារីបុត្ត ជាអ្នកអត់ទ្រាំនឹងពាក្យសំដី ម្នាលអានន្ទ សារីបុត្ត ជាអ្នកដាស់តឿនគេ ម្នាលអានន្ទ សារីបុត្ត ជាអ្នកតិះដៀលបុគ្គលបាប ម្នាលអានន្ទ មិនសមបើនឹងថា សារីបុត្ត មិនគាប់ចិត្តនឹងបុគ្គលមិនពាល មិនប្រទូស្ត មិនវង្វេង មិនមានចិត្តវិបល្លាសទេ ។

[៣០៩] អថខោ សុសិមោ ទេវបុត្តោ អាយស្មតោ សារីបុត្តស្ស វណ្ណេ ភញ្ញមានេ មហតិយា ទេវបុត្តបរិសាយ បរិវុតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សុសិមោ ទេវបុត្តោ ភគវន្តំ ឯតទវោច ឯវមេតំ ភគវា ឯវមេតំ សុគត កស្ស ហិ នាម ភន្តេ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស អវិបល្លត្ថចិត្តស្ស អាយស្មា សារីបុត្តោ ន រុច្ចេយ្យ បណ្ឌិតោ ភន្តេ អាយស្មា សារីបុត្តោ ។ បេ ។ ចាបតរហី ភន្តេ អាយស្មា សារីបុត្តោ កស្ស ហិ នាម ភន្តេ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស អវិបល្លត្ថចិត្តស្ស អាយស្មា សារីបុត្តោ ន រុច្ចេយ្យ អហម្បិ ហិ ភន្តេ យញ្ញ[១] ទេវបុត្តបរិសំ ឧបសង្កមឹ ឯតទេវ ពហុលំ សទ្ទំ សុណាមិ

១ ឱ. យញ្ញទេវ ។ ម. យទេវ ។

ទេវបុត្តសំយុត្ត នានាតិត្ថិយវគ្គ សេចក្ដីសរសើរព្រះសារីបុត្ត

[៣០៩] គ្រាកាលដែលព្រះមានព្រះភាគ កំពុងត្រាស់សរសើរគុណរបស់ព្រះសារីបុត្តមានអាយុ ក៏សុសិមទេវបុត្តដែលមានទេវបុត្តជាបរិស័ទជាច្រើន ហែហមចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះសុសិមទេវបុត្ត ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន មិនសមបើនឹងថា ព្រះសារីបុត្តមានអាយុ មិនគាប់ចិត្តនឹងបុគ្គលមិនពាល មិនប្រទូស្ត មិនវង្វេង មិនមានចិត្តវិបល្លាសទេ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតព្រះសារីបុត្តមានអាយុ ជាបណ្ឌិត ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ជាអ្នកតិះដៀលបុគ្គលបាប បពិត្រព្រះអង្គដ៏ចម្រើន មិនសមបើនឹងថា ព្រះសារីបុត្តមានអាយុ មិនគាប់ចិត្តនឹងបុគ្គលមិនពាល មិនជាអ្នកប្រទូស្ត មិនវង្វេង មិនមានចិត្តវិបល្លាសទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាខ្ញុំព្រះអង្គបានចូលទៅកាន់សំណាក់ទេវបុត្តជាបរិស័ទ ក៏បានឮសំឡេងជាច្រើន ដូច្នេះដែរថា

បណ្ឌិតោ អាយស្មា សារីបុត្តោ មហាបញ្ញោ អាយស្មា បុថុបញ្ញោ អាយស្មា ហាសបញ្ញោ អាយស្មា ជវ-នបញ្ញោ អាយស្មា តិក្ខបញ្ញោ អាយស្មា និព្វេធិ-កបញ្ញោ អាយស្មា អប្បិច្ឆោ អាយស្មា សន្តុដ្ឋោ អាយស្មា បវិវិត្តោ អាយស្មា អសំសដ្ឋោ អាយស្មា អារទ្ធវិរិយោ អាយស្មា វត្តា អាយស្មា វចនក្ខមោ អាយស្មា ចោទកោ អាយស្មា បាបគរហី អាយស្មា សារីបុត្តោ កស្ស ហិ នាម ភន្តេ អពាលស្ស អទុដ្ឋស្ស អមូឡ្ហស្ស អវិបល្លត្ថចិត្តស្ស អាយស្មា សារីបុត្តោ ន រុច្ចេយ្យាតិ ។

ព្រះសារីបុត្តមានអាយុ ជាបណ្ឌិត ព្រះសារីបុត្តមានអាយុ មានបញ្ញាច្រើន ព្រះសារីបុត្តមានអាយុ មានបញ្ញាក្រាស់ ព្រះសារីបុត្តមានអាយុ មានបញ្ញាជាគ្រឿងរីករាយ ព្រះសារីបុត្តមានអាយុ មានបញ្ញារហ័ស ព្រះសារីបុត្តមានអាយុ មានបញ្ញាមុត ព្រះសារីបុត្តមានអាយុ មានបញ្ញាជាគ្រឿងទម្លាយនូវកិលេស ព្រះសារីបុត្តមានអាយុ គ្មានសេចក្ដីប្រាថ្នា ព្រះសារីបុត្តមានអាយុ ជាអ្នកសន្ដោស ព្រះសារីបុត្តមានអាយុ ជាអ្នកស្ងប់ស្ងាត់ ព្រះសារីបុត្តមានអាយុ ជាអ្នកមិនច្រឡូកច្រឡំដោយគ្រហស្ថ ព្រះសារីបុត្តមានអាយុ មានព្យាយាមប្រារព្ធហើយ ព្រះសារីបុត្តមានអាយុ ជាអ្នកប៉ិនសំដី ព្រះសារីបុត្តមានអាយុ ជាអ្នកអត់ទ្រាំនឹងពាក្យសំដី ព្រះសារីបុត្តមានអាយុ ជាអ្នកដាស់តឿនគេ ព្រះសារីបុត្តមានអាយុ ជាអ្នកតិះដៀលបុគ្គលបាប បពិត្រព្រះអង្គដ៏ចម្រើន មិនសមបើនឹងថា ព្រះសារីបុត្តមានអាយុ មិនគាប់ចិត្តនឹងបុគ្គលមិនពាល មិនប្រទូស្ត មិនវង្វេង មិនមានចិត្តវិបល្លាសទេ ។

ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ នេក្ខជម្ពោនទោបមា

[៣១០] អថខោ សុសិមស្ស ទេវបុត្តស្ស ទេវ-បុត្តបរិសា អាយស្មតោ សារីបុត្តស្ស វណ្ណេ ភញ្ញមានេ អត្តមនា បមុទិតា បីតិសោមនស្សជាតា ឧច្ចាវចា វណ្ណនិភា ឧបទំសេតិ ។

[៣១១] សេយ្យថាបិ នាម មណិវេឡុរិយោ សុ-ភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ បណ្ឌុកម្ពលេ និក្ខិត្តោ ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវំ សុសិមស្ស ទេវបុត្តស្ស ទេវបុត្តបរិសា អាយស្មតោ សារីបុត្តស្ស វណ្ណេ ភញ្ញមានេ អត្តមនា បមុទិតា បីតិសោមនស្សជាតា ឧច្ចាវចា វណ្ណនិភា ឧបទំសេតិ ។

[៣១២] សេយ្យថាបិ នាម នេក្ខំ ជម្ពោនទំ ទក្ខេន កម្មារបុត្តំ ឧក្កាមុខេសុ កុសលំ សម្ប-ហដ្ឋំ[១] បណ្ឌុកម្ពលេ និក្ខិត្តំ ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវំ សុសិមស្ស ទេវបុត្តស្ស ទេវបុត្តបរិសា ។ បេ ។ ឧបទំសេតិ ។

១ ឱ. ទក្ខកម្មារបុត្តេន សុកុសលសម្បហដ្ឋំ ។ ម. ទក្ខកម្មារបុត្តឧក្កាមុខេសុ កុសលំ សំបហដ្ឋំ ។

[៣១០] គ្រាកាលដែលសុសិមទេវបុត្ត កំពុងពោលសរសើរគុណ នៃព្រះសារីបុត្តមានអាយុ ក៏ទេវបុត្តជាបរិស័ទ របស់សុសិមទេវបុត្តនោះ មានសេចក្តីត្រេកអរ រីករាយ កើតបីតិសោមនស្ស បញ្ចេញនូវរស្មី មានប្រការផ្សេង ៗ ។

[៣១១] កែវពៃទូរ្យដ៏ល្អ ប្រកបដោយជាតិដ៏បរិសុទ្ធ មានជ្រុង ៨ ដែលជាងបានច្នៃដោយល្អ ហើយដាក់លើសំពត់កម្ពលលឿងទុំ រមែងភ្លឺច្រាល រុងរឿង យ៉ាងណាមិញ កាលដែលសុសិមទេវបុត្តកំពុងពោលសរសើរគុណ នៃព្រះសារីបុត្តមានអាយុ ក៏ទេវបុត្តជាបរិស័ទ របស់សុសិមទេវបុត្ត មានសេចក្តីត្រេកអរ រីករាយ កើតបីតិសោមនស្ស បញ្ចេញរស្មីមានប្រការផ្សេង ៗ ក៏យ៉ាងនោះដែរ ។

[៣១២] គ្រឿងប្រដាប់ជាវិការៈនៃមាសជម្ពូនទ ដែលកូនជាងមាសដ៏ប៉ិនប្រសប់ បានឲ្យដីលើមាត់បាវ ហើយយកមកដាក់លើសំពត់កម្ពលលឿងទុំ រមែងភ្លឺច្រាល រុងរឿង យ៉ាងណាមិញ ក៏ទេវបុត្តជាបរិស័ទ របស់សុសិមទេវបុត្ត ។ បេ ។ បញ្ចេញរស្មីមានប្រការផ្សេង ៗ យ៉ាងនោះឯង ។

[៣១៣] សេយ្យថាបិ ជាម សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ[១] ឱសធិតារកា ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវំ សុសិមស្ស ទេវបុត្តស្ស ទេវបុត្តបរិសា អាយស្មតោ សារីបុត្តស្ស វណ្ណេ ភញ្ញមានេ អត្តមនា បមុទិតា បីតិសោមនស្សជាតា ឧច្ចាវចា វណ្ណនិភា ឧបទំសេតិ ។

[៣១៤] សេយ្យថាបិ ជាម សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អាទិច្ចោ ជភំ អព្ភុស្សុក្កមានោ សព្វំ អាកាសគតំ តមគតំ[២] អភិវិហច្ច ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវំ សុសិមស្ស ទេវបុត្តស្ស ទេវបុត្តបរិសា អាយស្មតោ សារីបុត្តស្ស វណ្ណេ ភញ្ញមានេ អត្តមនា បមុទិតា បីតិសោមនស្សជាតា ឧច្ចាវចា វណ្ណនិភា ឧបទំសេតិ ។

---

១ ឱ. សេយ្យថាបិ នាម វត្តិយា បច្ចូសសមយំ ។ ម. ឯវំ ។ ២ ឱ. តមំ ។

[៣១៣] ផ្កាយព្រឹក ឮដ៏អាកាសដ៏ស្រឡះប្រាសចាកពពក ក្នុងសរទសម័យ រមែងភ្លឺច្រាល រុងរឿង យ៉ាងណាមិញ កាលដែលសុសិមទេវបុត្ត កំពុងពោលសរសើរគុណ របស់ព្រះសារីបុត្តមានអាយុ ក៏ទេវបុត្តជាបរិស័ទរបស់សុសិមទេវបុត្ត មានសេចក្តីត្រេកអរ រីករាយ កើតបីតិសោមនស្ស បញ្ចេញរស្មីមានប្រការផ្សេង ៗ យ៉ាងនោះឯង ។

[៣១៤] ព្រះអាទិត្យ ឮដ៏អាកាសដ៏ស្រឡះប្រាសចាកពពក ក្នុងសរទសម័យ ខ្ពស់ត្រដែតឮដ៏អាកាស កម្ចាត់នូវងងឹតដែលតាំងនៅលើអាកាសទាំងអស់ រមែងភ្លឺច្រាល រុងរឿង យ៉ាងណាមិញ កាលដែលសុសិមទេវបុត្តកំពុងពោលសរសើរគុណ នៃព្រះសារីបុត្តមានអាយុ ក៏ទេវបុត្តជាបរិស័ទរបស់សុសិមទេវបុត្ត មានសេចក្តីត្រេកអរ រីករាយ កើតបីតិសោមនស្ស បញ្ចេញរស្មីមានប្រការផ្សេង ៗ យ៉ាងនោះឯង ។

[៣១៥] អថខោ សុសិមោ ទេវបុត្តោ អាយស្មន្តំ សារីបុត្តំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

បណ្ឌិតោតិ សមញ្ញាតោ
សារីបុត្តោ អកោធនោ
អប្បិច្ឆោ សោរតោ ទន្តោ
សត្ថុវណ្ណាភតោ ឥសីតិ ។

[៣១៦] អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អារព្ភ សុសិមំ ទេវបុត្តំ គាថាយ អជ្ឈភាសិ

បណ្ឌិតោតិ សមញ្ញាតោ
សារីបុត្តោ អកោធនោ
អប្បិច្ឆោ សោរតោ ទន្តោ
កាលំ កង្ខតិ ភាវិតោ[១] សុទន្តោតិ ។

## ទសមំ នានាតិត្ថិយសុត្តំ

[៣១៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។

១ ឱ. ភតិកោ ។ អ. ភត្តិកោ ។ ម. ភាវិតោតិ ន ទិស្សតិ ។

[៣១៥] លំដាប់នោះ សុសិមទេវបុត្តប្រារព្ធចំពោះព្រះសារីបុត្ត មានអាយុ ក៏ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ព្រះសារីបុត្ត ប្រាកដថាជាបណ្ឌិត មិនមានសេចក្ដីក្រោធ
គ្មានសេចក្ដីប្រាថ្នា ជាអ្នកស្ងួតបូត មានខ្លួនទូន្មានហើយ
ជាឥសីមានគុណដែលព្រះសាស្ដាទ្រង់នាំមកសរសើរហើយ ។

[៣១៦] គ្រានោះ ព្រះមានព្រះភាគ ប្រារព្ធចំពោះព្រះសារី-បុត្តមានអាយុហើយ ក៏ត្រាស់តបនឹងសុសិមទេវបុត្ត ដោយគាថា ថា

សារីបុត្ត ប្រាកដថាជាបណ្ឌិត មិនមានសេចក្ដីក្រោធ
គ្មានសេចក្ដីប្រាថ្នា ជាអ្នកស្ងួតបូត មានខ្លួនទូន្មានហើយ
ចម្រើនហើយ ទូន្មានដោយល្អហើយ តែងប្រាថ្នានូវ
បរិនិព្វានកាល ។

# នានាតិត្ថិយសូត្រ ទី ១០

[៣១៧] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។

អថខោ សម្ពហុលា នានាតិត្ថិយសាវកា ទេវបុត្តា អសមោ ច សហលី ច ងិកោ[១] ច អាកោដកោ ច វេជម្ពរី[២] ច មាណវគាមិយោ ច អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ វេឡុវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

[៣១៨] ឯកមន្តំ ឋិតោ ខោ អសមោ ទេវបុត្តោ បូរណំ កស្សបំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ឥធ ឆិន្ទិតមារិតេ
ហាតជានីសុ កស្សបោ
ន ចាបំ សមនុបស្សតិ
បុញ្ញំ វា បន អត្តនោ
សវេ វិស្សាសមាចិក្ខិ
សត្ថា អរហតិ មាននន្តិ ។

---

១ ឱ. និកោ ។ ២ ម. វេគព្ភរិ ។

គ្រាកាលដែលរាត្រីបឋមយាមកន្លងទៅហើយ មានពួកទេវបុត្តជាសាវ័កនៃនានាតិរ្ថិយជាច្រើនអង្គ គឺ ទេវបុត្តឈ្មោះអសមៈ ១ សហលី ១ និកៈ ១ អាកោដកៈ ១ វេដម្ពរី ១ មាណវគាមិយៈ ១ មានរស្មីដ៏រុងរឿង ញុំាងវត្តវេឡុវ័នជុំវិញទាំងអស់ ឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ឋិតនៅក្នុងទីសមគួរ ។

[៣១៨] លុះអសមទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ប្រារព្ធចំពោះគ្រូឈ្មោះបូរណកស្សប ហើយពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

គ្រូឈ្មោះកស្សប មិនឃើញច្បាស់នូវបាប ក្នុងការកាត់
និងការសម្លាប់ ក្នុងការបៀតបៀន និងការវិនាសនៃទ្រព្យ
ទាំងឡាយ ក្នុងលោកនេះ ទាំងមិនឃើញច្បាស់នូវបុណ្យ
របស់ខ្លួនសោះឡើយ គ្រូឈ្មោះកស្សបនោះឯង គ្រាន់តែ
ប្រាប់នូវសេចក្តីស្និទ្ធស្នាលគឺទីពឹងអាស្រ័យ (ដល់ពួកសត្វ)
ក៏គួរដើម្បីធ្វើនូវការរាប់អាន (ថ្វាយបង្គំរបស់មនុស្ស) បូជា ។

ទេវបុត្តសំយុត្តស្ស នានាតិត្ថិយវគ្គេ នានាតិត្ថិយាវព្ភាសនំ

[៣១៩] អថខោ សហលី ទេវបុត្តោ មក្ខលី គោសាលំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

តបោជិគុច្ឆាយ សុសំវុតត្តោ
វាចំ បហាយ កលហំ ជនេន
សមោ សវជ្ជា វិរតោ សច្ចវាទី
នហិ នូន តាទី បករោតិ[១] បាបន្តិ ។

[៣២០] អថខោ និកោ ទេវបុត្តោ និគន្ថំ នាដ-បុត្តំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ជេគុច្ឆី និបកោ ភិក្ខុ
ចាតុយាមសុសំវុតោ
ទិដ្ឋំ សុតញ្ច អាចិក្ខំ
នហិ នូន កិព្វិសី សិយាតិ ។

[៣២១] អថខោ អាកោដកោ ទេវបុត្តោ នា-នាតិត្ថិយេ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

---

១ ឱ. ម. ន ហិ នូន តាទិសំ ករោតិ ។

[៣១៩] លំដាប់នោះ សហលីទេវបុត្ត ប្រារព្ធចំពោះគ្រូឈ្មោះមក្ខលិគោសាល ហើយពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បុគ្គល មានខ្លួនសង្រួមហើយដោយប្រពៃ ព្រោះខ្ពើមបាប
ដោយតបៈ លះបង់នូវវាចាជាគ្រឿងឈ្លោះជាមួយនឹងមហា-
ជន ជាបុគ្គលស្ងប់រម្ងាប់ វៀរចាកកម្មប្រកបដោយទោស
ពោលតែពាក្យពិត បុគ្គលមានសភាពដូច្នោះ រមែងមិន
ធ្វើនូវបាបដោយពិត ។

[៣២០] លំដាប់នោះ និកទេវបុត្ត ប្រារព្ធនិគន្ថនាដបុត្ត ហើយពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ភិក្ខុជាបណ្ឌិត មានសេចក្តីខ្ពើមបាប សង្រួមដោយប្រពៃ
គ្រប់យាមទាំង ៤ ប្រាប់នូវហេតុដែលខ្លួនឃើញហើយផង នូវ
ហេតុដែលខ្លួនឮហើយផង មិនឈ្មោះថា ធ្វើនូវអំពើអាក្រក់
ដោយពិត ។

[៣២១] លំដាប់នោះ អាកោដកទេវបុត្ត ប្រារព្ធចំពោះពួកនានាតិរ្ថិយ ហើយពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

បកុដកោ កាតិយានោ និគណ្ឋោ
យេ ចាបិមេ មក្ខលិបូរណាសេ
គណស្ស សត្ថារោ សាមញ្ញបត្តា
នហិ នូន តេ សប្បុរិសេហិ ទូរេតិ ។

[៣២២] អថខោ វេណ្ឌុ ទេវបុត្តោ អាកោដកំ ទេវបុត្តំ គាថាយ អជ្ឈភាសិ[១]

សហា រចិតេន[២] ឆវោ សិគាលោ
ន កោដ្ឋុកោ[៣] សីហសមោ កទាចិ
នគ្គោ[៤] មុសាវាទិ គណស្ស សត្ថា
សង្កស្សរាចារោ ន សតំ សរិក្ខោតិ ។

[៣២៣] អថខោ មារោ បាបិមា វេណ្ឌុំ ទេវ-
បុត្តំ អន្វាវិសិត្វា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

១ ឱ. ម. បច្ចភាសិ ។ ២ ឱ. សគារវេនាបិ ។ ម. សីហាចរិតេន ។ ៣ ឱ. កុត្ថកោ ។ ម. កោត្ថុកោ ។ អដ្ឋកថាយម្បន កុដ្ឋកោ ។ ឱ. ម. នគ្គោ ។

ពួកគ្រូនៃគណៈណា គឺគ្រូ ឈ្មោះបកុធកកាតិយានៈ ១ និគន្ថនាដបុត្ត ១ មក្ខលិគោសាល ១ បូរណកស្សប ១ សុទ្ធតែដល់នូវភាពនៃខ្លួនជាសមណៈ គ្រូទាំងនោះឋិតនៅមិនឆ្ងាយអំពីពួកសប្បុរសដោយពិត ។

[៣២២] គ្រានោះ វេដម្ពរីទេវបុត្ត ពោលទៅនឹងអាកោដកទេវបុត្ត ដោយគាថា ថា

សត្វចចកខ្វាក់ លាមក ដើរទៅជាមួយនឹងសត្វសីហៈ សត្វចចក (នោះ) នឹងស្មើដោយសត្វសីហៈ ក្នុងកាលណាមួយមិនមានទេ ឯគ្រូរបស់គណៈ ជាអ្នកអាក្រាត អ្នកពោលពាក្យកុហក មានមារយាទគួររឭកដោយសេចក្ដីរង្កៀស ក៏មិនប្រហែលដោយពួកសប្បុរសដែរ ។

[៣២៣] គ្រានោះ មារមានចិត្តបាប ជ្រែកចូលវេដម្ពរីទេវបុត្ត ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

តចោជិគុច្ឆាយ អាយុត្តា
ចាលយំ បវិវេកិយំ
រូបេ ច យេ និវិដ្ឋាសេ
ទេវលោកាភិនន្ទិនោ
តេ ចេ(១) សម្មានុសាសន្តិ
បរលោកាយ មាតិយាតិ ។

[៣២៤] អថខោ ភគវា មារោ អយំ ចាបិមា ឥតិ វិជិត្វា មារំ ចាបិមន្តំ គាថាយ បច្ចភាសិ

យេ កេចិ រូបា ឥធ វា ហុរំ វា
យេ ចន្តលិក្ខស្មិ(២) បភាសវណ្ណា
សព្វេវ តេ តេ នមុចិប្បសត្ថា
អាមិសំវ មច្ឆានំ វធាយ ខិត្តាតិ ។

[៣២៥] អថខោ មាណវគាមិយោ ទេវបុត្តោ ភគវន្តំ អារព្ភ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

វិបុលោ រាជគហិយានំ
គិរិ សេដ្ឋោ បវុច្ចតិ

---

១ ឱ. ម. វេ ។ ២ ឱ. អន្តលិក្ខស្មិ ។

សត្វទាំងឡាយណា ប្រកបក្នុងកិរិយាខ្ពើមបាប ដោយតបៈ
រក្សានូវសេចក្ដីស្ងប់ស្ងាត់ តាំងនៅក្នុងរូប ត្រេកអរចំពោះ
ទេវលោក សត្វទាំងនោះឯង រមែងប្រៀនប្រដៅដោយ
ប្រពៃ ដើម្បីទៅកាន់លោកខាងមុខ ។

[៣២៤] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា នេះជាតួមារមានចិត្តបាប ហើយក៏ត្រាស់តបទៅនឹងមារមានចិត្តបាបវិញ ដោយគាថា ថា

រូបទាំងឡាយណាមួយ មានក្នុងលោកនេះក្ដី ក្នុងលោក
ខាងមុខក្ដី និងរូបទាំងឡាយណា ដែលមានរស្មីរុងរឿងព្ធដ៏
អាកាស ម្នាលមារ ឯរូបទាំងអស់នោះ អ្នកឯងបានសរសើរ
ហើយ ដូចជានុយដែលគេបោះទៅដើម្បីសម្លាប់ពួកត្រី ។

[៣២៥] គ្រានោះ មាណវគាមិយទេវបុត្ត ប្រារព្ធចំពោះព្រះមានព្រះភាគហើយ ពោលនូវគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

ភ្នំវិបុលប្រសើរវិសេសជាងពួកភ្នំដែលនៅក្បែរក្រុងរាជគ្រឹះ

សេតោ ហិមវតំ សេដ្ឋោ
អាទិច្ចោ អឃគាមិនំ
សមុទ្ទោឧធិនំ សេដ្ឋោ
នក្ខត្តានញ្ច ចន្ទិមា
សទេវកស្ស លោកស្ស
ពុទ្ធោ អគ្គោ បវុច្ចតីតិ ។

នានាតិត្ថិយវគ្គោ តតិយោ

## តស្សុទ្ទានំ

សិវោ ខេមោ ច សេរី ច
ឃដិ ជន្តុ ច រោហិតោ
នន្ទោ នន្ទិវិសាលោ ច
សុសិមោ នានាតិត្ថិយេន តេ ទសាតិ ។

ទេវបុត្តសំយុត្តំ និដ្ឋិតំ ។

ភ្នំសេត (ភ្នំកៃលាស) ប្រសើរវិសេសជាងពួកភ្នំហេមពាន្ត ព្រះអាទិត្យ ប្រសើរវិសេសជាងសភាវៈដែលដើរទៅ ក្នុងអាកាស សមុទ្រ ប្រសើរវិសេស ជាងទីដែលទ្រទ្រង់ទឹក ព្រះចន្ទ ប្រសើរវិសេសជាងពួកផ្កាយ ឯព្រះពុទ្ធ ប្រសើរជាងពួកមនុស្សលោកព្រមទាំងទេវលោក ។

ចប់ នានាតិត្ថិយវគ្គ ទី ៣ ។

## ឧទ្ទាននៃនានាតិត្ថិយវគ្គនោះ គឺ

សិវសូត្រ ១ ខេមសូត្រ ១ សេរីសូត្រ ១ ឃដិការសូត្រ ១ ជន្តុសូត្រ ១ រោហិតស្សសូត្រ ១ នន្ទសូត្រ ១ នន្ទិវិសាលសូត្រ ១ សុសិមសូត្រ ១ និងនានាតិត្ថិយសូត្រ ១ ជា ១០ ។

ចប់ ទេវបុត្តសំយុត្ត ។

# កោសលសំយុត្តំ

## បឋមោ ទហរវគ្គោ

### បឋមំ ទហរសុត្តំ

[៣២៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ រាជា បសេនទិកោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៣២៧] ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច ភវំបិ នោ គោតមោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បដិជានាតីតិ ។ យំ ហិ តំ មហារាជ សម្មា វទមានោ វទេយ្យ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ មមន្តំ សម្មា វទមានោ វទេយ្យ អហំ ហិ មហារាជ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ។

# កោសលសំយុត្ត

## ទហរវគ្គ ទី ១

### ទហរសូត្រ ទី ១

[៣២៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើនូវសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់នៅក្នុងទីសមគួរ ។

[៣២៧] លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរ ព្រះមានព្រះភាគ ដូច្នេះថា ព្រះគោតមដ៏ចម្រើនប្តេជ្ញាថា ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណដូច្នេះឬទេ ។ ព្រះអង្គត្រាស់ថា បពិត្រមហារាជ បុគ្គលនិយាយដោយប្រពៃ នូវពាក្យណាថា តថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បុគ្គលពោលពាក្យនោះចំពោះតថាគត ឈ្មោះថាពោលដោយប្រពៃ បពិត្រមហារាជ ព្រោះថា តថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណមែន ។

[៣២៨] យេបិ តេ ភោ គោតម សមណព្រា-ហ្មណា សង្ឃិនោ គណិនោ គណាចរិយា ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា ពហុជនស្ស សេយ្យថីទំ បូរណោ កស្សបោ មក្ខលិ គោសាលោ និគណ្ឋោ នាដបុត្តោ សញ្ជយោ វេលដ្ឋបុត្តោ បកុធោ[១] កច្ចាយនោ អជិតោ កេសកម្ពលោ តេបិ មយា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បដិជានាថាតិ បុដ្ឋា សមានា ន អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បដិជានន្តិ កឹ បន ភវំ គោតមោ ទហរោ ចេវ ជា-តិយា នវោ ច បព្វជ្ជាយាតិ ។

[៣២៩] ចត្តារោ ខោមេ មហារាជ ទហរាតិ ន ឧញ្ញាតព្វា ទហរាតិ ន បរិភោតព្វា កតមេ ចត្តារោ ខត្តិយោ ខោ មហារាជ ទហរោតិ ន ឧញ្ញាតព្វោ ទហ-រោតិ ន បរិភោតព្វោ ឧរគោ ខោ មហារាជ ទហរោតិ ន ឧញ្ញាតព្វោ ទហរោតិ ន បរិភោតព្វោ អគ្គិ ខោ មហារាជ

១ ឱ. កកុធោ ។

[៣២៨] ព្រះរាជាត្រាស់ថា បពិត្រព្រះគោតមដ៏ចម្រើន ពួកសមណព្រាហ្មណ៍ណា ដែលមានពួក មានគណៈ ជាអាចារ្យរបស់គណៈ មានកេរ្តិ៍ឈ្មោះប្រាកដ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិដូចជាកំពង់ ដែលជនជាច្រើនសន្មតថាជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សប ១ មក្ខលិគោសាល ១ និគន្ថនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុធកច្ចាយនៈ ១ អជិតកេសកម្ពល ១ ឯសមណព្រាហ្មណ៍ទាំងនោះ កាលដែលខ្ញុំព្រះអង្គបានសួរហើយថា លោកទាំងឡាយ ប្តេជ្ញាខ្លួនថា ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណឬ ក៏មិនប្តេជ្ញាខ្លួនថា ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ចំណែកព្រះគោតមដ៏ចម្រើន ក្មេងដោយកំណើតផង ថ្មីដោយផ្នួសផង មែនឬ ។

[៣២៩] បពិត្រមហារាជ សភាវៈ ៤ ពួកនេះ បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង ឡើយ ឯសភាវៈ ៤ ពួកនោះ តើដូចម្តេច បពិត្រមហារាជ ក្សត្រិយ៍ បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង ១ បពិត្រមហារាជ ពស់ បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង ១ បពិត្រមហារាជ ភ្លើង

ទហរោតិ ន ឧញ្ញាតព្វោ ទហរោតិ ន បរិភោតព្វោ ភិក្ខុ ខោ មហារាជ ទហរោតិ ន ឧញ្ញាតព្វោ ទហ-រោតិ ន បរិភោតព្វោ ឥមេ ខោ មហារាជ ចត្តារោ ទហរាតិ ន ឧញ្ញាតព្វា ទហរាតិ ន បរិភោតព្វា ។

[៣៣០] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ខត្តិយំ ជាតិសម្បន្នំ
អភិជាតំ យសស្សិនំ
ទហរោតិ នាវជានេយ្យ
ន នំ បរិភវេ នរោ
ឋានម្ហិ សោ មនុស្សិន្ទោ
រជ្ជំ លទ្ធាន ខត្តិយោ

បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង គឺថាភ្លើងតិច ១ បពិត្រមហារាជ ភិក្ខុ បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង ១ បពិត្រមហារាជ សភាវៈ ៤ ពួកនេះឯង បុគ្គលមិនគប្បីមើលងាយថា ក្មេង មិនគប្បីរិះគន់ថា ក្មេង ឡើយ ។

[៣៣០] ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះរួចហើយ ព្រះសុគតជាសាស្តា លុះត្រាស់ពាក្យនេះរួចហើយ ក៏ទ្រង់ត្រាស់ពាក្យដូច្នេះ តទៅទៀតថា

បុគ្គលមិនគប្បីមើលងាយក្សត្រិយ៍ ដែលបរិបូណ៌ដោយជាតិ
មានជាតិដ៏ខ្ពង់ខ្ពស់ មានយសបរិវារ ថា ក្មេង មិនគប្បីរិះ-
គន់ក្សត្រិយ៍នោះ ថា ក្មេង ទេ ព្រោះក្សត្រិយ៍នោះ រមែង
មានឋានៈជាធំជាងមនុស្ស លុះបានសោយរាជសម្បត្តិហើយ

សោ កុទ្ធោ រាជទណ្ឌេន
តស្មឹ បក្កមតេ ភុសំ
តស្មា តំ បរិវជ្ជេយ្យ
រក្ខំ ជីវិតមត្តនោ
គាមេ វា យទិ វារញ្ញេ
យត្ថ បស្សេ ភុជង្គមំ
ទហរោតិ នាវជានេយ្យ
ន នំ បរិភវេ នរោ
ឧច្ចាវចេហិ វណ្ណេហិ
ឧរគោ ចរតិ តេជសី
សោ អាសជ្ជ ឌំសេ ពាលំ
នរំ នារិញ្ច ឯកទា
តស្មា តំ បរិវជ្ជេយ្យ
រក្ខំ ជីវិតមត្តនោ
បហូតភក្ខំ ជាលិនំ
ចាវកំ កណ្ហវត្តនឹ
ទហរោតិ នាវជានេយ្យ

ក្សត្រិយ៍នោះទ្រង់ក្រោធឡើង រមែងព្យាយាមដ៏ក្លាខ្លាំង ចំពោះបុគ្គលនោះ ដោយព្រះរាជអាជ្ញា ព្រោះហេតុនោះ បុគ្គលកាលរក្សានូវជីវិតរបស់ខ្លួន គប្បីវៀរនូវក្សត្រិយ៍នោះ បុគ្គលឃើញនូវពស់ ក្នុងទីណា ទោះក្នុងស្រុកក្ដី ព្រៃក្ដី កុំគប្បីមើលងាយថា តូច កុំគប្បីបំពាននូវពស់នោះថា តូច ព្រោះពស់មានតេជះតែងត្រាច់ទៅដោយភេទ មានប្រការផ្សេង ៗ ពស់នោះបើចួបនឹងមនុស្សប្រុសក្ដី ស្រីក្ដី ដែលល្ងង់ តែងចឹកក្នុងកាលណាមួយ ព្រោះហេតុនោះ បុគ្គលកាលរក្សាជីវិតរបស់ខ្លួន គប្បីវៀរពស់នោះឲ្យស្រឡះ បុគ្គលមិនគប្បីមើលងាយភ្លើង ដែលមានអណ្ដាត មានចំណីគឺឧសច្រើន មានផ្លូវគឺស្នាមប្រផេះខ្មៅ ថាជាភ្លើងតិច កុំគប្បីបំពានភ្លើងនោះ

កោសលសំយុត្តស្ស ទហរវគ្គេ ទហរានាវជាននំ

ន នំ បរិភវេ នរោ
លទ្ធា ហិ សោ ឧចាទានំ
មហា ហុត្វាន ចាវកោ
សោ អាសជ្ជ ឌហេ ពាលំ
នរំ នារិញ្ច ឯកទា
តស្មា តំ បរិវជ្ជេយ្យ
រក្ខំ ជីវិតមត្តនោ
វនំ យទគ្គិ ឌហតិ
ចាវកោ កណ្ហវត្តនី
ជាយន្តិ តត្ថ ចារោហា
អហោរត្តានមច្ចយេ
យញ្ច ខោ សីលសម្បន្នោ
ភិក្ខុ ឌហតិ តេជសា
ន តស្ស បុត្តា បសវោ
ទាយាទា វិន្ទរេ ធនំ
អនបច្ចា អទាយាទា
តាលវត្ថុ ភវន្តិ តេ

ថា តិច ឡើយ ដ្បិតភ្លើងនោះ លុះបានកម្មេចជាគ្រឿង ឆេះហើយ នឹងទៅជាភ្លើងធំបាន ភ្លើងនោះ ចួបនឹងមនុស្ស ប្រុសក្តី ស្រីក្តី ដែលល្ងង់ តែងឆេះក្នុងកាលណាមួយ ព្រោះ ហេតុនោះ បុគ្គលកាលរក្សាជីវិតរបស់ខ្លួន គប្បីវៀរនូវភ្លើង នោះ ភ្លើងជាសភាវៈធ្វើឲ្យស្អាត ជាសភាវៈមានផ្លូវខ្មៅ បើ ឆេះនូវព្រៃណា ឯសភាវៈដុះនៅលើផែនដីទាំងឡាយ (មាន ឈើនិងស្មៅជាដើម) តែងដុះឡើងក្នុងព្រៃនោះវិញ ក្នុង កាលដែលកន្លងទៅនៃថ្ងៃនិងយប់ ឯភិក្ខុដែលបរិបូណ៌ដោយ សីល បើឆេះនូវបុគ្គលណាដោយតេជះហើយ ពួកកូននិង សត្វចិញ្ចឹមរបស់បុគ្គលនោះ ក៏មិនមាននៅ ពួកជនជាញាតិ ក៏មិនបាននូវទ្រព្យ ឯពួកជនមិនមែនជាកូនចៅ និងជនមិន មែនជាញាតិទាំងនោះ (មិនចម្រើនឡើង) ដូចជាត្នោតកំបុតក

តស្មា ហិ បណ្ឌិតោ ចោសោ

សម្បស្សំ ភយមត្តនោ[១]

ភុជង្គមំ បាវកញ្ច

ខត្តិយញ្ច យសស្សិនំ

ភិក្ខុញ្ច សីលសម្បន្នំ

សម្មទេវ សមាចរេតិ ។

[៣៣១] ឯវំ វុត្តេ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

១ អត្តមត្តនោតិបិ បាឋេន ភវិតព្វំ ។

ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវភ័យនៃខ្លួន គប្បីប្រព្រឹត្តឲ្យស្មើដោយប្រពៃ ចំពោះពស់ផង ភ្លើងផង ក្សត្រិយ៍ដែលមានយសផង និងភិក្ខុដែលបរិបូណ៌ដោយសីលផង ។

[៣៣១] កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រះបាទបសេនទិកោសល ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ដូចបុគ្គលផ្ងារ នូវរបស់ដែលផ្កាប់ ឬបើកនូវរបស់ដែលកំបាំង ពុំនោះសោត ដូចបុគ្គលប្រាប់ផ្លូវដល់មនុស្សអ្នកវង្វេងទិស ឬទ្រោលនូវប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានភ្នែក រមែងឃើញរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគ ទាំងព្រះធម៌ ទាំងភិក្ខុសង្ឃ ថាជាទីពឹងទីរឭក សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យជាទីពឹងទីរឭក ស្មើដោយជីវិត តាំងតែអំពីថ្ងៃនេះជាដើមទៅ ។

# ទុតិយំ បុរិសសុត្តំ

[៣៣២] សាវត្ថិយំ អារាមេ... អថខោ រាជា បសេនទិកោសលោ យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

[៣៣៣] តយោ ខោ មហារាជ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ កតមេ តយោ លោភោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជ-មានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុ-វិហារាយ ទោសោ ខោ មហារាជ បុរិសស្ស ធម្មោ

# បុរិសសូត្រ ទី ២

[៣៣២] ព្រះមានព្រះភាគ ទ្រង់គង់ក្នុងអារាម ជិតក្រុងសាវត្ថី... គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់បុរសមានប៉ុន្មានយ៉ាង កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ។

[៣៣៣] ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ធម៌របស់បុរសមាន ៣ យ៉ាង កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ធម៌ទាំង ៣ តើដូចម្តេច បពិត្រមហារាជ លោភៈជាធម៌របស់បុរស កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហារាជ ទោសៈជាធម៌របស់បុរស

អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ មោហោ ខោ មហារាជ បុរិសស្ស ជម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ឥមេ ខោ មហារាជ តយោ បុរិសស្ស ជម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

[៣៣៤] ឥទមវោច[១] ។ បេ ។

លោភោ ទោសោ ច មោហោ ច
បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា
តចសារំវ សម្ផលន្តិ ។

# តតិយំ រាជសុត្តំ

[៣៣៥] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ ជាតស្ស អញ្ញត្រ ជរាមរណាតិ ។

---

១ ឱ. ម. ឥទមវោចាតិ ន ទិស្សតិ ។

កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហារាជ មោហៈជាធម៌របស់បុរស កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហារាជ ធម៌របស់បុរសមាន ៣ យ៉ាងនេះឯង កាលកើតឡើងក្នុងខ្លួន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ។

[៣៣៤] ព្រះមានព្រះភាគ បានទ្រង់ត្រាស់ពាក្យនេះហើយ ។ បេ ។

លោភៈ ១ ទោសៈ ១ មោហៈ ១ កើតអំពីខ្លួន តែងសម្លាប់បុរសដែលមានចិត្តលាមក ដូចជាផ្លែ រមែងសម្លាប់ឈើដែលមានខ្លឹមខាងក្រៅ (មានឫស្សីនិងបបុសជាដើម) ។

# រាជសូត្រ ទី ៣

[៣៣៥] ជិតក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សត្វដែលកើតហើយ វៀរចាកជរានិងមរណៈបាន មានដែរឬ ។

កោសលសំយុត្តស្ស ទុហរវគ្គេ ភេទនធម្មោ

[៣៣៦] នត្ថិ ខោ មហារាជ ជាតស្ស អញ្ញត្រ ជរាមរណា យេបិ តេ មហារាជ ខត្តិយមហាសាលា អឌ្ឍា មហទ្ធនា មហាភោគា បហូតជាតរូបរជតា បហូតវិត្តូបករណា បហូតធនធញ្ញា តេសម្បិ ជាតានំ នត្ថិ អញ្ញត្រ ជរាមរណា យេបិ តេ មហារាជ ព្រាហ្មណមហាសាលា ។ បេ ។ គហបតិមហាសាលា អឌ្ឍា មហទ្ធនា មហាភោគា បហូតជាតរូបរជតា បហូតវិត្តូបករណា បហូតធនធញ្ញា តេសម្បិ ជាតានំ នត្ថិ អញ្ញត្រ ជរាមរណា យេបិ តេ មហារាជ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេសម្បាយំ កាយោ ភេទនធម្មោ និក្ខេបនធម្មោតិ ។

កោសលសំយុត្ត ទហរវគ្គ កាយមានកិរិយាបែកធ្លាយជាធម្មតា

[៣៣៦] ព្រះអង្គត្រាស់ថា បពិត្រមហារាជ សត្វដែលកើតហើយ វៀរចាកជរានិងមរណៈបាន មិនមានទេ បពិត្រមហារាជ ពួកខត្តិយមហាសាលណា ដែលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានទ្រព្យនិងស្រូវច្រើន សូម្បីពួកខត្តិយមហាសាលទាំងនោះ ដែលកើតហើយ វៀរចាកជរានិងមរណៈ មិនមានទេ បពិត្រមហារាជ ពួកព្រាហ្មណមហាសាលណា ។ បេ ។ ពួកគហបតិមហាសាល អ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានគ្រឿងឧបរកណ៍ជាទីត្រេកអរច្រើន មានទ្រព្យនិងស្រូវច្រើន សូម្បីពួកគហបតិមហាសាលទាំងនោះ ដែលកើតហើយ វៀរចាកជរានិងមរណៈ ក៏មិនមានដែរ បពិត្រមហារាជ ទុកជាពួកភិក្ខុណាជាព្រះអរហន្ត មានអាសវៈអស់ហើយ មានព្រហ្មចរិយធម៌បានប្រព្រឹត្តហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានអរហត្តផលជាប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានភវសញ្ញោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ សូម្បីកាយនេះរបស់ព្រះអរហន្តនោះ ក៏គង់មានកិរិយាបែកធ្លាយទៅជាធម្មតា មានកិរិយាដាក់ចុះជាធម្មតា ។

[៣៣៧] ឥទមវោច(១) ។ បេ ។

ជីវន្តិ វេ រាជវចា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តីតិ ។

# ចតុត្ថំ បិយសុត្តំ

[៣៣៨] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កេសំ នុ ខោ បិយោ អត្តា កេសំ អប្បិយោ អត្តាតិ តស្ស មយ្ហំ ភន្តេ ឯតទ-ហោសិ យេ ច(២) ខោ កេចិ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេសំ អប្បិយោ អត្តា កិញ្ចាបិ តេ ឯវំ វទេយ្យុំ បិយោ នោ អត្តាតិ អថខោ តេសំ អប្បិយោ អត្តា តំ

១ ឱ. ម. ឥទមវោចាតិ ន ទិស្សតិ ។ ២ ឱ. ម. ចសទ្ទោ នត្ថិ ។

[៣៣៧] ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះហើយ ។ បេ ។ រាជរថទាំងឡាយ ដែលជាង៍វិចិត្រហើយដោយប្រពៃ រមែង គ្រាំគ្រាទៅ សូម្បីសរីរៈក៏រមែងដល់នូវសេចក្តីគ្រាំគ្រា មាន តែធម៌របស់ពួកសប្បុរស ទើបមិនដល់នូវសេចក្តីគ្រាំគ្រា ពួក សប្បុរស រមែងពោលជាមួយនឹងពួកសប្បុរស ។

# បិយសូត្រ ទី ៩

[៣៣៨] ជិតក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសលគង់ ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ សម្ងំនៅតែម្នាក់ឯង ក្នុងទីឯ-ណោះ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ខ្លួនជាទីស្រឡាញ់ របស់បុគ្គលពួកណាហ្ន៎ ខ្លួនមិនជាទីស្រឡាញ់ របស់បុគ្គលពួកណាហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះដូច្នេះថា បុគ្គល ណាមួយ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្ត ទុច្ចរិតដោយចិត្ត ខ្លួនមិនជាទីស្រឡាញ់របស់បុគ្គលពួកនោះ ទុកជាបុគ្គល ទាំងនោះ ពោលយ៉ាងនេះថា ខ្លួនជាទីស្រឡាញ់របស់យើង ក៏ឈ្មោះ ជាខ្លួនមិនជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ដោយពិត សេចក្តីនោះ

កិស្ស ហេតុ យំ ហិ អប្បិយោ អប្បិយស្ស ករេយ្យ តំ តេ អត្តនា វ អត្តនោ ករោន្តិ តស្មា តេសំ អប្បិយោ អត្តា យេ ច ខោ កេចិ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ តេសំ បិយោ អត្តា កិញ្ចាបិ តេ ឯវំ វទេយ្យុំ អប្បិ-យោ នោ អត្តាតិ អថខោ តេសំ បិយោ អត្តា តំ កិស្ស ហេតុ យំ ហិ បិយោ បិយស្ស ករេយ្យ តំ តេ អត្តនា វ អត្តនោ ករោន្តិ តស្មា តេសំ បិយោ អត្តាតិ ។

[៣៣៩] ឯវមេតំ មហារាជ ឯវមេតំ មហា-រាជ យេ ហិ កេចិ មហារាជ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេសំ អប្បិយោ អត្តា កិញ្ចាបិ តេ ឯវំ វទេយ្យុំ

ព្រោះហេតុដូចម្តេច ព្រោះថា ខ្លួនមិនជាទីស្រឡាញ់ គប្បីធ្វើនូវអំពើណា ដល់ខ្លួនមិនជាទីស្រឡាញ់ ឯបុគ្គលទាំងនោះ រមែងធ្វើនូវអំពើនោះ ដល់ខ្លួនដោយខ្លួនឯង ព្រោះហេតុនោះ ខ្លួនមិនជាទីស្រឡាញ់របស់បុគ្គលទាំងនោះឡើយ លុះតែបុគ្គលណាមួយ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ទើបខ្លួនឈ្មោះថាជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ទុកជាបុគ្គលទាំងនោះពោលយ៉ាងនេះថា ខ្លួនមិនជាទីស្រឡាញ់របស់យើង ក៏ឈ្មោះថាខ្លួនជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ដោយពិត សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះថា ខ្លួនជាទីស្រឡាញ់ គប្បីធ្វើនូវអំពើណាដល់ខ្លួនជាទីស្រឡាញ់ បុគ្គលទាំងនោះ តែងធ្វើនូវអំពើនោះដល់ខ្លួនដោយខ្លួនឯង ព្រោះហេតុនោះ ខ្លួនឈ្មោះថាជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ។

[៣៣៩] ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ បុគ្គលណាមួយ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ខ្លួនឈ្មោះថាមិនជាទីស្រឡាញ់របស់បុគ្គលទាំងនោះឡើយ ទុកជាបុគ្គលទាំងនោះ ពោលយ៉ាងនេះថា

១៩៦



បិយោ ជោ អត្តាតិ អថខោ តេសំ អប្បិយោ អត្តា តំ កិស្ស ហេតុ យំ ហិ មហារាជ អប្បិយោ អប្បិយស្ស ករេយ្យ តំ តេ អត្តនា វ អត្តនោ ករោន្តិ តស្មា តេសំ អប្បិយោ អត្តាតិ យេ ច ខោ កេចិ មហារាជ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ តេសំ បិយោ អត្តា កិញ្ចាបិ តេ ឯវំ វទេយ្យុំ អប្បិយោ ជោ អត្តាតិ អថខោ តេសំ បិយោ អត្តា តំ កិស្ស ហេតុ យំ ហិ មហារាជ បិយោ បិយស្ស ករេយ្យ តំ តេ អត្តនា វ អត្តនោ ករោន្តិ តស្មា តេសំ បិយោ អត្តាតិ ។

ខ្លួនជាទីស្រឡាញ់របស់យើង ក៏ឈ្មោះថាខ្លួនមិនជាទីស្រឡាញ់ របស់បុគ្គលទាំងនោះដោយពិត សេចក្តីនោះ ព្រោះហេតុដូចម្តេច បពិត្រមហារាជ ព្រោះថា ខ្លួនមិនជាទីស្រឡាញ់ គប្បីធ្វើនូវអំពើណាដល់ខ្លួនមិនជាទីស្រឡាញ់ បុគ្គលទាំងនោះ តែងធ្វើនូវអំពើនោះ ដល់ខ្លួនដោយខ្លួនឯង ព្រោះហេតុនោះ ខ្លួនឈ្មោះថាមិនជាទីស្រឡាញ់របស់បុគ្គលទាំងនោះ បពិត្រមហារាជ លុះតែបុគ្គលណាមួយ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ទើបខ្លួនឈ្មោះថាជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ទុកជាបុគ្គលទាំងនោះពោលយ៉ាងនេះថា ខ្លួនមិនជាទីស្រឡាញ់របស់យើង ក៏ឈ្មោះថាខ្លួនជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ដោយពិត សេចក្តីនោះ ព្រោះហេតុដូចម្តេច បពិត្រមហារាជ ព្រោះថា ខ្លួនជាទីស្រឡាញ់ គប្បីធ្វើនូវអំពើណាដល់ខ្លួនជាទីស្រឡាញ់ បុគ្គលទាំងនោះ តែងធ្វើនូវអំពើនោះដល់ខ្លួនដោយខ្លួនឯង ព្រោះហេតុនោះ ខ្លួនឈ្មោះថាជាទីស្រឡាញ់របស់បុគ្គលទាំងនោះ ។

[៣៤០] ឥធមហេច ។ បេ ។

អត្តានញ្ចេ បិយំ ជញ្ញា

ន នំ បាបេន សំយុជេ

ន ហិ តំ សុលភំ ហោតិ

សុខំ ទុក្កដការិនា

អន្តកេនាធិបន្នស្ស

ជហតោ មានុសំ ភវំ

កឹ ហិ តស្ស សកំ ហោតិ

កិញ្ច អាទាយ គច្ឆតិ

កិញ្ចស្ស អនុគំ ហោតិ

ឆាយាវ អនុបាយិនី

ឧភោ បុញ្ញញ្ច បាបញ្ច

យំ មច្ចោ កុរុតេ ឥធ

តំ ហិ តស្ស សកំ ហោតិ

តញ្ច អាទាយ គច្ឆតិ

តញ្ចស្ស អនុគំ ហោតិ

ឆាយាវ អនុបាយិនី

[៣៤០] ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះហើយ ។ បេ ។

បើបុគ្គល ដឹងខ្លួនថាជាទីស្រឡាញ់ហើយ កុំគប្បីប្រកបខ្លួននោះដោយបាបឡើយ ព្រោះថា ខ្លួននោះ មិនមែនរកបានដោយងាយទេ បុគ្គលអ្នកធ្វើអំពើអាក្រក់ មិនមែនរកសេចក្តីសុខបាន ដោយងាយទេ បុគ្គលដែលសេចក្តីស្លាប់គ្របសង្កត់ លះបង់ភពជារបស់នៃមនុស្សទៅហើយ បុគ្គលនោះ មានអ្វីជារបស់ខ្លួន បុគ្គលនោះ កាន់យកអ្វីទៅ អ្វីទៅតាមបុគ្គលនោះបាន ដូចជាស្រមោល អន្ទោលតាមរូប ធម្មជាតទាំងពីរ គឺបុណ្យនិងបាប រមែងទៅតាមបុគ្គលនោះ សត្វធ្វើអំពើណា ទុកក្នុងលោកនេះ បុគ្គលនោះ មានអំពើនោះជារបស់ខ្លួន បុគ្គលនោះ កាន់យកអំពើនោះទៅ អំពើនោះទៅតាមបុគ្គលនោះ ដូចជាស្រមោល អន្ទោលតាមរូប

តស្មា ករេយ្យ កល្យាណំ

និចយំ សម្បរាយិកំ

បុញ្ញានិ បរលោកស្មឹ

បតិដ្ឋា ហោន្តិ បាណិនន្តិ ។

## បញ្ចមំ អត្តរក្ខិតសុត្តំ

[៣៤១] ឯកមន្តំ និសិន្នោ ខោ រាជា បសេន-និកោសលោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កេសំ នុ ខោ រក្ខិតោ អត្តា កេសំ នុ ខោ អរក្ខិតោ អត្តាតិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ យេ ច ខោ កេចិ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេសំ អរក្ខិ-តោ អត្តា កិញ្ចាបិ តេ ហត្ថិកាយោ វា រក្ខេយ្យ អស្សកាយោ វា រក្ខេយ្យ រថកាយោ វា រក្ខេយ្យ

ព្រោះហេតុនោះ បុគ្គល គប្បីធ្វើនូវកុសលដែលប្រព្រឹត្តទៅក្នុងបរលោកឲ្យចម្រើនឡើង (ព្រោះ) បុណ្យទាំងឡាយរមែងជាទីពឹងរបស់ពួកសត្វ ក្នុងបរលោក ។

# អត្តរក្ខិតសូត្រ ទី ៥

[៣៤១] ព្រះបាទបសេនទិកោសល ទ្រង់គង់ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ សម្ងំនៅតែម្នាក់ឯងក្នុងទីឯណោះ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើង យ៉ាងនេះថា ខ្លួនរបស់បុគ្គលដូចម្តេចហ្ន៎ ដែលឈ្មោះថារក្សាហើយ ខ្លួនរបស់បុគ្គលដូចម្តេចហ្ន៎ ដែលឈ្មោះថាមិនរក្សាហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីយល់ឃើញដូច្នេះថា បុគ្គលណាមួយ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត បុគ្គលទាំងនោះឈ្មោះថាមិនរក្សាខ្លួនទេ បុគ្គលនោះ ទុកជាមានពលដំរីរក្សា មានពលសេះរក្សា មានពលរថរក្សា

បត្តិកាយោ វា រក្ខេយ្យ អថខោ តេសំ អរក្ខិតោ អត្តា តំ កិស្ស ហេតុ ពាហិរា ហេសា រក្ខា នេសា រក្ខា អជ្ឈត្តិកា តស្មា តេសំ អរក្ខិតោ អត្តាតិ យេ ច ខោ កេចិ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ តេសំ រក្ខិតោ អត្តា កិញ្ចាបិ តេ នេវ ហត្ថិកាយោ រក្ខេយ្យ ន អស្សកាយោ រក្ខេយ្យ ន រថកាយោ រក្ខេយ្យ ន បត្តិកាយោ រក្ខេយ្យ អថខោ តេសំ រក្ខិតោ អត្តា តំ កិស្ស ហេតុ អជ្ឈត្តិកា ហេសា រក្ខា នេសា រក្ខា ពាហិរា តស្មា តេសំ រក្ខិតោ អត្តាតិ ។

[៣៤២] ឯវមេតំ មហារាជ ឯវមេតំ មហារាជ យេ ហិ កេចិ មហារាជ កាយេន ទុច្ចរិតំ ចរន្តិ ។ បេ ។ តេសំ អរក្ខិតោ អត្តាតិ តំ កិស្ស ហេតុ ពាហិរា ហេសា មហារាជ រក្ខា

ឬមានពលថ្មើរជើងរក្សាក៏ដោយ តែថាបុគ្គលនោះ ឈ្មោះថាមិនរក្សាខ្លួនដោយពិត សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះថា ការរក្សានេះជាខាងក្រៅ ការរក្សានេះមិនមែនជាការរក្សាខាងក្នុងទេ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថាមិនរក្សាខ្លួនទេ លុះតែបុគ្គលណាមួយ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះ ទើបឈ្មោះថារក្សាខ្លួន បុគ្គលនោះ ទុកជាមិនមានពលដំរីរក្សា មិនមានពលសេះរក្សា មិនមានពលរថរក្សា មិនមានពលថ្មើរជើងរក្សាក៏ដោយ គង់តែបុគ្គលទាំងនោះ ឈ្មោះថារក្សាខ្លួនដោយពិត សេចក្តីនេះ ព្រោះហេតុដូចម្តេច ព្រោះថា ការរក្សានេះជាខាងក្នុង ការរក្សានេះមិនមែនជាការរក្សាខាងក្រៅទេ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថារក្សាខ្លួន ។

[៣៤២] ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ មែនហើយ បុគ្គលណាមួយ ប្រព្រឹត្តទុច្ចរិតដោយកាយ ។ បេ ។ ខ្លួនរបស់បុគ្គលទាំងនោះ ឈ្មោះថាមិនរក្សាទេ សេចក្តីនោះ ព្រោះហេតុដូចម្តេច បពិត្រមហារាជ ព្រោះថា ការរក្សានេះជាខាងក្រៅ

នេសា រក្ខា អជ្ឈត្តិកា តស្មា តេសំ អរក្ខិតោ អត្តាតិ យេ ហិ កេចិ មហារាជ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ តេសំ រក្ខិតោ អត្តា កិញ្ចាបិ តេ នេវ ហត្ថិកាយោ រក្ខេយ្យ ន អស្សកាយោ រក្ខេយ្យ ន រថកាយោ រក្ខេយ្យ ន បត្តិកាយោ រក្ខេយ្យ អថខោ តេសំ រក្ខិតោ អត្តា តំ កិស្ស ហេតុ អជ្ឈត្តិកា ហេសា មហារាជ រក្ខា នេសា រក្ខា ពាហិរា តស្មា តេសំ រក្ខិតោ អត្តាតិ ។

[៣៤៣] ឥទមវោច ។ បេ ។

កាយេន សំវរោ សាធុ
សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ
សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ លជ្ជី
រក្ខិតោតិ បវុច្ចតីតិ ។

ការរក្សានេះមិនមែនជាការរក្សាខាងក្នុងទេ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា មិនរក្សាខ្លួនទេ បពិត្រមហារាជ លុះតែបុគ្គលណាមួយ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលទាំងនោះ ទើបឈ្មោះថារក្សាខ្លួន ទុកជាមិនមានពលដំរីរក្សា មិនមានពលសេះរក្សា មិនមានពលរថរក្សា មិនមានពលថ្មើរជើងរក្សាក៏ដោយ គង់តែបុគ្គលទាំងនោះ ឈ្មោះថារក្សាខ្លួនដោយពិត សេចក្តីនោះ ព្រោះហេតុដូចម្តេច បពិត្រមហារាជ ព្រោះថា ការរក្សានេះជាខាងក្នុង ការរក្សានេះមិនមែនជាការរក្សាខាងក្រៅទេ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថារក្សាខ្លួន ។

[៣៤៣] ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះហើយ ។ បេ ។

សេចក្តីសង្រួមដោយកាយ ជាការប្រពៃ សេចក្តីសង្រួម
ដោយវាចា ជាការប្រពៃ សេចក្តីសង្រួមដោយចិត្ត ជា
ការប្រពៃ សេចក្តីសង្រួមក្នុងទ្វារទាំងអស់ ជាការប្រពៃ
បុគ្គលមានសេចក្តីខ្មាស បានសង្រួម ក្នុងទ្វារទាំងអស់
បណ្ឌិតហៅថា រក្សាខ្លួន ។

# ឆដ្ឋំ អប្បកសុត្តំ

[៣៤៤] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អប្បកា តេ សត្តា លោកស្មឹ យេ ឧឡារេ ឧឡារេ ភោគេ លភិត្វា ន ចេវ មជ្ជន្តិ ន ច បមជ្ជន្តិ ន ច កាមេសុ គេធំ អាបជ្ជន្តិ ន ច សត្តេសុ វិប្បដិបជ្ជន្តិ អថខោ ឯតេវ ពហុតរា សត្តា លោកស្មឹ យេ ច ឧឡារេ ឧឡារេ ភោគេ លភិត្វា មជ្ជន្តិ ចេវ បមជ្ជន្តិ ច កាមេសុ ច គេធំ អាបជ្ជន្តិ សត្តេសុ ច វិប្បដិបជ្ជន្តីតិ ។

# អប្បកសូត្រ ទី ៦

[៣៤៤] ជិតក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ សម្ងំនៅតែម្នាក់ឯង ក្នុងទីឯណោះ មានសេចក្តីត្រិះរិះក្នុងចិត្ត កើតឡើងយ៉ាងនេះថា សត្វទាំងឡាយឯណា បាននូវភោគៈដ៏ថ្លៃថ្លាលើសលុបហើយ មិនស្រវឹង (ដោយមានះ)ផង មិនប្រមាទផង មិនដល់នូវសេចក្តីប្រាថ្នាក្នុងកាមផង មិនប្រតិបត្តិខុសក្នុងសត្វទាំងឡាយផង សត្វទាំងនោះ មានចំនួនតិចក្នុងលោក មួយទៀត សត្វទាំងឡាយណា បាននូវភោគៈដ៏ថ្លៃថ្លាលើសលុបហើយ តែងស្រវឹងផង ប្រមាទផង ដល់នូវសេចក្តីប្រាថ្នាក្នុងកាមផង ប្រតិបត្តិខុសក្នុងសត្វទាំងឡាយផង សត្វទាំងនុ៎ះ មានចំនួនច្រើនក្នុងលោក ដោយពិត ។

[៣៤៥] ឯវមេតំ មហារាជ ឯវមេតំ មហារាជ អប្បកា តេ មហារាជ សត្តា លោកស្មឹ យេ ឧឡារេ ឧឡារេ ភោគេ លភិត្វា ន ចេវ មជ្ជន្តិ ន ច បមជ្ជន្តិ ន ច កាមេសុ គេធំ អាបជ្ជន្តិ ន ច សត្តេសុ វិប្បដិ-បជ្ជន្តិ អថខោ ឯតេវ ពហុតរា សត្តា លោកស្មឹ យេ ឧឡារេ ឧឡារេ ភោគេ លភិត្វា មជ្ជន្តិ ចេវ ប-មជ្ជន្តិ ច កាមេសុ ច គេធំ អាបជ្ជន្តិ សត្តេសុ ច វិប្បដិបជ្ជន្តីតិ ។

[៣៤៦] ឥទមវោច ។ បេ ។

សារត្តា កាមភោគេសុ
គិទ្ធា កាមេសុ មុច្ឆិតា
អតិសារំ ន ពុជ្ឈន្តិ
មិគា[១] កូដំវ ឱឌ្ឌិតំ
បច្ឆាសំ កដុកំ ហោតិ
វិបាកោ ហិស្ស បាបកោតិ ។

---

១ មគាតិបិ បាឋោ ។

[៣៨៥] ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ សត្វទាំងឡាយណា បាននូវភោគៈដ៏ថ្លៃថ្លាលើសលុបហើយ មិនស្រវឹងផង មិនប្រមាទផង មិនដល់នូវសេចក្តីប្រាថ្នាក្នុងកាមផង មិនប្រតិបត្តិខុសក្នុងសត្វទាំងឡាយផង សត្វទាំងនោះ មានចំនួនតិច ក្នុងលោក សត្វទាំងឡាយណា បាននូវភោគៈដ៏ថ្លៃថ្លាលើសលុបហើយ តែងស្រវឹងផង ប្រមាទផង ដល់នូវសេចក្តីប្រាថ្នាក្នុងកាមផង ប្រតិបត្តិខុសក្នុងសត្វទាំងឡាយផង សត្វទាំងនុ៎ះ មានចំនួនច្រើន ក្នុងលោកដោយពិត ។

[៣៨៦] ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះហើយ ។ បេ ។

ពួកសត្វ មានសេចក្តីត្រេកអរខ្លាំង ក្នុងកាមនិងភោគៈទាំងឡាយ ប្រាថ្នាជ្រុលជ្រប់ក្នុងកាមទាំងឡាយ មិនដឹងនូវទោសដែលប្រព្រឹត្តល្មើស ដូចជាពួកម្រឹគ មិនដឹងនូវអន្ទាក់ដែលគេដាក់ ពួកសត្វនោះរមែងមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ព្រោះថា ផលនៃកម្មនោះ ជាផលលាមក ។

# សត្តមំ អត្ថករណសុត្តំ

[៣៤៧] ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ-កោសលោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ អត្ថករ-ណេ[១] និសិន្នោ ខោ បស្សាមិ ខត្តិយមហាសាលេបិ ព្រាហ្មណមហាសាលេបិ គហបតិមហាសាលេបិ អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូ-បករណេ បហូតធនធញ្ញេ កាមហេតុ កាមនិទានំ កាមាធិករណំ សម្បជានមុសា ភាសន្តេ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អលំទានិ មេ អត្ថករណេន ភទ្រ-មុខោទានិ អត្ថករណេន បញ្ញាយិស្សតីតិ ។

[៣៤៨] ឯវមេតំ មហារាជ ឯវមេតំ មហារាជ[២] យេបិ តេ មហារាជ ខត្តិយមហាសាលា ព្រាហ្មណ-មហាសាលា គហបតិមហាសាលា អឌ្ឍា មហទ្ធនា មហាភោគា បហូតជាតរូបរជតា បហូតវិត្តូបករណា

---

១ ឱ. អ. ឯវំ ។ ម. អដ្ដករណោ ។ ២ ឱ. ឥមេ ន ទិស្សន្តិ ។

# អត្ថករណសូត្រ ទី ៧

[៣៤៧] លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ អង្គុយក្នុងរោងសម្រាប់កាត់សេចក្តីក្នុងទីឯណោះ បានឃើញពួកខត្តិយមហាសាល ព្រាហ្មណមហាសាលនិងគហបតិមហាសាល អ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានទ្រព្យនិងស្រូវច្រើន ពោលនូវពាក្យកុហក ចំពោះហេតុដែលដឹងច្បាស់ ព្រោះកាមជាហេតុ ព្រោះកាមជាដំណើរ ព្រោះកាមជាអធិករណ៍ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ណ្ហើយ អាត្មាអញនឹងមានប្រយោជន៍អ្វី ដោយការកាត់សេចក្តីក្នុងកាលឥឡូវនេះ បុគ្គលមានមុខល្អ នឹងប្រាកដដោយការកាត់សេចក្តី ក្នុងកាលឥឡូវនេះ ។

[៣៤៨] ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ សេចក្តីនុ៎ះយ៉ាងនេះឯង បពិត្រមហារាជ ពួកជនណា គឺខត្តិយមហាសាល ព្រាហ្មណមហាសាលនិងគហបតិមហាសាល ដែលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន

បហូតជនជញ្ញា  កាមហេតុ  កាមនិទានំ  កាមាធិ-
ករណំ  សម្បជានមុសា  ភាសន្តិ  តេសំ  តំ  ភវិស្សតិ
ទីឃរត្តំ  អហិតាយ  ទុក្ខាយាតិ  ។

[៣៤៩]  ឥធមវោច  ។  បេ  ។

សារត្តា  កាមភោគេសុ
គិទ្ធា  កាមេសុ  មុច្ឆិតា
អតិសារំ  ន  ពុជ្ឈន្តិ
មច្ឆា  ខិប្បំវ  ឱឌ្ឌិតំ
បច្ឆាសំ  កដុកំ  ហោតិ
វិបាកោ  ហិស្ស  បាបកោតិ  ។

មានទ្រព្យនិងស្រូវច្រើន ពោលនូវពាក្យកុហក ចំពោះហេតុដែលដឹងច្បាស់ ព្រោះកាមជាហេតុ ព្រោះកាមជាដំណើរ ព្រោះកាមជាអធិករណ៍ អំពើនោះនឹងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាអង្វែង ដល់ពួកជនទាំងនោះ ។

[៣៤៩] ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះហើយ ។ បេ ។

ពួកសត្វ មានសេចក្តីត្រេកអរខ្លាំង ក្នុងកាមនិងភោគៈទាំង-
ឡាយ ប្រាថ្នាជ្រុលជ្រប់ ក្នុងកាមទាំងឡាយ មិនដឹងនូវ
ទោសដែលប្រព្រឹត្តល្មើស ដូចជាត្រីមិនស្គាល់លប ដែល
គេដាក់ហើយ ពួកសត្វនោះ រមែងមានសេចក្តីក្តៅក្រហាយ
ក្នុងកាលជាខាងក្រោយ ព្រោះថា ផលនៃកម្មនោះ ជាផល
លាមក ។

# អដ្ឋមំ មល្លិកាសុត្តំ

[៣៨០] សាវត្ថិយំ... តេន ខោ បន សមយេន រាជា បសេនទិកោសលោ មល្លិកាយ ទេវិយា សទ្ធឹ ឧបរិបាសាទវរគតោ ហោតិ ។ អថខោ រាជា បសេនទិកោសលោ មល្លិកំ ទេវឹ ឯតទវោច អត្ថិ នុ ខោ តេ មល្លិកេ កោ ចញ្ញោ អត្តនា បិយតរោតិ ។ នត្ថិ ខោ មេ មហារាជ កោ ចញ្ញោ អត្តនា បិយតរោ តុយ្ហំ បន មហារាជ អត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។ មយ្ហម្បិ ខោ មល្លិកេ នត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។

[៣៨១] អថខោ រាជា បសេនទិកោសលោ បាសាទា ឱរោហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

# មល្លិកាសូត្រ ទី ៨

[៣៥០] *ជិតក្រុងសាវត្ថី... សម័យនោះ ព្រះបាទបសេនទិកោសល គង់ក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើ ជាមួយនឹងព្រះនាងមល្លិកាទេវី ។ គ្រានោះ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលនឹងព្រះនាងមល្លិកាទេវី ដូច្នេះថា ម្នាលនាងមល្លិកា បុគ្គលដទៃណាដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួននាងទៅទៀត មានដែរឬ ។ បពិត្រមហារាជ បុគ្គលដទៃណា ដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនខ្ញុំម្ចាស់ មិនមានទេ បពិត្រមហារាជ ចុះបុគ្គលដទៃនីមួយដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនព្រះអង្គទៅទៀត មានដែរឬ ។ ម្នាលនាងមល្លិកា បុគ្គលដទៃនីមួយ ដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនយើងទៅទៀត មិនមានទេ ។*

[៣៥១] *លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ចុះអំពីប្រាសាទ ហើយស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។*

ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ មល្លិកាយ ទេវិយា សទ្ធឹ ឧបរិបាសាទវរគតោ មល្លិកំ ទេវឹ ឯតទវោចំ អត្ថិ នុ ខោ តេ មល្លិកេ កោ ចញ្ញោ អត្តនា បិ-យតរោតិ ឯវំ វុត្តេ ភន្តេ មល្លិកា ទេវី មំ ឯតទវោ-ច នត្ថិ ខោ មេ មហារាជ កោ ចញ្ញោ អត្តនា បិយតរោ តុយ្ហំ បន មហារាជ អត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ឯវំ វុត្តាហំ ភន្តេ មល្លិកំ ទេវឹ ឯតទវោចំ មយ្ហម្បិ ខោ មល្លិកេ នត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។

[៣៨២] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ គាថំ អភាសិ

លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើ ជាមួយនឹងនាងមល្លិកាទេវីក្នុងទីឯណោះ បានសួរនាងមល្លិកាទេវី ដូច្នេះថា ម្នាលនាងមល្លិកា បុគ្គលដទៃណាដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួននាងទៅទៀត មានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ នាងមល្លិកាទេវីក៏ពោលតបមកនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រមហារាជ បុគ្គលដទៃណាដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនខ្ញុំម្ចាស់ទៅទៀត មិនមានទេ បពិត្រមហារាជ ចុះបុគ្គលនីមួយ ដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនព្រះអង្គទៅទៀត មានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន កាលបើនាងមល្លិកាទេវី សួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គឆ្លើយតបនាងមល្លិកាទេវីដូច្នេះវិញថា ម្នាលនាងមល្លិកា បុគ្គលដទៃនីមួយ ដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនយើងទៅទៀត មិនមានទេ ។

[៣៥២] លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏ត្រាស់នូវគាថានេះ ក្នុងវេលានោះ ថា

សព្វា ទិសា អនុបរិគម្ម ចេតសា
នេវជ្ឈគា បិយតរមត្តនោ ក្វចិ
ឯវំ បិយោ បុថុ អត្តា បរេសំ
តស្មា ន ហឹសេ បរំ អត្តកាមោតិ ។

## នវមំ យញ្ញសុត្តំ

[៣៨៣] សាវត្ថិយំ... តេន ខោ បន សមយេន រញ្ញោ បសេនទិកោសលស្ស មហាយញ្ញោ បច្ចុបដ្ឋិ-តោ ហោតិ ។ បញ្ច ច ឧសភសតានិ បញ្ច ច វច្ឆតរសតានិ បញ្ច ច វច្ឆតរិសតានិ បញ្ច ច អជស-តានិ បញ្ច ច ឧរព្ភសតានិ ថូណូបនីតានិ ហោន្តិ យញ្ញត្ថាយ ។ យេបិស្ស តេ ហោន្តិ ទាសាតិ[១] វា បេស្សាតិ វា កម្មករាតិ វា តេបិ ទណ្ឌតជ្ជិតា ភយ-តជ្ជិតា អស្សុមុខា រុទមានា បរិកម្មានិ ករោន្តិ ។

[៣៨៤] អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹសុ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ

១ មរម្មបោត្ថកេ យេវ ទាសីតិ វាតិ ព្យទិស្សោ បាឋោ ទិស្សតិ ។

បុគ្គល មានចិត្តរំពឹងគិតសព្វទិស រមែងរកមិនឃើញនូវបុគ្គលជាទីស្រឡាញ់ជាងខ្លួនក្នុងទីណាមួយទេ ខ្លួនទើបជាទីស្រឡាញ់ច្រើនជាងបុគ្គលដទៃយ៉ាងនោះឯង ព្រោះហេតុនោះ បុគ្គល ដែលស្រឡាញ់ខ្លួន មិនគប្បីបៀតបៀនបុគ្គលដទៃឡើយ ។

# យញ្ញសូត្រ ទី ៩

[៣៥៣] ជិតក្រុងសាវត្ថី... សម័យនោះ ព្រះបាទបសេនទិកោសល តាំងផ្តើមធ្វើមហាយ័ញ្ញ (បូជាធំ) ។ ពួកគោឧសភ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ គេចងភ្ជាប់នឹងសសរយ័ញ្ញ ដើម្បីបូជា ។ ពួកជនណា ដែលជាខ្ញុំប្រុសក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការងារក្តី ជនទាំងនោះ ត្រូវអាជ្ញាគម្រាមហើយ ត្រូវភ័យគម្រាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ស្រែកយំធ្វើនូវបរិកម្មទាំងឡាយ (ការរំពឹងគិត) ។

[៣៥៤] គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់ពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រញ្ញោ បសេនទិកោសលស្ស មហាយញ្ញោ បច្ចុបដ្ឋិតោ ហោតិ បញ្ច ច ឧសភសតានិ បញ្ច ច វច្ឆតរសតានិ បញ្ច ច វច្ឆតរិសតានិ បញ្ច ច អជសតានិ បញ្ច ច ឧរព្ភសតានិ ថូណូបនីតានិ ហោន្តិ យញ្ញត្ថា-យ យេបិស្ស តេ ហោន្តិ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ ទណ្ឌតជ្ជិតា ភយតជ្ជិតា អស្សុមុខា រុទមានា បរិកម្មានិ ករោន្តីតិ ។

[៣៤៤] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

អស្សមេធំ បុរិសមេធំ

សម្មាបាសំ វាជបេយ្យំ

លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទបសេនទិកោសល តាំងផ្តើមធ្វើមហាយញ្ញក្នុងទីឯណោះ ពួកគោឧសភ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ គេចងភ្ជាប់នឹងសសរយញ្ញ ដើម្បីបូជា ពួកជនណា ដែលជាខ្ញុំប្រុសក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការងារក្តី ជនទាំងនោះ ត្រូវអាជ្ញាគម្រាមហើយ ត្រូវភ័យគម្រាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ ។

[៣៥៥] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបត្រាស់នូវគាថាទាំងនេះក្នុងវេលានោះថា

(មហាយញ្ញទាំងឡាយ) មានការរវល់ច្រើន គឺ អស្សមេធៈ[១] ១ បុរិសមេធៈ[២] ១ សម្មាបាសៈ[៣] ១ វាជបេយ្យៈ[៤] ១

---

១ អស្សមេធំ សម្លាប់សេះ ។ ២ បុរិសមេធំ សម្លាប់បុរស ។ ៣ សម្មាបាសំ ពួកជននាំគ្នាបោះកាំនឹមទៅឰដ៏អាកាសរាល់ ៗ ថ្ងៃ កាំនឹមនោះធ្លាក់ចុះត្រង់កន្លែងណា ក៏នាំគ្នាទៅសាងវេទិកា គឺទីសម្រាប់បូជាយញ្ញត្រង់កន្លែងនោះ ។ ៤ វាជបេយ្យំ ផឹកទឹកផ្អែមមានសប្បិ និងទឹកឃ្មុំជាដើម ។

២០៩

កោសលសំយុត្តស្ស ទហរវគ្គេ មហាយញ្ញា

និរគ្គឡំ (មហាយញ្ញា[១]) មហារម្ភា
ន តេ ហោន្តិ មហប្ផលា
អជេឡកា ច គាវោ ច
វិវិធា យត្ថ ហញ្ញរេ
ន តំ សម្មគ្គតា យញ្ញំ
ឧបយន្តិ មហេសិនោ
យេ ច យញ្ញា និរារម្ភា
យជន្តានុកុលំ សទា
អជេឡកា ច គាវោ ច
វិវិធា នេត្ថ ហញ្ញរេ
ឯតំ សម្មគ្គតា យញ្ញំ
ឧបយន្តិ មហេសិនោ
ឯតំ យជេថ មេធាវី
ឯសោ យញ្ញោ មហប្ផលោ
ឯតញ្ហិ យជមានស្ស
សេយ្យោ ហោតិ ន ចាបិយោ

១ ឱ. ម. អយំ ន ទិស្សតិ ។

កោសលសំយុត្ត ទហរវគ្គ មហាយ័ញ្ញ

និរគ្គឡ:[១] ១ យ័ញ្ញទាំងនោះ មិនមែនមានផលច្រើនទេ ពួកសត្វផ្សេង ៗ គឺពពែ ចៀម គោ ត្រូវគេសម្លាប់ក្នុងយ័ញ្ញណា ពួកបុគ្គលអ្នកប្រតិបត្តិល្អ អ្នកស្វែងរកគុណដ៏ធំ រមែងមិនប្រកបនូវយ័ញ្ញនោះឡើយ មួយទៀត ពួកយ័ញ្ញណា មិនមានកិច្ចកង្វល់ ជនទាំងឡាយ តែងបូជាយ័ញ្ញទាំងនោះតាមលំដាប់ត្រកូល សព្វ ៗ កាល ពួកសត្វផ្សេង ៗ គឺពពែ ចៀម គោ បុគ្គលមិនបានសម្លាប់ក្នុងយ័ញ្ញនុ៎ះទេ ពួកបុគ្គលអ្នកប្រតិបត្តិល្អ អ្នកស្វែងរកគុណដ៏ធំ តែងប្រកបនូវយ័ញ្ញនុ៎ះ អ្នកប្រាជ្ញគប្បីបូជានូវយ័ញ្ញនុ៎ះ យ័ញ្ញនុ៎ះមានផលច្រើន ព្រោះថា កាលបើបុគ្គលបូជានូវយ័ញ្ញនុ៎ះហើយ គុណដ៏ប្រសើរ រមែងមាន ឯសេចក្ដីអាក្រក់មិនមានឡើយ

---

១ និរគ្គឡំ មិនមានទ្វារបើកបិទ ។

យញ្ញោ ច វិបុលោ ហោតិ
បសីទន្តិ ច ទេវតាតិ ។

# ទសមំ ពន្ធនសុត្តំ

[៣៨៦] តេន ខោ បន សមយេន រញ្ញោ បសេនទិកោសលេន មហាជនកាយោ ពន្ធាបិតោ ហោតិ ។ អប្បេកច្ចេ រជ្ជូហិ អប្បេកច្ចេ អន្ទូហិ[១] អប្បេកច្ចេ សង្ខលិកាហិ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បាវិសឹសុ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

១ ឱ. ម. អន្ទូហិ ។

យញ្ញ ជាសភាវៈមានផលដ៏បរិបូណ៌ផង ទេវតាទាំងឡាយ រមែងជ្រះថ្លាផង ។

# ពន្ធនសូត្រ ទី ១០

[៣៨៦] សម័យនោះ ព្រះបាទបសេនទិកោសល ទ្រង់បង្គាប់រាជបុរសឲ្យចងពួកមហាជន ។ ជនពួកខ្លះគេចងដោយខ្សែ ជនពួកខ្លះគេចងដោយខ្នោះ ជនពួកខ្លះគេចងដោយច្រវាក់ ។ គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងឡាយនោះ អង្គុយក្នុងទីសមគួរហើយ

ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រញ្ញា បសេនទិកោ-សលេន មហាជនកាយោ ពន្ធាបិតោ ហោតិ[១] អប្បេកច្ចេ រជ្ជូហិ អប្បេកច្ចេ អន្ទូហិ អប្បេកច្ចេ សង្ខលិកាហីតិ ។

[៣៤៧] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច[២]
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតម្បិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយាតិ ។

ទហរវគ្គោ បឋមោ ។

១ ឱ. ម. ហោតីតិ ន ទិស្សតិ ។ ២ ពព្វជញ្ចាតិ វា បាឋោ ។

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងសាវត្ថីឯណោះ ព្រះបាទបសេនទិកោសល បង្គាប់រាជបុរសឲ្យចងពួកមហាជន ជនពួកខ្លះគេចងដោយខ្សែ ជនពួកខ្លះគេចងដោយខ្នោះ ជនពួកខ្លះគេចងដោយច្រវាក់ ។

[៣៩៧] លំដាប់នោះ ព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្តីនេះហើយ ទ្រង់ត្រាស់នូវគាថាទាំងនេះក្នុងវេលានោះថា

ចំណងណា ធ្វើដោយដែកក្តី កើតដោយឈើក្តី កើតដោយស្មៅដំណេកទន្សាយក្តី អ្នកប្រាជ្ញទាំងឡាយ មិនបានពោលនូវចំណងនោះថាមាំទេ សេចក្តីអាឡោះអាល័យណា ប្រកបដោយសេចក្តីត្រេកដ៏ក្រៃលែង ក្នុងកែវមណីនិងកុណ្ឌលផង ក្នុងកូននិងប្រពន្ធផង អ្នកប្រាជ្ញទាំងឡាយ ពោលនូវចំណងនុ៎ះថាជាចំណងមាំ ជាគ្រឿងទាញសត្វឲ្យចុះក្នុងអបាយ ជាចំណងធូរ ប៉ុន្តែបុគ្គលស្រាយបានដោយក្រ អ្នកប្រាជ្ញទាំង-ឡាយ រមែងកាត់នូវចំណងនេះហើយ វៀរចេញស្រឡះ ជាអ្នកលះបង់នូវកាមសុខ មិនមានអាឡោះអាល័យ ។

ចប់ ទហរវគ្គ ទី ១ ។

# តស្សុទ្ទានំ

ឱហាយោ បុរិសោ រាជា

បិយំ អត្តានរក្ខិតា

អប្បកា អត្ថករណា

មល្លិកា យញ្ញពន្ធនន្តិ ។

# ឧទ្ទាននៃទហរវគ្គនោះ គឺ

*ទហរសូត្រ ១ បុរិសសូត្រ ១ រាជសូត្រ ១ បិយសូត្រ ១ អត្តានរក្ខិតសូត្រ ១ អប្បកសូត្រ ១ អត្ថករណសូត្រ ១ មល្លិកាសូត្រ ១ យញ្ញសូត្រ ១ ពន្ធនសូត្រ ១ ។*

# ទុតិយោ ជដិលវគ្គោ

## បឋមំ ជដិលសុត្តំ

[៣៤៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ពហិទ្វារកោដ្ឋកេ និសិន្នោ ហោតិ ។ អថខោ រាជា បសេនទិកោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៣៤៩] តេន ខោ បន សមយេន សត្ត ច ជដិលា សត្ត ច និគណ្ឋា សត្ត ច អចេលា សត្ត ច ឯកសាដកា សត្ត ច បរិព្វាជកា បរុឡ្ហកច្ឆនខលោមា ខារិវិវិធមាទាយ[១] ភគវតោ អវិទូរេ អតិក្កមន្តិ ។ អថខោ រាជា បសេនទិកោសលោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជានុមណ្ឌលំ បឋវិយំ និហន្តោ[២]

១ ឱ. ខារិវិធំ ។ ២ ឱ. និហន្ត្វា ។

# ជដិលវគ្គ ទី ២

## ជដិលសូត្រ ទី ១

[៣៥៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើមិគារមាតុប្រាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយទ្រង់គង់ត្រង់ក្លោងទ្វារខាងក្រៅ ។ គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយ ទ្រង់គង់នៅក្នុងទីសមគួរ ។

[៣៥៩] ក៏សម័យនោះឯង ពួកជដិល ៧ នាក់ ពួកនិគ្រន្ថ ៧ នាក់ ពួកអចេល ៧ នាក់ ពួកឯកសាដកបុគ្គល ៧ នាក់ ពួកបរិព្វាជក ៧ នាក់ មានរោមក្លៀក មានក្រចក និងរោមឯទៀតដុះវែង ៗ នាំគ្នារែកអម្រែកផ្សេង ៗ ដើរជិតព្រះមានព្រះភាគហើយហួសទៅ ។ លំដាប់នោះឯង ព្រះបាទបសេនទិកោសល ទ្រង់ក្រោកអំពីអាសនៈ ធ្វើនូវឧត្តរាសង្គតៀងព្រះអង្សាម្ខាង លុតព្រះជានុមណ្ឌលខាងស្តាំលើផែនដី

យេន តេ សត្ត ច ជដិលា សត្ត ច និគ្គន្ថា សត្ត ច អចេលា សត្ត ច ឯកសាដកា សត្ត ច បរិព្វាជកា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ នាមំ សាវេសិ រាជាហំ ភន្តេ បសេនទិ កោសលោ... រាជាហំ ភន្តេ បសេនទិកោសលោតិ ។ អថខោ រាជា បសេនទិកោសលោ អចិរប្បក្កន្តេសុ តេសុ សត្តសុ ច ជដិលេសុ សត្តសុ ច និគ្គន្ថេសុ សត្តសុ ច អចេលេសុ សត្តសុ ច ឯកសាដកេសុ សត្តសុ ច បរិព្វាជកេសុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច យេ តេ[១] ភន្តេ លោកេ អរហន្តោ វា អរហន្តមគ្គំ វា សមាបន្នា ឯតេ តេសំ អញ្ញតរោតិ ។

---
១ ម. ច ។

ប្រណាម្យអញ្ជលីចំពោះជដិល ៧ នាក់ផង និគ្រន្ថ ៧ នាក់ផង អចេល ៧ នាក់ផង ឯកសាដកបុគ្គល ៧ នាក់ផង បរិព្វាជក ៧ នាក់ផង ទ្រង់ប្រកាសព្រះនាមអស់វារៈបីដងផង បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំជាព្រះរាជាបសេនទិកោសល... បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំជាព្រះរាជាបសេនទិកោសល ។ កាលដែលជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដកបុគ្គល ៧ នាក់ បរិព្វាជក ៧ នាក់ទាំងនោះ ចៀសចេញទៅមិនយូរប៉ុន្មាន ទើបព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយទ្រង់គង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំងឡាយណា ជាព្រះអរហន្តក្តី ជាអ្នកដល់នូវព្រះអរហត្តមគ្គក្តី ក្នុងលោក បណ្តាបុគ្គលទាំងនោះ លោកអស់ទាំងនេះ ជាព្រះអរហន្តមួយដែរ ។

កោសលសំយុត្តស្ស ជដិលវគ្គេ ទុជ្ជាននភាវោ

[៣៦០] ទុជ្ជានំ ខោ ឯតំ មហារាជ តយា គិហិ- នា កាមភោគិនា បុត្តសម្ពាធសយនំ អជ្ឈាវសន្តេន កាសិកចន្ទនំ បច្ចនុភោន្តេន មាលាគន្ធវិលេបនំ ធារ- យន្តេន ជាតរូបរជតំ សាទិយន្តេន ឥមេ វា អរហន្តោ ឥមេ វា អរហត្តមគ្គំ សមាបន្នាតិ សំវាសេន ខោ មហារាជ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិករា[១] បញ្ញវតា នោ ទុប្បញ្ញេន សំវោហារេន ខោ មហារាជ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិ- ករោតា នោ អមនសិករា បញ្ញវតា នោ ទុប្បញ្ញេន

១ ឱ. អមនសិករោតា ។

កោសលសំយុត្ត ជដិលវគ្គ ភាពនៃកិរិយាដឹងបានដោយក្រ

[៣៦០] ព្រះអង្គត្រាស់តបថា បពិត្រមហារាជ ពាក្យថា បុគ្គលពួកនេះ ជាព្រះអរហន្តក្តី បុគ្គលពួកនេះ ដល់នូវអរហត្តមគ្គក្តី ដូច្នេះនេះ ព្រះអង្គជាគ្រហស្ថ នៅបរិភោគកាម អាស្រ័យព្រះក្រឡាបន្ទំ ចង្អៀតដោយព្រះរាជបុត្រ ប្រើប្រាស់នូវខ្លឹមចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងលាប ត្រេកអរនូវមាសនិងប្រាក់ ក៏ដឹងបានដោយក្រពេកណាស់ បពិត្រមហារាជ សីល បុគ្គលគប្បីដឹងបានដោយការនៅរួមគ្នា ក៏សីលនោះឯង បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីទេ បុគ្គលធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រមហារាជ សេចក្តីស្អាត បុគ្គលគប្បីដឹងបានដោយពាក្យសំដី ឯសេចក្តីស្អាតនោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ

អាបជាសុ ខោ មហារាជ ថាមោ វេជិតព្វោ សោ ច ខោ ឪយេន អន្ធុជា ន ឥតរំ មងសិកហេតា ជោ អមងសិការា បញ្ញវតា ជោ ទុប្បញ្ញេន សាកច្ឆាយ ខោ មហារាជ បញ្ញា វេជិតព្វា សា ច ខោ ឪយេន អន្ធុជា ន ឥតរំ មងសិកហេតា ជោ អមងសិការា បញ្ញវតា ជោ ទុប្បញ្ញេជាតិ ។

[៣៦១] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា ទុដ្ឋានំ ខោ ឯតំ មហារាជ តយា តិហិជា កាមភោគិជា ។ បេ ។ បញ្ញវតា ជោ ទុប្បញ្ញេជាតិ ឯតេ ភន្តេ មម បុរិសា ចារា ឱចរកា ជនបទំ ឱចរិត្វា អាគច្ឆន្តិ

បពិត្រមហារាជ កម្លាំងបញ្ញា បុគ្គលគប្បីដឹងក្នុងពេលដែលមានសេចក្តីអន្តរាយ ឯកម្លាំងនោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រមហារាជ បញ្ញា បុគ្គលគប្បីដឹងបានដោយការសាកសួរ ឯបញ្ញានោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបាន ដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ ។

[៣៦១] ព្រះបាទបសេនទិកោសល ទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះអង្គបានសំដែងសេចក្តីនេះថា បពិត្រមហារាជ ពាក្យនេះព្រះអង្គជាគ្រហស្ថ នៅបរិភោគកាម ដឹងបានដោយកម្រ ។ បេ ។ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ពួកបុរសរបស់ខ្ញុំព្រះអង្គទាំងនេះ ជាអ្នកឈ្លបដើររករឿង បានដឹងរឿងអ្នកជនបទរួចត្រឡប់មកវិញ

តេហិ បឋមំ ឱចិណ្ណំ អហំ បច្ឆា ឱហយិស្សាមិ[១] ឥមានិ តេ ភន្តេ តំ រជោជល្លំ បវាហេត្វា សុនហា-តា សុវិលិត្តា កប្បិតកេសមស្សូ ឱទាតវត្ថវសនា[២] បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិ-ចារយន្តីតិ[៣] ។

[៣៦២] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

ន វណ្ណរូបេន នរោ សុជាតោ[៤]
ន វិស្សសេ ឥត្តរទស្សនេន
សុសញ្ញតានម្ហិ វិយញ្ជនេន
អសញ្ញតា លោកមិមំ ចរន្តិ
បដិរូបកោ មត្តិកកុណ្ឌលោវ[៥]
លោហឌ្ឍមាសោ ច សុវណ្ណឆន្នោ
ចរន្តិ លោកេ បរិវារឆន្នា
អន្តោ អសុទ្ធា ពហិ សោភមានាតិ ។

១ ឱ. ឱសាបយិស្សាមិ ។ ២ ឱ. ម. ឱទាតវត្ថា ។ ៣ ឱ. បរិចារយិស្សន្តីតិ ។ ម. បរិចារេស្សន្តីតិ ។ ៤ ឱ. ម. សុជានោ ។ ៥ ឱ. ម. វ. ។

កាលបើបុរសទាំងនោះ យករឿងបានមុនហើយ ទើបខ្ញុំព្រះអង្គពិនិត្យជាខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ បុរសទាំងនោះបានបន្សាត់បង់នូវធូលីនិងមន្ទិលនោះ ងូតដោយស្រួលបួល លាបដោយប្រេង ហើយកោរសក់និងពុកមាត់ ស្លៀកសំពត់មានពណ៌ស ឲ្យគេបម្រើផ្អែតស្កប់ស្កល់ ដោយកាមគុណទាំង ៥ ។

[៣៦២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវសេចក្តីនុ៎ះហើយ ទើបត្រាស់នូវគាថាទាំងឡាយនេះ ក្នុងវេលានោះថា

ជនមិនមែនមានជាតិល្អ ដោយសម្បុរនិងរូបទេ បុគ្គលមិនត្រូវស្និទ្ធស្នាលដោយការឃើញភ្លាមទេ ព្រោះថា ពួកជនមិនសង្រួមត្រាច់ទៅក្នុងលោកនេះបាន ដោយសារគណ្ឋបរិក្ខាររបស់ពួកជនដែលសង្រួមល្អ កុណ្ឌល ជាវិការនៃដី មានរូបប្រៀបដូចជាកុណ្ឌលមាសក្តី មាសកជាវិការៈនៃលោហៈស្រោបដោយមាសក្តី (យ៉ាងណា) ជនទាំងឡាយ មានបរិវារហែហម មិនស្អាតខាងក្នុង ស្អាតតែខាងក្រៅ តែងត្រាច់ទៅក្នុងលោកបាន (យ៉ាងនោះដែរ) ។

# ទុតិយំ បញ្ចរាជសុត្តំ

[៣៦៣] សាវត្ថិយំ វិហរតិ... តេន ខោ បន សមយេន បញ្ចន្នំ រាជូនំ បសេនទិប្បមុខានំ បញ្ចហិ កាមគុណេហិ សមប្បិតានំ សមង្គីភូតានំ បរិចារយមានានំ អយមន្តរា កថា ឧទបាទិ កឹ នុ ខោ កាមានំ អគ្គន្តិ ។ តត្រេកច្ចេ ឯវមាហំសុ រូបា កាមានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ សទ្ទា កាមានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ គន្ធា កាមានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ រសា កាមានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ផោដ្ឋព្វា កាមានំ អគ្គន្តិ ។ យតោ ខោ តេ រាជានោ នាសក្ខឹសុ អញ្ញមញ្ញំ សញ្ញាបេតុំ អថខោ រាជា បសេនទិកោសលោ តេ រាជានោ ឯតទវោច អាយាម មារិសា យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា

# បញ្ចរាជសូត្រ ទី ២

[៣៦៣] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក៏សម័យនោះឯង ព្រះរាជាទាំងឡាយ ៥ អង្គមានព្រះបាទបសេនទិជាប្រធាន កំពុងឲ្យគេបម្រើឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ ក៏កើតមានអន្តរាកថា ដូច្នេះថា បណ្តាកាមទាំងឡាយ អ្វីហ្ន៎ប្រសើរជាងគេ ។ បណ្តាព្រះរាជាទាំងនោះ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ រូបប្រសើរជាងគេ ។ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ សំឡេងប្រសើរជាងគេ ។ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ ក្លិនប្រសើរជាងគេ ។ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ រសប្រសើរជាងគេ ។ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ ផស្សប្រសើរជាងគេ ។ ព្រះរាជាទាំងនោះ មិនអាចញ៉ាំងគ្នានិងគ្នាឲ្យយល់បានក្នុងកាលណាឡើយ ទើបព្រះបាទបសេនទិកោសលទ្រង់ត្រាស់ពាក្យនេះ នឹងព្រះរាជាទាំងនោះថា ម្នាលគ្នាយើងទាំងឡាយមក យើងនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

ភគវន្តំ ឯតមត្ថំ បដិបុច្ឆិស្សាម យថា នោ ភគវា ព្យាករិស្សតិ តថា នំ ធារេយ្យាមាតិ[១] ។ ឯវំ មារិសា-តិ ខោ តេ រាជានោ រញ្ញោ បសេនទិកោសលស្ស បច្ចស្សោសុំ ។

[៣៦៤] អថខោ តេ បញ្ច រាជានោ បសេន-ទិប្បមុខា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច ឥធ ភន្តេ អម្ហាកំ បញ្ចន្នំ រាជូនំ បញ្ចហិ កាមគុណេហិ សមប្បិតានំ សមង្គីភូតានំ បរិចារយមា-នានំ អយមន្តរា កថា ឧទបាទិ កឹ នុ ខោ កាមានំ អគ្គន្តិ ឯកេច្ចេ ឯវមាហំសុ រូបា កាមានំ អគ្គន្តិ ឯកេច្ចេ ឯវមាហំសុ សទ្ទា កាមានំ អគ្គន្តិ ឯកេច្ចេ

---
១ ម. ធារេស្សាមាតិ ។

យើងនឹងទូលសួរនូវសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ បើព្រះមានព្រះភាគ ទ្រង់ព្យាករចំពោះយើងទាំងឡាយយ៉ាងណា យើងទាំងឡាយនឹងចាំទុកនូវព្យាករណ៍នោះយ៉ាងនោះ ។ ព្រះរាជាទាំងនោះទទួលស្តាប់ (នូវព្រះបន្ទូល) នៃព្រះបាទបសេនទិកោសលថា ព្រះករុណាវិសេស ។

[៣៦៤] លំដាប់នោះឯង ព្រះរាជាទាំង ៥ អង្គមានព្រះបាទបសេនទិជាប្រធាននោះ ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយជាព្រះរាជាទាំង ៥ កំពុងឲ្យគេបម្រើឆ្អែតស្កប់ស្កល់ ដោយកាមគុណទាំង ៥ ក្នុងទីឯណោះ ក៏កើតមានអន្តរាកថា ដូច្នេះថា បណ្តាកាមទាំង-ឡាយ អ្វីហ្ន៎ ប្រសើរជាងគេ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ រូបប្រសើរជាងគេ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ សំឡេងប្រសើរជាងគេ ព្រះរាជាពួកខ្លះ

ឯវមាហំសុ គន្ធា កាមាន់ អត្ថន្តិ ឯកច្ចេ ឯវមាហំសុ រសា កាមាន់ អត្ថន្តិ ឯកច្ចេ ឯវមាហំសុ ផោដ្ឋព្វា កាមាន់ អត្ថន្តិ កឹ នុ ខោ ភន្តេ កាមាន់ អត្ថន្តិ ។

[៣៦៥] មនាបបរិយន្តំ ខ្វាហំ មហារាជ បញ្ចសុ កាមគុណេសុ អត្តន្តិ វទាមិ យេន[១] ច មហារាជ រូបា ឯកច្ចស្ស មនាបា ហោន្តិ តេ ច រូបា ឯកច្ចស្ស អមនាបា ហោន្តិ យេហិ ច សោ រូបេហិ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ សោ តេហិ រូបេហិ អញ្ញំ រូបំ ឧត្តរិតរំ វា បណីតតរំ វា ន បត្ថេតិ តេ តស្ស រូបា បរមា ហោន្តិ តេ តស្ស រូបា អនុត្តរា ហោន្តិ ។ យេ[២] ច មហារាជ សទ្ទា... យេ ច មហារាជ គន្ធា... យេ ច មហារាជ រសា... យេ ច មហារាជ ផោដ្ឋព្វា

១-២ ឱ. ម. តេ ។

ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ ក្លិនប្រសើរជាងគេ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ រសប្រសើរជាងគេ ព្រះរាជាពួកខ្លះ ពោលយ៉ាងនេះថា បណ្តាកាមទាំងឡាយ ផ្សព្វប្រសើរជាងគេ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាកាមទាំងឡាយ អ្វីហ្ន៎ ដែលប្រសើរជាងគេ ។

[៣៦៥] ព្រះអង្គត្រាស់ថា បពិត្រមហារាជ បណ្តាកាមគុណទាំង ៥ តថាគតពោលសំដៅត្រង់របស់ជាទីគាប់ចិត្តបំផុតថា ប្រសើរជាងគេ បពិត្រមហារាជ ព្រោះថា រូបទាំងឡាយណា ជាទីគាប់ចិត្តរបស់បុគ្គលខ្លះ រូបទាំងនោះ ទៅជាមិនគាប់ចិត្តរបស់បុគ្គលខ្លះក៏មាន បុគ្គលនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយរូបទាំងឡាយណា បុគ្គលនោះ ក៏មិនប្រាថ្នារូបឯទៀត ដែលលើសលុបឬឧត្តមជាងរូបទាំងនោះឡើយ រូបទាំងនោះ ជារូបក្រៃលែងរបស់បុគ្គលនោះ រូបទាំងនោះ ជារូបប្រសើរលើសរបស់បុគ្គលនោះ ។ បពិត្រមហារាជ សំឡេងទាំង-ឡាយណា... បពិត្រមហារាជ ក្លិនទាំងឡាយណា... បពិត្រមហា-រាជ រសទាំងឡាយណា... បពិត្រមហារាជ ផ្សព្វទាំងឡាយណា

ឯកច្ចស្ស មនាបា ហោន្តិ តេ ច ដោដ្ឋព្វា ឯកច្ចស្ស អមនាបា ហោន្តិ យេហិ ច សោ[១] ដោដ្ឋព្វេហិ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ សោ តេហិ ដោដ្ឋព្វេហិ អញ្ញំ ដោដ្ឋព្វំ ឧត្តរិតរំ វា បណីតតរំ វា ន បត្ថេតិ តេ តស្ស ដោដ្ឋព្វា បរមា ហោន្តិ តេ តស្ស ដោដ្ឋព្វា អនុត្តរា ហោន្តីតិ ។

[៣៦៦] តេន ខោ បន សមយេន ចន្ទនង្គលិកោ[២] ឧបាសកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ ចន្ទនង្គលិកោ ឧបាសកោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ ចន្ទនង្គលិកាតិ ភគវា អវោច ។ អថខោ ចន្ទនង្គលិកោ ឧបាសកោ ភគវន្តំ[៣] សម្មុខា តទនុរូបាយ គាថាយ អភិត្ថវិ

---

១ ឱ. យោ ។ ២ ឱ. ឯវំ ។ អដ្ឋកថាយម្បន ចន្ទនង្គលិយោតិ ទិស្សតិ ។ ៣ ភគវតោតិបិ បាឋោ ទិស្សតិ ។

ជាទីគាប់ចិត្តបុគ្គលខ្លះ ផ្សេងៗទាំងនោះ ទៅជាមិនជាទីគាប់ចិត្តបុគ្គលខ្លះក៏មាន បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយផ្សេងៗទាំងឡាយណា បុគ្គលនោះក៏មិនប្រាថ្នានូវផ្សេងៗឯទៀត សូម្បីលើសលុប ឬ ឧត្តមជាងផ្សេងៗទាំងនោះឡើយ ផ្សេងៗទាំងនោះ ជាផ្សេងៗក្រៃលែងរបស់បុគ្គលនោះ ផ្សេងៗទាំងនោះ ជាផ្សេងៗប្រសើរលើសរបស់បុគ្គលនោះ ។

[៣៦៦] ក្នុងសម័យនោះឯង ឧបាសកឈ្មោះចន្ទនង្គលិកៈ អង្គុយនៅក្នុងបរិស័ទនោះ ។ លំដាប់នោះ ចន្ទនង្គលិកឧបាសក ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមសំដែងហេតុមួយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងហេតុមួយ ។ ព្រះមានព្រះភាគ បានត្រាស់ថា ម្នាលចន្ទនង្គលិកៈ អ្នកចូរសំដែងហេតុនោះចុះ ។ លំដាប់នោះ ចន្ទនង្គលិកឧបាសក បានសរសើរព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រ ដោយគាថាដ៏សមគួរដល់សេចក្តីនោះ ថា

បទុមំ យថា កោកនទំ សុគន្ធំ
បាតោ សិយា ផុល្លមវីតគន្ធំ
អង្គីរសំ បស្ស វិរោចមានំ
តបន្តមាទិច្ចមិវន្តលិក្ខេតិ ។

[៣៦៧] អថខោ តេ បញ្ច រាជានោ ចន្ទនង្គលិកំ ឧបាសកំ បញ្ចហិ ឧត្តរាសង្គេហិ អច្ឆាទេសុំ ។ អថខោ ចន្ទនង្គលិកោ ឧបាសកោ តេហិ បញ្ចហិ ឧត្តរាសង្គេហិ ភគវន្តំ អច្ឆាទេសីតិ ។

## តតិយំ ទោណបាកសុត្តំ

[៣៦៨] សាវត្ថិយំ វិហរតិ... តេន ខោ បន សមយេន រាជា បសេនទិកោសលោ ទោណបាកសុទំ[១] ភុញ្ជតិ ។ អថខោ រាជា បសេនទិកោសលោ ភុត្តាវី មហស្សាសី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

---

១ ឱ. ទោណបាកំ សុទំ ។ ម. ទោណបាកកុរំ ។

ផ្កាឈូក (ក្រហមច្រាល) រីកក្នុងវេលាព្រឹក មានក្លិនក្រអូប មិនប្រាសចាកក្លិន យ៉ាងណា អ្នកចូរមើលនូវព្រះសម្មាសម្ពុទ្ធមានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿង ដូចព្រះអាទិត្យដែលរុងរឿងក្នុងអាកាស យ៉ាងនោះឯង ។

[៣៦៧] គ្រានោះឯង ព្រះរាជាទាំង ៥ អង្គនោះ ទ្រង់បានបំពាក់នូវចន្ទនង្គលិកឧបាសក ដោយសំពត់ឧត្តរាសង្គទាំង ៥ ។ លំដាប់នោះឯង ចន្ទនង្គលិកឧបាសក ថ្វាយសំពត់ឧត្តរាសង្គទាំង ៥ នោះដល់ព្រះមានព្រះភាគ ។

## ទោណបាកសូត្រ ទី ៣

[៣៦៨] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... ក៏ក្នុងសម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់សោយនូវព្រះស្ងោយដែលពួកពិសេសចំអិនដោយអង្ករមួយទោណៈ ។ លំដាប់នោះឯង ព្រះបាទបសេនទិកោសល ទ្រង់សោយរួចហើយ ទ្រង់ដកព្រះអស្សាសៈធំស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីសមគួរ ។

កោសលសំយុត្តស្ស ជដិលវគ្គេ ភោជនេ អមត្តញ្ញុតា

[៣៦៩] អថខោ ភគវា តំ រាជានំ បសេនទិ-
កោសលំ កុត្តាវឹ មហស្សាសឹ វិទិត្វា តាយំ វេលាយំ
ឥមំ គាថំ អភាសិ

មនុជស្ស សទា សតិមតោ
មត្តំ ជានតោ លទ្ធភោជនេ
តនុកស្ស[១] ភវន្តិ វេទនា
សណិកំ ជីរតិ អាយុ បាលយន្តិ ។

[៣៧០] តេន ខោ បន សមយេន សុទស្សនោ
មាណវោ រញ្ញោ បសេនទិកោសលស្ស ភិដ្ឋិតោ ឋិតោ
ហោតិ ។ អថខោ រាជា បសេនទិកោសលោ សុ-
ទស្សនំ មាណវំ អាមន្តេសិ ឯហិ ត្វំ តាត សុទស្ស-
ន ភគវតោ សន្តិកេ ឥមំ គាថំ បរិយាបុណិត្វា

១ ម. ឯវំ ។ ឱ. តនុ តស្ស ។

[៣៦៩] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា ព្រះបាទបសេនទិកោសលនោះ សោយរួចហើយ ទ្រង់ដកព្រះអស្សាសៈធំ ទើបត្រាស់នូវគាថានេះ ក្នុងវេលានោះថា

មនុស្ស មានស្មារតីសព្វកាល ដឹងប្រមាណក្នុងភោជនដែល

ខ្លួនបានហើយ រមែងមានវេទនាស្រាល អាហារនោះតែង

រក្សាអាយុ ជ្រួតជ្រាបបន្តិចម្តង ៗ ។

[៣៧០] ក៏សម័យនោះឯង មាណពឈ្មោះសុទស្សនៈ ឈរនៅក្រោយព្រះបិដ្ឋិនៃព្រះបាទបសេនទិកោសល ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ហៅសុទស្សនមាណព មកថា ម្នាលបាសុ-ទស្សនៈ អ្នកចូរមករៀននូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ

មម ភត្តាភិហារេ ភាស អហញ្ច តេ ទេវសិកំ កហាបណសតំ និច្ចភត្តំ[១] បវត្តយិស្សាមីតិ ។ បរមំ ភោតិ ខោ[២] សុទស្សនោ មាណវោ រញ្ញោ បសេនទិកោសលស្ស បដិស្សុណិត្វា ភគវតោ សន្តិកេ ឥមំ គាថំ បរិយាបុណិត្វា រញ្ញោ បសេនទិកោសលស្ស ភត្តាភិហារេ ភាសតិ

មនុជស្ស សទា សតិមតោ
មត្តំ ជានតោ លទ្ធភោជនេ
តនុកស្ស ភវន្តិ វេទនា
សណិកំ ជិរតិ អាយុ បាលយន្តិ ។

[៣៧១] អថខោ រាជា បសេនទិកោសលោ អនុបុព្វេន ទោណបាកបរមតាយ សណ្ឋាសិ ។ អថខោ រាជា បសេនទិកោសលោ អបរេន សមយេន សុសល្លិខិតគត្តោ បាណិនា គត្តានិ អនុមជ្ជន្តោ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ ឧភយេន វត មំ សោ ភគវា អត្ថេន អនុកម្បី ទិដ្ឋធម្មិកេន ចេវ អត្ថេន សម្បរាយិកេន ចាតិ ។

១ និច្ចភិក្ខន្តិបិ បាឋោ ។ ឱ. ម. ឯវំ ទេវាតិ ខោតិ ទិស្សតិ ។

ហើយសូត្រក្នុងកាលដែលនាំមកនូវភត្តដល់អញ អញនឹងឲ្យកហាបណៈមួយរយ ជានិច្ចភត្ត ដល់អ្នករាល់ថ្ងៃ ។ សុទស្សនមាណពទទួលព្រះរាជឱង្ការព្រះបាទបសេនទិកោសលថា សូមទ្រង់ព្រះមេត្តាប្រោស ប្រ-សើរណាស់ ក៏រៀននូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគហើយ សូត្រក្នុងកាលនាំភត្តមកថ្វាយព្រះបាទបសេនទិកោសលថា

មនុស្ស មានស្មារតីសព្វកាល ដឹងប្រមាណក្នុងភោជន
ដែលខ្លួនបានហើយ រមែងមានវេទនាស្រាល អាហារនោះ
តែងរក្សាអាយុ ជ្រួតជ្រាបបន្តិចម្តងៗ ។

[៣៧១] គ្រានោះឯង ព្រះបាទបសេនទិកោសល ទ្រង់កំណត់អង្ករមួយនាឡិតាមលំដាប់ ។ ក្នុងសម័យតមកទៀត ទើបព្រះបាទបសេនទិកោសល មានព្រះកាយផូរផង់ល្អ ទ្រង់យកព្រះហស្តស្ទាបព្រះអង្គហើយ បន្លឺនូវឧទាននេះក្នុងវេលានោះថា ឱហ្ន៎ ព្រះមានព្រះភាគនោះ ទ្រង់អនុគ្រោះយើងដោយប្រយោជន៍ ២ ប្រការគឺ ប្រយោជន៍បច្ចុប្បន្ន ១ ប្រយោជន៍បរលោក ១ ។

# ចតុត្ថំ បឋមសង្គាមវត្ថុសុត្តំ

[៣៧២] សាវត្ថិយំ វិហរតិ... អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ បសេនទិកោសលំ អព្ភុយ្យាសិ យេន កាសី ។ អស្សោសិ ខោ រាជា បសេនទិកោសលោ រាជា កិរ មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មមំ អព្ភុយ្យាតោ យេន កាសីតិ ។ អថខោ រាជា បសេនទិកោសលោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ បច្ចុយ្យាសិ យេន កាសី ។ អថខោ រាជា ច មាគធោ អជាតសត្តុ វេទេហិបុត្តោ រាជា ច បសេនទិកោសលោ សង្គាមេសុំ ។ តស្មឹ ខោ បន សង្គាមេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ រាជានំ បសេនទិកោសលំ បរាជេសិ ។ បរាជិតោ ច រាជា បសេនទិកោសលោ សកមេវ រាជធានឹ សាវត្ថឹ បច្ចុយ្យាសិ ។

# បឋមសង្គាមវត្ថុសូត្រ ទី ៤

[៣៧២] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី... គ្រានោះឯង ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់រៀបចតុរង្គសេនាលើកទៅច្បាំងនឹងព្រះបាទបសេនទិកោសល ឰដ៏ដែនកាសី ។ ព្រះបាទបសេនទិកោសល បានឮដំណឹងថា ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ រៀបចតុរង្គសេនាលើកមកច្បាំងនឹងព្រះអង្គ ឰដ៏ដែនកាសីហើយ ។ ទើបព្រះបាទបសេនទិ-កោសល ទ្រង់រៀបចតុរង្គសេនា តទល់គ្នានឹងព្រះបាទអជាតសត្តុវេទេ-ហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ឰដ៏ដែនកាសី ។ គ្រានោះឯង ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈ ក្នុងដែនមគធៈ និងព្រះបាទបសេនទិកោសលច្បាំងគ្នា ។ ក៏ក្នុងសង្គ្រាមនោះឯង ព្រះបាទអជាត-សត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់ផ្ចាញ់ព្រះបាទបសេន-ទិកោសលបាន ។ លុះព្រះបាទបសេនទិកោសលទ្រង់បរាជ័យហើយ ក៏ស្តេចចូលមកកាន់ក្រុងសាវត្ថី ជាព្រះរាជធានីរបស់ព្រះអង្គវិញ ។

[៣៧៣] អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បវិសឹសុ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌចាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ បសេនទិកោសលំ អព្ភុយ្យាសិ យេន កាសី អស្សោសិ ខោ ភន្តេ រាជា បសេនទិកោសលោ រាជា កិរ មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មមំ អព្ភុយ្យាតោ យេន កាសីតិ អថខោ ភន្តេ រាជា បសេនទិកោសលោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ បច្ចុយ្យាសិ យេន កាសី

[៣៧៣] គ្រានោះឯង ភិក្ខុច្រើនរូបស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងអម្បាលនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលានេះ ព្រះបាទអជាតសត្តុវេទេហិ-បុត្ត ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់រៀបចតុរង្គសេនាទៅច្បាំងនឹងព្រះបាទបសេនទិកោសល ឰដ៏ដែនកាសីឯណោះ បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះបាទបសេនទិកោសល បានឮដំណឹងថា ព្រះបាទអជាតសត្តុវេ-ទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់រៀបចតុរង្គសេនាមកច្បាំងនឹងព្រះអង្គ ឰដ៏ដែនកាសីហើយ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯងព្រះបាទបសេនទិកោសល ក៏ទ្រង់រៀបចតុរង្គសេនាទៅតទល់គ្នានឹងព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ឰដ៏ដែនកាសី

អថខោ ភន្តេ រាជា ច មាគធោ អជាតសត្តុ វេទេហិបុត្តោ រាជា ច បសេនទិកោសលោ សង្គាមេសុំ តស្មឹ ខោ បន ភន្តេ សង្គាមេ អជាតសត្តុ វេទេហិបុត្តោ រាជានំ បសេនទិកោសលំ បរាជេសិ បរាជិតោ ច ភន្តេ រាជា បសេនទិកោសលោ សកមេវ រាជធានឹ សាវត្ថឹ បច្ចុយ្យាសីតិ ។

[៣៧៤] រាជា ភិក្ខវេ មាគធោ អជាតសត្តុ វេទេហិបុត្តោ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ រាជា ច ខោ[១] បសេនទិកោសលោ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អជ្ជេវំ[២] ភិក្ខវេ រាជា បសេនទិកោសលោ ឥមំ រត្តឹ ទុក្ខំ សេស្សតិ បរាជិតោតិ ។

---

១ ឱ. ខោការោ ន ទិស្សតិ ។ ២ ម. ឯវំ ។ ឱ. អជ្ជតញ្ច ។

បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ និងព្រះបាទបសេនទិកោសល ក៏បានច្បាំងគ្នា បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងសង្រ្គាមនោះឯង ព្រះបាទអជាតសត្តុវេ-ទេហិបុត្ត ទ្រង់ផ្ចាញ់ព្រះបាទបសេនទិកោសលឲ្យចាញ់បាន បពិត្រព្រះអង្គដ៏ចម្រើន លុះព្រះបាទបសេនទិកោសលទ្រង់បរាជ័យហើយ ក៏ស្តេចចូលមកកាន់ក្រុងសាវត្ថី ជាព្រះរាជធានីរបស់ព្រះអង្គវិញ ។

[៣៧៤] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ មានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានព្រះទ័យឱនទៅរកសេចក្តីអាក្រក់ ក៏ឯ ព្រះបាទបសេនទិកោសល មានមិត្តល្អ មានសំឡាញ់ល្អ មានព្រះទ័យឱនទៅរកសេចក្តីល្អ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃនេះ ព្រះបាទបសេនទិកោ-សលទ្រង់បរាជ័យហើយផ្ទំជាទុក្ខក្នុងរាត្រីនេះ ដោយប្រការយ៉ាងនេះ ។

[៣៧៥] ឥធមវោច ។ បេ ។

ជយំ វេរំ បសវតិ
ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ
ហិត្វា ជយបរាជយន្តិ ។

## បញ្ចមំ ទុតិយសង្គាមវត្ថុសុត្តំ

[៣៧៦] អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ បសេនទិកោសលំ អព្ភុយ្យាសិ យេន កាសី ។ អស្សោសិ ខោ រាជា បសេនទិកោសលោ រាជា កិរ មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មមំ អព្ភុយ្យាតោ យេន កាសីតិ ។ អថខោ រាជា បសេនទិកោសលោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ បច្ចុយ្យាសិ យេន កាសី ។ អថខោ រាជា ច មាគធោ អជាតសត្តុ វេទេហិបុត្តោ

[៣៧៥] ព្រះមានព្រះភាគបានត្រាស់នូវភាសិតនេះ ។ បេ ។ បុគ្គលអ្នកឈ្នះ តែងប្រទះពៀរ បុគ្គលអ្នកចាញ់ តែងដេកកើតទុក្ខ បុគ្គលអ្នកស្ងប់រម្ងាប់ លះបង់នូវការឈ្នះនិងការចាញ់បានហើយ តែងដេកជាសុខ ។

# ទុតិយសង្គាមវត្ថុសូត្រ ទី ៥

[៣៧៦] គ្រានោះឯង ព្រះបាទអជាតសត្តុ វេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់រៀបចតុរង្គសេនាទៅច្បាំងនឹងព្រះបាទបសេនទិកោសល ឰដ៏ដែនកាសី ។ ព្រះបាទបសេនទិកោសល បានឮដំណឹងថា ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ រៀបចតុរង្គសេនា លើកមកច្បាំងនឹងព្រះអង្គ ឰដ៏ដែនកាសីហើយ ។ ទើបព្រះបាទបសេនទិកោសល ស្ដេចរៀបចតុរង្គសេនា ទៅតទល់គ្នានឹងព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ឰដ៏ដែនកាសី ។ គ្រានោះឯង ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ

រាជា ច បសេនទិកោសលោ សង្គាមេសុំ ។ តស្មឹ ខោ បន សង្គាមេ រាជា បសេនទិកោសលោ រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ បរាជេសិ ជីវគ្គាហញ្ច នំ អគ្គហេសិ ។

[៣៧៧] អថខោ រញ្ញោ បសេនទិកោសលស្ស ឯតទហោសិ កិញ្ចាបិ ខោ ម្យាយំ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ អទុព្ភន្តស្ស ទុព្ភតិ អថ ច បន មេ ភាគិនេយ្យោ ហោតិ យន្នូនាហំ រញ្ញោ មាគធស្ស អជាតសត្តុនោ វេទេហិបុត្តស្ស សព្វំ ហត្ថិ-កាយំ បរិយាទិយិត្វា សព្វំ អស្សកាយំ បរិយាទិ-យិត្វា សព្វំ រថកាយំ បរិយាទិយិត្វា សព្វំ បត្តិកាយំ បរិយាទិយិត្វា ជីវន្តមេវ នំ ឱស្សជ្ជេយ្យន្តិ ។ អថខោ រាជា បសេនទិកោសលោ រញ្ញោ មាគធស្ស អជាត-សត្តុនោ វេទេហិបុត្តស្ស សព្វំ ហត្ថិកាយំ បរិយា-ទិយិត្វា សព្វំ អស្សកាយំ បរិយាទិយិត្វា សព្វំ រថ-កាយំ បរិយាទិយិត្វា សព្វំ បត្តិកាយំ បរិយាទិយិត្វា ជីវន្តមេវ នំ ឱស្សជ្ជិ ។

និងព្រះបាទបសេនទិកោសលក៏ច្បាំងគ្នា ។ ឯក្នុងសង្គ្រាមនោះឯង ព្រះបាទបសេនទិកោសល ញុំាងព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈឲ្យចាញ់ ហើយចាប់យកព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈនោះបានទាំងរស់ ។

[៣៧៧] គ្រានោះឯង ព្រះបាទបសេនទិកោសល មានសេចក្តីត្រិះរិះថា ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈនេះ ប្រទូស្តនឹងអាត្មាអញ ដែលជាអ្នកមិនប្រទូស្ត ពិតមែនហើយ តែថាស្តេចនោះ ត្រូវជាក្មួយរបស់អាត្មាអញ បើដូច្នោះ មានតែអាត្មាអញរឹបយកពលដំរីទាំងអស់ រឹបយកពលសេះទាំងអស់ រឹបយកពលរថទាំងអស់ រឹបយកពលថ្មើរជើងទាំងអស់ របស់ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ហើយលែងព្រះបាទអជាតសត្តុនោះ ឲ្យរួចទៅទាំងរស់វិញ ។ លំដាប់នោះឯង ព្រះបាទបសេនទិកោសល បានរឹបយកពលដំរីទាំងអស់ រឹបយកពលសេះទាំងអស់ រឹបយកពលរថទាំងអស់ រឹបយកពលថ្មើរជើងទាំងអស់ របស់ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ហើយលែងព្រះបាទអជាតសត្តុនោះឲ្យរួចទៅទាំងរស់វិញ ។

[៣៧៨] អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បវិសឹសុ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ បសេនទិកោសលំ អព្ភុយ្យាសិ យេន កាសី អស្សោសិ ខោ ភន្តេ រាជា បសេនទិកោសលោ រាជា កិរ មាគធោ អជាតសត្តុ វេទេហិបុត្តោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មមំ អព្ភុយ្យាតោ យេន កាសីតិ អថខោ ភន្តេ រាជា បសេនទិកោសលោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ បច្ចុយ្យាសិ យេន កាសី អថខោ ភន្តេ រាជា ច មាគធោ អជាតសត្តុ វេទេហិបុត្តោ រាជា ច បសេនទិកោសលោ សង្គាមេសុំ

[៣៧៨] គ្រានោះឯង ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងពេលក្រោយកត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈ ក្នុងដែនមគធៈ រៀបចតុរង្គសេនា លើកទៅច្បាំងនឹងព្រះបាទបសេនទិកោសល ឰដ៏ដែនកាសីឯណោះ បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះបាទបសេនទិកោសលបានឮដំណឹងថា ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែលមគធៈ រៀបចតុរង្គសេនាលើកមកច្បាំងនឹងព្រះអង្គ ឰដ៏ដែនកាសីហើយ បពិត្រព្រះអង្គដ៏ចម្រើន ទើបព្រះបាទបសេនទិកោសល រៀបចតុរង្គសេនាទៅចាំតទល់គ្នានឹងព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ឰដ៏ដែនកាសី បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ និងព្រះបាទបសេនទិកោសល ក៏ច្បាំងគ្នា

តស្មឹ ខោ បន ភន្តេ សង្គាមេ រាជា បសេនទិ-
កោសលោ រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ
បរាជេសិ ជីវគ្គាហញ្ច នំ អគ្គហេសិ អថខោ ភន្តេ
រញ្ញោ បសេនទិកោសលស្ស ឯតទហោសិ កិញ្ចាបិ
ខោ មយ្ហំ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ
អទុព្ភន្តស្ស ទុព្ភតិ អថ ច បន មេ ភាគិនេយ្យោ
ហោតិ យន្នូនាហំ រញ្ញោ មាគធស្ស អជាតសត្តុនោ
វេទេហិបុត្តស្ស សព្វំ ហត្ថិកាយំ បរិយាទិយិត្វា សព្វំ
អស្សកាយំ សព្វំ រថកាយំ សព្វំ បត្តិកាយំ បរិយា-
ទិយិត្វា ជីវន្តមេវ នំ ឱស្សជ្ជេយ្យន្តិ ។ អថខោ
ភន្តេ រាជា បសេនទិកោសលោ រញ្ញោ មាគធស្ស
អជាតសត្តុនោ វេទេហិបុត្តស្ស សព្វំ ហត្ថិកាយំ បរិ-
យាទិយិត្វា សព្វំ អស្សកាយំ បរិយាទិយិត្វា សព្វំ
រថកាយំ បរិយាទិយិត្វា សព្វំ បត្តិកាយំ បរិយាទិ-
យិត្វា ជីវន្តមេវ នំ ឱស្សជ្ជីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងសង្គ្រាមនោះ ព្រះបាទបសេនទិកោសល ទ្រង់ផ្ចាញ់ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ឲ្យបរាជ័យហើយ ចាប់យកព្រះបាទអជាតសត្តុនោះបានទាំងរស់ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ព្រះបាទបសេនទិកោសល មានសេចក្តីត្រិះរិះដូច្នេះថា ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈនេះ ប្រទូស្តចំពោះអាត្មាអញដែលជាអ្នកមិនប្រទូស្តក៏មែនហើយ តែថាស្តេចនោះត្រូវជាក្មួយរបស់អាត្មាអញ បើដូច្នោះ មានតែអាត្មាអញ រឹបយកពលដំរីទាំងអស់ រឹបយកពលសេះទាំងអស់ រឹបយកពលរថទាំងអស់ រឹបយកពលថ្មើរជើងទាំងអស់ របស់ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ហើយលែងព្រះបាទអជាតសត្តុនោះឲ្យរួចទៅទាំងរស់វិញ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ព្រះបាទបសេនទិកោសល ក៏បានរឹបយកពលដំរីទាំងអស់ រឹបយកពលសេះទាំងអស់ រឹបយកពលរថទាំងអស់ រឹបយកពលថ្មើរជើងទាំងអស់ របស់ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ ហើយលែងព្រះបាទអជាតសត្តុនោះឲ្យរួចទៅទាំងរស់វិញ ។

[៣៧៩] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

វិលុម្បតេវ បុរិសោ
យាវស្ស ឧបកប្បតិ
យទា ចញ្ញេ វិលុម្បន្តិ
សោ វិលុត្តោ វិលុម្បតិ
ឋានញ្ហិ មញ្ញតី ពាលោ
យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ
អថ (ពាលោ) ទុក្ខំ និគច្ឆតិ
លភតិ ហន្តា ហន្តារំ
ជេតារំ លភតេ ជយំ
អក្កោសកោ ច អក្កោសំ
រោសេតារញ្ច រោសកោ
អថ កម្មវិវដ្ដេន
សោ វិលុត្តោ វិលុម្បតីតិ ។

[៣៧៩] គ្រាកាលដែលព្រះមានព្រះភាគ ជ្រាបសេចក្តីនុ៎ះច្បាស់ហើយ ទ្រង់ត្រាស់ព្រះគាថាទាំងនេះក្នុងវេលានោះថា

ការរឹបជាន់ សម្រេចដល់បុរសនោះ ដរាបណា បុរសនោះឈ្មោះថារឹបជាន់គេ ដរាបនោះ ជនទាំងឡាយដទៃរឹបជាន់គេក្នុងកាលណា គេដែលពួកជនដទៃរឹបជាន់នោះ នឹងរឹបជាន់វិញ ក្នុងកាលនោះ បាបមិនទាន់ឲ្យផល ដរាបណា បុគ្គលពាលតែងសំគាល់បាបនោះថា គ្រាន់តែជាហេតុ ដរាបនោះ លុះតែបាបឲ្យផល ក្នុងកាលណា បុគ្គលពាលរមែងដល់នូវទុក្ខ ក្នុងកាលនោះ អ្នកសម្លាប់គេ តែងបានគេសម្លាប់ខ្លួនវិញ អ្នកឈ្នះគេ តែងបានគេឈ្នះខ្លួនវិញ អ្នកជេរគេ តែងបានគេជេរខ្លួនវិញ អ្នកប្រទូស្តគេ តែងបានគេប្រទូស្តខ្លួនវិញ មួយទៀត អ្នកដែលគេរឹបជាន់នោះ រមែងរឹបជាន់គេវិញ តាមការដែលផ្លាស់ប្តូរនៃកម្ម ។

# ឆដ្ឋំ ធីតុសុត្តំ

[៣៨០] សាវត្ថីនិទានំ ។ អថខោ រាជា បសេនទិកោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អថខោ អញ្ញតរោ បុរិសោ យេន រាជា បសេនទិកោសលោ តេនុបសង្កមិ ឧបសង្កមិត្វា រញ្ញោ បសេនទិកោសលស្ស ឧបកណ្ណកេ អារោចេសិ មល្លិកា ទេវ ទេវី ធីតរំ វិជាតាតិ ។ ឯវំ វុត្តេ រាជា បសេនទិកោសលោ អនត្តមនោ អហោសិ ។

[៣៨១] អថខោ ភគវា រាជានំ បសេនទិកោសលំ អនត្តមនំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

# ធីតុសូត្រ ទី ៦

[៣៨០] *សាវត្ថីនិទាន ។ គ្រានោះឯង ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយ ទ្រង់គង់នៅក្នុងទីសមគួរ ។ លំដាប់នោះ បុរសម្នាក់ ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ ខ្សឹបទូលព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព ព្រះនាងមល្លិកាទេវី ប្រសូតព្រះរាជធីតាហើយ ។ កាលបើបុរសនោះក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទបសេនទិកោសល ក៏មានព្រះហឫទ័យអាក់អន់ ។*

[៣៨១] *លុះព្រះមានព្រះភាគ ទ្រង់ជ្រាបថា ព្រះបាទបសេនទិកោសល មានព្រះហឫទ័យអាក់អន់ហើយ ទើបត្រាស់នូវគាថាទាំងឡាយនេះក្នុងវេលានោះថា*

ឥត្ថីបិ ហិ ឯកច្ចិយា
សេយ្យា[១] បោស ជនាធិប
មេធាវិនី សីលវតី
សស្សុទេវា បតិព្វតា
តស្សា យោ ជាយតី បោសោ
សូរោ ហោតិ ទិសម្បតិ
តាទិសា[២] សុភរិយា បុត្តោ
រជ្ជម្បិ អនុសាសតីតិ ។

## សត្តមំ បឋមអប្បមាទសុត្តំ

[៣៨២] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ ឯកោ ធម្មោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ចាតិ ។ អត្ថិ ខោ មហារាជ ឯកោ ធម្មោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ចាតិ ។

---
១ សេយ្យោតិបិ បាឋោ ។ ២ ម. អយមេវ បាឋោ ។ ឱ. តាទិសោ ។

បពិត្រព្រះអង្គជាធំជាងជន សូមព្រះអង្គចិញ្ចឹមតែស្ត្រីមួយពួក ដែលមានបញ្ញា មានសីល មានម្តាយក្មេកនិងឪពុកក្មេកដូចជាទេព្តា ជាអ្នកធ្វើវត្តដល់ប្តី ជាស្ត្រីប្រសើរ បពិត្រព្រះអង្គជាធំក្នុងទិស បុរសណា កើតចាកស្ត្រីនោះ បុរសនោះជាអ្នកក្លៀវក្លា ឯបុត្តនៃភរិយាល្អប្រាកដដូច្នោះ តែងប្រៀនប្រដៅនូវជនដែលនៅក្នុងដែនបាន ។

# បឋមអប្បមាទសូត្រ ទី ៧

[៣៨២] ទៀបក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសលគង់ក្នុងទីសមគួរហើយ ទ្រង់ត្រាស់នឹងព្រះមានព្រះភាគដូច្នេះថា ធម៌តែមួយ ដែលឲ្យសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ មានដែរឬ ព្រះអង្គ ។ ព្រះអង្គត្រាស់ថា ធម៌តែមួយ ដែលឲ្យសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ មានដែរ មហារាជ ។

កតមោ បន ភន្តេ ឯកោ ធម្មោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរា-យិកញ្ចាតិ ។

[៣៨៣] អប្បមាទោ ខោ មហារាជ ឯកោ ធម្មោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ចាតិ ។ សេយ្យថាបិ មហារាជ យានិ កានិចិ ជង្គលានំ[១] បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន[២] ឯវមេវ ខោ មហារាជ អប្បមាទោ ឯកោ ធម្មោ យោ ឧ-ភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ចាតិ ។

១ ឱ. ជង្គមានំ ។ ២ ឱ. មហន្តេន ។ ម. មហន្តត្តេន ។

បពិត្រព្រះអង្គដ៏ចម្រើន ធម៌តែមួយ ដែលឲ្យសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ តើដូចម្ដេចខ្លះ ។

[៣៨៣] ព្រះអង្គត្រាស់ថា បពិត្រមហារាជ ធម៌តែមួយ គឺអប្បមាទធម៌ តែងឲ្យសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ ។ បពិត្រមហារាជ ដានជើងណាមួយនៃពួកសត្វដែលដើរលើផែនដី ដានជើងទាំងអស់នោះ រមែងប្រជុំចុះក្នុងដានជើងដំរី ដានជើងដំរីប្រាកដជាធំជាងដានជើងសត្វទាំងអម្បាលនោះ ព្រោះថា ដានជើងដំរី ជាដានជើងធំ យ៉ាងណាមិញ បពិត្រមហារាជ ធម៌តែមួយ គឺអប្បមាទធម៌ តែងឲ្យសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ យ៉ាងនោះឯង ។

[៣៨៤] ឥទមវោច ។ បេ ។

អាយុំ អារោគិយំ វណ្ណំ

សគ្គំ ឧច្ចាកុលីនតំ

រតិយោ បត្ថយន្តេន

ឧឡារា អបរាបរា

អប្បមាទំ បសំសន្តិ

បុញ្ញក្រិយាសុ[១] បណ្ឌិតា

អប្បមត្តោ ឧភោ អត្ថេ

អធិគ្គណ្ហាតិ បណ្ឌិតោ

ទិដ្ឋេ ធម្មេ ច យោ អត្ថោ

យោ ចត្ថោ សម្បរាយិកោ

អត្ថាភិសមយា ធីរោ

បណ្ឌិតោតិ បវុច្ចតីតិ ។

# អដ្ឋមំ ទុតិយអប្បមាទសុត្តំ

[៣៨៥] សាវត្ថិយំ វិហរតិ... ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ។

១ បុញ្ញកិរិយាសូតិបិ បាឋោ ។

[៣៨៤] ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះ ។ បេ ។ បុគ្គល កាលប្រាថ្នា នូវអាយុ ភាពជាអ្នកមិនមានរោគ សម្បុរកាយ ឋានសួគ៌ ត្រកូលខ្ពស់ និងសេចក្តីត្រេកអរទាំងឡាយ ដ៏លើសលុប ត ៗ ទៅ (គួរតែធ្វើសេចក្តីមិនប្រមាទ) បណ្ឌិតទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ បណ្ឌិតជាអ្នកមិនប្រមាទ តែងបានប្រយោជន៍ទាំងពីរ គឺប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថាបណ្ឌិត ព្រោះការបាននូវប្រយោជន៍ទាំងពីរនោះ ។

# ទុតិយអប្បមាទសូត្រ ទី ៨

[៣៨៥] ព្រះមានព្រះភាគគង់នៅទៀបក្រុងសាវត្ថី... គង់នៅក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ

២៣៧

កោសលសំយុត្តស្ស ជដិលវគ្គេ កល្យាណមិត្តប្បសំសា

ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវញ្ចេតសោ បរិវិតក្កោ ឧទបាទិ ស្វាក្ខាតោ ភគវតា ធម្មោ សោ ច ខោ កល្យាណមិត្តស្ស កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស នោ បាបមិត្តស្ស នោ បាបសហាយស្ស នោ បាបសម្បវង្កស្សាតិ ។ ឯវមេតំ មហារាជ ឯវមេតំ មហារាជ ស្វាក្ខាតោ មហារាជ មយា ធម្មោ សោ ច ខោ កល្យាណមិត្តស្ស កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស នោ បាបមិត្តស្ស នោ បាបសហាយស្ស នោ បាបសម្បវង្កស្សាតិ ។

[៣៨៦] ឯកមិទាហំ មហារាជ សមយំ សក្កេសុ វិហរាមិ នគរកំ នាម[១] សក្យានំ និគមោ ។ អថខោ មហារាជ អានន្ទោ ភិក្ខុ យេនាហំ តេនុបសង្កមិ

១ មហាវារវគ្គេ មគ្គសំយុត្តស្ស អវិជ្ជាវគ្គេ សក្ករំ នាម ។

បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គពួនសម្ងំនៅក្នុងទីស្ងាត់ ក្នុងទីឯណោះ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ធម៌ ដែលព្រះមានព្រះភាគត្រាស់ហើយដោយប្រពៃ ធម៌នោះឯង ជារបស់បុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន មិនមែនជារបស់បុគ្គលអ្នកមានមិត្តអាក្រក់ អ្នកមានសម្លាញ់អាក្រក់ អ្នកបង្អោនទៅរកបាបជនឡើយ ។ បពិត្រមហារាជ នុ៎ះយ៉ាងនេះមែនហើយ បពិត្រមហារាជ នុ៎ះយ៉ាងនេះមែនហើយ បពិត្រមហារាជ ធម៌ដែលតថាគតត្រាស់ហើយដោយប្រពៃ ធម៌នោះឯង ជារបស់បុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន មិនមែនជារបស់បុគ្គលអ្នកមានមិត្តអាក្រក់ អ្នកមានសម្លាញ់អាក្រក់ អ្នកបង្អោនទៅរកបាបជនឡើយ ។

[៣៨៦] បពិត្រមហារាជ សម័យមួយ តថាគតនៅក្នុងនិគមឈ្មោះនគរកៈ របស់ពួកសក្យជន ក្នុងសក្កជនបទឯណោះ ។ បពិត្រមហារាជ លំដាប់នោះឯង ភិក្ខុឈ្មោះអានន្ទ បានចូលទៅរកតថាគត

ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហារាជ អានន្ទោ ភិក្ខុ មំ ឯតទវោច ឧបឌ្ឍមិទំ ភន្តេ ព្រហ្មចរិយស្ស យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណ-សម្បវង្កតាតិ ។ ឯវំ វុត្តាហំ មហារាជ អានន្ទំ ភិក្ខុំ ឯតទវោចំ មា ហេវំ អានន្ទ សកលមេវ ហិទំ អានន្ទ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យា-ណសហាយតា កល្យាណសម្បវង្កតា កល្យាណ-មិត្តស្សេតំ អានន្ទ ភិក្ខុនោ បាដិកង្ខំ កល្យាណស-ហាយស្ស កល្យាណសម្បវង្កស្ស អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេស្សតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករិស្ស តីតិ ។

[៣៨៧] កថញ្ច អានន្ទ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលី-ករោតិ ។ ឥធានន្ទ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេក-និស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ

លុះចូលទៅដល់ ថ្វាយបង្គំតថាគតហើយ អង្គុយក្នុងទីសមគួរ ។ បពិត្រមហារាជ លុះអានន្ទភិក្ខុអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាគុណពាក់កណ្តាលរបស់មគ្គព្រហ្មចរិយៈ ។ បពិត្រមហារាជ កាលអានន្ទភិក្ខុក្រាបទូលយ៉ាងនេះហើយ តថាគតបានត្រាស់នឹងអានន្ទភិក្ខុដូច្នេះថា ម្នាលអានន្ទ អ្នកកុំនិយាយយ៉ាងនេះឡើយ ឯភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះចាត់ជាមគ្គ-ព្រហ្មចរិយៈទាំងមូល ម្នាលអានន្ទ មគ្គព្រហ្មចរិយៈនុ៎ះ កើតប្រាកដដល់ភិក្ខុដែលជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ភិក្ខុនោះ នឹងចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នឹងធ្វើឲ្យរឿយ ៗ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

[៣៨៧] ម្នាលអានន្ទ ចុះភិក្ខុអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យរឿយ ៗ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិដែលអាស្រ័យវិវេក អា-ស្រ័យវិរាគ អាស្រ័យនិរោធ មានកិរិយាបង្អោនចិត្តទៅដើម្បីលះកិលេស

សម្មាសង្កប្បំ ភាវេតិ... សម្មាវាចំ ភាវេតិ... សម្មាកម្មន្តំ ភាវេតិ... សម្មាអាជីវំ ភាវេតិ... សម្មាវាយាមំ ភាវេតិ... សម្មាសតឹ ភាវេតិ... សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ អានន្ទ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ តទិមិនាបេតំ អានន្ទ បរិយាយេន វេទិតព្វំ យថា សកលមេវិទំ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតាតិ ។ មមញ្ហិ អានន្ទ កល្យាណមិត្តំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ ព្យាធិធម្មា សត្តា ព្យាធិតោ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុ-ចាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុ-

ចម្រើននូវសម្មាសង្កប្បៈ... ចម្រើននូវសម្មាវាចា... ចម្រើននូវសម្មាកម្មន្តៈ... ចម្រើននូវសម្មាអាជីវៈ... ចម្រើននូវសម្មាវាយាមៈ... ចម្រើននូវសម្មាសតិ... ចម្រើននូវសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ មានកិរិយាបង្អោនចិត្តទៅ ដើម្បីលះបង់កិលេស ។ ម្នាលអានន្ទ ភិក្ខុអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន តែងចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តែងធ្វើឲ្យរឿយ ៗ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយប្រការយ៉ាងនេះឯង ។ ម្នាលអានន្ទ ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាតួមគ្គព្រហ្មចរិយៈទាំងមូល ដោយហេតុណា ហេតុនោះ បុគ្គលត្រូវដឹងដោយបរិយាយនេះឯង ។ ម្នាលអានន្ទ សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិ សត្វទាំងឡាយមានជរាជាធម្មតា រមែងរួចចាកជរា សត្វទាំងឡាយមានព្យាធិជាធម្មតា រមែងរួចចាកព្យាធិ សត្វទាំងឡាយមានមរណៈជាធម្មតា រមែងរួចចាកមរណៈ សត្វទាំងឡាយមានសោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសជាធម្មតា រមែងរួចចាកសោក បរិទេវៈ ទុក្ខ ទោមនស្ស

ចាយាសេហិ បរិមុច្ចន្តីតិ ។ ឥមិនា ខោ ឯតំ អានន្ទ បរិយាយេន វេទិតព្វំ យថា សកលមេវិទំ ព្រហ្មចរិ-យំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតាតិ ។

[៣៨៨] តស្មាតិហ តេ មហារាជ ឯវំ សិក្ខិ-តព្វំ កល្យាណមិត្តោ ភវិស្សាមិ កល្យាណសហាយោ កល្យាណសម្បវង្កោតិ ។ ឯវំ ហិ តេ មហារាជ សិក្ខិតព្វំ ។ កល្យាណមិត្តស្ស តេ មហារាជ កល្យា-ណសហាយស្ស កល្យាណសម្បវង្កស្ស អយំ ឯកោ ធម្មោ ឧបនិស្សាយ វិហាតព្វោ អប្បមាទោ កុស-លេសុ ធម្មេសុ ។ អប្បមត្តស្ស តេ មហារាជ វិហរតោ អប្បមាទំ ឧបនិស្សាយ ឥត្ថាគារស្ស អនុ-យាយន្តស្ស[១] ឯវំ ភវិស្សតិ រាជា ខោ អប្បមត្តោ វិហរតិ អប្បមាទំ ឧបនិស្សាយ ហន្ទ មយំបិ អប្បមត្តា វិហរាម អប្បមាទំ ឧបនិស្សាយាតិ ។ អប្បមត្តស្ស តេ មហារាជ វិហរតោ អប្បមាទំ ឧបនិស្សាយ ខត្តិយានម្បិ អនុយន្តានំ[២] ឯវំ ភវិស្សតិ

១ ឱ. អនុយាយន្តស្សាតិ ន ទិស្សតិ ។ ២ ឱ. អនុយុត្តានំ ។

និងឧបាយាសទាំងឡាយបាន ក៏ព្រោះអាស្រ័យនឹងតថាគតជាមិត្តល្អ ។ ម្នាលអានន្ទ ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាតួមគ្គព្រហ្មចរិយៈទាំងមូល ដោយហេតុណា ហេតុនេះ បុគ្គលត្រូវដឹងដោយបរិយាយនេះឯង ។

[៣៨៨] បពិត្រមហារាជ ព្រោះហេតុនោះ ក្នុងសាសនានេះ ព្រះអង្គគប្បីសិក្សាយ៉ាងនេះថា អាត្មាអញជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ។ បពិត្រមហារាជ ព្រះអង្គគប្បីសិក្សាយ៉ាងនេះឯង ។ បពិត្រមហារាជ ធម៌មួយនេះ គឺសេចក្តីមិនប្រមាទក្នុងធម៌ជាកុសលទាំងឡាយ ព្រះអង្គជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន គួរតែអាស្រ័យនៅកុំខាន ។ បពិត្រមហារាជ កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទហើយ សូម្បីស្រីស្នំដែលដើរហែតាម ក៏គង់មានសេចក្តីត្រិះរិះថា ព្រះរាជាមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទដែរ ។ បពិត្រមហារាជ កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទហើយ សូម្បីក្សត្រទាំងឡាយដែលជាចំណុះ គង់មាន

រាជា ខោ អប្បមត្តោ វិហរតិ អប្បមាទំ ឧបនិស្សាយ ហន្ទ មយំបិ អប្បមត្តា វិហរាម អប្បមាទំ ឧប-និស្សាយាតិ ។ អប្បមត្តស្ស តេ មហារាជ វិហរតោ អប្បមាទំ ឧបនិស្សាយ ពលកាយស្សបិ ឯវំ ភវិស្សតិ រាជា ខោ អប្បមត្តោ វិហរតិ អប្បមាទំ ឧបនិស្សាយ ហន្ទ មយំបិ អប្បមត្តា វិហរាម អប្បមាទំ ឧប-និស្សាយាតិ ។ អប្បមត្តស្ស តេ មហារាជ វិហរតោ អប្បមាទំ ឧបនិស្សាយ នេគមជានបទស្សាបិ ឯវំ ភវិស្សតិ រាជា ខោ អប្បមត្តោ វិហរតិ អប្បមាទំ ឧបនិស្សាយ ហន្ទ មយំបិ អប្បមត្តា វិហរាម អប្បមាទំ ឧបនិស្សាយាតិ ។ អប្បមត្តស្ស តេ មហារាជ វិហ-រតោ អប្បមាទំ ឧបនិស្សាយ អត្តាបិ គុត្តោ រក្ខិតោ ភវិស្សតិ ឥត្ថាគារម្បិ គុត្តំ រក្ខិតំ ភវិស្សតិ កោស-កោដ្ឋាគារម្បិ គុត្តំ រក្ខិតំ ភវិស្សតីតិ ។

សេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។ បពិត្រមហារាជ កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីពួកពលគង់មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។ បពិត្រមហារាជ កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីអ្នកនិគមនិងអ្នកជនបទគង់មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។ បពិត្រមហារាជ កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីខ្លួនក្ដី ក៏នឹងឈ្មោះថា ព្រះអង្គបានគ្រប់គ្រងរក្សា ស្រីស្នំក្ដី ក៏នឹងឈ្មោះថា ព្រះអង្គបានគ្រប់គ្រងរក្សា ព្រះឃ្លាំងនិងជង្រុកក្ដី ក៏នឹងឈ្មោះថា ព្រះអង្គបានគ្រប់គ្រងរក្សា ។

[៣៨៩] ឥធមេវេច ។ បេ ។
ភោគេ បត្ថយមានេន
ឧឡារេ អបរាបរេ
អប្បមាទំ បសំសន្តិ
បុញ្ញកិរិយាសុ បណ្ឌិតា
អប្បមត្តោ ឧភោ អត្ថេ
អធិគណ្ហាតិ បណ្ឌិតោ
ទិដ្ឋេ ធម្មេ ច យោ អត្ថោ
យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ
បណ្ឌិតោតិ បវុច្ចតីតិ ។

## នវមំ បឋមាបុត្តកសុត្តំ

[៣៩០] សាវត្ថិយំ... អថខោ រាជា បសេនទិកោ-សលោ ទិវាទិវស្ស យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ បសេនទិកោសលំ

[៣៨៩] ព្រះមានព្រះភាគ បានត្រាស់នូវគាថានេះ ។ បេ ។ បុគ្គលកាលប្រាថ្នានូវភោគៈទាំងឡាយ ឲ្យច្រើនលើសលុប ត ៗ ទៅ (គួរតែធ្វើសេចក្តីមិនប្រមាទ) បណ្ឌិតទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ ក្នុងបុញ្ញកិរិយាវត្ថុទាំង-ឡាយ បណ្ឌិតអ្នកមិនប្រមាទ តែងបានសម្រេចប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាក្នុងបរលោកក្តី ធីរជនឈ្មោះថា បណ្ឌិត ព្រោះបាននូវប្រយោជន៍នោះ ៗ ។

## បឋមាបុត្តកសូត្រ ទី ៩

[៣៩០] ទៀបក្រុងសាវត្ថី... គ្រានោះឯង ព្រះបាទបសេន-ទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ទាំងក្នុងវេលាថ្ងៃត្រង់ លុះស្តេចយាងដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយទ្រង់គង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ

កោសលសំយុត្តស្ស ជដិលវគ្គេ អសប្បុរិសភោគលាភោ

ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ មហារាជ អា-
គច្ឆសិ ទិវាទិវស្សាតិ ។ ឥធ ភន្តេ សាវត្ថិយំ សេដ្ឋី
គហបតិ កាលកតោ តមហំ អបុត្តកំ សាបតេយ្យំ
រាជន្តេបុរំ អតិហរិត្វា អាគច្ឆាមិ អសីតិ ភន្តេ សត-
សហស្សានិ ហិរញ្ញស្សេវ កោ បន វាទោ រូបិយស្ស
តស្ស ខោ បន ភន្តេ សេដ្ឋិស្ស គហបតិស្ស ឯវរូបោ
ភត្តភោគោ អហោសិ កណាជកំ ភុញ្ជតិ ពិលង្គទុ-
តិយំ ឯវរូបោ វត្ថភោគោ អហោសិ សាណំ ធារេតិ
តិបក្ខវសនំ ឯវរូបោ យានភោគោ អហោសិ ជជ្ជរ-
រថកេន យាតិ បណ្ណច្ឆត្តកេន ធារិយមានេនាតិ ។

ទើបព្រះមានព្រះភាគត្រាស់ដូច្នេះថា បពិត្រមហារាជ ចុះព្រះអង្គទើបនឹងស្តេចមកពីណាទាំងថ្ងៃត្រង់ ។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីក្នុងក្រុងសាវត្ថីនេះ ធ្វើមរណកាលទៅហើយ ខ្ញុំព្រះអង្គ នាំទ្រព្យរបស់សេដ្ឋីដែលគ្មានកូននោះមកកាន់ខាងក្នុងព្រះរាជវាំង បពិត្រព្រះអង្គដ៏ចម្រើន គ្រាន់តែប្រាក់មានប៉ែតសិបសែនទៅហើយ នឹងបាច់ពោលទៅថ្វីដល់រូបិយៈ[១] បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីនោះ មានការបរិភោគភត្តបែបនេះ គឺគាត់បរិភោគបាយចុងអង្ករ មានជ្រក់ជាគម្រប់ពីរ មានការប្រើប្រាស់សំពត់បែបនេះ គឺគាត់ស្លៀកសំពត់សំបកធ្មៃប៉ះជា ៣ ផ្ទាំង[២] មានការប្រើប្រាស់យានបែបនេះ គឺគាត់ជិះរថតូចកញ្ចាស់ បាំងឆត្រស្លឹកយ៉ាងតូច ។

១ រូបិយៈនោះសំដៅយករបស់ដុំ ដូចមាស ប្រាក់ ទង់ដែង សំរិទ្ធិ ផាលនិងដឹងជាដើមខ្លះ សំដៅយករូបិយភណ្ឌ ដូចភាជនៈសម្រាប់ប្រើប្រាស់ជាដើមខ្លះ ។ អដ្ឋកថា ។ ២ សំពត់ធ្មៃ បី កន្សែង ដេរភ្ជាប់គ្នា ៣ អន្លើ ។

[៣៩១] ឯវមេតំ មហារាជ ឯវមេតំ មហារាជ អសប្បុរិសោ ខោ មហារាជ ឧឡារេ ភោគេ លភិត្វា នេវត្តានំ សុខេតិ បិណេតិ ន មាតាបិតរោ សុខេ-តិ បិណេតិ ន បុត្តទារំ សុខេតិ បិណេតិ ន ទា-សកម្មករបោរិសេ សុខេតិ បិណេតិ ន មិត្តាមច្ចេ សុខេតិ បិណេតិ ន សមណេសុ ព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ ។ តស្ស តេ ភោគេ ឯវំ សម្មា អបរិ-ភុញ្ជមានេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា វា ទាយាទា ហរន្តិ ។ ឯវំស តេ[១] មហារាជ ភោគា សម្មា អបរិភុញ្ជមានា បរិក្ខយំ គច្ឆន្តិ នោ បរិភោគំ ។ សេយ្យថាបិ មហារាជ អមនុស្សដ្ឋានេ បោក្ខរណី អច្ឆោទកា សីតោទកា សាតោទកា សេតកា សុបតិត្ថា

១ ឱ. ឯវំ សន្តេ ។

[៣៩១] បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ធម្មតាអសប្បុរស បើបានភោគៈច្រើនលើសលុបហើយ មិនធ្វើខ្លួនឲ្យសុខ មិនបំពេញខ្លួន មិនធ្វើមាតាបិតាឲ្យសុខ មិនបំពេញមាតាបិតា មិនធ្វើបុត្តភរិយាឲ្យបានសុខ មិនបំពេញបុត្តភរិយា មិនធ្វើពួកបុរសជាទាសកម្មករឲ្យបានសុខ មិនបំពេញពួកបុរសជាទាសកម្មករ មិនធ្វើពួកមិត្តនិងអាមាត្យឲ្យបានសុខ មិនបំពេញពួកមិត្តនិងអាមាត្យ ទាំងមិនតំកល់ទុក នូវទក្ខិណាទានក្នុងសមណព្រាហ្មណ៍ទាំងឡាយ ដែលជាទានមានផលខ្ពង់ខ្ពស់ ជាទានឲ្យនូវអារម្មណ៍មានរូបជាដើមដ៏ប្រសើរដោយប្រពៃ មានវិបាកជាសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ឡើយ ។ កាលបើអសប្បុរសនោះ មិនប្រើប្រាស់ភោគសម្បត្តិទាំងនោះដោយស្រួល យ៉ាងនេះហើយ ព្រះរាជាទាំងឡាយនាំយកទៅខ្លះ ពួកចោរនាំយកទៅខ្លះ ភ្លើងឆេះខ្ទេចទៅខ្លះ ទឹកបន្សាត់ទៅខ្លះ ពួកញាតិដែលមិនជាទីស្រឡាញ់នាំយកទៅខ្លះ ។ បពិត្រមហារាជ កាលបើភោគៈទាំងនោះ ដែលអសប្បុរសនោះមិនប្រើប្រាស់ដោយប្រពៃ យ៉ាងនេះហើយ រមែងដល់នូវការអស់ទៅ មិនដល់នូវការប្រើប្រាស់បានឡើយ ។ បពិត្រមហារាជ ស្រះបោក្ខរណីក្នុងទីគ្មានមនុស្ស មានទឹកថ្លា មានទឹកត្រជាក់ មានទឹកឆ្ងាញ់ មានទឹកស (ដោយអន្ទើ) មានកំពង់ល្អ

រមណីយា តញ្ញោ នេវ ហរេយ្យ ន បិវេយ្យ ន នហាយេយ្យ ន យថាបច្ចយំ វា ករេយ្យ ឯវញ្ហិ តំ មហារាជ ឧទកំ សម្មា អបរិភុញ្ជមានំ បរិក្ខយំ គច្ឆេយ្យ នោ បរិភោគំ ឯវមេវ ខោ មហារាជ អសប្បុរិសោ ឧឡារេ ភោគេ លភិត្វា នេវត្តានំ សុខេតិ បិណេតិ ។ បេ ។ ឯវំស តេ មហារាជ ភោគា សម្មា អបរិភុញ្ជមានា បរិក្ខយំ គច្ឆន្តិ នោ បរិភោគំ ។

[៣៩២] សប្បុរិសោ ច ខោ មហារាជ ឧឡារេ ភោគេ លភិត្វា អត្តានំ សុខេតិ បិណេតិ មាតាបិតរោ សុខេតិ បិណេតិ បុត្តទារំ សុខេតិ បិណេតិ ទាសកម្មករបោរិសេ សុខេតិ បិណេតិ មិត្តា-

គួរជាទីត្រេកអរ អ្នកផងមិនទៅដងទឹកនោះ មិនផឹកទឹកនោះ មិនងូត ទឹកនោះ មិនយកទឹកនោះទៅប្រើប្រាស់តាមសមគួរដល់សេចក្តីត្រូវការ ឡើយ បពិត្រមហារាជ ឯទឹកនោះ កាលគេមិនប្រើប្រាស់ ដោយ ប្រពៃ យ៉ាងនេះហើយ គប្បីដល់នូវការអស់ទៅ មិនដល់នូវការប្រើ ប្រាស់បាន យ៉ាងណា បពិត្រមហារាជ អសប្បុរស បានភោគៈច្រើន លើសលុបហើយ មិនធ្វើខ្លួនឲ្យសុខ មិនបំពេញខ្លួន ។ បេ ។ បពិត្រ មហារាជ កាលបើភោគៈទាំងឡាយ ដែលអសប្បុរសនោះមិនប្រើប្រាស់ ដោយប្រពៃ យ៉ាងនេះហើយ តែងដល់នូវការអស់ទៅ មិនដល់នូវ ការប្រើប្រាស់បាន យ៉ាងនោះឯង ។

[៣៩២] បពិត្រមហារាជ ចំណែកសប្បុរស បានភោគៈច្រើន លើសលុបហើយ តែងធ្វើខ្លួនឲ្យសុខ បំពេញខ្លួន ធ្វើមាតាបិតាឲ្យសុខ បំពេញមាតាបិតា ធ្វើបុត្តភរិយាឲ្យសុខ បំពេញបុត្តភរិយា ធ្វើពួក បុរសជាទាសកម្មករឲ្យសុខ បំពេញពួកបុរសជាទាសកម្មករ ធ្វើពួកមិត្ត

មច្ចេ សុខេតិ បិណេតិ សមណេសុ ព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ ។ តស្ស តេ ភោគេ ឯវំ សម្មា បរិភុញ្ជមានេ នេវ រាជានោ ហរន្តិ ន ចោរា ហរន្តិ ន អគ្គិ ឌហតិ ន ឧទកំ វហតិ ន អប្បិយា ទាយាទា ហរន្តិ ។ ឯវំស តេ មហារាជ ភោគា សម្មា បរិភុញ្ជមានា បរិភោគំ គច្ឆន្តិ នោ បរិក្ខយំ ។ សេយ្យថាបិ មហារាជ គាមស្ស វា និគមស្ស វា អវិទូរេ បោក្ខរណី អច្ឆោទកា សីតោទកា សាតោទកា សេតកា សុបតិត្ថា រមណីយា តញ្ជនោ ហរេយ្យបិ បិវេយ្យបិ នហាយេយ្យបិ យថាបច្ចយំបិ ករេយ្យ ឯវញ្ហិ តំ មហារាជ ឧទកំ សម្មា បរិភុញ្ជមានំ បរិភោគំ គច្ឆេយ្យ នោ បរិក្ខយំ ឯវមេវ ខោ មហារាជ សប្បុរិសោ ឧឡារេ ភោគេ លភិត្វា

និងអាមាត្យឲ្យសុខ បំពេញពួកមិត្តនិងអាមាត្យ ទាំងបានតម្កល់ទុកនូវទក្ខិណាទាន ក្នុងសមណព្រាហ្មណ៍ទាំងឡាយ ដែលជាទានមានផលខ្ពង់ខ្ពស់ ជាទានឲ្យនូវអារម្មណ៍មានរូបជាដើមដ៏ប្រសើរដោយប្រពៃ មានវិបាកជាសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ ។ កាលបើសប្បុរសនោះបានប្រើប្រាស់ភោគសម្បត្តិទាំងនោះដោយប្រពៃ យ៉ាងនេះហើយ ពួកព្រះរាជាក៏មិននាំយកទៅ ពួកចោរក៏មិនលួចទៅ ភ្លើងក៏មិនឆេះ ទឹកក៏មិនបន្សាត់ទៅ ពួកញាតិដែលមិនជាទីស្រឡាញ់ក៏មិនបាននាំយកទៅ ។ បពិត្រមហារាជ ភោគៈទាំងនោះ ដែលសប្បុរសនោះប្រើប្រាស់ដោយប្រពៃយ៉ាងនេះហើយ រមែងដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ ។ បពិត្រមហារាជ ស្រះបោក្ខរណីដែលនៅជិតស្រុកឬនិគម មានទឹកថ្លា មានទឹកត្រជាក់ មានទឹកឆ្ងាញ់ មានទឹកស (ដោយអន្ទើ) មានកំពង់ល្អ គួរជាទីត្រេកអរ អ្នកផង ទៅដងទឹកនោះមកខ្លះ ផឹកខ្លះ ងូតខ្លះ ប្រើប្រាស់តាមសមគួរដល់សេចក្តីត្រូវការខ្លះ បពិត្រមហារាជ ឯទឹកនោះ ដែលអ្នកផងបរិភោគដោយប្រពៃ យ៉ាងនេះហើយ គប្បីដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ យ៉ាងណាមិញ បពិត្រមហារាជ សប្បុរស បានភោគៈច្រើនលើសលុបហើយ

កោសលសំយុត្តស្ស ជដិលវគ្គេ និគមគាថា

អត្តានំ សុខេតិ បិណេតិ ។ បេ ។ ឯវំស តេ ភោគា សម្មា បរិភុញ្ជមានា បរិភោគំ គច្ឆន្តិ នោ បរិក្ខយន្តិ ។

[៣៩៣] ឥទមវោច ។ បេ ។

អមនុស្សដ្ឋានេ ឧទកំ វសិតំ

តទបេយ្យមានំ បរិសោ សមេតិ

ឯវំ ធនំ កាបុរិសោ លភិត្វា

នេវត្តនា បរិភុញ្ជតិ នោ ទទាតិ

ធីរោ ច វិញ្ញូ អធិគម្ម ភោគេ

សោ បរិភុញ្ជតិ កិច្ចការោ ច ហោតិ

សោ ញាតិសង្ឃំ និសភោ ភរិត្វា

អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

តែងធ្វើខ្លួនឲ្យសុខ បំពេញខ្លួន ។ បេ ។ កាលបើភោគសម្បត្តិទាំងនោះ ដែលសប្បុរសនោះប្រើប្រាស់ដោយប្រពៃ យ៉ាងនេះហើយ តែងដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ យ៉ាងនោះឯង ។

[៣៩៣] ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះហើយ ។ បេ ។

បុរស បានចួបប្រទះនឹងទឹក ដែលដក់នៅក្នុងទីគ្មានមនុស្ស
ជាទឹកផឹកមិនបាន យ៉ាងណាមិញ បុរសអាក្រក់ បានទ្រព្យហើយ មិនប្រើប្រាស់ខ្លួនឯង មិនឲ្យទាន យ៉ាងនោះឯង ឯអ្នកប្រាជ្ញ ជាអ្នកចេះដឹងនោះ បើបានភោគសម្បត្តិហើយ តែងប្រើប្រាស់ខ្លួនឯងខ្លះ ធ្វើកិច្ចឯទៀត ៗ ខ្លះ អ្នកប្រាជ្ញនោះ ជាបុគ្គលប្រសើរ ចំណាយចិញ្ចឹមពួកញាតិខ្លះ ឥតមានគេតិះដៀល (លុះស្លាប់ទៅ) ក៏ទៅកាន់ស្ថានសួគ៌ ។

# ទសមំ  ទុតិយាបុត្តកសុត្តំ

[៣៩៤] អថខោ រាជា បសេនទិកោសលោ ទិវា-
ទិវស្ស យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នំ ខោ រាជានំ បសេនទិកោសលំ ភគវា ឯតទ-
វោច ហន្ទ កុតោ នុ ត្វំ មហារាជ អាគច្ឆសិ ទិវាទិ-
វស្សាតិ ។ ឥធ ភន្តេ សាវត្ថិយំ សេដ្ឋី គហបតិ
កាលកតោ តមហំ អបុត្តកំ សាបតេយ្យំ រាជន្តេបុរំ
អតិហរិត្វា អាគច្ឆាមិ សតំ ភន្តេ សតសហស្សានិ
ហិរញ្ញស្សេវ កោ បន វាទោ រូបិយស្ស តស្ស ខោ
បន ភន្តេ សេដ្ឋិស្ស គហបតិស្ស ឯវរូបោ ភត្តភោគោ
អហោសិ កណាជកំ ភុញ្ជតិ ពិលង្គទុតិយំ ឯវរូបោ
វត្ថភោគោ អហោសិ សាណំ ធារេតិ តិបក្ខវសនំ ឯ-
វរូបោ យានភោគោ អហោសិ ជជ្ជររថកេន យាតិ
បណ្ណច្ឆត្តកេន ធារិយមានេនាតិ ។

# ទុតិយាបុត្តកសូត្រ ទី ១០

[៣៩៤] គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ ទាំងថ្ងៃត្រង់ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា បពិត្រមហារាជ ចុះព្រះអង្គទើបនឹងស្តេចមកពីណា ទាំងថ្ងៃត្រង់ ។ ព្រះបាទបសេនទិកោសល ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីក្នុងក្រុងសាវត្ថីនេះ ធ្វើមរណកាលទៅហើយ ខ្ញុំព្រះអង្គមកនាំយកទ្រព្យសេដ្ឋីគ្មានកូននោះទៅកាន់ខាងក្នុងព្រះរាជវាំង បពិត្រព្រះអង្គដ៏ចម្រើន គ្រាន់តែប្រាក់មានមួយរយសែនទៅហើយ នឹងបាច់ពោលទៅថ្វីដល់រូបិយៈ បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីនោះមានការបរិភោគភត្តបែបនេះ គឺគាត់បរិភោគបាយចុងអង្ករ មានជ្រក់ជាគម្រប់ពីរ មានការប្រើប្រាស់សំពត់បែបនេះ គឺគាត់ប្រើប្រាស់សំពត់សំបកធ្មៃ ប៉ះជា ៣ ផ្ទាំង មានការប្រើប្រាស់យានបែបនេះ គឺគាត់ជិះរថតូចកញ្ចាស់បាំងឆត្រស្លឹកយ៉ាងតូច ។

កោសលសំយុត្តស្ស ជដិលវគ្គេ ភូតបុព្វវត្ថុ

[៣៩៥] ឯវមេតំ មហារាជ ឯវមេតំ មហារាជ ភូតបុព្វំ សោ មហារាជ សេដ្ឋី គហបតិ តគរសិខឹ នាម បច្ចេកសម្ពុទ្ធំ បិណ្ឌបាតេន បដិបាទេសិ ទេហិ សមណស្ស បិណ្ឌន្តិ វត្វា ឧដ្ឋាយាសនា បក្កាមិ ទត្វា ច បន បច្ឆា វិប្បដិសារី អហោសិ វរមេតំ បិណ្ឌបាតំ ទាសា វា កម្មករា វា ភុញ្ជេយ្យុន្តិ ភាតុ ច បន ឯកំ បុត្តកំ សាបតេយ្យស្ស ការណា ជីវិតា វោរោបេសិ ។ យំ ខោ សោ មហារាជ សេដ្ឋី គហបតិ តគរសិខឹ បច្ចេកសម្ពុទ្ធំ បិណ្ឌបាតេន បដិបាទេសិ តស្ស កម្មស្ស វិបាកេន សត្តក្ខត្តុំ សុគតឹ សគ្គំ លោកំ ឧបបជ្ជិ តស្សេវ កម្មស្ស វិបាកាវសេសេន ឥមិស្សាយេវ សាវត្ថិយា សត្តក្ខត្តុំ សេដ្ឋិត្តំ ការេសិ ។ យំ ខោ សោ មហារាជ សេដ្ឋី គហបតិ ទត្វា បច្ឆា វិប្បដិសារី អហោសិ វរមេតំ បិណ្ឌបាតំ ទាសា វា កម្មករា វា ភុញ្ជេយ្យុន្តិ តស្ស កម្មស្ស វិបាកេន នាស្សុឡារាយ ភត្តភោគាយ ចិត្តំ នមតិ

[៣៩៥] បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ កាលពីព្រេងនាយមក សេដ្ឋីគហបតីនោះ បានឲ្យគេប្រតិបត្តិព្រះតគរសិខីបច្ចេកសម្ពុទ្ធ ដោយបិណ្ឌបាតថា អ្នកទាំងឡាយ ចូរឲ្យនូវដុំបាយដល់សមណៈដូច្នេះ លុះពោលរួចហើយ ក៏ក្រោកអំពីអាសនៈចៀសចេញទៅ លុះសេដ្ឋីគហបតីនោះឲ្យរួចហើយ ជាអ្នកមានសេចក្តីក្តៅក្រហាយ ក្នុងពេលជាខាងក្រោយថា ទាសៈទាំងឡាយក្តី កម្មករទាំងឡាយក្តី គប្បីបរិភោគនូវបិណ្ឌបាតនេះប្រសើរជាង មិនតែប៉ុណ្ណោះ សេដ្ឋីគហបតីនោះ បានទាំងផ្តាច់ជីវិតកូនម្នាក់របស់បង ព្រោះហេតុនៃទ្រព្យ ។ បពិត្រមហារាជ សេដ្ឋីគហបតីនោះ បានឲ្យគេប្រតិបត្តិព្រះតគរសិខីបច្ចេកសម្ពុទ្ធ ដោយបិណ្ឌបាតហើយ បានទៅកាន់សុគតិសួគ៌ទេវលោក អស់វារៈ ៧ ដង ដោយវិបាករបស់កម្មនោះឯង បានដំណែងជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះឯង អស់វារៈ ៧ ដង ដោយសេសសល់ផលកម្មនោះឯង ។ បពិត្រមហារាជ លុះសេដ្ឋីគហបតីនោះឲ្យរួចហើយ ជាអ្នកមានសេចក្តីក្តៅក្រហាយក្នុងពេលជាខាងក្រោយថា ទាសៈទាំងឡាយក្តី កម្មករទាំងឡាយក្តី គប្បីបរិភោគនូវបិណ្ឌបាតនេះប្រសើរជាង ដោយវិបាកនៃកម្មនោះ បានជាសេដ្ឋីគហបតីនោះ មិនបង្អោនចិត្តទៅដើម្បីបរិភោគនូវភត្តឆ្ងាញ់ពិសា

ជាតរូបរជតាយ វត្ថភោគាយ ចិត្តំ នមតិ ជាតរូបរជតាយ យានភោគាយ ចិត្តំ នមតិ ជាតរូបរជតានំ បញ្ចន្នំ កាមគុណានំ ភោគាយ ចិត្តំ នមតិ ។ យំ ខោ សោ មហារាជ សេដ្ឋី គហបតិ ភាតុ ច បន ឯកំ បុត្តកំ សាបតេយ្យស្ស ការណា ជីវិតា វោរោបេសិ តស្ស កម្មស្ស វិបាកេនពហូនិ វស្សានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ និរយេ បច្ចិត្ថ តស្សេវ វស្សសតានិ ពហូនិ កម្មស្ស វិបាកាវសេសេន ឥទំ សត្តមំ អបុត្តកំ សាបតេយ្យំ រាជកោសំ បវេសេតិ ។ តស្ស ខោ បន មហារាជ សេដ្ឋិស្ស គហបតិស្ស បុរាណញ្ច បុញ្ញំ បរិក្ខីណំ នវញ្ច បុញ្ញំ អនុបចិតំ ។ អជ្ជ បន មហារាជ សេដ្ឋី គហបតិ មហារោរុវេ និរយេ បច្ចតីតិ ។ ឯវំ ភន្តេ សេដ្ឋី គហបតិ មហារោរុវំ និរយំ ឧបបន្នោតិ ។ ឯវំ មហារាជ សេដ្ឋី គហបតិ មហារោរុវំ និរយំ ឧបបន្នោតិ ។

មិនបង្អោនចិត្តទៅ ដើម្បីប្រើប្រាស់សំពត់ល្អថ្លៃថ្លា មិនបង្អោនចិត្តទៅ ដើម្បីប្រើប្រាស់យានល្អ មិនបង្អោនចិត្តទៅ ដើម្បីបរិភោគបញ្ចកាមគុណដ៏ថ្លៃថ្លា ។ បពិត្រមហារាជ សេដ្ឋីគហបតីនោះ ផ្តាច់ជីវិតកូនប្រុសម្នាក់របស់បង ព្រោះហេតុនៃទ្រព្យ បានជាឆេះនៅក្នុងនរកអស់ឆ្នាំជាច្រើន អស់ពាន់នៃឆ្នាំជាច្រើន អស់សែននៃឆ្នាំជាច្រើន ដោយវិបាកនៃកម្មនោះ ជនទាំងឡាយ តែងទៅនាំយកទ្រព្យសេដ្ឋីគ្មានកូននេះមកដាក់ព្រះឃ្លាំង អស់វារៈជាគម្រប់ ៧ ដងនេះហើយ ដោយសេសសល់នៃផលកម្មនោះឯង អស់រយនៃឆ្នាំជាច្រើន ។ បពិត្រមហារាជ បុណ្យចាស់របស់សេដ្ឋីគហបតីនោះ អស់រលីងទៅ ទាំងបុណ្យថ្មី គាត់ក៏មិនសន្សំឡើង ។ បពិត្រមហារាជ ក៏ក្នុងថ្ងៃនេះ សេដ្ឋីគហបតីនោះឆេះក្នុងមហារោរុវនរក ។ បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីចូលទៅកាន់មហារោរុវនរក មែនឬ ។ បពិត្រមហារាជ សេដ្ឋីគហបតីចូលទៅកាន់មហារោរុវនរក មែន ។

កោសលសំយុត្តស្ស ជដិលវគ្គេ និគមគាថា

[៣៩៦] ឥធមហោច ។ បេ ។

ធញ្ញំ ធនំ រជតំ ជាតរូបំ
បរិគ្គហំ វាបិ យទត្ថិ កិញ្ចិ
ទាសា កម្មករា បេស្សា
យេ ចស្ស អនុជីវិនោ
សព្វន្នាទាយ គន្តព្វំ
សព្វំ និក្ខិបគាមិនំ
យញ្ច ករោតិ កាយេន
វាចាយ ឧទ ចេតសា
តំ ហិ តស្ស សកំ ហោតិ
តញ្ច អាទាយ គច្ឆតិ
តញ្ចស្ស អនុគំ ហោតិ
ឆាយាវ អនុបាយិនី

កោសលសំយុត្ត ជដិលវគ្គ និគមគាថា

[៣៩៦] ព្រះមានព្រះភាគ ទ្រង់បានត្រាស់នូវពាក្យនេះហើយ ។ បេ ។

របស់ណាមួយ គឺស្រូវ ទ្រព្យ ប្រាក់ មាស ដែលខ្លួន ហួងហែងក្តី ជនទាំងឡាយណា គឺទាសៈ កម្មករ អ្នក បម្រើ និងអ្នកស៊ីឈ្នួលនៃខ្លួននោះក្តី បុគ្គលមិនគប្បីកាន់យក របស់ទាំងអស់នោះទៅបានទេ ត្រូវតែលះបង់របស់ទាំងអស់ នោះហើយទៅ លុះតែបុគ្គលធ្វើកម្មណា ដោយកាយ ដោយ វាចា ឬដោយចិត្ត កម្មនោះឯង ជារបស់ខ្លួននៃបុគ្គល នោះ បុគ្គលតែងកាន់យកនូវកម្មនោះទៅ កម្មនោះតែងទៅ តាមនូវបុគ្គលនោះ ដូចជាស្រមោល អន្ទោលតាមប្រាណ

តស្មា ករេយ្យ កល្យាណំ

និចយំ សម្បរាយិកំ

បុញ្ញានិ បរលោកស្មឹ

បតិដ្ឋា ហោន្តិ បាណិនន្តិ

ជដិលវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ជដិលា បញ្ចរាជានោ

ទោណបាកកុរេន ច

សង្គាមេន ទ្វេ វុត្តានិ

ធីតរា[១] ទ្វេ អប្បមាទេន ច

អបុត្តកេន ទ្វេ វុត្តា

វគ្គោ តេន បវុច្ចតីតិ ។

១ ម. មល្លិកា ។

ព្រោះហេតុនោះ សាធុជនគួរធ្វើកម្មជាកុសល ដែលប្រព្រឹត្តទៅក្នុងបរលោកឲ្យចម្រើន (ព្រោះថា) បុណ្យទាំងឡាយតែងជាទីពឹងរបស់សត្វទាំងឡាយ ក្នុងបរលោក ។

ចប់ ជដិលវគ្គ ទី ២ ។

## បញ្ជីរឿងនៃជដិលវគ្គទីពីរនោះ គឺ

ជដិលសូត្រ ១ បញ្ចរាជសូត្រ ១ ទោណបាកសូត្រ ១ សង្គាមសូត្រ ២ ដែលលោកពោលហើយ ធីតុសូត្រ ១ អប្បមាទសូត្រ ២ អបុត្តកសូត្រ ២ ដែលលោកពោលហើយ ព្រោះហេតុនោះ បានជាលោកហៅថា វគ្គ ។

# តតិយោ បុគ្គលវគ្គោ

## បឋមំ បុគ្គលសុត្តំ

[៣៩៧] សាវត្ថិយំ... អថខោ រាជា បសេនទិ-
កោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និ-
សិន្នំ ខោ រាជានំ បសេនទិកោសលំ ភគវា ឯត-
ទវោច ចត្តារោមេ មហារាជ បុគ្គលា សន្តោ សំវិជ្ជ-
មានា លោកស្មឹ កតមេ ចត្តារោ តមោ តមបរាយ-
នោ តមោ ជោតិបរាយនោ ជោតិ តមបរាយនោ
ជោតិ ជោតិបរាយនោ ។

[៣៩៨] កថញ្ច មហារាជ បុគ្គលោ តមោ
តមបរាយនោ ហោតិ ។ ឥធ មហារាជ ឯកច្ចោ
បុគ្គលោ នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌា-
លកុលេ វា វេណកុលេ វា នេសាទកុលេ វា

# បុគ្គលវគ្គ ទី ៣

## បុគ្គលសូត្រ ទី ១

[៣៩៧] ទៀបក្រុងសាវត្ថី... គ្រានោះឯង ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះបាទបសេនទិកោសល ដែលគង់ក្នុងទីសមគួរហើយដូច្នេះថា បពិត្រមហារាជ បុគ្គល ៤ ពួក មានប្រាកដក្នុងលោក បុគ្គល ៤ ពួក តើដូចម្តេច គឺបុគ្គលងងឹត មានងងឹតទៅខាងមុខ ១ បុគ្គលងងឹត មានពន្លឺទៅខាងមុខ ១ បុគ្គលភ្លឺ មានងងឹតទៅខាងមុខ ១ បុគ្គលភ្លឺ មានពន្លឺទៅខាងមុខ ១ ។

[៣៩៨] បពិត្រមហារាជ បុគ្គលងងឹត មានងងឹត ទៅខាងមុខដូចម្តេច ។ បពិត្រមហារាជ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺក្នុងត្រកូលចណ្ឌាល ឬត្រកូលជាងផែង ត្រកូលព្រាន

រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្ន-
បានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆា-
ទោ លព្ភតិ ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទស្សិកោ
ឱកោដិមកោ ពវ្ហាពាធោ កាណោ វា កុណី
វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស
បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស
សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន ទុច្ចរិតំ
ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។
សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា
មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា
អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ សេយ្យ-
ថាបិ មហារាជ បុរិសោ អន្ធការា វា អន្ធការំ
គច្ឆេយ្យ តមា វា តមំ គច្ឆេយ្យ លោហិតមលា វា
លោហិតមលំ គច្ឆេយ្យ តថូបមាហំ[១] មហារាជ
ឥមំ បុគ្គលំ វទាមិ ។ ឯវំ ខោ[២] មហារាជ បុគ្គលោ
តមោ តមបរាយណោ ហោតិ ។

---

១ ម. តថូបមំ ។ ២ ឱ. ខោសទ្ទោ នត្ថិ ។

ឬក៏ត្រកូលធ្វើរថ ត្រកូលអ្នកចោលសម្រាម ជាត្រកូលអ្នកក្រីក្រមិនស្តុកស្តម្ភ មានបាយទឹកនិងភោជន ចិញ្ចឹមជីវិតដោយលំបាក រកបាយបរិភោគនិងសំពត់ស្លៀកបានដោយលំបាក បុគ្គលនោះ មានសម្បុរក៏អាក្រក់ មិនគួរមើល ទាបតឿ មានអាពាធច្រើន ខ្វាក់ភ្នែក ឬក្ញែងកួង ខ្វក ឬខ្វិន រកបាយ ទឹក សំពត់ស្លៀក យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងស្រឡាប ទីដេក ទីសំណាក់អាស្រ័យនិងគ្រឿងឧបករណ៍នៃប្រទីប មិនបានជាប្រក្រតី ។ បុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ លុះបុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ បែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ ក៏ចូលទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ។ បពិត្រមហារាជ ប្រៀបដូចជាបុរសចេញអំពីទីងងឹតឈឹង ទៅកាន់ទីងងឹតឈឹង ឬចេញអំពីទីងងឹតព្រិល ៗ ទៅកាន់ទីងងឹតព្រិល ៗ ចេញអំពីទីមន្ទិលក្រហម ទៅកាន់ទីមន្ទិលក្រហម យ៉ាងណា បពិត្រមហារាជ តថាគតពោលថាបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បពិត្រមហារាជ យ៉ាងនេះឯង ហៅថាបុគ្គលងងឹត មានងងឹតទៅខាងមុខ ។

[៣៩៩] កថញ្ច មហារាជ បុគ្គលោ តមោ ជោតិបរាយនោ ហោតិ ។ ឥធ មហារាជ ឯកច្ចោ បុគ្គលោ នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា វេណកុលេ វា នេសាទកុលេ វា រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទស្សិកោ ឱកោដិមកោ ពហ្វាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ ។ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ សេយ្យថាបិ មហារាជ បុរិសោ បឋវិយា វា បល្លង្កំ អារោហេយ្យ បល្លង្កា វា អស្សបិដ្ឋឹ អារោហេយ្យ អស្សបិដ្ឋិយា វា ហត្ថិក្ខន្ធំ អារោហេយ្យ

កោសលសំយុត្ត បុគ្គលវគ្គ ភាពនៃបុគ្គលងងឹត ទៅខាងមុខភ្លឺ

[៣៩៩] បពិត្រមហារាជ បុគ្គលងងឹត មានពន្លឺទៅខាងមុខ តើដូចម្ដេច ។ បពិត្រមហារាជ បុគ្គលពួកខ្លះក្នុងលោកនេះ មកកើតក្នុងត្រកូលទាប គឺក្នុងត្រកូលចណ្ឌាល ឬត្រកូលជាងផែង ត្រកូលព្រាន ឬត្រកូលអ្នកធ្វើរថ ត្រកូលអ្នកចោលសម្រាម ជាត្រកូលអ្នកក្រីក្រ មិនសូវមានបាយទឹកនិងភោជន ចិញ្ចឹមជីវិតដោយលំបាក រកបាយបរិភោគនិងសំពត់ស្លៀកបានដោយលំបាក ។ បុគ្គលនោះ មានសម្បុរអាក្រក់ មិនគួរមើល ទាបតឿ មានអាពាធច្រើន ខ្វាក់ភ្នែក ឬក្ញែងក្ងង់ ខ្វក ឬខ្វិន រកបាយ ទឹក សំពត់ស្លៀក យាន កម្រងផ្កា គ្រឿងក្រអូប និងគ្រឿងស្រឡាប ទីដេក ទីសំណាក់អាស្រ័យ ឬគ្រឿងឧបករណ៍នៃប្រទីប មិនបានជាប្រក្រតី ។ បុគ្គលនោះ តែងប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ។ លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ ក៏ចូលទៅកាន់សុគតិសួគ៌ទេវលោក ។ បពិត្រមហារាជ ប្រៀបដូចជាបុរស ឈានអំពីផែនដីឡើងទៅលើបល្ល័ង្ក ឬឈានអំពីបល្ល័ង្កឡើងទៅលើខ្នងសេះ ឈានអំពីខ្នងសេះឡើងទៅលើ-កដំរី

ហត្ថិក្ខន្ធា វា ចាសាធំ អាពេហេយ្យ តថូបមាហំ មហារាជ ឥមំ បុគ្គលំ វទាមិ ។ ឯវំ ខោ មហារាជ បុគ្គលោ តមោ ជោតិបរាយនោ ហោតិ ។

[៤០០] កថញ្ច មហារាជ បុគ្គលោ ជោតិ តមបរាយនោ ហោតិ ។ ឥធ មហារាជ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ព្រាហ្មណមហាសាលកុលេ វា គហបតិមហាសាលកុលេ វា អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណេ បហូតធនធញ្ញេ ។ សោ ច ហោតិ អភិរូបោ ទស្សនីយោ ចាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ លាភី អន្នស្ស ចានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា

ឬឈានអំពីកដំរីឡើងទៅលើប្រាសាទ យ៉ាងណាមិញ បពិត្រមហារាជ តថាគតពោលថាបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បពិត្រមហារាជ យ៉ាងនេះឯង ហៅថាបុគ្គលងងឹត មានពន្លឺទៅខាងមុខ ។

[៤០០] បពិត្រមហារាជ ចុះបុគ្គលភ្លឺ មានងងឹតទៅខាងមុខវិញ តើដូចម្តេច ។ បពិត្រមហារាជ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល ឬក៏ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានធនច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានទ្រព្យនិងស្រូវច្រើន ។ បុគ្គលនោះ មានរូបក៏ល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង រកបាយ ទឹក សំពត់ស្លៀក យាន កម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងស្រឡាប ទីដេក ទីសំណាក់អាស្រ័យ និងគ្រឿងឧបករណ៍នៃប្រទីប បានជាប្រក្រតី ។ បុគ្គលនោះ តែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់

អថាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ សេយ្យថាបិ មហារាជ បុរិសោ បាសាទា វា ហត្ថិក្ខន្ធំ ឱរោហេយ្យ ហត្ថិក្ខន្ធា វា អស្សបិដ្ឋឹ ឱរោហេយ្យ អស្សបិដ្ឋិយា វា បល្លង្កំ ឱរោហេយ្យ បល្លង្កា វា បឋវឹ ឱរោហេយ្យ បឋវិយា វា អន្ធការំ បវិសេយ្យ តថូបមាហំ មហារាជ ឥមំ បុគ្គលំ វទាមិ ។ ឯវំ ខោ មហារាជ បុគ្គលោ ជោតិ តមបរាយនោ ហោតិ ។

[៤០១] កថញ្ច មហារាជ បុគ្គលោ ជោតិ ជោតិបរាយនោ ហោតិ ។ ឥធ មហារាជ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ព្រាហ្មណមហាសាលកុលេ វា គហបតិមហាសាលកុលេ វា អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណេ បហូតធនធញ្ញេ ។ សោ ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ

ក៏ចូលទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ។ បពិត្រមហារាជ ប្រៀបដូចបុរស ចុះអំពីប្រាសាទមកកាន់កដំរី ចុះអំពីកដំរីមកកាន់ខ្នងសេះ ចុះអំពីខ្នងសេះមកកាន់បល្ល័ង្ក ចុះអំពីបល្ល័ង្កមកកាន់ផែនដី ចេញអំពីផែនដីចូលទៅកាន់ទីងងឹតឈឹង យ៉ាងណាមិញ បពិត្រមហារាជ តថាគតពោលថា បុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បពិត្រមហារាជ យ៉ាងនេះឯង ហៅថាបុគ្គលភ្លឺ មានងងឹតទៅខាងមុខ ។

[៤០១] បពិត្រមហារាជ បុគ្គលភ្លឺ មានពន្លឺទៅខាងមុខ តើដូចម្តេច ។ បពិត្រមហារាជ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល ឬក៏ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានធនច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានទ្រព្យនិងស្រូវច្រើន ។ បុគ្គលនោះ មានរូបក៏ល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង

លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ ។ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ សេយ្យថាបិ មហារាជ បុរិសោ បល្លង្កា វា បល្លង្កំ សង្កមេយ្យ អស្សបិដ្ឋិយា វា អស្សបិដ្ឋឹ សង្កមេយ្យ ហត្ថិក្ខន្ធា វា ហត្ថិក្ខន្ធំ សង្កមេយ្យ បាសាទា វា បាសាទំ សង្កមេយ្យ តថូបមាហំ មហារាជ ឥមំ បុគ្គលំ វទាមិ ។ ឯវំ ខោ មហារាជ បុគ្គលោ ជោតិ ជោតិបរាយណោ ហោតិ ។ ឥមេ ខោ មហារាជ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

រកបាយ ទឹក សំពត់ស្លៀក យាន កម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងស្រឡាប ទីដេក ទីសំណាក់អាស្រ័យ និងគ្រឿងឧបករណ៍នៃប្រទីបបានជាប្រក្រតី ។ បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ។ លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ បែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ ក៏ចូលទៅកាន់សុគតិសួគ៌ទេវលោក ។ បពិត្រមហារាជ ប្រៀបដូចបុរស ឆ្លងអំពីបល្ល័ង្កទៅកាន់បល្ល័ង្ក ឬឆ្លងអំពីខ្នងសេះទៅកាន់ខ្នងសេះ ឆ្លងអំពីកដំរីទីកាន់កដំរី ឆ្លងអំពីប្រាសាទទៅកាន់ប្រាសាទ យ៉ាងណាមិញ បពិត្រមហារាជ តថាគតពោលថា បុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បពិត្រមហារាជ យ៉ាងនេះឯង ហៅថាបុគ្គលភ្លឺ មានពន្លឺទៅខាងមុខ ។ បពិត្រមហារាជ បុគ្គលទាំង ៤ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។

២៤៩

កោសលសំយុត្តស្ស បុគ្គលវគ្គេ និគមគាថា

[៤០២] ឥទមវោច ។ បេ ។

ទឡិទ្ទោ បុរិសោ រាជ
អស្សទ្ធោ ហោតិ មច្ឆរី
កទរិយោ បាបសង្កប្បោ
មិច្ឆាទិដ្ឋិ អនាទរោ
សមណេ ព្រាហ្មណេ វាបិ
អញ្ញេ វាបិ វណិព្វកេ
អក្កោសតិ បរិភាសតិ
នត្ថិកោ ហោតិ រោសកោ
ទទមានំ និវារេតិ
យាចមានាន ភោជនំ
តាទិសោ បុរិសោ រាជ
មិយ្យមានោ ជនាធិប
ឧបេតិ និរយំ ឃោរំ
តមោ តមបរាយនោ
ទឡិទ្ទោ បុរិសោ រាជ
សទ្ធោ ហោតិ អមច្ឆរី

កោសលសំយុត្ត បុគ្គលវគ្គ និគមគាថា

[៤០២] ព្រះអង្គទ្រង់ត្រាស់នូវពាក្យនេះ ។ បេ ។ បពិត្រព្រះរាជា បុរសទ័លក្រ ឥតមានសទ្ធា មានតែសេចក្តីកំណាញ់និងសេចក្តីស្វះរកទ្រឹស មានតម្រិះអាក្រក់ យល់ខុស មិនអើពើ រមែងជេរគម្រាមពួកសមណៈ ឬព្រាហ្មណ៍ ឬក៏ពួកបុគ្គលដទៃដែលពណ៌នាហើយសូម ជាអ្នកមិនត្រូវការ ជាអ្នកខឹង ហាមឃាត់ជនដែលកំពុងឲ្យនូវភោជន ដល់ពួកស្មូម បពិត្រព្រះរាជាជាធំជាងជន បុរសបែបនោះ កាលបើស្លាប់ទៅហើយ ទៀងតែចូលទៅកាន់នរកដ៏ជ្រៅពន្ទឹក (យ៉ាងនេះ) ឈ្មោះថាបុគ្គលងងឹត មានងងឹតទៅខាងមុខ បពិត្រព្រះរាជា បុរសជាអ្នកទ័លក្រ តែថាមិនកំណាញ់ មាន

ទទាតិ សេដ្ឋសង្កប្បោ
អព្យត្តមនសោ នរោ
សមណោ ព្រាហ្មណោ វាបិ
អញ្ញោ វាបិ វណិព្វកោ
ឧដ្ឋាយ អភិវាទេតិ
សមចរិយាយ សិក្ខតិ
ទទមានំ ន វារេតិ
យាចមានាន ភោជនំ
តាទិសោ បុរិសោ រាជ
មិយ្យមានោ ជនាធិប
ឧបេតិ តិទិវំ ឋានំ
តមោ ជោតិបរាយនោ
អឌ្ឍោ ចេ[១] បុរិសោ រាជ
អស្សទ្ធោ ហោតិ មច្ឆរី
កទរិយោ បាបសង្កប្បោ
មិច្ឆាទិដ្ឋិ អនាទរោ

---
១ ឱ. ម. ឥ ។

សទ្ធា រមែងឲ្យទាន ជាជនមានតម្រិះប្រសើរ មានចិត្តមិនរាយមាយ រមែងក្រោកឡើងគោរពពួកសមណព្រាហ្មណ៍ ឬពួកបុគ្គលដទៃដែលពណ៌នាហើយសូម សិក្សាដើម្បីប្រព្រឹត្តស្មើ មិនហាមឃាត់ជនកំពុងឲ្យភោជនដល់ពួកស្មូម បពិត្រព្រះរាជាជាធំជាងជន បុរសបែបនោះ កាលបើស្លាប់ទៅរមែងចូលទៅកាន់ត្រៃទិព្វស្ថាន (យ៉ាងនេះ) ឈ្មោះថាបុគ្គលងងឹត មានពន្លឺទៅខាងមុខ បពិត្រព្រះរាជា បើបុរសជាអ្នកស្អុកស្គម្ភ ឥតមានសទ្ធា មានតែសេចក្ដីកំណាញ់និងសេចក្ដីស្មូរកន្ទ្រើស មានតម្រិះអាក្រក់ យល់ខុស មិនអើពើ

២៦១

កោសលសំយុត្តស្ស បុគ្គលវគ្គេ និគមគាថា

សមណោ ព្រាហ្មណោ វាបិ
អញ្ញោ វាបិ វណិព្វកោ
អក្កោសតិ បរិភាសតិ
នត្ថិកោ ហោតិ រោសកោ
ទទមានំ និវារេតិ
យាចមានាន ភោជនំ
តាទិសោ បុរិសោ រាជ
មិយ្យមានោ ជនាធិប
ឧបេតិ និរយំ ឃោរំ
ជោតិ តមបរាយនោ
អញ្ញោ ចេ[១] បុរិសោ រាជ
សទ្ធោ ហោតិ អមច្ឆរី
ទទាតិ សេដ្ឋសង្កប្បោ
អព្យគ្គមនសោ នរោ

---
១ ឱ. ម. វេ ។

កោសលសំយុត្ត បុគ្គលវគ្គ និគមគាថា

រមែងជេរគម្រាមពួកសមណព្រាហ្មណ៍ ឬពួកបុគ្គលដទៃដែល ពណ៌នាហើយសូម ជាអ្នកមិនត្រូវការ ជាអ្នកខឹង ហាម ឃាត់ជនកំពុងឲ្យនូវភោជនដល់ពួកស្មូម បពិត្រព្រះរាជាជា ធំជាងជន បុរសបែបនោះ កាលបើស្លាប់ទៅ រមែង ចូលទៅកាន់នរកដ៏ជ្រៅពន្លឹក (យ៉ាងនេះ) ឈ្មោះថាបុគ្គល ភ្លឺ មានងងឹតទៅខាងមុខ បពិត្រព្រះរាជា បើបុរសជា អ្នកស្តុកស្តម្ភ មានសទ្ធា មិនមានសេចក្តីកំណាញ់ រមែង ឲ្យទាន ជាជនមានតម្រិះប្រសើរ មានចិត្តមិនរាយមាយ

សមណោ ព្រាហ្មណោ វាបិ
អញ្ញោ វាបិ វណិព្វកោ
ឧដ្ឋាយ អភិវាទេតិ
សមចរិយាយ សិក្ខតិ
ននមានំ ន វាវេតិ
យាចមានាន ភោជនំ
តាទិសោ បុរិសោ រាជ
មិយ្យមានោ ជនាធិប
ឧបេតិ តិទិវំ ឋានំ
ជោតិ ជោតិបរាយនោតិ ។

# ទុតិយំ អយ្យិកាសុត្តំ

[៤០៣] សាវត្ថីនិទានំ ។ អថខោ រាជា បសេនទិ-
កោសលោ ទិវាទិវស្ស យេន ភគវា តេនុបសង្កមិ ឧ-
បសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯ-
កមន្តំ និសិន្នំ ខោ រាជានំ បសេនទិកោសលំ ភគវា

រមែងក្រោកឡើងគោរពបង្គំពួកសមណព្រាហ្មណ៍ ឬ ពួកបុគ្គលដែលពណ៌នាហើយសូម សិក្សាដើម្បីប្រព្រឹត្តស្មើ មិនហាមឃាត់នូវជនកំពុងឲ្យនូវភោជនដល់ពួកស្មូម បពិត្រព្រះរាជាជាធំជាងជន បុរសបែបនោះ កាលបើស្លាប់ទៅរមែងចូលទៅកាន់ត្រៃទិព្វស្ថាន (យ៉ាងនេះ) ឈ្មោះថាបុគ្គលភ្លឺ មានពន្លឺទៅខាងមុខ ។

# អយ្យិកាសូត្រ ទី ២

[៤០៣] សាវត្ថីនិទាន ។ គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ទាំងថ្ងៃត្រង់ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ

ឯតទវោច  ហន្ទ  កុតោ  នុ  ត្វំ  មហារាជ  អាគច្ឆសិ  ទិវាទិវស្សាតិ ។ អយ្យិកា[១] មេ ភន្តេ កាលកតា ជិណ្ណា វុឌ្ឍា មហល្លិកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា អយ្យិកា ខោ បន ភន្តេ បិយា អហោសិ មនាបា ហត្ថិរតនេន ចេបហំ[២] ភន្តេ លភេយ្យំ មា មេ អយ្យិកា កាលមកាសីតិ ហត្ថិរត-នំបហំ ទទេយ្យំ មា មេ អយ្យិកា កាលមកាសីតិ អស្សរតនេន ចេបហំ ភន្តេ លភេយ្យំ មា មេ អយ្យិកា កាលមកាសីតិ អស្សរតនំបហំ ទទេយ្យំ មា មេ អយ្យិកា កាលមកាសីតិ គាមវរេន ចេបហំ ភន្តេ លភេយ្យំ មា មេ អយ្យិកា កាលមកាសីតិ គាម-វរំបហំ ទទេយ្យំ មា មេ អយ្យិកា កាលមកាសីតិ

១ ម. ឯវំ ។ ឱ. អយ្យកា ។ ២ ឱ. បាហំ ។

ទ្រង់ត្រាស់ដូច្នេះថា បពិត្រមហារាជ អើហ្ន៎ មហារាជស្តេចមកពីទីណា ទាំងថ្ងៃត្រង់ដូច្នេះ ។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអយ្យិកាខ្ញុំព្រះអង្គគ្រាំគ្រា ព្រឹទ្ធា ចាស់ កន្លងកាលវែងឆ្ងាយហើយ ចូលមកក្នុងបច្ឆិមវ័យហើយ មានព្រះជន្ម ១២០ វស្សាអំពីកំណើត (ឥឡូវនេះ) ធ្វើមរណកាលទៅហើយ បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះអយ្យិកាក៏ជាទីស្រឡាញ់ ជាទីពេញចិត្ត បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គដូរដោយហត្ថិរ័តន៍ កុំឲ្យអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានដូច្នេះ ខ្ញុំព្រះអង្គនឹងឲ្យហត្ថិរ័តន៍ ដោយគិតថា កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គដូរដោយអស្សរ័តន៍ កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានដូច្នេះ ខ្ញុំព្រះអង្គនឹងឲ្យអស្សរ័តន៍ ដោយគិតថា កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គដូរដោយស្រុកសួយ កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានដូច្នេះ ខ្ញុំព្រះអង្គនឹងឲ្យស្រុកសួយ ដោយគិតថា កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានឡើយ

ជនបទេន ចេបហំ ភន្តេ លភេយ្យំ មា មេ អយ្យិកា កាលមកាសីតិ ជនបទំបហំ ទទេយ្យំ មា មេ អយ្យិកា កាលមកាសីតិ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា សព្វេ សត្តា មរណធម្មា មរណបរិយោសានា មរណំ អនតីតាតិ ។

[៤០៤] ឯវមេតំ មហារាជ ឯវមេតំ មហារាជ សព្វេ សត្តា មរណធម្មា មរណបរិយោសានា មរណំ អនតីតា ។ សេយ្យថាបិ មហារាជ យានិ កានិចិ កុម្ភ-ការកភាជនានិ អាមកានិ ចេវ បក្កានិ ច សព្វានិ តានិ ភេទនធម្មានិ ភេទនបរិយោសានានិ ភេទនំ អនតីតានិ ឯវមេវ ខោ មហារាជ សព្វេ សត្តា មរ-ណធម្មា មរណបរិយោសានា មរណំ អនតីតាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គដូរដោយជនបទ កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានដូច្នេះ ខ្ញុំព្រះអង្គនឹងឲ្យជនបទដោយគិតថា កុំឲ្យព្រះអយ្យិការបស់ខ្ញុំព្រះអង្គធ្វើមរណកាលបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា សុភាសិតនេះ ព្រះអង្គត្រាស់ថា សត្វទាំងអស់ មានសេចក្តីស្លាប់ជាធម្មតា មានសេចក្តីស្លាប់ជាទីបំផុត មិនកន្លងនូវសេចក្តីស្លាប់បានឡើយ ។

[៤០៤] ព្រះអង្គត្រាស់ថា បពិត្រមហារាជ នុ៎ះយ៉ាងនេះហើយ បពិត្រមហារាជ នុ៎ះយ៉ាងនេះហើយ សត្វទាំងអស់ មានសេចក្តីស្លាប់ជាធម្មតា មានសេចក្តីស្លាប់ជាទីបំផុត មិនកន្លងនូវសេចក្តីស្លាប់បានទេ ។ បពិត្រមហារាជ ប្រៀបដូចជាភាជន៍នៃស្មូនឆ្នាំងទាំងឡាយ ណាមួយទោះបីឆៅក្តី ឆ្អិនក្តី ភាជន៍ទាំងអស់នោះ ក៏គង់មានកិរិយាបែកធ្លាយជាធម្មតា មានកិរិយាបែកធ្លាយជាទីបំផុត មិនកន្លងនូវកិរិយាបែកធ្លាយបានឡើយ យ៉ាងណាមិញ បពិត្រមហារាជ សត្វទាំងអស់ មានសេចក្តី ស្លាប់ជាធម្មតា មានសេចក្តីស្លាប់ជាទីបំផុត មិនកន្លងនូវសេចក្តីស្លាប់បានឡើយ ក៏យ៉ាងនេះឯង ។

[៤០៥] ឥទមវោច ។ បេ ។

សព្វេ សត្តា មរិស្សន្តិ
មរណន្តំ ហិ ជីវិតំ
យថាកម្មំ គមិស្សន្តិ
បុញ្ញបាបផលូបគា
និរយំ បាបកម្មន្តា
បុញ្ញកម្មា ច សុគតឹ
តស្មា ករេយ្យ កល្យាណំ
និចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

## តតិយំ លោកសុត្តំ

[៤០៦] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ លោកស្ស ធម្មា ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិ-តាយ ទុក្ខាយ អផាសុវិហារាយាតិ ។

[៤០៥] *ព្រះអង្គទ្រង់ត្រាស់នូវពាក្យនេះ ។ បេ ។ សត្វទាំងអស់ មុខជានឹងស្លាប់ ព្រោះថា ជីវិត (របស់សត្វ) មានសេចក្តីស្លាប់ជាទីបំផុត សត្វទាំងឡាយ ទទួលយកផលបុណ្យផលបាបហើយ នឹងទៅតាមយថាកម្ម គឺអ្នកធ្វើបាប តែងទៅកាន់នរក ចំណែកខាងអ្នកធ្វើបុណ្យ តែងទៅកាន់សុគតិភព ព្រោះហេតុនោះ បុគ្គលគួរតែធ្វើបុណ្យ ដែលនាំទៅក្នុងបរលោក ឲ្យចម្រើន (ព្រោះថា) បុណ្យទាំងឡាយ ជាទីពឹងរបស់ពួកសត្វ ក្នុងបរលោក ។*

## លោកសូត្រ ទី ៣

[៤០៦] *ទៀបក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសលគង់ក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់លោក មានប៉ុន្មានយ៉ាង កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ ។*

[៤០៧] តយោ ខោ មហារាជ លោកស្ស ធម្មា ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ។ កតមេ តយោ ។ លោភោ ខោ មហារាជ លោកស្ស ធម្មោ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ទោសោ ខោ មហារាជ លោកស្ស ធម្មោ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ មោហោ ខោ មហារាជ លោកស្ស ធម្មោ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ។ ឥមេ ខោ មហារាជ តយោ លោកស្ស ធម្មា ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

[៤០៨] ឥទមវោច ។ បេ ។

លោភោ ទោសោ ច មោហោ ច
បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា
តចសារំវ សម្ផលន្តិ ។

[៤០៧] ព្រះអង្គត្រាស់ថា បពិត្រមហារាជ ធម៌របស់លោកមាន ៣ យ៉ាង កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ ។ ធម៌ ៣ យ៉ាង ដូចម្តេច ។ បពិត្រមហារាជ លោភៈ ជាធម៌របស់លោក ១ កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ បពិត្រមហារាជ ទោសៈ ជាធម៌របស់លោក ១ កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ បពិត្រមហារាជ មោហៈ ជាធម៌របស់លោក ១ កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ ។ បពិត្រមហារាជ ធម៌របស់លោក ទាំង ៣ នេះឯង កាលដែលកើតឡើង តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីនៅមិនសប្បាយ ។

[៤០៨] ព្រះអង្គទ្រង់ត្រាស់នូវពាក្យនេះ ។ បេ ។

លោភៈក្តី ទោសៈក្តី មោហៈក្តី កើតអំពីខ្លួនហើយ តែងបៀតបៀននូវបុរសដែលមានចេតនាអាក្រក់វិញ ដូចផ្លែរបស់ខ្លួន បៀតបៀននូវឈើដែលមានសម្បកជាខ្លឹម ។

# ចតុត្ថំ ឥស្សត្ថសុត្តំ

[៤០៩] សាវត្ថិយំ... ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច កត្ថ នុ ខោ ភន្តេ ទានំ ទាតព្វន្តិ ។ យត្ថ ខោ មហារាជ ចិត្តំ បសីទតីតិ ។ កត្ថ បន ភន្តេ ទិន្នំ មហប្ផលន្តិ ។

[៤១០] អញ្ញំ ខោ ឯតំ មហារាជ កត្ថ ទានំ ទាតព្វំ អញ្ញំ បនេតំ កត្ថ ទិន្នំ មហប្ផលន្តិ សីលវតោ ខោ មហារាជ ទិន្នំ មហប្ផលំ នោ តថា ទុស្សីលេ ។ តេនហិ មហារាជ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។

# ឥស្សត្ថសូត្រ ទី ៤

[៤០៩] ទៀបក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទាន តើបុគ្គលត្រូវឲ្យដល់បុគ្គលណា ។ ព្រះអង្គត្រាស់ថា បពិត្រមហារាជ ចិត្តជ្រះថ្លាចំពោះបុគ្គលណា (ត្រូវឲ្យដល់បុគ្គលនោះ) ។ បពិត្រព្រះអង្គដ៏ចម្រើន ទាន ដែលបុគ្គលឲ្យហើយដល់បុគ្គលណា ទើបមានផលច្រើន ។

[៤១០] ព្រះអង្គត្រាស់ថា បពិត្រមហារាជ ពាក្យថា ទាន បុគ្គលត្រូវឲ្យដល់បុគ្គលណា នេះជាពាក្យដទៃ ពាក្យថា ទាន ដែលបុគ្គលឲ្យហើយដល់បុគ្គលណា ទើបមានផលច្រើន នេះក៏ជាពាក្យដទៃដែរ បពិត្រមហារាជ ទាន ដែលបុគ្គលឲ្យដល់បុគ្គលមានសីល ទើបមានផលច្រើន ទាន ដែលបុគ្គលឲ្យដល់បុគ្គលទ្រុស្តសីល មិនមានផលច្រើនទេ ។ បពិត្រមហារាជ បើដូច្នោះ តថាគតនឹងសួរព្រះអង្គក្នុងប្រស្នានេះ ប្រស្នានេះគាប់ចិត្តព្រះអង្គ យ៉ាងណា ត្រូវព្រះអង្គព្យាករនូវប្រស្នានោះ យ៉ាងនោះ ។

[៤១១] តំ កឹ មញ្ញសិ មហារាជ ឥធ ត្យស្ស យុទ្ធំ បច្ចុបដ្ឋិតំ សង្គាមោ សមុបព្យូឡ្ហោ អថ អាគច្ឆេយ្យ ខត្តិយកុមារោ អសិក្ខិតោ អកតហត្ថោ អកតយោគ្គោ អកតុបាសនោ ភីរុ ឆម្ភី ឧត្រាសី បលាយី ភរេយ្យាសិ តំ បុរិសំ អត្ថោ ច តេ តាទិសេន បុរិសេនាតិ ។ នាហំ ភន្តេ ភរេយ្យំ តំ បុរិសំ ន ច មេ អត្ថោ តាទិសេន បុរិសេនាតិ ។ អថ អាគច្ឆេយ្យ ព្រាហ្មណកុមារោ អសិក្ខិតោ ។ បេ ។ អថ អាគច្ឆេយ្យ វេស្សកុមារោ អសិក្ខិតោ ។ បេ ។ អថ អាគច្ឆេយ្យ សុទ្ទកុមារោ អសិក្ខិតោ ។ បេ ។ ន ច មេ អត្ថោ តាទិសេន បុរិសេនាតិ ។

[៤១១] បពិត្រមហារាជ ព្រះអង្គសំគាល់ហេតុនោះដូចម្តេច ក្នុងជនបទនេះ មានចម្បាំងមកប្រាកដដល់ព្រះអង្គហើយ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែជាខត្តិយកុមារ មិនបានសិក្សា មិនមានថ្វីដៃ មិនទាន់កបន្ទាយ មិនចេះថ្លៃងសរ មានសេចក្តីខ្លាច រន្ធត់ តក់ស្លុត រត់ទៅជាប្រក្រតី តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនគួរចិញ្ចឹមបុរសនោះ ខ្ញុំព្រះអង្គមិនត្រូវការដោយបុរសបែបនោះឡើយ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែជាកុមាររបស់ព្រាហ្មណត្រកូល មិនបានសិក្សា ។ បេ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែជាកុមាររបស់វេស្សត្រកូល មិនបានសិក្សា ។ បេ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែជាកុមាររបស់សុទ្ទត្រកូល មិនបានសិក្សា ។ បេ ។ ខ្ញុំព្រះអង្គក៏មិនត្រូវការដោយបុរសបែបដូច្នោះឡើយ ។

[៤១២] តំ កឹ មញ្ញសិ មហារាជ ឥធ ត្យស្ស យុទ្ធំ បច្ចុបដ្ឋិតំ សង្គាមោ សមុបព្យុឡ្ហោ អថ អាគច្ឆេយ្យ ខត្តិយកុមារោ សុសិក្ខិតោ កាតហាត្ថោ កាតយោគ្គោ កាតុចាសនោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី ភរេយ្យាសិ តំ បុរិសំ អត្ថោ ច តេ តាទិសេន បុរិសេនាតិ ។ ភរេយ្យាហំ ភន្តេ តំ បុរិសំ អត្ថោ ច មេ តាទិសេន បុរិសេនាតិ ។ អថ អាគច្ឆេយ្យ ព្រាហ្មណកុមារោ ។ បេ ។ អថ អាគច្ឆេយ្យ វេស្សកុមារោ ។ បេ ។ អថ អាគច្ឆេយ្យ សុទ្ទកុមារោ សុសិក្ខិតោ កាតហាត្ថោ កាតយោគ្គោ កាតុចាសនោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី ភរេយ្យាសិ តំ បុរិសំ អត្ថោ ច តេ តាទិសេន បុរិសេនាតិ ។ ភរេយ្យាហំ ភន្តេ តំ បុរិសំ អត្ថោ ច មេ តាទិសេន បុរិសេនាតិ ។

[៤១២] បពិត្រមហារាជ ព្រះអង្គសំគាល់នូវហេតុនោះដូចម្តេច ក្នុងជនបទនេះ មានចម្បាំងមកប្រាកដដល់ព្រះអង្គហើយ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ ចួនជាខត្តិយកុមារ បានសិក្សាល្អ មានថ្វីដៃ បានទាំងកបន្ទាយ ចេះថ្វៃងសរ ឥតមានសេចក្តីខ្លាច រន្ធត់ តក់ស្លុត មិនរត់ទៅឡើយ តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរចិញ្ចឹមបុរសនោះ ខ្ញុំព្រះអង្គត្រូវការ ដោយបុរសបែបនោះដែរ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ កុមាររបស់ព្រាហ្មណ-ត្រកូល ។ បេ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ កុមាររបស់វេស្សត្រកូល ។ បេ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ កុមាររបស់សុទ្ទត្រកូល បានសិក្សាល្អ មានថ្វីដៃ បានទាំងកបន្ទាយ ចេះថ្វៃងសរ ឥតមានសេចក្តីខ្លាច រន្ធត់ តក់ស្លុត មិនរត់ទៅឡើយ តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរចិញ្ចឹមបុរសនោះ ខ្ញុំព្រះអង្គត្រូវការដោយបុរសបែបនោះដែរ ។

[៤១៣] ឯវមេវ ខោ មហារាជ យស្មា ចេបិ កុលា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច ហោតិ បញ្ចង្គវិប្បហីនោ បញ្ចង្គសមន្នាគតោ តស្មឹ ទិន្នំ មហប្ផលំ ហោតិ ។ កតមានិ បញ្ចង្គានិ បហីនានិ ហោន្តិ ។ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ វិចិកិច្ឆា បហីនា ហោ-តិ ។ ឥមានិ បញ្ចង្គានិ បហីនានិ ហោន្តិ ។ កតមេ-ហិ បញ្ចហង្គេហិ សមន្នាគតោ ហោតិ ។ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន ស-មាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញា-ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញ្ញាណទស្ស-នក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ បញ្ចហង្គេ-ហិ សមន្នាគតោ ហោតិ ។ ឥតិ បញ្ចង្គវិប្បហីនេ បញ្ចង្គសមន្នាគតេ ទិន្នំ មហប្ផលន្តិ ។

[៤១៣] បពិត្រមហារាជ បើបុគ្គលចេញចាកត្រកូល ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស បុគ្គលនោះឯង បានលះបង់អង្គ ៥ ប្រកបដោយអង្គ ៥ ទាន ដែលបុគ្គលឲ្យដល់បុគ្គលនោះ ទើបមានផលច្រើន ក៏យ៉ាងនោះឯង ។ អង្គ ៥ ដែលបុគ្គលនោះបានលះបង់ដូចម្តេច ។ គឺ កាមច្ឆន្ទៈ បុគ្គលនោះបានលះបង់ហើយ ១ ព្យាបាទៈ បុគ្គលនោះបានលះបង់ហើយ ១ ថីនមិទ្ធៈ បុគ្គលនោះបានលះបង់ហើយ ១ ឧទ្ធច្ចកុក្កុច្ចៈ បុគ្គលនោះបានលះបង់ហើយ ១ វិចិកិច្ឆា បុគ្គលនោះបានលះបង់ហើយ ១ ។ អង្គទាំង ៥ នេះ បុគ្គលនោះបានលះបង់អស់ហើយ ។ បុគ្គលប្រកបដោយអង្គ ៥ ដូចម្តេច ។ បុគ្គល ប្រកបដោយសីលក្ខន្ធជារបស់អសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជារបស់អសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធ ជារបស់អសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធ ជារបស់អសេក្ខៈ ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជារបស់អសេក្ខៈ ១ ។ បុគ្គល បានប្រកបដោយអង្គទាំង ៥ នេះ ។ ទាន ដែលបុគ្គលឲ្យដល់បុគ្គលដែលបានលះបង់អង្គ ៥ ប្រកបដោយអង្គ ៥ ហើយ ទើបមានផលច្រើន ដូច្នេះឯង ។

កោសលសំយុត្តស្ស  បុគ្គលវគ្គេ  និគមគាថា

[២១៤]  ឥទមវោច  ភគវា  ។  បេ  ។

ឥស្សត្ថំ  ពលវីរិយញ្ច

យស្មឹ  វិជ្ជេថ  មាណវេ

តំ  យុទ្ធត្ថោ  ភជេ  រាជា

នាសូរំ  ជាតិបច្ចយា

តថេវ  ខន្តិសោរច្ចំ

ធម្មា  យស្មឹ  បតិដ្ឋិតា

តមរិយវុត្តិ  មេធាវឹ

ហីនជច្ចម្បិ  បូជយេ

ការយេ  អស្សមេ  រម្មេ

វាសយេត្ថ  ពហុស្សុតេ

កោសលសំយុត្ត  បុគ្គលវគ្គ  និគមគាថា

[៤១៤] ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះ ។ បេ ។ សិល្បសាស្ត្រខាន់ធ្នូក្តី កម្លាំងនិងសេចក្តីព្យាយាមក្តី មាន ក្នុងមាណពណា ព្រះរាជាដែលត្រូវការដោយចម្បាំង គួរ ចិញ្ចឹមមាណពនោះ មិនគួរចិញ្ចឹមមាណពដែលឥតក្លៀវក្លា ដោយហេតុគឺជាតិឡើយ ធម៌ទាំងឡាយ គឺសេចក្តីអត់ធន់ និងសេចក្តីស្ងួត (ព្រះអរហត្ត) តាំងនៅក្នុងបុគ្គលណាហើយ បុគ្គលត្រូវតែបូជានូវបុគ្គលនោះ សូម្បីមានជាតិដ៏ថោកទាប តែជាអ្នកប្រាជ្ញ ចិញ្ចឹមជីវិតដ៏ប្រសើរ បុគ្គលគប្បីឲ្យគេធ្វើ អាស្រមជាទីត្រេកអរ ហើយញ៉ាំងពហុស្សូតឲ្យនៅក្នុងទីនុ៎ះ

បបញ្ច វិទេ កាយិកា

ទុគ្គេ សង្កមនានិ ច

អន្នំ បានំ ខាទនីយំ

វត្ថសេនាសនានិ ច

ទទេយ្យ ឧជុភូតេសុ

វិប្បសន្នេន ចេតសា

យថាបិ មេឃោ ថនយំ

វិជ្ជុមាលី សតក្កកុ

ថលំ និន្នញ្ច បូរេតិ

អភិវស្សំ វសុន្ធរំ

តថេវ សទ្ធោ សុតវា

អភិសង្ខច្ច ភោជនំ

វណិព្វកេ តប្បយតិ

អន្នបានេន បណ្ឌិតោ

អនុមោទមានោ បកិរេតិ

ទេថ ទេថាតិ ភាសតិ

បុគ្គល គប្បីជីកអណ្តូងឬស្រះ ក្នុងព្រៃ ធ្វើស្ពាន ក្នុងទីដែលលំបាកឆ្លង បុគ្គលមានចិត្តជ្រះថ្លា គប្បីឲ្យបាយ ទឹក ខាទនីយៈ សំពត់និងទីសេនាសនៈទាំងឡាយ ដល់ពួកបុគ្គលដែលមានកាយនិងចិត្តត្រង់ មហាមេឃ គ្រហឹមមានរបៀបផ្លេកបន្ទោរមានកំពូលរាប់រយ បង្អុរចុះលើផែនដី ញុំាងទីទួលនិងទីទាបឲ្យពេញបាន យ៉ាងណាមិញ បុគ្គលជាបណ្ឌិត មានសទ្ធា ចេះដឹងហើយ តាក់តែងភោជនឲ្យពួកវណិព្វកៈឆ្អែត ដោយបាយនិងទឹក ក៏យ៉ាងនោះដែរ បុគ្គលមានចិត្តត្រេកអរ បាចសាចទ្រព្យធ្វើជាទាន ពោលពាក្យថា អ្នកទាំងឡាយចូរឲ្យ អ្នកទាំងឡាយចូរឲ្យដូច្នេះ

តញ្ហិស្ស តទ្ធិតំ[១] ហោតិ
ទេវស្សេវ បវស្សតោ
សា បុញ្ញជាភា វិបុលា
ជាតា អភិវស្សតីតិ ។

## បញ្ចមំ បព្វតោបមសុត្តំ

[៤១៨] សាវត្ថីនិទានំ ។ អថខោ រាជា បសេនទិកោសលោ ទិវាទិវស្ស យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ បសេនទិកោសលំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ មហារាជ អាគច្ឆសិ ទិវាទិវស្សាតិ ។ យានិ តានិ ភន្តេ រញ្ញោ ខត្តិយានំ មុទ្ធាភិសិត្តានំ ឥស្សរិយមទមត្តានំ កាមគេធបរិយុដ្ឋិតានំ ជនបទត្ថាវរិយប្បត្តានំ មហន្តំ បឋវីមណ្ឌលំ អភិវិជិយ អជ្ឈាវសន្តានំ រាជករណីយានិ ភវន្តិ តេស្វាហំ ឯតរហិ ឧស្សុក្កំ អាបន្នោតិ ។

១ ឱ. ម. គទ្ធិតំ ។

ពាក្យនោះ បុគ្គលនោះបានបញ្ចេញឲ្យលាន់ឮហើយ ធារទឹកគឺបុណ្យដ៏ធំទូលាយនោះ នឹងបង្អុរចុះលើបុគ្គលអ្នកឲ្យ ដូចជាមហាមេឃដែលបង្អុរភ្លៀងមកលើផែនដីដែរ ។

## បព្វតោបមសូត្រ ទី ៥

[៤១៥] សាវត្ថីនិទាន ។ គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ទាំងថ្ងៃត្រង់ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា អើហ្ន៎មហារាជ ព្រះអង្គទើបស្តេចយាងមកពីទីណា ទាំងថ្ងៃត្រង់ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្សត្រជាស្តេចបានមុទ្ធាភិសេករួចហើយ ស្រវឹងជ្រប់ដោយភាពជាធំ មានសេចក្តីត្រេកអរក្នុងកាមគ្របសង្កត់ ដល់នូវការមាំមួនក្នុងជនបទ នៅត្រួតត្រាបបវរិមណ្ឌលដ៏ធំ តែងមានរាជកិច្ចណា ឥឡូវនេះ ខ្ញុំព្រះអង្គដល់នូវការខ្វល់ខ្វាយចំពោះរាជ-កិច្ចនោះ ។

[៤១៦] តំ កឹ មញ្ញសិ មហារាជ ឥធ តេ បុរិសោ អាគច្ឆេយ្យ បុរត្ថិមាយ ទិសាយ សទ្ធាយិកោ បច្ចយិកោ សោ តំ ឧបសង្កមិត្វា ឯវំ វទេយ្យ យគ្ឃេ មហារាជ ជានេយ្យ អហំ អាគច្ឆាមិ បុរត្ថិមាយ ទិសាយ តត្ថទ្ទសំ មហន្តំ បព្វតំ អព្ភសមំ សព្វេ បាណេ និប្បោថេន្តោ[១] អាគច្ឆតិ យន្តេ មហារាជ ករណីយំ តំ ករោហីតិ ។ អថ ទុតិយោ បុរិសោ អាគច្ឆេយ្យ ទក្ខិណាយ ទិសាយ ។ បេ ។ អថ តតិយោ បុរិសោ អាគច្ឆេយ្យ បច្ឆិមាយ ទិសាយ ។ បេ ។ អថ ចតុត្ថោ បុរិសោ អាគច្ឆេយ្យ ឧត្តរាយ ទិសាយ សទ្ធាយិកោ បច្ចយិកោ សោ តំ ឧបសង្កមិត្វា ឯវំ វទេយ្យ យគ្ឃេ មហារាជ ជានេយ្យ អហំ អាគច្ឆាមិ ឧត្តរាយ ទិសាយ តត្ថទ្ទសំ មហន្តំ បព្វតំ អព្ភសមំ សព្វេ បាណេ និប្បោថេន្តោ អាគច្ឆតិ យន្តេ មហារាជ ករណីយំ តំ ករោហីតិ ។

១ ឱ. និប្បោដេន្តោ ។

[៤១៦] បពិត្រមហារាជ ព្រះអង្គសំគាល់ហេតុនោះដូចម្តេច បុរសរបស់ព្រះអង្គក្នុងជនបទនេះ មានពាក្យគួរជឿ មានពាក្យគួរធ្វើតាម មកពីទិសខាងកើត បុរសនោះចូលមកគាល់ព្រះអង្គ ក្រាបបង្គំទូល យ៉ាងនេះថា សូមព្រះរាជតេជះតំកល់លើត្បូង បពិត្រមហារាជ សូមទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពីទិសខាងកើត បានឃើញភ្នំធំខ្ពស់ស្មើនឹងអាកាស រមៀលមកកិនសត្វទាំងអស់ ក្នុងទីនោះ បពិត្រមហារាជ សូមព្រះអង្គធ្វើកិច្ចដែលទ្រង់ត្រូវធ្វើឥឡូវនេះចុះ ។ លំដាប់នោះ បុរសទីពីរមកអំពីទិសខាងត្បូង ។ បេ ។ លំដាប់នោះ បុរសទីបីមកអំពីទិសខាងលិច ។ បេ ។ លំដាប់នោះ បុរសទីបួន មានពាក្យគួរជឿ មានពាក្យគួរធ្វើតាម មកអំពីទិសខាងជើង បុរសនោះចូលមកគាល់ព្រះអង្គ ក្រាបបង្គំទូលយ៉ាងនេះថា សូមព្រះរាជតេជះតំកល់លើត្បូង បពិត្រមហារាជ សូមទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពីទិសខាងជើង បានឃើញភ្នំធំខ្ពស់ស្មើនឹងអាកាស រមៀលមកកិនសត្វទាំងអស់ ក្នុងទីនោះ បពិត្រមហារាជ សូមព្រះអង្គធ្វើកិច្ចដែលទ្រង់ត្រូវធ្វើឥឡូវនេះចុះ ។

ឯវរូបេ តេ មហារាជ មហតិ មហព្ភយេ សមុប្បន្នេ ទារុណេ មនុស្សក្ខយេ[១] ទុល្លភេ មនុស្សត្តេ កិមស្ស ករណីយន្តិ ។ ឯវរូបេ មេ ភន្តេ មហតិ មហព្ភយេ សមុប្បន្នេ ទារុណេ មនុស្សក្ខយេ ទុល្លភេ មនុស្សត្តេ កិមស្ស ករណីយំ អញ្ញត្រ ធម្មចរិយាយ អញ្ញត្រ សមចរិយាយ អញ្ញត្រ កុសលកិរិយាយ អញ្ញត្រ បុញ្ញកិរិយាយាតិ ។

[៤១៧] អារោចេមិ ខោ តេ មហារាជ បដិវេទេមិ ខោ តេ មហារាជ អធិវត្តតិ ខោ តំ មហារាជ ជរាមរណំ អធិវត្តមានេ ច តេ មហារាជ ជរាមរណេ កិមស្ស ករណីយន្តិ ។ អធិវត្តមានេ ច មេ ភន្តេ ជរាមរណេ កិមស្ស ករណីយំ អញ្ញត្រ ធម្មចរិយាយ អញ្ញត្រ សមចរិយាយ អញ្ញត្រ កុសលកិរិយាយ អញ្ញត្រ បុញ្ញកិរិយាយ យានិ តានិ ភន្តេ រញ្ញោ ខត្តិយានំ

១ ម. មនុស្សាកាយេ ។

បពិត្រមហារាជ កាលបើភ័យធំយ៉ាងនេះកើតឡើងក្តី ហេតុអាក្រក់ គឺការអស់ទៅនៃមនុស្សក្តី មនុស្សភាពដែលសត្វបានដោយក្រក្តី ព្រះអង្គអាចធ្វើបាន ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើភ័យធំយ៉ាងនេះកើតឡើងក្តី ហេតុអាក្រក់ គឺការអស់ទៅនៃមនុស្សក្តី មនុស្សភាពដែលសត្វបានដោយក្រក្តី ខ្ញុំព្រះអង្គគប្បីធ្វើដូចម្តេចបាន ក្រៅអំពីការប្រព្រឹត្តធម៌ ក្រៅអំពីការប្រព្រឹត្តស្មើ ក្រៅអំពីការធ្វើកុសល ក្រៅអំពីការធ្វើបុណ្យ ។

[៤១៧] ព្រះអង្គត្រាស់ថា បពិត្រមហារាជ តថាគតសូមថ្វាយព្រះពរព្រះអង្គ បពិត្រមហារាជ តថាគតសូមថ្វាយដំណឹងព្រះអង្គ បពិត្រមហារាជ ជរានិងមរណៈរមែងគ្របសង្កត់ព្រះអង្គពិត បពិត្រមហារាជ កាលបើជរានិងមរណៈគ្របសង្កត់ព្រះអង្គ តើព្រះអង្គត្រូវធ្វើដូចម្តេច ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើជរានិងមរណៈគ្របសង្កត់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គគប្បីធ្វើដូចម្តេចបាន ក្រៅអំពីការប្រព្រឹត្តធម៌ ក្រៅអំពីការប្រព្រឹត្តស្មើ ក្រៅអំពីការធ្វើកុសល ក្រៅអំពីការធ្វើបុណ្យ បពិត្រព្រះអង្គដ៏ចម្រើន ក្សត្រជាស្តេច

មុទ្ធាវសិត្តានំ ឥស្សរិយមទមត្តានំ កាមគេធបរិយុដ្ឋិតានំ ជនបទត្ថាវរិយប្បត្តានំ មហន្តំ បឋវីមណ្ឌលំ អភិវិជិយ អជ្ឈាវសន្តានំ ហត្ថិយុទ្ធានិ ភវន្តិ តេសម្បិ ភន្តេ ហត្ថិយុទ្ធានំ នត្ថិ គតិ នត្ថិ វិសយោ អជិវត្តមានេ ជរាមរណេ យានិបិ តានិ ភន្តេ រញ្ញំ ខត្តិយានំ មុទ្ធាវសិត្តានំ ។ បេ ។ អជ្ឈាវសន្តានំ អស្សយុទ្ធានិ ភវន្តិ ។ បេ ។ រថយុទ្ធានិ ភវន្តិ ។ បេ ។ បត្តិយុទ្ធានិ ភវន្តិ តេសម្បិ ភន្តេ បត្តិយុទ្ធានំ នត្ថិ គតិ នត្ថិ វិសយោ អជិវត្តមានេ ជរាមរណេ សន្តិ ខោ បន ភន្តេ ឥមស្មឹ រាជកុលេ មន្តិនោ មហាមត្តា យេ បហោន្តិ[១] អាគតេ បច្ចត្ថិកេ មន្តេហិ ភេទយិតុំ តេសម្បិ ភន្តេ មន្តយុទ្ធានំ នត្ថិ គតិ នត្ថិ វិសយោ អជិវត្តមានេ ជរាមរណេ សំវិជ្ជតិ ខោ បន

១ ម. យេសំ ហោន្តិ ។

បានមុទ្ធាភិសេកហើយ ស្រវឹងជ្រប់ដោយភាពជាធំ មានសេចក្តីត្រេក អរក្នុងកាមមកគ្របសង្កត់ ដល់នូវការមាំមួនក្នុងជនបទ នៅត្រួតត្រា បឋវីមណ្ឌលដ៏ធំ តែងមានចម្បាំងដោយដំរីណា បពិត្រព្រះអង្គដ៏ចម្រើន ចម្បាំងដោយដំរីទាំងនោះ នឹងយកជាគតិ យកជាវិស័យ ក្នុងវេលា ដែលជរានិងមរណៈគ្របសង្កត់ ពុំបាន បពិត្រព្រះអង្គដ៏ចម្រើន ឯក្សត្រ ជាស្តេចបានមុទ្ធាភិសេកហើយ ។ បេ ។ នៅត្រួតត្រាបឋវីមណ្ឌលដ៏ធំ រមែងមានចម្បាំងដោយសេះ ។ បេ ។ រមែងមានចម្បាំងដោយរថ ។ បេ ។ រមែងមានចម្បាំងដោយពលថ្មើរជើង បពិត្រព្រះអង្គដ៏ចម្រើន ចម្បាំង ដោយពលថ្មើរជើងទាំងនោះ នឹងយកជាគតិ យកជាវិស័យ ក្នុងវេលា ដែលជរានិងមរណៈគ្របសង្កត់ ពុំបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងរាជត្រកូលនេះ ទោះបីមានពួកមហាមាត្យ ដែលជាមន្ត្រី ល្មមនឹង ទម្លាយពួកសត្រូវ ដែលមកដល់ដោយអាថ៌កំបាំងទាំងឡាយបាន បពិត្រ ព្រះអង្គដ៏ចម្រើន ចម្បាំងដោយអាថ៌កំបាំងទាំងនោះ នឹងយកជាគតិ យកជាវិស័យ ក្នុងវេលាដែលជរានិងមរណៈមកគ្របសង្កត់ ពុំបានដែរ

## ២៧៧

### កោសលសំយុត្តស្ស បុគ្គលវគ្គេ និគមគាថា

ភន្តេ ឥមស្មឹ រាជកុលេ បហូតំ ហិរញ្ញសុវណ្ណំ ភូមិគតញ្ចេវ វេហាសដ្ឋញ្ច យេន មយំ បហោម អាគតេ បច្ចត្ថិកេ ធនេន ឧបលាបេតុំ តេសម្បិ ភន្តេ ធនយុទ្ធានំ នត្ថិ គតិ នត្ថិ វិសយោ អភិវត្តមានេ ជរាមរណេ អភិវត្តមានេ ច មេ ភន្តេ ជរាមរណេ កិមស្ស ករណីយំ អញ្ញត្រ ធម្មចរិយាយ អញ្ញត្រ សមចរិយាយ អញ្ញត្រ កុសលកិរិយាយ អញ្ញត្រ បុញ្ញកិរិយាយាតិ ។

[៤១៨] ឯវមេតំ មហារាជ ឯវមេតំ មហារាជ អភិវត្តមានេ ច តេ ជរាមរណេ កិមស្ស ករណីយំ អញ្ញត្រ ធម្មចរិយាយ អញ្ញត្រ សមចរិយាយ អញ្ញត្រ កុសលកិរិយាយ អញ្ញត្រ បុញ្ញកិរិយាយាតិ ។

[៤១៩] ឥទមវោច ភគវា ។ បេ ។

យថាបិ សេលា វិបុលា
នភំ អាហច្ច បព្វតា
សមន្តា អនុបរិយេយ្យុំ
និប្បោថេន្តោ ចតុទ្ទិសា
ឯវំ ជរា ច មច្ចុ ច

បពិត្រព្រះអង្គដ៏ចម្រើន ក្នុងរាជត្រកូលនេះ មានប្រាក់និងមាសជាច្រើន ដែលឋិតនៅលើផែនដីក្តី ដែលឋិតនៅលើអាកាសក្តី ល្មមឲ្យខ្ញុំព្រះអង្គកម្ចាត់ពួកសត្រូវដែលមកដល់ដោយទ្រព្យបាន បពិត្រព្រះអង្គដ៏ចម្រើន តែថាចម្បាំងដោយទ្រព្យទាំងនោះ នឹងយកជាគតិ យកជាវិស័យ ក្នុងវេលាដែលជរានិងមរណៈគ្របសង្កត់ ក៏ពុំបាន បពិត្រព្រះអង្គដ៏ចម្រើន កាលដែលជរានិងមរណៈមកគ្របសង្កត់ ខ្ញុំព្រះអង្គ អាចធ្វើដូចម្តេចបាន ក្រៅអំពីការប្រព្រឹត្តធម៌ ក្រៅអំពីការប្រព្រឹត្តធម៌ស្មើ ក្រៅអំពីការធ្វើកុសល ក្រៅអំពីការធ្វើបុណ្យ ។

[៦១៨] ព្រះអង្គត្រាស់ថា បពិត្រមហារាជ នុ៎ះយ៉ាងហ្នឹងហើយ បពិត្រមហារាជ នុ៎ះយ៉ាងហ្នឹងហើយ កាលជរានិងមរណៈមកគ្របសង្កត់ ព្រះអង្គ អាចធ្វើដូចម្តេចបាន ក្រៅអំពីការប្រព្រឹត្តធម៌ ក្រៅអំពីការប្រព្រឹត្តស្មើ ក្រៅអំពីការធ្វើកុសល ក្រៅអំពីការធ្វើបុណ្យ ។

[៦១៩] ព្រះមានព្រះភាគ បានត្រាស់នូវភាសិតនេះ ។ បេ ។

ភ្នំថ្មតាន់សុទ្ធ ដ៏ធំទូលាយ ទល់នឹងអាកាស រលំចុះមកកិន
ពួកសត្វជុំវិញក្នុងទិសទាំង ៤ យ៉ាងណាមិញ ជរានិងមច្ចុ

២៧៨



អជិវត្តន្តិ ចាណិនោ

ខត្តិយេ ព្រាហ្មណេ វេស្សេ

សុទ្ទេ ចណ្ឌាលបុក្កុសេ

ន កញ្ចិ បរិវជ្ជេតិ

សព្វមេវាភិមទ្ទតិ

ន តត្ថ ហត្ថិនំ ភូមិ

ន រថានំ ន បត្តិយា

ន ចាបិ មន្តយុទ្ធេន

សក្កា ជេតុំ ធនេន វា

តស្មា ហិ បណ្ឌិតោ ចោសោ

តែងគ្របសង្កត់ពួកសត្វទាំងឡាយ ទោះក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ មនុស្សចណ្ឌាល ត្រកូលអ្នកចោលសម្រាម យ៉ាងនោះឯង ឥតមានវៀរលែងបុគ្គលណាមួយឡើយ តែង ញាំញីពួកសត្វទាំងអស់ ទីរបស់ពួកពលដំរី មិនមានក្នុង មច្ចុសង្គ្រាមនោះទេ ទីរបស់ពួកពលរថ ក៏មិនមាន ទាំងទី របស់ពួកពលថ្មើរជើង ក៏មិនមាន ក្នុងមច្ចុសង្គ្រាមនោះដែរ មួយទៀត ឥតមានអ្នកណាមួយ អាចឈ្នះ (នូវជរានិងមរ- ណៈនោះ) ដោយចម្បាំង ដោយអាថ៌កំបាំងឬដោយទ្រព្យ បានឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិតអ្នកមានប្រាជ្ញា

២៧៩

កោសលសំយុត្តស្ស  បុគ្គលវគ្គេ  ឧទ្ទានំ

សម្បស្សំ  អត្ថមត្តនោ

ពុទ្ធេ  ធម្មេ  ច  សង្ឃេ  ច

ជីវេ  សទ្ធំ  និវេសយេ

យោ  ធម្មចារី  កាយេន

វាចាយ  ឧទ  ចេតសា

ឥធេវ  នំ  បសំសន្តិ

បេច្ច  សគ្គេ  បមោទតីតិ  ។

បុគ្គលវគ្គោ  តតិយោ  ។

## តស្សុទ្ទានំ

បុត្តោ  អយ្យិកា  លោកោ

ឥស្សត្ថំ  បព្វតោបមំ

ទេសិតំ  ពុទ្ធសេដ្ឋេន

ឥមំ  កោសលបញ្ចកំ  ។

កោសលសំយុត្តំ  សមត្តំ  ។

កាលឃើញប្រយោជន៍របស់ខ្លួន  ក៏គួរញុំាងសទ្ធាឲ្យតំកល់ នៅក្នុងព្រះពុទ្ធ  ព្រះធម៌  ព្រះសង្ឃ  បុគ្គលណាប្រព្រឹត្តធម៌ ដោយកាយ  ដោយវាចា  ឬដោយចិត្ត  បណ្ឌិតទាំងឡាយ តែងសរសើរបុគ្គលនោះ  ក្នុងលោកនេះឯង  លុះបុគ្គលនោះ រំលាងខន្ធ  ទៅកាន់បរលោក  តែងត្រេកអរ  ក្នុងឋានសួគ៌ ទៀត  ។

ចប់  បុគ្គលវគ្គ  ទី  ៣  ។

# បញ្ជីរឿងនៃបុគ្គលវគ្គនោះ  គឺ

បុគ្គលសូត្រ  ១  អយ្យិកាសូត្រ  ១  លោកសូត្រ  ១  ឥស្សត្ថ-សូត្រ  ១  បព្វតោបមសូត្រ  ១  ដែលព្រះពុទ្ធដ៏ប្រសើរទ្រង់ ត្រាស់ហើយ  នេះហៅថា  កោសលបញ្ចកៈ  ។

ចប់  កោសលសំយុត្ត  ។

# មារសំយុត្តំ

## បឋមោ តបោកម្មវគ្គោ

### បឋមំ តបោកម្មសុត្តំ

[៤២០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជចាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មុត្តោ វតម្ហិ តាយ ទុក្ករការិកាយ សាធុ មុត្តោ វតម្ហិ តាយ អនត្ថសញ្ហិតាយ ទុក្ករការិកាយ សាធុ វតម្ហិ សត្តោ ពោធិសមជ្ឈគូតិ[១] ។

[៤២១] អថខោ មារោ ចាបិមា ភគវតោ ចេតសា ចេតោ បរិវិតក្កមញ្ញាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

១ ឱ. សាធុ ជិតោ សត្តោ ពោធឹ សមជ្ឈគុន្តិ ។

# មារសំយុត្ត

## តបោកម្មវគ្គ ទី ១

## តបោកម្មសូត្រ ទី ១

[៤២០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបនឹងត្រាស់ដឹងជាដំបូង គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ពួនសម្ងំ មានព្រះហឫទ័យត្រិះរិះកើតឡើង យ៉ាងនេះថា អាត្មាអញ រួចចាកទុក្ករកិរិយានោះហើយហ្ន៎ ឱហ្ន៎ អាត្មាអញ រួចចាកទុក្ករកិរិយា ដែលមិនប្រកបដោយប្រយោជន៍នោះ ល្អហើយ ឱហ្ន៎ អាត្មាអញ ជាអ្នកបានត្រាស់ដឹងនូវពោធិញ្ញាណ ប្រពៃហើយ ។

[៤២១] លំដាប់នោះឯង មារមានចិត្តបាប បានដឹងសេចក្តីត្រិះរិះក្នុងព្រះហឫទ័យ របស់ព្រះមានព្រះភាគ ដោយចិត្តរបស់ខ្លួនហើយ ចូលទៅជិតព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា

តបោកម្មា អបក្កម្ម
យេន សុជ្ឈន្តិ មាណវា
អសុទ្ធោ មញ្ញសិ សុទ្ធោ
សុទ្ធិមគ្គំ អបរទ្ធោតិ ។

[៤២២] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

អនត្ថសញ្ហិតំ ញត្វា
យំ កិញ្ចិ អបរំ តបំ
សព្វំ នត្ថាវហំ ហោតិ
ផិយារិត្តំវ[១] ធម្មនិ
សីលំ សមាធឹ បញ្ញញ្ច
មគ្គំ ពោធាយ ភាវយំ
បត្តោស្មិ បរមំ សុទ្ធឹ
និហតោ ត្វមសិ អន្តកាតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

១ ផិយារិត្តន្តិបិ បាឋោ ។ អដ្ឋកថាយម្បន ផិយារិត្តន្តិ ទិស្សតិ ។

ពួកមាណព ចេញចាកតបោកម្ម ហើយបរិសុទ្ធ ដោយផ្លូវណា ព្រះអង្គ ជាអ្នកមិនទាន់បរិសុទ្ធ ដើរវាងផ្លូវដ៏បរិសុទ្ធនោះ ហើយសំគាល់ខ្លួនថាជាអ្នកបរិសុទ្ធ ។

[៤២២] ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា អ្នកនេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបទ្រង់ត្រាស់នឹងមារមានចិត្តបាប ដោយគាថាទាំងឡាយ ថា

តថាគត ដឹងនូវតបៈដទៃណាមួយ ដែលមិនប្រកបដោយប្រយោជន៍ថា តបៈទាំងអស់ មិនជាតបៈនាំមកនូវប្រយោជន៍ឡើយ ដូចបុគ្គលកាន់ច្រវានិងថ្នោល អុំដោលទូកលើគោកដូច្នេះ ហើយចម្រើននូវសីលផង នូវសមាធិផង នូវបញ្ញាផង ដើម្បីត្រាស់ដឹងនូវមគ្គ ឥឡូវនេះ ក៏បានដល់នូវសេចក្តីបរិសុទ្ធិដ៏ប្រសើរហើយ ម្នាលមារ អ្នកឯង តថាគតបានកម្ចាត់ចេញហើយ ។

គ្រានោះឯង មារមានចិត្តបាប ក៏កើតទុក្ខ ទោមនស្ស ដោយគិតថា ព្រះមានព្រះភាគស្គាល់ច្បាស់នូវអញ ព្រះសុគតស្គាល់ច្បាស់នូវអញ ដូច្នេះហើយ ក៏ស្រាប់តែបាត់ចាកទីនោះទៅ ។

# ទុតិយំ នាគសុត្តំ

[៤២៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អព្ភោកាសេ និសិន្នោ ហោតិ ។ ទេវោ ច ឯកមេកំ ផុសាយតិ ។

[៤២៤] អថខោ មារោ បាបិមា ភគវតោ ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិនិត្វា យេន ភគវា តេនុបសង្កមិ ។ សេយ្យថាបិ នាម មហាអរិដ្ឋកោ មណិ ឯវមស្ស សីសំ ហោតិ ។ សេយ្យថាបិ នាម សុទ្ធំ រូបិយំ ឯវមស្ស ទន្តា ហោន្តិ ។ សេយ្យថាបិ នាម មហតី នង្គលីសា[១] ឯវមស្ស សោណ្ឌោ ហោតិ ។

[៤២៥] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

១ ឱ. ម. នង្គលសីសា ។

# នាគសូត្រ ទី ២

[៤២៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរនៃស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ គង់នៅក្នុងទីវាលស្រឡះ ក្នុងវេលារាត្រីងងឹតសូន្យឈឹង ។ ចួនជាភ្លៀង ក៏រលឹមស្រិប ៗ ។

[៤២៤] លំដាប់នោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត ការព្រួចព្រឺរោម ឲ្យកើតឡើងដល់ព្រះមានព្រះភាគ ក៏និម្មិតភេទជាស្តេចដំរីធំ ហើយចូលសំដៅទៅរកព្រះមានព្រះភាគ ។ ក្បាលរបស់ដំរីនោះ មានទំហំប៉ុនថ្មខ្មៅដ៏ធំ ។ ភ្លុករបស់វា ដូចប្រាក់សុទ្ធ ។ ប្រមោយរបស់វា ដូចយាមនង្គ័លដ៏ធំ ។

[៤២៥] គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា នេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបទ្រង់ត្រាស់នឹងមារមានចិត្តបាបនោះ ដោយគាថាដូច្នេះ ថា

សំសរំ ទីឃមទ្ធានំ
វណ្ណំ កត្វា សុភាសុភំ
អលន្តេ តេន បាបិម
និហតោ ត្វមសិ អន្តកាតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## តតិយំ សុភសុត្តំ

[៤២៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អជ្ឈោកាសេ និសិន្នោ ហោតិ ។ ទេវោ ច ឯកមេកំ ផុសាយតិ ។

អ្នកឯង កាលអន្ទោលទៅមក អស់កាលយូរអង្វែង បាន តំណែងភេទល្អខ្លះមិនល្អខ្លះ ម្នាលមារមានចិត្តបាប អ្នកឯង មិនគួរនឹងធ្វើដូច្នោះឡើយ ម្នាលមារ ទាំងអ្នកឯងសោត ក៏តថាគតបានកម្ចាត់ចោលស្រឡះហើយដែរ ។

គ្រានោះឯង មារមានចិត្តបាប ក៏កើតទុក្ខ តូចចិត្ត ដោយគិត ថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# សុភសូត្រ ទី ៣

[៤២៦] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះ មានព្រះភាគ ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើម អជបាលនិគ្រោធ ទៀបឆ្នេរនៃស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាលស្រឡះក្នុង វេលារាត្រីងងឹតសូន្យឈឹង ។ ចួនជាភ្លៀង ក៏រលឹមស្រិប ៗ ។

[៤២៧] អថខោ មារោ បាបិមា ភគវតោ ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ អវិទូរេ ឧច្ចាវចា វណ្ណនិភា ឧបទំសេតិ សុភា ចេវ អសុភា ច ។

[៤២៨] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

សំសរំ ទីឃមទ្ធានំ
វណ្ណំ កត្វា សុភាសុភំ
អលន្តេ តេន បាបិម
និហតោ ត្វមសិ អន្តក
យេ ច កាយេន វាចាយ
មនសា ច សុសំវុតា
ន តេ មារ វសានុគា
ន តេ មារស្ស បច្ចគូ[១]តិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

១ ម. មារស្ស ពទ្ធគូតិ ។

[៤២៧] គ្រានោះឯង មារមានចិត្តបាប ប្រាថ្នានឹងញុំាងភ័យ សេចក្តីតក់ស្លុត ការព្រួចព្រឹពោម ឲ្យកើតឡើង ដល់ព្រះមានព្រះភាគ ក៏ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏សំដែង នូវភេទដ៏ខ្ពស់និងទាប ល្អខ្លះមិនល្អខ្លះ ក្នុងទីជិតនៃព្រះមានព្រះភាគ ។

[៤២៨] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា នេះជាមារ មានចិត្តបាប ដូច្នេះហើយ ទើបទ្រង់ត្រាស់នឹងមារមានចិត្ត បាបនោះ ដោយគាថាដូច្នេះ ថា

អ្នកឯង កាលអន្ទោលទៅមក អស់កាលយូរអង្វែង បាន
តំណែងភេទល្អខ្លះមិនល្អខ្លះ ម្នាលមារ អ្នកឯង មិនគួរនឹង
ធ្វើដូច្នោះឡើយ ម្នាលមារ អ្នកឯង តថាគតបានកម្ចាត់
ចោលស្រឡះហើយ (ព្រោះថា) បុគ្គលទាំងឡាយណា
បានសង្រួមល្អ ដោយកាយ ដោយវាចា ដោយចិត្តហើយ
ម្នាលមារ បុគ្គលនោះឯង មិនលុះក្នុងអំណាចអ្នកឯងឡើយ
មិនមែនជាសិស្សគណ របស់អ្នកឯងជាមារឡើយ ។

គ្រានោះ មារមានចិត្តបាប ។ បេ ។ ក៏អន្តរធានចាកទីនោះទៅ ។

# ចតុត្ថំ  បឋមបាសសុត្តំ

[៤២៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មយ្ហំ ខោ ភិក្ខវេ យោនិសោមនសិការា យោនិសោសម្មប្បធានា អនុត្តរា វិមុត្តិ អនុប្បត្តា អនុត្តរា វិមុត្តិ សច្ឆិកតា តុម្ហេបិ ភិក្ខវេ យោនិសោមនសិការា យោនិសោសម្មប្បធានា អនុត្តរំ វិមុត្តឹ អនុបាបុណាថ អនុត្តរំ វិមុត្តឹ សច្ឆិករោថាតិ ។

# បឋមបាសសូត្រ ទី ៤

[៤២៩] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានសម្រេចហើយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះការយកចិត្តទុកដាក់ដោយឧបាយ ព្រោះសេចក្តីព្យាយាមដ៏ល្អដោយឧបាយ ម្នាលភិក្ខុទាំងឡាយ ទាំងចំណែកអ្នកទាំងឡាយ ក៏ចូរសម្រេចនូវអរហត្តផលវិមុត្តិដ៏ប្រសើរ ចូរធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលវិមុត្តិដ៏ប្រសើរ ព្រោះការយកចិត្តទុកដាក់ដោយឧបាយ ព្រោះសេចក្តីព្យាយាមដ៏ល្អដោយឧបាយ ។

[៤៣០] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈ-ភាសិ

ពទ្ធោសិ មារបាសេន
យេ ទិព្វា យេ ច មានុសា
មារពន្ធនពទ្ធោសិ
ន មេ សមណ មោក្ខសីតិ ។

[៤៣១] មុត្តាហំ មារបាសេន
យេ ទិព្វា យេ ច មានុសា
មារពន្ធនមុត្តោម្ហិ
និហតោ ត្វមសិ អន្តកាតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

[៤៣០] គ្រានោះឯង មារមានចិត្តបាប បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះ ថា

ព្រះអង្គ ជាប់ហើយដោយអន្ទាក់នៃមារ អន្ទាក់ទាំងឡាយ
ណា ៗ ទោះជារបស់ទេវតាក្តី ជារបស់មនុស្សក្តី ព្រះអង្គ
ជាប់ហើយដោយអន្ទាក់ទាំងនោះ ព្រះអង្គជាប់ចំពាក់ហើយ
ដោយចំណងនៃមារ បពិត្រព្រះសមណៈ ព្រះអង្គមិនរួច
(ចាកវិស័យ) របស់ខ្ញុំឡើយ ។

[៤៣១] ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា តថាគត រួច
ហើយចាកអន្ទាក់នៃមារ អន្ទាក់ទាំងឡាយណា ៗ ទោះជា
របស់ទេវតាក្តី ជារបស់មនុស្សក្តី តថាគតបានរួចស្រឡះ
ហើយ ចាកអន្ទាក់ទាំងនោះ តថាគតរួចហើយចាកចំណង
របស់មារ ម្នាលមារ ទាំងអ្នកឯងសោត ក៏តថាគតកម្ចាត់
បានហើយដែរ ។

គ្រានោះ មារមានចិត្តបាប ។ បេ ។ ក៏អន្តរធានចាកទីនោះទៅ ។

# បញ្ចមំ ទុតិយបាសសុត្តំ

[៤៣២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មុត្តាហំ ភិក្ខវេ សព្វបាសេហិ យេ ទិព្វា យេ ច មានុសា តុម្ហេបិ ភិក្ខវេ មុត្តា សព្វបាសេហិ យេ ទិព្វា យេ ច មានុសា ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ

# ទុតិយបាសសូត្រ ទី ៥

[៤៣២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយចាកអន្ទាក់ទាំងអស់ ទោះជារបស់ទេវតាក្តី ជារបស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ ទាំងអ្នកទាំងឡាយសោត ក៏បានរួចចាកអន្ទាក់ទាំងអស់ដែរ ទោះជារបស់ទេវតាក្តី ជារបស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ តែអ្នកទាំងឡាយកុំទៅពីរនាក់ តាមផ្លូវមួយជាមួយគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ សម្តែងធម៌

អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យា-ណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-ចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អហម្បិ ភិក្ខវេ យេន ឧរុវេលា សេនា-និគមោ[១] តេនុបសង្កមិស្សាមិ ធម្មទេសនាយាតិ ។

[៤៣៣] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ពទ្ធោសិ សព្វបាសេហិ
យេ ទិព្វា យេ ច មានុសា
មហាពន្ធនពទ្ធោសិ
ន មេ សមណ មោក្ខសីតិ ។

---

១ វិនយបោត្ថកេ យេន ឧរុវេលា យេន សេនានិគមោតិ ព្យទិស្សោ បាឋោ ទិស្សតិ ។

មានលំអបទដើម លំអបទកណ្តាល លំអបទចុង បរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ អ្នកទាំងឡាយ ចូរប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិ-បូណ៌ទាំងអស់ សត្វទាំងឡាយ ដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកគឺបញ្ញា សត្វទាំងនោះនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយបម្រុងនឹងត្រាស់ដឹងធម៌ ក៏មានដែរ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ក៏នឹងចូលទៅឯសេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងធម៌ដែរ ។

[៤៣៣] គ្រានោះឯង មារមានចិត្តបាប ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះ ថា

ព្រះអង្គជាប់ចំពាក់ហើយដោយអន្ទាក់ទាំងពួង ទោះជារបស់ទេវតាក្តី ជារបស់មនុស្សក្តី បពិត្រព្រះសមណៈ ព្រះអង្គជាបុគ្គលជាប់ចំពាក់ដោយចំណងដ៏មាំ ព្រះអង្គមិនរួច (ចាកវិស័យ) របស់ខ្ញុំឡើយ ។

[៤៣៨] មុត្តោហំ សព្វបាសេហិ

យេ ទិព្វា យេ ច មានុសា

មហាពន្ធនមុត្តោម្හិ

និហតោ ត្វមសិ អន្តកាតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

## ឆដ្ឋំ សប្បសុត្តំ

[៤៣៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អជ្ឈោ-កាសេ និសិន្នោ ហោតិ ។ ទេវោ ច ឯកមេកំ ផុសាយតិ ។

[៤៣៤] ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា តថាគតរួចចាកអន្ទាក់ទាំងអស់ហើយ ទោះជារបស់ទេវតាក្តី ជារបស់មនុស្សក្តី តថាគតរួចស្រឡះចាកចំណងដ៏មាំហើយ នៃមារ ទាំងអ្នកឯង ក៏តថាគតបានកម្ចាត់ហើយដែរ ។

គ្រានោះឯង មារមានចិត្តបាប ។ បេ ។ បាត់ចាកទីនោះទៅ ។

# សប្បសូត្រ ទី ៦

[៤៣៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាលស្រឡះ ក្នុងវេលារាត្រីងងឹតសូន្យឈឹង ។ ចួនជាមានភ្លៀងរលឹមស្រិប ៗ ។

[៤៣៦] អថខោ មារោ បាបិមា ភគវតោ ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ មហន្តំ សប្បរាជវណ្ណំ អភិនិម្មិនិត្វា យេន ភគវា តេនុបសង្កមិ ។ សេយ្យថាបិ នាម មហតី ឯករុក្ខិកា នាវា ឯវមស្ស កាយោ ហោតិ ។ សេយ្យថាបិ នាម មហន្តំ សោណ្ឌិកា កិលញ្ជំ ឯវមស្ស ផណោ ហោតិ ។ សេយ្យថាបិ នាម មហតី កោសលិកា កំសបាតិ ឯវមស្ស អក្ខីនិ ភវន្តិ ។ សេយ្យថាបិ នាម ទេវេ គឡគឡាយន្តេ វិជ្ជុល្លតា និច្ឆរន្តិ ឯវមស្ស មុខតោ ជិវ្ហា និច្ឆរន្តិ ។ សេយ្យថាបិ នាម កម្មារគគ្គរិយា ធមមានាយ សទ្ទោ ហោតិ ឯវមស្ស អស្សាសបស្សាសានំ សទ្ទោ ហោតិ ។

[៤៣៧] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

យោ សុញ្ញគេហានិ សេវតិ
សេយ្យា សោ មុនិ អត្តសញ្ញតោ
វោស្សជ្ជ ចរេយ្យ តត្ថ សោ

[៤៣៦] លំដាប់នោះឯង មារមានចិត្តបាប មានប្រាថ្នានឹងញុំាងភ័យ សេចក្តីតក់ស្លុត ការព្រួចព្រឺរោម ឲ្យកើតឡើង ដល់ព្រះមានព្រះភាគ ទើបនិម្មិតភេទជាស្តេចពស់ ១ ធំ ហើយលូនចូលទៅរកព្រះមានព្រះភាគ ។ កាយរបស់ស្តេចពស់នោះ ប៉ុនទូកធំ ១ ដែលធ្វើដោយដើមឈើទាំងមូល ។ ពពាររបស់វា ប៉ុនកន្ទេលធំសម្រាប់ហាលម្សៅរបស់អ្នកធ្វើស្រា ។ ភ្នែករបស់វា ប៉ុនភាជន៍សំរិទ្ធិធំសម្រាប់សោយ[១] របស់ព្រះបាទបសេនទិកោសល ។ អណ្តាតរបស់វា លៀនចេញអំពីមាត់មក ដូចផ្លេកបន្ទោរផ្សាយចេញក្នុងកាលមេឃគ្រហឹម ។ សូរសន្ធឹកនៃខ្យល់ដង្ហើមចេញចូលរបស់វា ដូចសំឡេងនៃស្នប់របស់ជាងលោហៈដែលគេកំពុងសប់ ។

[៤៣៧] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា ពស់នេះ ជាមារមានចិត្តបាប ដូច្នេះហើយ ទើបទ្រង់ត្រាស់នឹងមារមានចិត្តបាបនោះ ដោយគាថាដូច្នេះ ថា

បុគ្គលណា គប់រកនូវសុញ្ញាគារស្ថានដើម្បីដេក បុគ្គលនោះ
ឈ្មោះថាអ្នកប្រាជ្ញមានខ្លួនសង្រួមហើយ បុគ្គលនោះឈ្មោះ
ថាប្រព្រឹត្តលះបង់ (នូវសេចក្តីអាល័យ) ក្នុងអត្តភាពនោះ

១ ភាជន៍សម្រាប់សោយរបស់ព្រះបាទបសេនទិកោសលនេះ ទំហំប៉ុនកង់រាជរថ ។

២៩១

មារសំយុត្តស្ស តបោកម្មវគ្គេ ភគវតោ មារជ្ឈភាសនំ

បដិរូបញ្ហិ តថាវិធស្ស តំ

ចរកា ពហូ ភេរវា ពហូ

អថោ ឌំសសិរីសបា ពហូ

លោមម្បិ ន តត្ថ ឥញ្ជយេ

សុញ្ញាគារគតោ មហា មុនិ

នភំ ផលេយ្យ បឋវី ចលេយ្យ

សព្វេវ បាណា ឧទ សន្តសេយ្យុំ

សល្លម្បិ ចេ ឧរសិកម្បសេយ្យុំ[១]

ឧបធីសុ តាណំ ន ករោន្តិ ពុទ្ធាតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានា-តិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

១ ឱ. បកម្បយេយ្យុំ ។ ម. កប្បរេយ្យ ។

ព្រោះថាការប្រព្រឹត្តធម៌លះបង់ (នូវសេចក្ដីអាល័យ) ក្នុងអត្តភាពនោះ របស់បុគ្គលមានសភាពដូច្នោះ ជាការសមគួរហើយ ពួកសត្វដែលសញ្ចារទៅមក (មានខ្លាធំជាដើម) ក៏មានច្រើន អារម្មណ៍ដែលគួរខ្លាចក៏មានច្រើន ទាំងរបោមនិងសត្វទីឃជាតិក៏មានច្រើន ព្រះមហាមុនី ដែលនៅក្នុងសុញ្ញាគារស្ថានក៏មិនព្រឺព្រួចរោម ព្រោះអារម្មណ៍ដែលគួរខ្លាចទាំងនោះឡើយ (កាលបើ) អាកាសគប្បីបែក ផែនដីគប្បីកម្រើក ពួកសត្វទាំងអស់គប្បីតក់ស្លុតក្ដី សត្វទាំងឡាយទ្រទ្រង់សរព្វដ៏ទ្រូងក្ដី ព្រះពុទ្ធទាំងឡាយមិនធ្វើទីពឹងចំពោះខន្ធូបធិទាំងឡាយឡើយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏អន្តរធានចាកទីនោះទៅ ។

# សត្តមំ សុប្បតិសុត្តំ

[៤៣៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ ភគវា ពហុទេវ រត្តឹ អជ្ឈោកាសេ ចង្កមិត្វា រត្តិយា បច្ចូសសមយំ បាទេ បក្ខាលេត្វា វិហារំ បវិសិត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។

[៤៣៩] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

កឹ សោប្បសិ កឹ នុ សោប្បសិ
កិមិទំ សោប្បសិ ទុព្ភគោ វិយ
សុញ្ញមគារន្តិ សោប្បសិ
កិមិទំ សោប្បសិ សុរិយេ ឧគ្គតេតិ ។

# សុប្បតិសូត្រ ទី ៧

[៤៣៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចង្រ្កមក្នុងទីវាលស្រឡះ ដល់យប់ជ្រៅ ទ្រង់លាងព្រះបាទទាំងគូក្នុងបច្ចូសសម័យនៃរាត្រី ហើយចូលទៅកាន់វិហារ សម្រេចនូវសីហសេយ្យា ផ្អៀងទៅខាងស្តាំ យកព្រះបាទតម្រួតព្រះបាទ ទ្រង់មានសតិសម្បជញ្ញៈយកព្រះហឫទ័យទុកដាក់នូវឧដ្ឋានសញ្ញា ។

[៤៣៩] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះ ថា

ព្រះអង្គផ្ទំលក់ដូចម្តេច ព្រោះហេតុដូចម្តេចហ្ន៎ បានជា
ព្រះអង្គផ្ទំលក់ ហេតុដូចម្តេច បានជាព្រះអង្គផ្ទំលក់ដូចជា
មនុស្សស្លាប់ ព្រះអង្គផ្ទំលក់ដោយស្មានថា សុញ្ញាគារស្ថាន
អាត្មាអញ (បានហើយ) ព្រះអាទិត្យ រះឡើងហើយ
ហេតុដូចម្តេច បានជាព្រះអង្គនៅតែផ្ទំលក់ ។

[៤៤០] យស្ស ជាលិនី វិសត្តិកា

តណ្ហា នត្ថិ កុហិញ្ចិ នេតវេ

សព្វូបធីនំ បរិក្ខយា ពុទ្ធោ

សោប្បតិ កឹ តវេត្ថ មារាតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

អដ្ឋមំ នន្ទនសុត្តំ

[៤៤១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

[៤៤២] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[៤៤០] ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា បុគ្គលណា មិនមានតណ្ហាដូចជាបណ្តាញ ដែលជាប់ទៅក្នុងអារម្មណ៍ ផ្សេង ៗ ដើម្បីនាំទៅក្នុងភពណាមួយទេ បុគ្គលនោះឈ្មោះ ថាជាព្រះពុទ្ធ តែងដេកលក់ ព្រោះការអស់ទៅនៃឧបធិ ទាំងពួង ម្នាលមារ ចុះមានប្រយោជន៍អ្វី ដល់អ្នកឯង ក្នុងដំណើរនោះ ។

គ្រានោះឯង មារមានចិត្តបាប ។ បេ ។ ក៏អន្តរធានចាកទី នោះទៅ ។

# នន្ទនសូត្រ ទី ៨

[៤៤១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះ មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិត ក្រុងសាវត្ថី ។

[៤៤២] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅ រកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលគាថានេះ ក្នុងទីជិត នៃព្រះមានព្រះភាគ ថា

នន្ទតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ នន្ទតិ
ឧបធីហិ នរស្ស នន្ទនា
ន ហិ សោ នន្ទតិ យោ និរូបធីតិ ។

[៤៤៣] សោចតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ សោចតិ
ឧបធីហិ នរស្ស សោចនា
ន ហិ សោ សោចតិ យោ និរូបធីតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

# នវមំ បឋមអាយុសុត្តំ

[៤៤៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជ-គហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ

អ្នកមានកូនតែងត្រេកអរនឹងកូន អ្នកមានគោតែងត្រេកអរនឹងគោដូចគ្នា ឯឧបធិទាំងឡាយជាទីត្រេកអររបស់ជន បុគ្គលណាមិនមានឧបធិ បុគ្គលនោះ រមែងមិនត្រេកអរឡើយ ។

[៤៤៣] ព្រះសម្ពុទ្ធត្រាស់តបថា អ្នកមានកូន តែងក្រៀមក្រំចិត្តនឹងកូន អ្នកមានគោ តែងក្រៀមក្រំចិត្តនឹងគោដូចគ្នា ឧបធិជាទីក្រៀមក្រំចិត្តរបស់ជន បុគ្គលណា មិនមានឧបធិ បុគ្គលនោះ រមែងមិនក្រៀមក្រំចិត្តឡើយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# បឋមអាយុសូត្រ ទី ៩

[៤៤៤] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ កាលព្រះមានព្រះភាគទ្រង់គង់នៅក្នុងទីនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ

ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អប្បមិទំ ភិក្ខវេ មនុស្សានំ អាយុ គមនីយោ សម្បរាយោ កាត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោតិ ។

[៤៤៥] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ទីឃមាយុ មនុស្សានំ
ន នំ ហិឡេ សុបោរិសោ
ចរេយ្យ ខីរមត្តោវ
នត្ថិ មច្ចុស្ស អាគមោតិ ។

[៤៤៦] អប្បមាយុ មនុស្សានំ
ហិឡេយ្យ នំ សុបោរិសោ
ចរេយ្យាទិត្តសីសោវ
នត្ថិ មច្ចុស្ស នាគមោតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

ក៏ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះតិចណាស់ សត្វដែលត្រូវទៅកាន់បរលោក គួរធ្វើកុសល គួរប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយឈ្មោះថាមិនស្លាប់ មិនមានទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលរស់នៅយ៉ាងយូរត្រឹមមួយរយឆ្នាំ ឬ ថយចុះមកក៏មាន លើសជាងបន្តិចក៏មាន ។

[៤៤៥] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា

អាយុរបស់មនុស្សទាំងឡាយវែង សប្បុរសមិនគួរខ្ពើមឆ្អើមអាយុនោះឡើយ បុគ្គលគប្បីប្រព្រឹត្តខ្លួនឲ្យដូចជាក្មេងស្រ-វឹងទឹកដោះ (ព្រោះថា) ដំណើរមកនៃមច្ចុមិនមានទេ ។

[៤៤៦] ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អាយុរបស់មនុស្សទាំងឡាយតិច សប្បុរសគួរខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរខំប្រព្រឹត្ត (សុចរិត) ដូចបុគ្គលដែលភ្លើងកំពុងឆេះក្បាល (ព្រោះ) ដំណើរមិនមកនៃសេចក្តីស្លាប់មិនមានឡើយ ។

គ្រានោះ មារមានចិត្តបាប ។ បេ ។ ក៏បាត់ចាកទីនោះទៅ ។

# ទសមំ ទុតិយអាយុសុត្តំ

[៤៤៧] ឯកំ សមយំ ភគវា រាជគហេ ។ បេ ។ តត្រ ខោ ភគវា ឯតទវោច អប្បមិទំ ភិក្ខវេ មនុស្សានំ អាយុ គមនីយោ សម្បរាយោ កាត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោតិ ។

[៤៤៨] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ជាច្ចយន្តិ អហោរត្តា
ជីវិតំ នូបរុជ្ឈតិ
អាយុំ អនុចរិយតិ[១] មច្ចានំ
នេមិវ រថកុព្វរន្តិ ។

១ ឱ. អនុបរិយាតិ ។

# ទុតិយអាយុសូត្រ ទី ១០

[៤៤៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងរាជគ្រឹះ ។ បេ ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីនោះ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះ តិចពេក សត្វដែលត្រូវទៅកាន់បរលោក គួរធ្វើកុសល គួរប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថាមិនស្លាប់ មិនមានទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលរស់នៅយ៉ាងយូរ ត្រឹមមួយរយឆ្នាំ ឬថយតិចចុះក៏មាន លើសជាងបន្តិចទៅក៏មាន ។

[៤៤៨] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា

បើថ្ងៃនិងយប់ មិនកន្លងទៅ ជីវិតក៏មិនរួញថយចុះដែរ អាយុនៃសត្វទាំងឡាយ តែងប្រព្រឹត្តទៅតាម (ថ្ងៃនិងយប់) ដូចខ្នងកង់ ដែលវិលទៅតាមក្បាលក្រពើនៃរទេះ ។

២៩៧

មារសំយុត្តស្ស តបោកម្មវគ្គេ ឧទ្ទានំ

[៤៤៩] អច្ចយន្តិ អហោរត្តា
ជីវិតំ ឧបរុជ្ឈតិ
អាយុ ខីយតិ មច្ចានំ
កុន្នទីនំវ ឱទកន្តិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានា-
តិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

តបោកម្មវគ្គោ បឋមោ ។

## តស្សុទ្ទានំ

តបោកម្មញ្ច នាគោ ច
សុភំ បាសេន តេ ទុវេ
សប្បោ សុបតិ នន្ទនំ
អាយុនា អបរេ ទុវេតិ ។

[៤៤៩] ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ថ្ងៃនិងយប់ តែងកន្លងទៅ ជីវិតតែងរួញថយចុះមក អាយុរបស់សត្វទាំងឡាយចេះតែអស់ទៅ ដូចទឹកស្ទឹងតូចទាំងឡាយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏អន្តរធានចាកទីនោះទៅ ។

ចប់ តបោកម្មវគ្គ ទី ១ ។

# បញ្ជីរឿងនៃតបោកម្មវគ្គនោះ គឺ

តបោកម្មសូត្រ ១ នាគសូត្រ ១ សុភសូត្រ ១ បឋមបាសសូត្រ ១ ទុតិយបាសសូត្រ ១ សប្បសូត្រ ១ សុប្បតិសូត្រ ១ នន្ទនសូត្រ ១ បឋមអាយុសូត្រ ១ ទុតិយអាយុសូត្រ ១ ។

# ទុតិយោ បាសាណវគ្គោ

## បឋមំ បាសាណសុត្តំ

[៤៨០] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អព្ភោកាសេ និសិន្នោ ហោតិ ។ ទេវោ ច ឯកមេកំ ផុសាយតិ ។

[៤៨១] អថខោ មារោ បាបិមា ភគវតោ ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ អវិទូរេ មហន្តេ មហន្តេ បាសាណេ បក្កឡេសិ[១] ។

[៤៨២] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

១ ឱ. បទាលេសិ ។

# បាសាណវគ្គ ទី ២

## បាសាណសូត្រ ទី ១

[៤៥០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាលស្រឡះ ក្នុងវេលារាត្រីងងឹតសូន្យឈឹង ។ ចូនជាមានភ្លៀងរលឹមស្រិប ៗ ។

[៤៥១] គ្រានោះឯង មារមានចិត្តបាប ប្រាថ្នានឹងញុំាងភ័យ សេចក្តីតក់ស្លុត សេចក្តីព្រួចព្រឺរោម ឲ្យកើតឡើង ដល់ព្រះមានព្រះភាគ ហើយចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ប្រមៀលថ្មធំ ៗ ក្នុងទីជិតនៃព្រះមានព្រះភាគ ។

[៤៥២] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា អ្នកនេះជាមារមានចិត្តបាបដូច្នេះ ទើបត្រាស់នឹងមារមានចិត្តបាប ដោយគាថាដូច្នេះថា

សចេបិ កោវលំ សព្វំ
គិជ្ឈកូដំ គឡ្បេយ្យសិ(១)
នេវ សម្មា វិមុត្តានំ
ពុទ្ធានំ អត្ថិ ឥញ្ជិតន្តិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ទុតិយំ សីហសុត្តំ

[៤៩៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេតិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ អយំ ខោ សមណោ គោតមោ មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេតិ យន្នូនាហំ យេន សមណោ គោតមោ តេនុបសង្កមេយ្យំ វិចក្ខុកម្មាយាតិ ។

១ ឱ. ចឡ្បេស្សសិ ។ ម. ចឡ្បេយ្យាតិ ។

បើទុកជាអ្នកឯង ប្រមៀលក្នុំគិជ្ឈកូដអស់ទាំងមូល ក៏ព្រះពុទ្ធទាំងឡាយ ដែលមានចិត្តផុតស្រឡះដោយប្រពៃហើយ មិនបានញាប់ញ័រទេ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# សីហសូត្រ ទី ២

[៤៥៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានបរិស័ទជាច្រើនគាល់ត្រៀបត្រា កំពុងសម្តែងធម៌ ។ វេលានោះ មារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណគោតមនេះឯង មានបរិស័ទជាច្រើនគាល់ត្រៀបត្រា កំពុងសម្តែងធម៌ បើដូច្នោះ គួរតែអាត្មាអញចូលទៅជិតព្រះសមណ-គោតមនោះ ដើម្បីនឹងធ្វើបញ្ញាចក្ខុឲ្យវិនាស ។

[៤៩៤] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

កឹ នុ សីហោវ នទសិ
បរិសាយំ វិសារទោ
បដិមល្លោ ហិ តេ អត្ថិ
វិជិតាវី នុ មញ្ញសីតិ ។

[៤៩៥] នទន្តិ វេ មហាវីរា
បរិសាសុ វិសារទា
តថាគតា ពលប្បត្តា
តិណ្ណា លោកេ វិសត្តិកន្តិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

[៤៥៤] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា

ម្តេចក៏ព្រះអង្គ គ្រៀវក្លាក្នុងបរិស័ទម៉្លេះ បន្លឺដូចជាសីហៈ
មានអ្នកចំបាប់តនឹងព្រះអង្គដែរឬ បានជាព្រះអង្គសំគាល់
ថាមានជ័យជំនះ ។

[៤៥៥] ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អ្នកមានព្យាយាមធំ
គ្រៀវក្លាក្នុងពួកបរិស័ទ រមែងបន្លឺឡើងយ៉ាងហ្នឹងឯង ព្រះ
តថាគតទាំងឡាយ ជាអ្នកបរិបូណ៌ដោយកម្លាំង ទ្រង់បាន
ឆ្លងនូវតណ្ហាដែលជាប់ចំពាក់ក្នុងលោកហើយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏អន្តរធានចាកទីនោះទៅ ។

មារសំយុត្តស្ស បាសាណវគ្គេ ភគវន្តូបសង្កមនំ

# តតិយំ សកលិកសុត្តំ

[៤៩៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ មទ្ទកុច្ឆិស្មឹ មិគទាយេ ។ តេន ខោ បន សមយេន ភគវតោ បាទោ សកលិកាយ ខតោ ហោតិ ។ ភុសា សុទំ ភគវតោ វេទនា វត្តន្តិ សារីរិកា ទុក្ខា តិព្វា ខរា កដុកា អសាតា អមនាបា ។ តា សុទំ ភគវា សតោ សម្បជានោ អធិវាសេតិ អវិហញ្ញ-មានោ ។ អថខោ ភគវា ចតុគ្គុណំ សង្ឃាដឹ បញ្ញបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ។

[៤៩៧] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

# សកលិកសូត្រ ទី ៣

[៤៩៦] ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងឱទ្យានឈ្មោះមទ្ទកុច្ឆិ[១] ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះបាទរបស់ព្រះមានព្រះភាគ ដាំដាំដោយបំណែកថ្ម ។ បានឮថា ព្រះមានព្រះភាគ មានវេទនាច្រើន ប្រជុំក្នុងព្រះសរីរៈ ជាទុក្ខ ក្លៀវក្លា រឹងខ្លាចផ្សា មិនត្រេកអរ មិនជាទីគាប់ចិត្ត ។ បានឮថា ព្រះមានព្រះភាគ ទ្រង់មានព្រះសតិសម្បជញ្ញៈ មិនត្អូញត្អែរ ទ្រង់អត់ទ្រាំនូវវេទនាទាំងនោះ ។ ទើបព្រះមានព្រះភាគ ទ្រង់ក្រាលសង្ឃាដី ៤ ជាន់ សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្ដាំ យកព្រះបាទតម្រួតព្រះបាទ មានព្រះសតិសម្បជញ្ញៈ ។

[៤៩៧] គ្រានោះឯង មារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដោយគាថា ថា

---

១ កាលដែលព្រះបាទអជាតសត្តុរាជ ស្ថិតនៅក្នុងផ្ទៃព្រះមាតា ៗ ទ្រង់ជ្រាបថា ព្រះរាជឱរសនេះជាសត្រូវនឹងព្រះបិតារបស់ខ្លួន នឹងសម្លាប់ព្រះបិតាមិនខាន ហើយក៏ឲ្យគេច្របាច់ផ្ទៃបំណាងនឹងរំលូតព្រះរាជឱរសនោះ ក្នុងឱទ្យាននេះឯង បានជាហៅថា មទ្ទកុច្ឆិឱទ្យាន ប្រែថា សួនច្របាច់ផ្ទៃ ។ អដ្ឋកថា ។

មន្ទិយា នុ សេសិ ឧទាហុ កាវេយ្យមត្តោ
អត្ថា នុ តេ សម្បចុរា ន សន្តិ
ឯកោ វិវិត្តេ សយនាសនម្ហិ
និទ្ទាមុខោ កិមិទំ សោប្បសេវាតិ ។

[៤៩៨] ន មន្ទិយា សយាមិ នាបិ កាវេយ្យមត្តោ
អត្ថំ សមេច្ចាហមបេតសោកោ
ឯកោ វិវិត្តេ សយនាសនម្ហិ
សយាមហំ សព្វភូតានុកម្បី
យេសម្បិ សល្លំ ឧរសិ បវិដ្ឋំ
មុហុំ មុហុំ ហទយំ សេវមានំ
តេបីធ សោប្បំ លភរេ សសល្លា
កស្មា អហំ ន សុបេ វីតសល្លោ
ជគ្គំ ន សង្កេមិ នបិ ភេមិ សោត្តុំ
រត្តិន្ទិវា នានុតបន្តិ មា មំ

ព្រះអង្គទ្រង់ផ្ទំដោយសេចក្តីវង្វេងជ្រប់ឬ ឬក៏ផ្ទំដូចជាបុគ្គលដែលស្រវឹងដោយការធ្វើកាព្យឃ្លោង ប្រយោជន៍របស់ព្រះអង្គមិនមានច្រើនទេឬ ព្រោះហេតុអ្វី ព្រះអង្គជាបុគ្គលម្នាក់ឯង មានព្រះភក្ត្រឆ្ពោះទៅកាន់ការលក់ ទ្រង់ផ្ទំលក់លើអាសនៈសម្រាប់ផ្ទំដ៏ស្ងាត់យ៉ាងនេះ ។

[៤៩៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា តថាគតមិនមែនសិងដោយសេចក្តីវង្វេងជ្រប់ទេ មិនមែនសិងដូចជាបុគ្គលដែលស្រវឹងដោយការធ្វើកាព្យឃ្លោងទេ តថាគតបានសម្រេចប្រយោជន៍ ប្រាសចាកសេចក្តីសោកហើយ តថា-គតតែម្នាក់ឯង ជាអ្នកអនុគ្រោះ ដល់សត្វទាំងអស់ សិងលើអាសនៈសម្រាប់សិងដ៏ស្ងាត់ ឯពួកជនណា ដែលមានសរមុតត្រង់ទ្រូង (សរនោះ) រមែងជ្រួតជ្រាបទៅកាន់ហឫទ័យភ្លាម ៗ ជនទាំងនោះឯង ឈ្មោះថា ប្រកបដោយសរ រមែងបាននូវការដេកលក់ក្នុងលោកនេះ តថាគតជាអ្នកប្រាសចាកសរ លែងដេកលក់ហើយ កាលតថាគតភ្ញាក់ក៏លែងវង្វៀស ទាំងលែងខ្លាចនឹងការដេកលក់ ព្រោះហេតុអ្វី (ព្រោះថា) ថ្ងៃនិងយប់មិនបានដុតកម្តៅនូវតថាគតឡើយ

ហានឹ ន បស្សាមិ កុហិញ្ចិ លោកេ
តស្មា សុបេ សព្វភូតានុកម្បីតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

# ចតុត្ថំ បដិរូបសុត្តំ

[៤៩៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ វិហរតិ ឯកសាលាយំ ព្រាហ្មណគាមេ ។ តេន ខោ បន សមយេន ភគវា មហតិយា គិហិ-បរិសាយ បរិវុតោ ធម្មំ ទេសេតិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ អយំ ខោ សមណោ គោត-មោ មហតិយា គិហិបរិសាយ បរិវុតោ ធម្មំ ទេសេតិ យន្នូនាហំ យេន សមណោ គោតមោ តេនុបសង្ក-មេយ្យំ វិចក្ខុកម្មាយាតិ ។

(ឈ្មោះថាការងារមួយដែលមិនទាន់សម្រេច) របស់តថាគត មិនមានឡើយ តថាគតមិនបានឃើញសេចក្តីសាបសូន្យណា មួយក្នុងលោកឡើយ ព្រោះហេតុនោះ តថាគតឈ្មោះថា មានសេចក្តីអនុគ្រោះចំពោះសត្វទាំងអស់ ទើបផ្ចំលក់ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# បដិរូបសូត្រ ទី ៤

[៤៥៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងព្រាហ្មណគ្រាមឈ្មោះឯកសាលា នាដែនកោសល ។ សម័យនោះឯង ព្រះមានព្រះភាគ មានគិហិបរិស័ទជាច្រើនគាល់គ្រៀបគ្រា ហើយទ្រង់សំដែងធម៌ ។ វេលានោះ មារមានចិត្តបាប មានសេចក្តីត្រិះរិះ យ៉ាងនេះថា សមណគោតមនេះឯងមានគិហិបរិស័ទជាច្រើនគាល់គ្រៀបគ្រា សំដែងធម៌ បើដូច្នោះ គួរតែអាត្មាអញចូលទៅរកព្រះសមណគោតម ដើម្បីធ្វើបញ្ញាចក្ខុឲ្យវិនាស ។

[៤៦០] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

នេតំ តវ បដិរូបំ
យទញ្ញមនុសាសសិ
អនុរោធវិរោធេសុ
មា សជ្ជិត្ថ[១] តថាចរន្តិ ។

[៤៦១] ហិតានុកម្បី សម្ពុទ្ធោ
យទញ្ញមនុសាសតិ
អនុរោធវិរោធេហិ
វិប្បមុត្តោ តថាគតោតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

---
១ ឱ. ម. សជ្ជិត្ថោ ។

[៤៦០] លំដាប់នោះឯង មារមានចិត្តបាប ក៏ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ បានពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា

ព្រះអង្គ ទ្រង់ប្រៀនប្រដៅនូវបុគ្គលដទៃ ដោយពាក្យណា
ពាក្យនុ៎ះ មិនសមគួរដល់ព្រះអង្គទេ ព្រះអង្គប្រព្រឹត្តនូវធម្ម-
កថានោះ កុំជាប់ចំពាក់ចិត្តក្នុងអំណរនិងកំហឹងឡើយ ។

[៤៦១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ព្រះសម្ពុទ្ធ
មានសេចក្ដីអនុគ្រោះ ដោយប្រយោជន៍ តែងប្រៀនប្រដៅ
នូវបុគ្គលដទៃ ព្រះតថាគតទ្រង់ផុតស្រឡះ ចាកអំណរនិង
កំហឹងហើយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# បញ្ចមំ មានសសុត្តំ

[៤៦២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

[៤៦៣] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

អន្តលិក្ខចរោ បាសោ
យ្វាយំ ចរតិ មានសោ
តេន តំ ពាធយិស្សាមិ
ន មេ សមណ មោក្ខសីតិ ។

[៤៦៤] រូបា សទ្ទា គន្ធា រសា
ផោដ្ឋព្វា ច មនោរមា
ឯត្ថ មេ វិគតោ ឆន្ទោ
និហតោ ត្វមសិ អន្តកាតិ ។

# មានសសូត្រ ទី ៥

[៤៦២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

[៤៦៣] លំដាប់នោះឯង មារមានចិត្តបាប ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ បានពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

អន្ទាក់គឺរាគៈណា ដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ខ្ញុំនឹងបៀតបៀនព្រះអង្គ ដោយអន្ទាក់នោះ បពិត្រព្រះសមណៈ ព្រះអង្គមិនរួច (ចាកវិស័យ) របស់ខ្ញុំឡើយ ។

[៤៦៤] ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា រូប សំឡេង ក្លិន រស ផ្សព្វ ដែលជាទីត្រេកអររបស់ចិត្ត តថាគត បានប្រាសចាកសេចក្តីពេញចិត្ត ចំពោះអារម្មណ៍ទាំងនោះហើយ ម្នាលមារ អ្នកឯង ក៏តថាគតបានកម្ចាត់ចេញហើយ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ឆដ្ឋំ បត្តសុត្តំ

[៤៦៩] សាវត្ថិយំ អារាមេ... ។ តេន ខោ បន សមយេន ភគវា បញ្ចន្នំ ឧបាទានក្ខន្ធានំ ឧបាទាយ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ អយំ ខោ សមណោ គោតមោ បញ្ចន្នំ ឧបាទានក្ខន្ធានំ ឧបាទាយ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ យន្នូ-

លំដាប់នោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថាព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# បត្តសូត្រ ទី ៦

[៤៦៥] ក្នុងវត្តទៀបក្រុងសាវត្ថី... ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់លើកយកឧបាទានក្ខន្ធទាំង ៥ ប្រការមកពន្យល់ភិក្ខុទាំងឡាយឲ្យយល់ជាក់ ឲ្យកាន់តាម ឲ្យកើតសេចក្តីខ្មីឃ្មាត ឲ្យរីករាយដោយធម្មីកថា ។ ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្តប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងត្រចៀកប្រុងចាំស្តាប់ធម៌ ។ លំដាប់នោះឯង មារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណគោតមនេះឯង លើកយកឧបាទានក្ខន្ធទាំង ៥ ប្រការ មកពន្យល់ភិក្ខុទាំងឡាយឲ្យយល់ជាក់ ឲ្យកាន់តាម ឲ្យកើតសេចក្តីខ្មីឃ្មាត ឲ្យរីករាយដោយធម្មីកថា ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្តប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងត្រចៀកប្រុងចាំស្តាប់ធម៌ បើដូច្នោះ

ជាហំ យេន សមណោ គោតមោ តេនុបសង្កមេយ្យំ វិចក្ខុកម្មាយាតិ ។ តេន ខោ បន សមយេន សម្ពហុលា បត្តា អជ្ឈោកាសេ និក្ខិត្តា ហោន្តិ ។

[៤៦៦] អថខោ មារោ បាបិមា ពលិពទ្ទវណ្ណំ អភិនិម្មិនិត្វា យេន តេ បត្តា តេនុបសង្កមិ ។ អថខោ អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ ឯតទវោច ភិក្ខុ ភិក្ខុ ឯសោ ពលិពទ្ទោ បត្តេ ភិន្ទេយ្យាតិ ។ ឯវំ វុត្តេ ភគវា តំ ភិក្ខុំ ឯតទវោច នេសោ ភិក្ខុ ពលិពទ្ទោ មារោ ឯសោ បាបិមា តុម្ហាកំ វិចក្ខុកម្មាយ អាគតោតិ ។

[៤៦៧] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

គួរតែអាត្មាអញចូលទៅរកព្រះសមណគោតម ដើម្បីនឹងធ្វើបញ្ញាចក្ខុឲ្យវិនាសចេញ ។ ក៏សម័យនោះឯង ចួនជាមានបាត្រច្រើន ដែលដាក់ទុកក្នុងទីវាលស្រឡះ ។

[៤៦៦] គ្រានោះ មារមានចិត្តបាប បាននិម្មិតខ្លួនឲ្យមានភេទដូចជាគោហើយ ដើរសំដៅទៅត្រង់បាត្រទាំងនោះ ។ គ្រានោះឯង ភិក្ខុ ១ រូប បានស្រែកប្រាប់ទៅភិក្ខុ ១ រូបថា ហ៏ភិក្ខុ ភិក្ខុ គោនុ៎ះបំបែកបាត្រហើយ ។ កាលបើភិក្ខុនោះពោលដូច្នោះហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់នឹងភិក្ខុនោះដូច្នេះថា នែភិក្ខុ នុ៎ះមិនមែនជាគោទេ នុ៎ះឯងគឺមារមានចិត្តបាប មកដើម្បីធ្វើបញ្ញាចក្ខុរបស់អ្នកទាំងឡាយឲ្យវិនាសទេតើ ។

[៤៦៧] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថាអ្នកនេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបត្រាស់នឹងមារមានចិត្តបាបដោយគាថាដូច្នេះថា

រូបំ វេទយិតំ សញ្ញំ
វិញ្ញាណំ យញ្ច សង្ខតំ
នេសោហមស្មិ នេតំ មេ
ឯវំ តត្ថ វិរជ្ជតិ
ឯវំ វិរត្តំ ខេមត្តំ
សព្វសញ្ញោជនាតិគំ
អន្វេសំ សព្វដ្ឋានេសុ
មារសេនាបិ នាជ្ឈគាតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

## សត្តមំ អាយតនសុត្តំ

[៤៦៨] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ភគវា ឆន្នំ ផស្សាយតនានំ ឧបាទាយ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ

ខន្ធបញ្ចកៈណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បុគ្គលនឿយណាយក្នុងខន្ធបញ្ចកៈនោះយ៉ាងនេះថា នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជារបស់អញ សូម្បីមារនិងសេនានៃមារ កាលស្វែងរកក្នុងឋានទាំងពួង ក៏មិនបានឃើញនូវអត្តភាពក្សេមក្សាន្ត ប្រាសចាកតម្រេក កន្លងបង់នូវសំយោជនៈទាំងពួងយ៉ាងនេះឡើយ ។

គ្រានោះឯង មារមានចិត្តបាប ។ បេ ។ ក៏បាត់ចាកទីនោះទៅ ។

# អាយតនសូត្រ ទី ៧

[៤៦៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់លើកយកផស្សាយតនៈទាំង ៦ ប្រការមកពន្យល់ភិក្ខុទាំងឡាយឲ្យយល់ជាក់ ឲ្យកាន់តាម ឲ្យកើតសេចក្តីខ្មីឃ្មាត ឲ្យរីករាយដោយធម្មីកថា ។ ឯភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងសោតប្រសាទប្រុងស្តាប់ធម៌ ។ គ្រានោះឯង មារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា

អយំ ខោ សមណោ គោតមោ ឆន្នំ ផស្សាយត-
នានំ ឧទាទាយ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ
សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ តេ ច ភិក្ខូ
អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា
ឱហិតសោតា ធម្មំ សុណន្តិ យន្នូនាហំ យេន សម-
ណោ គោតមោ តេនុបសង្កមេយ្យំ វិចក្ខុកម្មាយាតិ ។

[៤៦៩] អថខោ មារោ បាបិមា យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ អវិទូរេ មហន្តំ
ភយភេរវំ សទ្ទំ អកាសិ អបិស្សុទំ បឋវី មញ្ញេ
ឧទ្រីយតីតិ ។ អថខោ អញ្ញតរោ ភិក្ខុ អញ្ញតរំ
ភិក្ខុំ ឯតទវោច ភិក្ខុ ភិក្ខុ ឯសា បឋវី មញ្ញេ
ឧទ្រីយតីតិ ។ ឯវំ វុត្តេ ភគវា តំ ភិក្ខុំ ឯតទវោច
នេសា ភិក្ខុ បឋវី ឧទ្រីយតិ មារោ ឯសោ បាបិមា
តុម្ហាកំ វិចក្ខុកម្មាយ អាគតោតិ ។

សមណគោតមនេះឯង បានលើកយកផស្សាយតនៈទាំង ៦ ប្រការមកពន្យល់ពួកភិក្ខុឲ្យយល់ជាក់ ឲ្យកាន់តាម ឲ្យកើតសេចក្តីខ្មីឃ្មាត ឲ្យរីករាយដោយធម្មីកថា ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងសោតប្រសាទប្រុងស្តាប់ធម៌ បើដូច្នោះ គួរតែអាត្មាអញចូលទៅរកព្រះសមណគោតម ដើម្បីធ្វើបញ្ញាចក្ខុឲ្យវិនាស ។

[៤៦៩] គ្រានោះឯង មារមានចិត្តបាប ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសំឡេងយ៉ាងខ្លាំង ដែលគួរខ្លាច ស្ញប់ស្ញែង ក្នុងទីជិតព្រះមានព្រះភាគថា ហ៏ញ៉ររផែនដីហើយ ។ គ្រានោះឯង ភិក្ខុមួយរូបបានស្រែកប្រាប់ភិក្ខុមួយរូបយ៉ាងនេះថា នែភិក្ខុ ភិក្ខុ ផែនដីនេះហាក់ដូចជាញ័រ ។ កាលភិក្ខុនោះពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់នឹងភិក្ខុនោះ យ៉ាងនេះថា ម្នាលភិក្ខុ ផែនដីនេះមិនមែនញ័រទេ នុ៎ះជាមារមានចិត្តបាប មកដើម្បីធ្វើបញ្ញាចក្ខុរបស់អ្នកទាំងឡាយឲ្យវិនាសទេតើ ។

[៤៧០] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

រូបា សទ្ទា គន្ធា រសា
ផស្សា ធម្មា ច កេវលា
ឯតំ លោកាមិសំ ឃោរំ
ឯត្ថ លោកោ វិមុច្ឆិតោ
ឯតញ្ច សមតិក្កម្ម
សតោ ពុទ្ធស្ស សាវកោ
មារធេយ្យមតិក្កម្ម
អាទិច្ចោវ វិរោចតីតិ ។

អថខោ មារោ ។ បេ ។ តត្ថេវន្តរធាយីតិ ។

[៤៧០] លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា អ្នកនេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបត្រាស់នឹងមារមានចិត្តបាប ដោយគាថាដូច្នេះថា

រូប សំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ទាំងអស់ របស់
ទាំងនុ៎ះ ជាអាមិសៈក្នុងលោកដ៏ពន្លឹក សត្វលោក តែង
ជ្រប់ចុះក្នុងអារម្មណ៍ទាំងនុ៎ះ សាវ័កដែលមានស្មារតី របស់
ព្រះពុទ្ធ បានឆ្លងផុតនូវអារម្មណ៍នុ៎ះផង បានកន្លងបង់នូវ
វដ្តៈជាទីនៅរបស់មារផង ហើយរុងរឿងដូចជាព្រះអាទិត្យ ។
គ្រានោះឯង មារ ។ បេ ។ ក៏បាត់ចាកទីនោះទៅ ។

# អដ្ឋមំ  បិណ្ឌសុត្តំ

[៤៧១] ឯកំ សមយំ ភគវា មគធេសុ វិហរតិ បញ្ចសាលាយំ ព្រាហ្មណគាមេ ។ តេន ខោ បន សមយេន បញ្ចសាលាយំ ព្រាហ្មណគាមេ កុមារកានំ ចាហុនកានិ ភវន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ បញ្ចសាលំ ព្រាហ្មណគាមំ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន បញ្ចសាលេយ្យកា ព្រាហ្មណគហបតិកា មារេន ចាបិមតា អន្វាវិដ្ឋា ភវន្តិ មា សមណោ គោតមោ បិណ្ឌមលត្ថាតិ ។ អថខោ ភគវា យថា ធោតេន បត្តេន បញ្ចសាលំ ព្រាហ្មណគាមំ បិណ្ឌាយ បាវិសិ តថា ធោតេន បត្តេន បដិក្កមិ ។

[៤៧២] អថខោ មារោ ចាបិមា យេន ភគ-វា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច

# បិណ្ឌសូត្រ ទី ៨

[៤៧១] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រាហ្មណគ្រាម ឈ្មោះបញ្ចសាលា នាដែនមគធៈ ។ សម័យនោះឯង ក្នុងព្រាហ្មណគ្រាមឈ្មោះបញ្ចសាលា មានវត្ថុសម្រាប់ទទួលភ្ញៀវរបស់កូនក្មេងទាំងឡាយ ។ គ្រានោះ ក្នុងបុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាត ក្នុងស្រុកព្រាហ្មណ៍ ឈ្មោះបញ្ចសាលា ។ សម័យនោះឯង មារមានចិត្តបាប ចូលជ្រែកពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកបញ្ចសាលា ដោយគិតថា កុំឲ្យព្រះសមណគោតម បានចង្ហាន់ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចូលទៅបិណ្ឌបាត ក្នុងព្រាហ្មណគ្រាមឈ្មោះបញ្ចសាលា ដោយបាត្រដែលលាងហើយយ៉ាងណា ទ្រង់ត្រឡប់មកវិញដោយបាត្រដែលលាងហើយយ៉ាងនោះដដែល ។*

[៤៧២] *គ្រានោះឯង មារមានចិត្តបាប ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏សួរព្រះមានព្រះភាគ យ៉ាងនេះថា*

អបិ សមណ បិណ្ឌមលត្ថាតិ ។ តថា នុ ត្វំ ចាបិម អកាសិ យថាហំ បិណ្ឌំ ន លភេយ្យន្តិ ។ តេនហិ ភន្តេ ភគវា ទុតិយម្បិ បញ្ចសាលំ ព្រាហ្មណគ្គាមំ បិណ្ឌាយ បវិសតុ តថាហំ ករិស្សាមិ យថា ភគវា បិណ្ឌំ លច្ឆតីតិ ។

[៤៧៣] អបុញ្ញំ បសវិ មារោ
អាសជ្ជនំ តថាគតំ
កឹ នុ មញ្ញសិ ចាបិម
ន មេ ចាបំ វិបច្ចតិ
សុសុខំ វត ជីវាម
យេសន្នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម
ទេវា អាភស្សរា យថាតិ ។

អថខោ មារោ ចាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

បពិត្រសមណៈ ចុះព្រះអង្គបានចង្ហាន់ដែរឬ ។ ព្រះអង្គត្រាស់តបថា ម្នាលមារ ក្រែងអ្នកឯងធ្វើតថាគតមិនឲ្យបានចង្ហាន់ឬ ។ មារតបថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគ ចូលទៅបិណ្ឌបាត ក្នុងព្រាហ្មណគ្រាមឈ្មោះបញ្ចសាលាជាលើកទីពីរទៀតចុះ ខ្ញុំព្រះអង្គនឹងធ្វើឲ្យព្រះមានព្រះភាគ បានចង្ហាន់វិញ ។

[៤៧៣] ព្រះមានព្រះភាគត្រាស់តបថា មារបៀតបៀន
នូវតថាគតនោះ រមែងបាននូវបាប ម្នាលមារមានចិត្តបាប
អ្នកសំគាល់ថា បាបមិនឲ្យផលដល់ខ្លួនអញទេឬ យើង
ដែលឥតមានកង្វល់ ឈ្មោះថារស់នៅដោយសេចក្តីសុខល្អ
ណាស់ ពួកយើង ជាអ្នកមានបីតិជាអាហារ ដូចពួក
ទេវតានៅឋានអាភស្សរៈ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

## នវមំ កស្សកសុត្តំ

[៤៧៤] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ អយំ ខោ សមណោ គោតមោ ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ ។ បេ ។ យន្នូនាហំ យេន សមណោ គោតមោ តេនុបសង្កមេយ្យំ វិចក្ខុកម្មាយាតិ ។

[៤៧៥] អថខោ មារោ បាបិមា កស្សកវណ្ណំ អភិនិម្មិនិត្វា មហន្តំ នង្គលំ ខន្ធេ ករិត្វា ទីឃំ បាចនយដ្ឋឹ គហេត្វា ហដហដកេសោ សាណសាដកនិវត្ថោ[១] កទ្ទមមក្ខិតេហិ បាទេហិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច

១ ឱ. សាណសាដិនិវត្ថោ ។

# កស្សកសូត្រ ទី ៩

[៤៧៤] សាវត្ថីនិទាន ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យយល់ជាក់ ឲ្យកាន់តាម ឲ្យកើតសេចក្ដីខ្មីឃ្មាត ឲ្យរីករាយដោយធម្មីកថា ដែលប្រកបព្រមដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងពួង មានសោតប្រសាទផ្ទៀងប្រុងស្តាប់ធម៌ ។ គ្រានោះឯង មារមានចិត្តបាប មានសេចក្ដីត្រិះរិះយ៉ាងនេះថា សមណគោតមនេះឯង ពន្យល់ភិក្ខុទាំងឡាយ ដោយធម្មីកថាដែលប្រកបដោយព្រះនិព្វាន ។ បេ ។ បើដូច្នោះ គួរអញចូលទៅរកព្រះសមណគោតមនោះ ដើម្បីធ្វើបញ្ញាចក្ខុឲ្យវិនាស ។

[៤៧៥] គ្រានោះឯង មារមានចិត្តបាប និម្មិតខ្លួនឲ្យមានភេទដូចជាអ្នកភ្ជួររាស់ លីនង្គ័លយ៉ាងធំ កាន់ដងជន្ទួញយ៉ាងវែង មានសក់កន្ទ្រើង ស្លៀកសំពត់ធ្មៃ មានជើងប្រឡាក់ភក់ ដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏សួរព្រះមានព្រះភាគ ដូច្នេះថា

អបិ សមណ ពលិពទ្ទេ អទ្ទសាតិ ។ កឹ បន ចាបិម តេ ពលិពទ្ទេហីតិ ។ មមេវ សមណ ចក្ខុ មម រូបា មម ចក្ខុសម្ផស្សវិញ្ញាណាយតនំ កុហឹ មេ សមណ គន្ត្វា មោក្ខសិ មមេវ សមណ សោតំ មម សទ្ទា ។ បេ ។ មមេវ សមណ ឃានំ មម គន្ធា ។ បេ ។ មមេវ សមណ ជិវ្ហា មម រសា ។ បេ ។ មមេវ សមណ កាយោ មម ផោដ្ឋព្វា ។ បេ ។ មមេវ សមណ មនោ មម ធម្មា មម មនោសម្ផស្សវិញ្ញាណាយតនំ កុហឹ មេ សមណ គន្ត្វា មោក្ខសីតិ ។

[៤៧៦] តវេវ ចាបិម ចក្ខុំ តវ រូបា តវ ចក្ខុ-សម្ផស្សវិញ្ញាណាយតនំ យត្ថ ច ខោ ចាបិម នត្ថិ ចក្ខុ នត្ថិ រូបា នត្ថិ ចក្ខុសម្ផស្សវិញ្ញាណាយតនំ អគតិ តវ តត្ថ ចាបិម តវេវ ចាបិម សោតំ តវ សទ្ទា តវ សោតសម្ផស្សវិញ្ញាណាយតនំ យត្ថ ច ខោ ចាបិម នត្ថិ សោតំ នត្ថិ សទ្ទា នត្ថិ សោតសម្ផស្សវិញ្ញាណាយតនំ

បពិត្រសមណៈ ព្រះអង្គបានឃើញគោផងទេ ។ ព្រះអង្គត្រាស់តបថា ចុះអ្នកឯងត្រូវការអ្វីដោយគោ ។ មារសួរថា បពិត្រសមណៈ ភ្នែករបស់ខ្ញុំ រូបរបស់ខ្ញុំ ចក្ខុសម្ផស្សនិងវិញ្ញាណាយតនៈរបស់ខ្ញុំ បពិត្រសមណៈ ព្រះអង្គទៅក្នុងទីណា ទើបរួចចាកវិស័យរបស់ខ្ញុំ បពិត្រសមណៈ ត្រចៀករបស់ខ្ញុំ សំឡេងរបស់ខ្ញុំ ។ បេ ។ បពិត្រសមណៈ ច្រមុះរបស់ខ្ញុំ ក្លិនរបស់ខ្ញុំ ។ បេ ។ បពិត្រសមណៈ អណ្តាតរបស់ខ្ញុំ រសរបស់ខ្ញុំ ។ បេ ។ បពិត្រសមណៈ កាយរបស់ខ្ញុំ ផោដ្ឋព្វៈរបស់ខ្ញុំ ។ បេ ។ បពិត្រសមណៈ ចិត្តរបស់ខ្ញុំ ធម្មារម្មណ៍របស់ខ្ញុំ មនោសម្ផស្ស និងវិញ្ញាណាយតនៈរបស់ខ្ញុំ បពិត្រសមណៈ ព្រះអង្គទៅក្នុងទីណា ទើបរួចចាកវិស័យរបស់ខ្ញុំ ។

[៤៧៦] ព្រះអង្គត្រាស់ថា ម្នាលមារ ភ្នែករបស់អ្នក រូបរបស់អ្នក ចក្ខុសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ម្នាលមារ តែថា ចក្ខុមិនមាន រូបមិនមាន ចក្ខុសម្ផស្សនិងវិញ្ញាណាយតនៈមិនមាន ក្នុងទីណា ម្នាលមារ ក្នុងទីនោះ មិនមែនជាគតិរបស់អ្នកឯងឡើយ ម្នាលមារ ត្រចៀករបស់អ្នក សំឡេងរបស់អ្នក សោតសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ម្នាលមារ តែថា ត្រចៀកមិនមាន សំឡេងមិនមាន សោតសម្ផស្សនិងវិញ្ញាណាយតនៈមិនមាន ក្នុងទីណា

អកតិ តវ តត្ថ ចាបិម តវេវ ចាបិម ឃានំ តវ គន្ធា តវ ឃានសម្ផស្សវិញ្ញាណាយតនំ យត្ថ ច ខោ ចាបិម នត្ថិ ឃានំ នត្ថិ គន្ធា នត្ថិ ឃានសម្ផស្ស-វិញ្ញាណាយតនំ អកតិ តវ តត្ថ ចាបិម តវេវ ចាបិម ជិវ្ហា តវ រសា តវ ជិវ្ហាសម្ផស្សវិញ្ញាណាយតនំ ។ បេ ។ តវេវ ចាបិម កាយោ តវ ផោដ្ឋព្វា តវ កាយ-សម្ផស្សវិញ្ញាណាយតនំ ។ បេ ។ តវេវ ចាបិម មនោ តវ ធម្មា តវ មនោសម្ផស្សវិញ្ញាណាយតនំ យត្ថ ច ខោ ចាបិម នត្ថិ មនោ នត្ថិ ធម្មា នត្ថិ មនោ-សម្ផស្សវិញ្ញាណាយតនំ អកតិ តវ តត្ថ ចាបិមាតិ ។

[៤៧៧] យំ វទន្តិ មមយិទន្តិ
យេ វទន្តិ មមន្តិ ច
ឯត្ថ ចេ តេ មនោ អត្ថិ
ន មេ សមណា មោក្ខសីតិ ។

ម្នាលមារ ក្នុងទីនោះ មិនមែនជាគតិរបស់អ្នកឯងឡើយ ម្នាលមារ ច្រមុះរបស់អ្នក ក្លិនរបស់អ្នក ឃានសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ម្នាលមារ តែថា ច្រមុះមិនមាន ក្លិនមិនមាន ឃានសម្ផស្សនិងវិញ្ញាណាយតនៈមិនមាន ក្នុងទីណា ម្នាលមារ ក្នុងទីនោះ មិនមែនជាគតិរបស់អ្នកឯងឡើយ ម្នាលមារ អណ្តាតរបស់អ្នក រសរបស់អ្នក ជិវ្ហាសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ។ បេ ។ ម្នាលមារ កាយរបស់អ្នក ផ្សព្វរបស់អ្នក កាយសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ។ បេ ។ ម្នាលមារ ចិត្តរបស់អ្នក ធម្មារម្មណ៍របស់អ្នក មនោសម្ផស្សនិងវិញ្ញាណាយតនៈរបស់អ្នកពិតមែន ម្នាលមារ តែថាចិត្តមិនមាន ធម្មារម្មណ៍មិនមាន មនោសម្ផស្សនិងវិញ្ញាណាយតនៈមិនមាន ក្នុងទីណា ម្នាលមារ ក្នុងទីនោះ មិនមែនជាគតិរបស់អ្នកទេ ។

[៤៧៧] មារពោលតបថា ជនទាំងឡាយណា តែង
ពោលនូវរបស់ណាថា នេះរបស់អញដូច្នេះក្តី ពោលថា
អញដូច្នេះក្តី បើព្រះទ័យរបស់ព្រះអង្គ មានក្នុងរបស់នុ៎ះនៃ
ជនទាំងនោះដែរ បពិត្រសមណៈ ព្រះអង្គមិនរួចចាកវិស័យ
របស់ខ្ញុំឡើយ ។

[៤៧៨] យំ វទន្តិ ន តំ មយ្ហំ
យេ វទន្តិ ន តេ អហំ
ឯវំ បាបិម ជានាហិ
ន មេ មគ្គម្បិ ទក្ខសីតិ ។

អថខោ មារោ បាបិមា ។ បេ ។ តត្ថេវន្តរធាយីតិ ។

## ទសមំ រជ្ជសុត្តំ

[៤៧៩] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ ហិមវន្តប្បទេសេ អរញ្ញកុដិកាយំ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ សក្កា នុ ខោ រជ្ជំ ការេតុំ អហនំ អឃាតយំ អជិនំ អជាបយំ អសោចំ អសោចាបយំ ធម្មេនាតិ ។

[៤៧៨] ព្រះសម្ពុទ្ធត្រាស់ថា ពួកជនពោលដោយក របស់ណា របស់នោះមិនមាន ដល់តថាគតទេ ពួកជន ណាពោលថា (អញដូច្នេះ) ពួកជននោះមិនដូចតថាគត ទេ ម្នាលមារ អ្នកឯង ចូរដឹងយ៉ាងនេះចុះ អ្នកឯងមិន ឃើញផ្លូវតថាគតទេ ។

គ្រានោះឯង មារមានចិត្តបាប ។ បេ ។ ក៏បាត់ចាកទីនោះទៅ ។

## រជ្ជសូត្រ ទី ១០

[៤៧៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងខ្ទម ក្នុងព្រៃ នាហិមវន្តប្បទេស ក្នុងដែនកោសល ។ គ្រានោះឯង ព្រះ មានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ពួនសម្ងំនៅ (ក្នុងផលសមាបត្តិ) មានព្រះទ័យត្រិះរិះកើតឡើងយ៉ាងនេះថា កាលបើតថាគត មិនសម្លាប់ មិនឲ្យគេសម្លាប់ មិនបំផ្លាញ មិនឲ្យគេបំផ្លាញ មិនសោកសៅ មិន ធ្វើគេឲ្យសោកសៅ អាចនឹងសោយរាជ្យដោយធម៌បានឬហ្ន៎ ។

[៤៨០] អថខោ មារោ បាបិមា ភគវតោ ចេ-
តសា ចេតោ បរិវិតក្កមញ្ញាយ យេន ភគវា តេនុប-
សង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច ការេតុ ភន្តេ
ភគវា រជ្ជំ ការេតុ សុគតោ រជ្ជំ អហនំ អឃាត-
យំ អជិនំ អជាបយំ អសោចំ អសោចាបយំ ធម្មេ-
នាតិ ។ កឹ បន មេ ត្វំ បាបិម បស្សសិ យំ មំ ត្វំ ឯវំ
វទេសិ ការេតុ ភន្តេ ភគវា រជ្ជំ ការេតុ សុគតោ រជ្ជំ
អហនំ អឃាតយំ អជិនំ អជាបយំ អសោចំ អ-
សោចាបយំ ធម្មេនាតិ ។ ភគវតោ ខោ ភន្តេ ចត្តា-
រោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា

[៤៨០] គ្រានោះឯង មារមានចិត្តបាប ដឹងនូវបរិវិតក្កៈក្នុងព្រះទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តរបស់ខ្លួនហើយ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់មិនសម្លាប់ មិនឲ្យគេសម្លាប់ មិនបំផ្លាញ មិនឲ្យគេបំផ្លាញ មិនសោកសៅ មិនធ្វើគេឲ្យសោកសៅ សូមសោយរាជ្យដោយធម៌ចុះ សូមព្រះសុគតសោយរាជ្យដោយធម៌ចុះ ។ ព្រះអង្គត្រាស់ថា ម្នាលមារ ចុះអ្នកឯង ឃើញហេតុដូចម្ដេច របស់តថាគត បានជាអ្នកឯងពោលនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនសម្លាប់ មិនឲ្យគេសម្លាប់ មិនបំផ្លាញគេ មិនឲ្យគេបំផ្លាញ មិនសោកសៅ មិនធ្វើគេឲ្យសោកសៅ សូមសោយរាជ្យដោយធម៌ចុះ សូមព្រះសុគតសោយរាជ្យដោយធម៌ចុះ ។ មារទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះឥទ្ធិបាទ ៤ ប្រការ ព្រះមានព្រះភាគបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ

វត្តកតា អនុជ្ជិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ បន ភន្តេ ភគវា ហិមវន្តំ បព្វតរាជំ សុវណ្ណត្តេវ អធិមុច្ចេយ្យ សុវណ្ណបព្វតស្សាតិ ។

[៤៨១] បព្វតស្ស សុវណ្ណស្ស
ជាតរូបស្ស កេវលោ
ទ្វិតាវ នាលមេកស្ស
ឥតិ វិទ្វា សមញ្ចរេ
យោ ទុក្ខមទ្ទក្ខិ យតោនិទានំ
កាមេសុ សោ ជន្តុ កថំ នមេយ្យ
ឧបធឹ វិទិត្វាន សង្គោតិ លោកេ
តស្សេវ ជន្តុ វិនយាយ សិក្ខេតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ភគវា ជានាតិ មំ សុគតោតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

បាសាណវគ្គោ ទុតិយោ ។

បានធ្វើឲ្យជាទីតាំងហើយ បានឲ្យឋិតនៅរឿយ ៗ ហើយ បានសន្សំហើយ បានប្រារព្ធដោយប្រពៃហើយ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើព្រះមានព្រះភាគ ប៉ុនប៉ង់នឹងអធិដ្ឋានស្តេចភ្នំឈ្មោះហិមវន្ត ឲ្យទៅជាមាស ភ្នំនោះ ក៏ក្លាយទៅជាភ្នំមាសបាន ។

[៤៨១] ព្រះអង្គត្រាស់ថា ភ្នំមាសសុទ្ធមានសម្បុរល្អ
ទោះបីភ្នំពីរក៏មិនល្មមគ្រាន់ដល់បុគ្គលម្នាក់ឡើយ បុគ្គលដឹង
ដូច្នេះ គួរប្រព្រឹត្តស្មើ សត្វណា បានឃើញសេចក្តីទុក្ខ
ដែលមានកាមជាហេតុ សត្វនោះនឹងបង្អោនចិត្តទៅរកកាម
ដូចម្តេចកើត លុះសត្វបានដឹងច្បាស់នូវឧបធិក្នុងលោកថាជា
គ្រឿងចំពាក់ដូច្នេះហើយ គួរសិក្សាដើម្បីកម្ចាត់បង់នូវឧបធិ
នោះចេញ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

ចប់ បាសាណវគ្គ ទី ២ ។

មារសំយុត្តស្ស បាសាណវគ្គេ ឧទ្ទានំ

## តស្សុទ្ទានំ

ចាសាណោ សីហោ សកលិកំ

បដិរូបញ្ច មានសំ

បត្តំ អាយតនំ បិណ្ឌំ

កស្សកំ រជ្ជេន តេ ឧសាតិ ។

# បញ្ជីរឿងនៃបាសាណវគ្គនោះ គឺ

*បាសាណសូត្រ ១ សីហសូត្រ ១ សកលិកសូត្រ ១ បដិ-រូបសូត្រ ១ មានសសូត្រ ១ បត្តសូត្រ ១ អាយតន-សូត្រ ១ បិណ្ឌសូត្រ ១ កស្សកសូត្រ ១ រជ្ជសូត្រ ១ រួមត្រូវជា ១០ សូត្រ ។*

# តតិយោ សម្ពហុលវគ្គោ

## បឋមំ សម្ពហុលសុត្តំ

[៤៨២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ សិលាវតិយំ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ អវិទូរេ អប្ប-មត្តា អាតាបិនោ បហិតត្តា វិហរន្តិ ។

[៤៨៣] អថខោ មារោ បាបិមា ព្រាហ្មណវណ្ណំ អភិនិម្មិនិត្វា មហន្តេន ជដណ្ឌុវេន អជិនក្ខិបនិវត្ថោ ជិណ្ណោ គោបានសិវង្កោ ឃុរុឃុរុបស្សាសី ឧទុម្ពរទណ្ឌំ គហេត្វា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច ទហរា ភវន្តោ បព្វជិតា សុសុ-កាឡកេសា ភទ្រេន យោព្វនេន សមន្នាគតា ប-ឋមេន វយសា អនិក្កីឡិតាវិនោ កាមេសុ ភុញ្ជន្តុ ភវន្តោ មានុសកេ កាមេ មា សន្ទិដ្ឋិកំ ហិត្វា

# សម្ពហុលវគ្គ ទី ៣

## សម្ពហុលសូត្រ ទី ១

[៤៨២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកសិលាវតី ក្នុងដែនសក្កៈ ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅហើយ នៅក្នុងទីជិតនៃព្រះមានព្រះភាគ ។

[៤៨៣] គ្រានោះឯង មារមានចិត្តបាប និម្មិតភេទជាព្រាហ្មណ៍ មានផ្នួងសក់ធំ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក ជាមនុស្សចាស់គ្រាំគ្រា មានកាយកោងដូចបង្កង់ផ្ទះ ដកដង្ហើមចូលឮសូរឃរូក ៗ កាន់ឈើច្រត់ដើមល្វា ចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ និយាយនឹងពួកភិក្ខុនោះដូច្នេះថា លោកដ៏ចម្រើនទាំងឡាយ ជាអ្នកបួស នៅក្មេងកំលោះ មានសក់ខ្មៅស្រិល ប្រកបដោយវ័យល្អគឺបឋមវ័យ មិនទាន់ដែលលេងកាមទាំងឡាយទេ ចូរលោកដ៏ចម្រើនទាំងឡាយ បរិភោគកាមជារបស់មនុស្សសិន ចូរលោកទាំងឡាយ កុំលះបង់សន្ទិដ្ឋិកកាម[១]

---

១ សំដៅយកកាមជារបស់មនុស្ស ។

កាលិកំ អនុជាវិត្វាតិ ។ ន ខោ មយំ ព្រាហ្មណ សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុជាវាម កាលិកញ្ច ខោ មយំ ព្រាហ្មណ ហិត្វា សន្ទិដ្ឋិកំ អនុជាវាម កាលិកា ហិ ព្រាហ្មណ កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ឯវំ វុត្តេ មារោ បាបិមា សីសំ ឱកម្បេត្វា ជិវ្ហំ និល្លាឡេត្វា តិវិសាខំ នលាដេន នលាដិកំ វុដ្ឋាបេត្វា ទណ្ឌ-មោលុព្ភ បក្កាមិ ។

[៤៨៤] អថខោ តេ ភិក្ខូ យេន ភគវា តេ-នុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-មន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

ហើយស្ទុះទៅរកកាលិកកាម[១]ឡើយ ។ ពួកភិក្ខុ តបវិញថា ម្នាលព្រាហ្មណ៍ ពួកយើងមិនមែនលះបង់សន្ទិដ្ឋិកកាម ស្ទុះទៅរកកាលិកកាមទេ ម្នាលព្រាហ្មណ៍ ពួកយើងលះបង់កាលិកកាម ស្ទុះទៅរកសន្ទិដ្ឋិក-លោកុត្តរធម៌ទេតើ ម្នាលព្រាហ្មណ៍ ព្រោះថា កាលិកកាមទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាលិកកាមនុ៎ះមានច្រើនក្រៃលែង ធម៌នេះ ជាធម៌ដែលត្រូវឃើញច្បាស់ខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងបានចំពោះខ្លួនឯង ។ កាលពួកភិក្ខុ ពោលយ៉ាងនេះ មារមានចិត្តបាប ក៏ងក់ក្បាល លៀនអណ្តាត ធ្វើថ្ងាសឲ្យមានផ្នត់ ៣ ជាន់ ហើយច្រត់ឈើច្រត់ដើរចៀសចេញទៅ ។

[៤៨២] ទើបភិក្ខុទាំងនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានជោគ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាប

---

១ សំដៅយកកាមជារបស់ទិព្វ ។

ភគវន្តំ ឯតទវោចុំ ឥធ មយំ ភន្តេ ភគវតោ អវិទូរេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាម អថខោ ភន្តេ អញ្ញតរោ ព្រាហ្មណោ មហន្តេន ជដណ្ឌុវេន អជិ-នក្ខិបនិវត្ថោ ជិណ្ណោ គោបានសិវង្កោ ឃុរុឃុរុប្ប-ស្សាសី ឧទុម្ពរទណ្ឌំ គហេត្វា យេន មយំ តេនុប-សង្កមិ ឧបសង្កមិត្វា អម្ហេ ឯតទវោច ទហរា ភវន្តោ បព្វជិតា សុសុកាឡកេសា ភទ្រេន យោព្វនេន សមន្នាគតា បឋមេន វយសា អនិក្កីឡិតាវិនោ កាមេ-សុ ភុញ្ជន្តុ ភវន្តោ មានុសកេ កាមេ មា សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវិត្ថាតិ ឯវំ វុត្តេ មយំ ភន្តេ តំ ព្រាហ្មណំ ឯតទវោចុម្ហ ន ខោ មយំ ព្រាហ្មណ សន្ទិដ្ឋិ-កំ ហិត្វា កាលិកំ អនុធាវាម កាលិកញ្ច ខោ មយំ ព្រាហ្មណ ហិត្វា សន្ទិដ្ឋិកំ អនុធាវាម កាលិ-កា ហិ ព្រាហ្មណ កាមា វុត្តា ភគវតា ពហុទុក្ខា

បង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គជាអ្នកមិនប្រមាទ ព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយនៅក្នុងទីជិតព្រះអង្គឯណោះ បពិត្រព្រះអង្គដ៏ចម្រើន ស្រាប់តែមានព្រាហ្មណ៍ម្នាក់ មានផ្នួងសក់ធំ ស្បៀកដណ្តប់ស្បែកខ្លាទាំងក្រចក ជាមនុស្សចាស់ជរា មានកាយកោងដូចបង្កង់ផ្ទះ ដកដង្ហើមឮឃរូក ៗ កាន់ឈើច្រត់ដើមល្វា ចូលទៅរកពួកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ បាននិយាយនឹងពួកខ្ញុំព្រះអង្គយ៉ាងនេះថា លោកទាំងឡាយដ៏ចម្រើន ជាអ្នកបួស នៅក្មេងកំលោះ មានសក់ខ្មៅស្រិល ប្រកបដោយវ័យល្អគឺបឋមវ័យ មិនទាន់ដែលលេងក្នុងកាមទាំងឡាយ ចូរលោកដ៏ចម្រើនទាំងឡាយ បរិភោគកាមជារបស់មនុស្សសិន កុំលះបង់សន្ទិដ្ឋិកកាម ស្ទុះទៅរកកាលិកកាមឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រាហ្មណ៍នោះពោលយ៉ាងនេះ ពួកខ្ញុំព្រះអង្គ ក៏បានតបនឹងព្រាហ្មណ៍នោះ ដូច្នេះថា ម្នាលព្រាហ្មណ៍ យើងមិនមែនលះបង់សន្ទិដ្ឋិកកាមស្ទុះទៅរកកាលិកកាមទេ ម្នាលព្រាហ្មណ៍ ពួកយើងលះបង់កាលិកកាមស្ទុះទៅរកសន្ទិដ្ឋិកលោកុត្តរធម៌ទេតើ ម្នាលព្រាហ្មណ៍ ព្រោះថា កាលិកកាមទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានទុក្ខច្រើន

ពហុចាយាសោ អាទីនវោ ឯត្ថ ភិយ្យោ សន្ទិដ្ឋិកោ អយំ ធម្មោ អកាលិកោ ឯហិបស្សិកោ ឱបន-យិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ឯវំ វុត្តេ ភន្តេ សោ ព្រាហ្មណោ សីសំ ឱកម្បេត្វា ជិវ្ហំ និល្លាឡេត្វា តិវិសាខំ នលាដេន នលាដិកំ វុដ្ឋាបេត្វា ទណ្ឌមោ-លុព្ភ បក្កាមោតិ ។

[៤៨៩] នេសោ ភិក្ខវេ ព្រាហ្មណោ មារោ ឯសោ បាបិមា តុម្ហាកំ វិចក្ខុកម្មាយ អាគតោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ គាថំ អភាសិ

យោ ទុក្ខមទ្ទក្ខិ យតោនិទានំ
កាមេសុ សោ ជន្តុ កថំ នមេយ្យ
ឧបធឹ វិទិត្វា សង្គោតិ លោកេ
តស្សេវ ជន្តុ វិនយាយ សិក្ខេតិ ។

មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាលិកកាមនុ៎ះមានច្រើនក្រៃ-លែង ធម៌នេះ ជាធម៌ដែលត្រូវឃើញច្បាស់ខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងបានចំពោះខ្លួនឯង បពិត្រព្រះអង្គដ៏ចម្រើន កាលបើយើងខ្ញុំព្រះអង្គពោលយ៉ាងនេះ ព្រាហ្មណ៍នោះ ក៏ងក់ក្បាល លៀនអណ្តាត ធ្វើថ្ងាសឲ្យមានផ្នត់ ៣ ជាន់ ហើយច្រត់ឈើច្រត់ដើរចៀសចេញទៅ ។

[៤៨៥] ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ អ្នកនុ៎ះ មិនមែនជាព្រាហ្មណ៍ទេ អ្នកនុ៎ះ ជាមារមានចិត្តបាប មកដើម្បីធ្វើបញ្ញាចក្ខុរបស់អ្នកទាំងឡាយឲ្យវិនាសទេតើ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបត្រាស់គាថានេះ ក្នុងវេលានោះ ថា

សត្វណា បានឃើញសេចក្តីទុក្ខ ដែលមានកាមណាជា
ហេតុ សត្វនោះ នឹងបង្អោនចិត្តទៅរកកាមនោះដូចម្តេច
កើត (បើ) សត្វ បានដឹងច្បាស់នូវឧបធិក្កិលេស ថាជា
គ្រឿងចំពាក់ក្នុងលោកដូច្នេះហើយ គួរសិក្សាដើម្បីកម្ចាត់បង់
នូវឧបធិក្កិលេសនោះចេញ ។

# ទុតិយំ សមិទ្ធិសុត្តំ

[៤៨៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ សិលាវតិយំ ។ តេន ខោ បន សមយេន អាយស្មា សមិទ្ធិ ភគវតោ អវិទូរេ អប្ប-មត្តោ អាតាបី បហិតត្តោ វិហរតិ ។ អថខោ អាយ-ស្មតោ សមិទ្ធិស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទចាទិ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ សត្ថា អរហំ សម្មាសម្ពុទ្ធោ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវំ ស្វាក្ខា-តេ ធម្មវិនយេ បព្វជិតោ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ សព្រហ្មចារិនោ សីលវន្តោ កល្យា-ណធម្មាតិ ។

# សមិទ្ធិសូត្រ ទី ២

[៤៨៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកសិលាវតី ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះសមិទ្ធិមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយនៅក្នុងទីជិតនៃព្រះមានព្រះភាគ ។ គ្រានោះឯង ព្រះសមិទ្ធិមានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្ត យ៉ាងនេះថា អាត្មាអញពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញមានព្រះអរហន្តសម្មាសម្ពុទ្ធជាគ្រូ អាត្មាអញពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញបានបួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយដោយប្រពៃ យ៉ាងនេះ អាត្មាអញពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញមានពួកបុគ្គលមានសីល មានធម៌ដ៏ល្អ ជាសព្រហ្មចារី ។

[៤៨៧] អថខោ មារោ បាបិមា អាយស្មតោ សមិទ្ធិស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ យេនាយស្មា សមិទ្ធិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ សមិទ្ធិស្ស អវិទូរេ មហន្តំ ភយភេរវំ សទ្ទមកាសិ អបិស្សុទំ បឋវី មញ្ញេ ឧទ្រីយតីតិ ។

[៤៨៨] អថខោ អាយស្មា សមិទ្ធិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សមិទ្ធិ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ ភគវតោ អវិទូរេ អប្បមត្តោ អាតាបី បហិតត្តោ វិហរាមិ តស្ស មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ សត្ថា អរហំ សម្មាសម្ពុទ្ធោ

[៤៨៧] លំដាប់នោះឯង មារមានចិត្តបាប បានដឹងសេចក្ដីត្រិះរិះក្នុងចិត្តរបស់ព្រះសមិទ្ធិមានអាយុ ដោយចិត្តរបស់ខ្លួន ក៏ចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសំឡេងគួរខ្លាចគួរស្ញប់-ស្ញែងយ៉ាងខ្លាំង ក្នុងទីជិតព្រះសមិទ្ធិមានអាយុ ចំណែកផែនដី ហាក់ដូចជាលាន់រំពង ។

[៤៨៨] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះសមិទ្ធិមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយនៅក្នុងទីជិតព្រះមានព្រះភាគឯ-ណោះ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ នៅក្នុងទីស្ងាត់ពួនសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្ដីត្រិះរិះកើតឡើងក្នុងចិត្ត យ៉ាងនេះថា អាត្មាអញ ពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញមានព្រះអរហន្តសម្មាសម្ពុទ្ធជាគ្រូ

លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតោ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ សព្រហ្មចារិនោ សីលវន្តោ កល្យាណ-ធម្មាតិ តស្ស មយ្ហំ ភន្តេ អវិទូរេ មហាភយភេរវសទ្ទោ អហោសិ អបិស្សុទំ បឋវី មញ្ញេ ឧទ្រិយតីតិ ។

[៤៨៩] នេសា សមិទ្ធិ បឋវី ឧទ្រិយតិ មារោ ឯសោ បាបិមា តុយ្ហំ វិចក្ខុកម្មាយ អាគតោ គច្ឆ ត្វំ សមិទ្ធិ តត្ថេវ អប្បមត្តោ អាតាបី បហិតត្តោ វិហរាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សមិទ្ធិ ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

អាត្មាអញពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញបានបួសក្នុងធម្មវិន័យ ដែលព្រះអង្គទ្រង់សំដែងហើយដោយប្រពៃ យ៉ាងនេះ អាត្មាអញពេញជាមានលាភ អត្តភាពជាមនុស្ស អាត្មាអញពេញជាបានដោយល្អ ព្រោះអាត្មាអញមានពួកបុគ្គលមានសីល មានធម៌ដ៏ល្អ ជាសព្រហ្មចារី បពិត្រព្រះអង្គដ៏ចម្រើន សំឡេងគួរខ្លាចគួរស្ញប់ស្ញែងយ៉ាងខ្លាំង ក៏កើតមានក្នុងទីជិតខ្ញុំព្រះអង្គនោះ ចំណែកផែនដី ហាក់ដូចជាលាន់ឮរំពង ។

[៤៨៩] ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលសមិទ្ធិ នុ៎ះមិនមែនជាផែនដីលាន់ឮរំពងទេ នុ៎ះជាមារមានចិត្តបាប មកដើម្បីធ្វើបញ្ញាចក្ខុរបស់អ្នកឲ្យវិនាសទេតើ ម្នាលសមិទ្ធិ ចូរអ្នកទៅចុះ អ្នកកុំប្រមាទ ខំព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយនៅក្នុងទីនោះវិញចុះ ។ ព្រះសមិទ្ធិមានអាយុ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ដូច្នេះហើយ ក្រោកអំពីអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណាដើរចេញទៅ ។

[៤៩០] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ សិលាវតិយំ ។ តេន ខោ បន សមយេន អាយស្មា សមិទ្ធិ ភគវតោ អវិទូរេ អប្បមត្តោ អាតាបី បហិតត្តោ វិហរតិ ។

[៤៩០] ទុតិយម្បិ ខោ អាយស្មា សមិទ្ធិ តត្ថេវ អប្បមត្តោ អាតាបី បហិតត្តោ វិហាសិ ។ ទុតិយម្បិ ខោ អាយស្មតោ សមិទ្ធិស្ស រហោគតស្ស បដិសល្លី-នស្ស ។ បេ ។ ទុតិយម្បិ ខោ មារោ បាបិមា អា-យស្មតោ សមិទ្ធិស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ ។ បេ ។ អបិស្សុ ទំ ឋបយី មញ្ញេ ឧទ្រីយតីតិ ។

[៤៩១] អថខោ អាយស្មា សមិទ្ធិ មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

សទ្ធាយាហំ បព្វជិតោ
អគារស្មា អនគារិយំ
សតិ បញ្ញា ច មេ ពុទ្ធា
ចិត្តញ្ច សុសមាហិតំ
កាមំ ករស្សុ រូបានិ
នេវ មំ ព្យាធយិស្សសីតិ ។

អថខោ មារោ បាបិមា ជានាតិ មំ សមិទ្ធិ ភិក្ខូតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

មារសំយុត្ត តតិយវគ្គ ពាក្យតបរបស់ព្រះសមិទ្ធិ

[៤៩០] ព្រះសមិទ្ធិមានអាយុ មិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយនៅក្នុងទីនោះឯង អស់វារៈជាគម្រប់ពីរដង ។ ព្រះសមិទ្ធិមានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំនៅក្នុងកម្មដ្ឋាន អស់វារៈជាគម្រប់ពីរដង ។ បេ ។ មារមានចិត្តបាប បានដឹងសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះសមិទ្ធិមានអាយុ ដោយចិត្តរបស់ខ្លួន អស់វារៈជាគម្រប់ពីរដងផង ។ បេ ។ ចំណែកផែនដី ហាក់ដូចជាលាន់ឮរំពង ។

[៤៩១] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ ដឹងច្បាស់ថា អ្នកនេះ ជាមារមានចិត្តបាប ដូច្នេះហើយ ទើបពោលនឹងមារមានចិត្តបាបដោយគាថាដូច្នេះថា

អាត្មាចេញចាកផ្ទះចូលមកកាន់ផ្នួស ដោយសទ្ធា សតិនិងបញ្ញា អាត្មាបានដឹងហើយ ទាំងចិត្តសោតក៏បានតាំងល្អហើយ ចូរអ្នកធ្វើរូប (ដែលគួរខ្លាច) តាមប្រាថ្នាចុះ អ្នកមិនអាចធ្វើអាត្មាឲ្យញាប់ញ័របានឡើយ ។

គ្រានោះឯង មារមានចិត្តបាប កើតទុក្ខ តូចចិត្តថា សមិទ្ធិភិក្ខុស្គាល់អាត្មាអញ ដូច្នេះហើយ ក៏បាត់ចាកទីនោះទៅ ។

# តតិយំ គោធិកសុត្តំ

[៤៩២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា គោធិកោ ឥសិគិលិបស្សេ វិហរតិ កាឡសិលាយំ ។

[៤៩៣] អថខោ អាយស្មា គោធិកោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ សាមាយិកំ(១) ចេតោវិមុត្តឹ ផុសិ ។ អថខោ អាយស្មា គោធិកោ តម្ហា សាមាយិកាយ ចេតោវិមុត្តិយា បរិហាយិ ។ ទុតិយម្បិ ខោ អាយស្មា គោធិកោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ សាមាយិកំ ចេតោវិមុត្តឹ ផុសិ ។ ទុតិយម្បិ ខោ អាយស្មា គោធិកោ តម្ហា សាមាយិកាយ ចេតោវិមុត្តិយា បរិហាយិ ។ តតិយម្បិ ខោ អាយស្មា គោធិកោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ សាមាយិកំ ចេតោវិមុត្តឹ ផុសិ ។

១ ឥទដ្ឋកថាយំ អយមេវ បាឋោ ។ ឱ. សាមាធិកំ ។

# គោធិកសូត្រ ទី ៣

[៤៩២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះគោធិកៈមានអាយុ នៅក្នុងកាឡសិលា ខាងភ្នំឥសិគិលិ ។

[៤៩៣] គ្រានោះឯង ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយបាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា ។ លំដាប់នោះឯង ព្រះគោធិកៈមានអាយុ សាបសូន្យចាកចេតោវិមុត្តិ ដែលប្រកបតាមកាលវេលានោះ ។ ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយក៏បាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា អស់វារៈជាគម្រប់ពីរដង ។ ព្រះគោ-ធិកៈមានអាយុ សាបសូន្យចាកចេតោវិមុត្តិ ប្រកបតាមកាលវេលានោះ អស់វារៈជាគម្រប់ពីរដងទៀត ។ ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយបាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា អស់វារៈជាគម្រប់បីដង ។

តតិយម្បិ ខោ អាយស្មា គោធិកោ តម្ហា ។ បេ ។ បរិហាយិ ។ ចតុត្ថម្បិ ខោ អាយស្មា គោធិកោ អប្បមត្តោ ។ បេ ។ ផុសិ ។ ចតុត្ថម្បិ ខោ អាយស្មា គោធិកោ តម្ហា ។ បេ ។ បរិហាយិ ។ បញ្ចមម្បិ ខោ អាយស្មា គោធិកោ ។ បេ ។ ផុសិ ។ បញ្ចមម្បិ ខោ អាយស្មា គោធិកោ ។ បេ ។ បរិហាយិ ។ ឆដ្ឋម្បិ ខោ អាយស្មា គោធិកោ អប្បមត្តោ អាតាបី បហិ-តត្តោ វិហរន្តោ សាមាយិកំ ចេតោវិមុត្តឹ ផុសិ ។ ឆដ្ឋម្បិ ខោ អាយស្មា គោធិកោ តម្ហា សាមាយិ-កាយ ចេតោវិមុត្តិយា បរិហាយិ ។ សត្តមម្បិ ខោ អាយស្មា គោធិកោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ សាមាយិកំ ចេតោវិមុត្តឹ ផុសិ ។ អថខោ អាយស្មតោ គោធិកស្ស ឯតទហោសិ យាវ ឆដ្ឋំ ខ្វាហំ សាមាយិកាយ ចេតោវិមុត្តិយា បរិហីនោ យន្នូ-ណាហំ សត្ថំ អាហារេយ្យន្តិ ។

ព្រះគោធិកៈមានអាយុ ។ បេ ។ សាបសូន្យចាកចេតោវិមុត្តិនោះ អស់វារៈជាគម្រប់បីដង ។ ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ ។ បេ ។ បាននូវចេតោវិមុត្តិ អស់វារៈជាគម្រប់ ៤ ដង ។ ព្រះគោធិកៈមានអាយុ ។ បេ ។ សាបសូន្យចាកចេតោវិមុត្តិនោះ អស់វារៈជាគម្រប់ ៤ ដង ។ ព្រះគោធិកៈមានអាយុ ។ បេ ។ បាននូវចេតោវិមុត្តិ អស់វារៈជាគម្រប់ ៥ ដង ។ ព្រះគោធិកៈមានអាយុ ។ បេ ។ សាបសូន្យចាកចេតោវិមុត្តិ អស់វារៈជាគម្រប់ ៥ ដង ។ ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយបាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា អស់វារៈជាគម្រប់ ៦ ដង ។ ព្រះគោធិកៈមានអាយុ សាបសូន្យចាកចេតោវិមុត្តិ ប្រកបតាមកាលវេលានោះ អស់វារៈជាគម្រប់ ៦ ដងទៀត ។ ព្រះគោធិកៈមានអាយុ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយក៏បាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា អស់វារៈជាគម្រប់ ៧ ដង ។ គ្រានោះឯង ព្រះគោធិកៈមានអាយុ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញសាបសូន្យចាកចេតោវិមុត្តិ ប្រកបតាមកាល ដរាបអស់វារៈជាគម្រប់ ៦ ដងហើយ បើដូច្នោះ គួរតែអាត្មាអញ យកកាំបិតមក ។

[៤៩៤] អថខោ មារោ បាបិមា អាយស្មតោ គោធិកស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាហិ អជ្ឈភាសិ

មហាវីរ មហាបញ្ញ
ឥទ្ធិយា យសសា ជល
សព្វវេរភយាតីត
បាទេ វន្ទាមិ ចក្ខុម
សាវកោ តេ មហាវីរ
មរណំ មរណាភិភូ
អាកង្ខតិ ចេតយតិ
តំ និសេធ ជុតិន្ធរ
កថញ្ហិ ភគវា តុយ្ហំ
សាវកោ សាសនេ រតោ
អប្បត្តមានសោ សេខោ[១]
កាលំ កយិរា ជនេ សុតាតិ ។

---

១ សេក្ខោតិបិ ។

[៤៩៤] គ្រានោះឯង មារមានចិត្តបាប បានដឹងនូវបរិវិតក្កៈក្នុងចិត្តរបស់ព្រះគោធិកៈមានអាយុ ដោយចិត្ត (របស់ខ្លួន) ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលនឹងព្រះមានព្រះភាគ ដោយគាថាទាំងឡាយ ថា

បពិត្រព្រះអង្គអ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន រុង-
រឿងដោយឫទ្ធិនិងយស កន្លងបង់នូវពៀរនិងភ័យគ្រប់ប្រ-
ការ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំព្រះបាទា
បពិត្រព្រះអង្គអ្នកមានព្យាយាមធំ សាវ័ករបស់ព្រះអង្គ ត្រូវ
សេចក្តីស្លាប់គ្របសង្កត់ ប្រាថ្នាគិតនូវសេចក្តីស្លាប់ បពិត្រ
ព្រះអង្គអ្នកទ្រទ្រង់នូវអានុភាព សូមព្រះអង្គឃាត់ នូវសាវ័ក
នោះ បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវ័ក
របស់ព្រះអង្គ ជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេច
នៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណកាលដូចម្តេចបាន ។

តេន ខោ បន សមយេន អាយស្មតា គោធិកេន សត្ថំ អាហារិតំ ហោតិ ។

[៤៩៥] អថខោ ភគវា មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាយ អជ្ឈភាសិ

ឯវំ ហិ ធីរា កុព្វន្តិ
នាវកង្ខន្តិ ជីវិតំ
សមូលំ តណ្ហំ អព្ពុយ្ហ
គោធិកោ បរិនិព្វុតោតិ ។

[៤៩៦] អថខោ ភគវា ភិក្ខូ អាមន្តេសិ អាយាម ភិក្ខវេ យេន ឥសិគិលិបស្សំ កាឡសិលា តេនុប-សង្កមិស្សាម យត្ថ គោធិកេន កុលបុត្តេន សត្ថំ អាហា-រិតន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោ-សុំ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ យេន ឥសិគិលិបស្សំ កាឡសិលា តេនុបសង្កមិ ។

សម័យនោះឯង ព្រះគោធិកៈមានអាយុ ក៏យកកាំបិតមក ។

[៤៩៥] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា អ្នកនេះ ជាមារមានចិត្តបាប ដូច្នេះហើយ ទើបពោលនឹងមារមានចិត្តបាប ដោយគាថាដូច្នេះថា

ពិតមែន អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនេះឯង រមែង
មិននឹកស្តាយនូវជីវិត គោធិកភិក្ខុ បានដកតណ្ហា ព្រមទាំង
ឫស បរិនិព្វានហើយ ។

[៤៩៦] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មកយើងនឹងចូលទៅឯកាឡសិលា ខាងភ្នំឥសិគិលិ ដ្បិតគោធិកកុលបុត្រយកកាំបិតមកហើយ ។ ពួកភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់កាឡសិលា ខាងភ្នំឥសិគិលិ មួយអន្លើដោយពួកភិក្ខុច្រើនរូប ។

អទ្ទសា ខោ ភគវា អាយស្មន្តំ គោធិកំ ឆវ្វគ្គោ វ មញ្ចកេ វិវត្តក្ខន្ធំ សេយ្យមានំ ។ តេន ខោ បន សមយេន ធូមាយិតត្តំ តិមិរាយិតត្តំ គច្ឆតេវ បុរិមំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ គច្ឆតិ ឧត្តរំ ទិសំ គច្ឆតិ ទក្ខិណំ ទិសំ គច្ឆតិ ឧទ្ធំ គច្ឆតិ អធោ គច្ឆតិ អនុទិសំ ។

[៤៩៧] អថខោ ភគវា ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ ធូមាយិតត្តំ តិមិរាយិតត្តំ គច្ឆតេវ បុរិមំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ គច្ឆតិ ឧត្តរំ ទិសំ គច្ឆតិ ទក្ខិណំ ទិសំ គច្ឆតិ ឧទ្ធំ គច្ឆតិ អធោ គច្ឆតិ អនុទិសន្តិ ។ ឯវំ ភន្តេតិ ។ ឯសោ ខោ ភិក្ខវេ មារោ បាបិមា គោធិកស្ស កុលបុត្តស្ស វិញ្ញាណំ សមន្វេសតិ កត្ថ គោធិកស្ស កុលបុត្តស្ស វិញ្ញាណំ បតិដ្ឋិតន្តិ អប្បតិដ្ឋិតេន ច ភិក្ខវេ វិញ្ញាណេន គោធិកោ កុលបុត្តោ បរិនិព្វុតោតិ ។

ព្រះមានព្រះភាគ ក៏បានឃើញគោធិកៈមានអាយុ កំពុងដេកផ្ងារផ្ងើយ-កលើគ្រែ អំពីចម្ងាយលឹម ៗ ។ សម័យនោះឯង ផ្សែងនិងអ័ព្ទ ក៏បក់ទៅកាន់ទិសខាងកើតខ្លះ បក់ទៅកាន់ទិសខាងលិចខ្លះ បក់ទៅកាន់ទិសខាងជើងខ្លះ បក់ទៅកាន់ទិសខាងត្បូងខ្លះ បក់ទៅកាន់ទិសខាងលើខ្លះ បក់ទៅកាន់ទិសខាងក្រោមខ្លះ បក់ទៅកាន់ទិសតូចខ្លះ ។

[៤៩៧] គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញនូវផ្សែងនិងអ័ព្ទនុ៎ះ បក់ទៅកាន់ទិសខាងកើត បក់ទៅកាន់ទិសខាងលិច បក់ទៅកាន់ទិសខាងជើង បក់ទៅកាន់ទិសខាងត្បូង បក់ទៅកាន់ទិសខាងលើ បក់ទៅកាន់ទិសខាងក្រោម បក់ទៅកាន់ទិសតូចឬទេ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ នុ៎ះឯងជាមារមានចិត្តបាប កំពុងស្វែងរកបដិសន្ធិវិញ្ញាណនៃគោធិកកុលបុត្តថា វិញ្ញាណរបស់គោធិកកុលបុត្ត ឋិតនៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ឯគោធិកកុលបុត្ត មានវិញ្ញាណមិនបានឋិតនៅទេ បរិនិព្វានហើយ ។

[៤៩៨] អថខោ មារោ បាបិមា វេឡុវបណ្ឌុវីណំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ឧទ្ធំ អធោ ច តិរិយំ
ទិសាអនុទិសាស្វហំ
អន្វេសំ នាធិគច្ឆាមិ
គោតមោ សោ កុហឹ គតោតិ ។

[៤៩៩] យោ ធីរោ ធិតិសម្បន្នោ
ឈាយី ឈានរតោ សទា
អហោរត្តមនុយុញ្ជំ
ជីវិតំ អនិកាមយំ
ជេត្វាន មច្ចុនោ សេនំ
អនាគន្ត្វា បុនព្ភវំ
សមូលំ តណ្ហំ អព្វុយ្ហ
គោតមោ បរិនិព្វុតោតិ ។
តស្ស សោកបរេតស្ស
វីណា កច្ឆកា អភស្សថ

[៤៩៨] គ្រានោះឯង មារមានចិត្តបាប យកពិណមានពណ៌លឿងដូចផ្លែព្នៅ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

ខ្ញុំព្រះអង្គបានស្វែងរក (វិញ្ញាណ) របស់គោធិកកុលបុត្ត
ក្នុងទិសខាងលើផង ខាងក្រោមផង ទិសទទឹងផង ទិស
ធំទិសតូចផង មិនបានចួបប្រទះសោះឡើយ ចុះគោធិកៈ
នោះ ទៅក្នុងទីណា ។

[៤៩៩] ព្រះអង្គត្រាស់តបថា គោធិកភិក្ខុ ជាអ្នកប្រាជ្ញ
បរិបូណ៌ដោយប្រាជ្ញា ជាអ្នកមានឈាន អ្នកត្រេកអរក្នុង
ឈាន សព្វកាល ខំប្រឹងប្រែងទាំងថ្ងៃទាំងយប់ មិនគិត
ស្តាយជីវិត បានឈ្នះសេនារបស់មច្ចុ មិនមកកាន់ភពថ្មីទៀត
ដកតណ្ហាព្រមទាំងឫស បរិនិព្វានហើយ ។ កាលមារ
នោះកំពុងត្រូវសោកគ្របសង្កត់ ពិណក៏របូតចេញអំពីក្លៀក

តតោ សោ ទុម្មនោ យក្ខោ

តត្ថេវន្តរធាយិថាតិ ។

## ចតុត្ថំ សត្តវស្សសុត្តំ

[៤០០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ ។ តេន ខោ បន សមយេន មារោ បាបិមា សត្ត វស្សានិ ភគវន្តំ អនុពន្ធោ ហោតិ ឱតារាបេក្ខោ ឱតារំ អលភមានោ ។

[៤០១] អថខោ មារោ បាបិមា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

តពីនោះមក យក្ខនោះក៏មានសេចក្ដីតូចចិត្ត ហើយក៏បាត់ចាកទីនោះទៅ ។

# សត្តវស្សសូត្រ ទី ៤

[៥០០] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្រោមអជបាលនិគ្រោធ ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង មារមានចិត្តបាប ដាប់តាមព្រះមានព្រះភាគ អស់ ៧ ឆ្នាំ រមិលមើលទោស តែមិនបានឃើញទោសឡើយ ។

[៥០១] គ្រានោះ មារមានចិត្តបាប ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

សោកាវតិណ្ណោ នុ វនស្មឹ ឈាយសិ

វិត្តំ នុ ជិន្នោ[១] ឧទ បត្ថយានោ

អាគុន្នុ គាមស្មិមកាសិ កិញ្ចិ

កស្មា ជនេន ន ករោសិ សក្ខឹ

សក្ខី ន សម្បជ្ជតិ កេនចិ តេតិ ។

[៤០២] សោកស្ស មូលំ បលិខាយ សព្វំ

អនាគុ ឈាយាមិ អសោចមានោ

ឆេត្វាន សព្វំ ភវលោភជប្បំ

អនាសវោ ឈាយាមិ បមត្តពន្ធូតិ ។

[៤០៣] យំ វទន្តិ មមយិទន្តិ

យេ វទន្តិ មមន្តិ ច

ឯត្ថ ចេ តេ មនោ អត្ថិ

ន មេ សមណ មោក្ខសីតិ ។

---

១ វិត្តំ នុ ជិនោតិ សតំ វា សហស្សំ វា ជិតោសិ នូតិ តព្វណ្ណនា ។

ព្រះអង្គ ត្រូវសេចក្តីសោកគ្របសង្កត់ ទើបសញ្ជប់សញ្ជឹង នៅក្នុងព្រៃឬ ព្រះអង្គប្រាថ្នានូវទ្រព្យបានឈ្នះហើយឬ ឬក៏ ព្រះអង្គធ្វើអំពើអាក្រក់ណាមួយក្នុងស្រុកទេដឹង ព្រោះហេតុ អ្វី ព្រះអង្គមិនយកពួកជនធ្វើជាមិត្ត មិត្តរបស់ព្រះអង្គ រមែង មិនសម្រេចដោយហេតុណាមួយឡើយ ។

[៥០២] ព្រះអង្គត្រាស់តបថា តថាគតជីកឫសគល់ សេចក្តីសោកទាំងអស់ហើយ មិនមានអំពើអាក្រក់ មិន សោកសៅ សញ្ជប់សញ្ជឹងទេ ម្នាលមារ តថាគត ឈ្នះនូវតណ្ហាគឺសេចក្តីលោភក្នុងភពទាំងអស់ហើយ ជា អ្នកមិនមានអាសវៈ តែងស្ងឹងស្ងាត់ ។

[៥០៣] មារតបថា ជនទាំងឡាយណា តែងពោល នូវរបស់ណាថា នេះរបស់អញដូច្នេះក្តី ពោលថា អញ ដូច្នេះក្តី បើព្រះហឫទ័យរបស់ព្រះអង្គ មានក្នុងរបស់នុ៎ះដែរ បពិត្រសមណៈ ព្រះអង្គមិនរួចចាកវិស័យរបស់ខ្ញុំឡើយ ។

[៥០៤] យំ វទន្តិ ន តំ មយ្ហំ

យេ វទន្តិ ន តេ អហំ

ឯវំ ចាបិម ជានាហិ

ន មេ មគ្គម្បិ ទក្ខសីតិ ។

[៥០៥] សចេ មគ្គំ អនុពុទ្ធំ

ខេមំ អមតគាមិនឹ

អបេហិ គច្ឆ ត្វមេកោ

កិមញ្ញមនុសាសសីតិ ។

[៥០៦] អមច្ចុធេយ្យំ បុច្ឆន្តិ

យេ ជនា បារគាមិនោ

តេសាហំ បុដ្ឋោ អក្ខាមិ

យំ សច្ចំ តំ និរុបធិន្តិ ។

[៩០៤] ព្រះអង្គត្រាស់ថា ពួកជន ពោលដោយករបស់ណា របស់នោះមិនមានដល់តថាគតទេ ពួកជនណាពោលថា (អញដូច្នេះ) ពួកជននោះ មិនដូចតថាគតទេ ម្នាលមារ អ្នកឯង ចូរដឹងយ៉ាងនេះចុះ អ្នកឯង មិនឃើញផ្លូវនៃតថាគតទេ ។

[៩០៥] មារទូលថា ប្រសិនបើព្រះអង្គបានទូវផ្លូវដែលព្រះអង្គបានត្រាស់ដឹងហើយ ជាផ្លូវដ៏ក្សេម ជាផ្លូវសម្រាប់ទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ចូរព្រះអង្គចេញទៅ ចូរព្រះអង្គទៅចុះ ព្រះអង្គជាបុគ្គលម្នាក់ឯង ប្រៀនប្រដៅបុគ្គលដទៃដូចម្ដេចកើត ។

[៩០៦] ព្រះអង្គត្រាស់ថា ពួកជនណា ប្រាថ្នាទៅកាន់ត្រើយគឺព្រះនិព្វាន លះបង់នូវព្រះនិព្វានដែលមិនមែនជាឱកាសនៃមច្ចុ តថាគត កាលបើពួកជននោះសួរហើយនឹងប្រាប់ថា ធម្មជាតណាជារបស់ពិត ធម្មជាតនោះមិនមានឧបធិក្កិលេសឡើយ ។

[៤០៧] សេយ្យថាបិ ភន្តេ គាមស្ស វា និគមស្ស វា អវិទូរេ បោក្ខរណី តត្រស្ស កក្កដកោ អថខោ ភន្តេ សម្ពហុលា កុមារកា វា កុមារិកាយោ វា តម្ហា គាមា វា និគមា វា និក្ខមិត្វា យេន សា បោក្ខរណី តេនុបសង្កមេយ្យុំ ឧបសង្កមិត្វា តំ កក្កដកំ ឧទកា ឧទ្ធរិត្វា ថលេ បតិដ្ឋាបេយ្យុំ យំ យទេវ ហិ សោ ភន្តេ កក្កដកោ អឡំ អភិនិន្នាមេយ្យ តំ តទេវ តេ កុមារកា វា កុមារិកាយោ វា កដ្ឋេន វា កឋលាយ វា សញ្ឆិន្ទេយ្យុំ សម្ភញ្ជេយ្យុំ សម្បលិភញ្ជេយ្យុំ ឯវំ ហិ សោ ភន្តេ កក្កដកោ សព្វេហិ អឡេហិ សញ្ឆិន្នេហិ សម្ភគ្គេហិ សម្បលិភគ្គេហិ អភព្វោ តំ បោក្ខរណឹ បុន ឱតរិតុំ សេយ្យថាបិ បុព្វេ ឯវមេវ ខោ ភន្តេ យានិ កានិចិ វិសូកាយិតានិ[១] វិសេវិតានិ វិប្ផន្ទិតានិ សព្វានិ តានិ ភគវតា បច្ឆិន្នានិ សម្ភគ្គានិ សម្បលិភគ្គានិ អភព្វោទានាហំ ភន្តេ បុន ភគវន្តំ ឧបសង្កមិតុំ យទិទំ ឱតារាបេក្ខោតិ ។

---

១ វិសូកាយិកានីតិ អដ្ឋកថាយំ ទិស្សតិ ។

មារសំយុត្ត តតិយវគ្គ ការទូលតបនៃមារ

[៥០៧] មារពោលតបថា បពិត្រព្រះអង្គដ៏ចម្រើន ស្រុក ឬនិគម មានស្រះបោក្ខរណីនៅជិត ក្នុងស្រះនោះមានក្តាម ១ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះឯង ពួកក្មេងប្រុសឬក្មេងស្រី ច្រើននាក់ នាំគ្នាចេញទៅអំពីស្រុក ឬនិគមនោះ ចូលសំដៅទៅរកស្រះបោក្ខរណី លុះចូលទៅដល់ហើយ ទើបស្រង់ក្តាមនោះ អំពីទឹកមកដាក់លើគោក បពិត្រព្រះអង្គដ៏ចម្រើន ក្តាមនោះ លាទូវជើងណា ៗ ពួកក្មេងប្រុស ឬក្មេងស្រី ក៏យកកំណាត់ឈើ ឬអំបែងមកកាច់បំបាក់កម្ទេចចោលនូវជើងនោះ ៗ ទៅ បពិត្រព្រះអង្គដ៏ចម្រើន លុះក្តាមនោះ មានជើងទាំងអស់ត្រូវគេកាច់បំបាក់កម្ទេចចោលយ៉ាងនេះហើយ ក៏មិនគួរនឹងចុះកាន់ស្រះបោក្ខរណីនោះ ឲ្យដូចជាក្នុងពេលមុនបានទៀតឡើយ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន មានឧបមេយ្យដូចយ៉ាងអំពើណាមួយ ដែលជាចម្រូងចម្រាស ជាទំនាស់ ញាប់ញ័រ អំពើទាំងអស់នោះ ព្រះមានព្រះភាគបានកាច់បំបាក់កម្ទេចចោលហើយ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ ខ្ញុំព្រះអង្គមិនគួរនឹងចូលទៅរមិលមើលទោសចំពោះព្រះមានព្រះភាគបានទៀតឡើយ ។

[៤០៨] អថខោ មារោ បាបិមា ភគវតោ សន្តិកេ ឥមា និព្ពេជនីយា គាថាយោ អភាសិ

មេទវណ្ណញ្ច បាសាណំ
វាយសោ អនុបរិយគា
អបេត្ថ មុទុ វិន្ទេម
អបិ អស្សាទនា សិយា
អលទ្ធា តត្ថ អស្សាទំ
វាយមេត្តោ អបក្កមេ
កាកោវ សេលំ អាសជ្ជ
និព្វិជ្ជាបេម គោតមាតិ ។

អថខោ មារោ បាបិមា ភគវតោ សន្តិកេ ឥមា និព្ពេជនីយា គាថាយោ ភាសិត្វា តម្ហា ឋានា អបក្កម្ម ភគវតោ អវិទូរេ បឋវិយំ បល្លង្កេន និសីទិ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ កដ្ឋេន ភូមឹ វិលិខន្តោ ។

[៤០៨] គ្រានោះឯង មារមានចិត្តបាប ក៏បានពោលគាថាដែលគួរនឿយណាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ ថា

ក្អែក ឃើញថ្មដែលមានសម្បុរដូចខ្លាញ់ខាប់ ហើរក្រឡឹង
ជុំវិញ ដោយគិតថា យើងនឹងបាននូវអាហារទន់ក្នុងទីនុ៎ះ
អាហារឆ្ងាញ់នឹងគប្បីមាន លុះក្អែកនោះមិនបាននូវអាហារ
ឆ្ងាញ់ក្នុងទីនោះហើយ ក៏ព្យាយាមហើរចេញទៅ បពិត្រ
ព្រះគោតម យើងក៏នឿយណាយដូចជាក្អែកដែលចូលប្រទះ
នឹងថ្មដូច្នោះដែរ ។

លុះមារមានចិត្តបាប បានពោលគាថាដែលគួរនឿយណាយនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគរួចហើយ ក៏គេចចេញពីទីនោះ ទៅអង្គុយពែនភ្នែនលើផែនដីនៅស្ងៀម អៀនអន់ ឱនក ដាក់មុខចុះ សញ្ជប់សញ្ជឹង មិនក្មៀវក្លា គូសផែនដីដោយកំណាត់ឈើ ក្នុងទីជិតនៃព្រះមានព្រះភាគ ។

# បញ្ចមំ មារធីតុសុត្តំ

[៤០៩] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ យេន មារោ ចាបិមា តេនុបសង្កមឹសុ ឧបសង្កមិត្វា មារំ ចាបិមន្តំ គាថាយ អជ្ឈភាសឹសុ

កេនាសិ ទុម្មនោ តាត
បុរិសំ កំ នុ សោចសិ
មយំ តំ រាគបាសេន
អរញ្ញមិវ កុញ្ជរំ
ពន្ធិត្វា អានយិស្សាម
វសគោ តេ ភវិស្សតីតិ ។

[៤១០] អរហំ សុគតោ លោកេ
ន រាគេន សុវានយោ
មារធេយ្យំ អតិក្កន្តោ
តស្មា សោចាមហំ ភុសន្តិ ។

[៤១១] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា

# មារធីតុសូត្រ ទី ៥

[៥០៩] គ្រានោះឯង ធីតារបស់មារឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ នាំគ្នាចូលទៅរកមារមានចិត្តបាប លុះចូលទៅដល់ ក៏ពោលនឹងមារមានចិត្តបាប ដោយគាថាដូច្នេះថា

បពិត្របិតា ព្រះអង្គតូចចិត្តដោយហេតុអ្វី ព្រះអង្គសោកស្តាយបុរសណាហ្ន៎ យើងខ្ញុំម្ចាស់នឹងចងបុរសនោះដោយអន្ទាក់គឺរាគៈហើយនាំមក ដូចជាបុគ្គលចងដំរីព្រៃ បុរសនោះនឹងលុះក្នុងអំណាចរបស់ព្រះអង្គ ។

[៥១០] មារតបថា ព្រះសុគតជាព្រះអរហន្តក្នុងលោក មិនងាយនឹងនាំមកដោយរាគៈបានឡើយ លោកកន្លងនូវវដ្តៈជាទីតាំងនៃមាររួចហើយ ព្រោះហេតុនោះ ទើបអញសោកស្តាយក្រៃលែង ។

[៥១១] លំដាប់នោះ ធីតារបស់មារឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ បាននាំគ្នាចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

ភគវន្តំ ឯតទវោចុំ ចរាម តេ សមណ បរិចារេមាតិ ។ អថខោ ភគវា ន មនសាកាសិ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

[៤១២] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ ឧច្ចាវចា ខោ បុរិសានំ អធិប្បាយា យន្នូន មយំ ឯកសតឯក-សតំ កុមារិវណ្ណសតំ អភិនិម្មិនេយ្យាមាតិ ។ អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកសតឯក-សតំ កុមារិវណ្ណសតំ អភិនិម្មិនិត្វា យេន ភគវា តេនុ-បសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ ឯតទវោចុំ ចរាម តេ សមណ បរិចារេមាតិ ។ តម្បិ ភគវា ន មនសា-កាសិ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រសមណៈ យើងទាំងឡាយសូមបម្រើបាទាព្រះអង្គ ។ គ្រានោះឯង ព្រះមានព្រះភាគ មិនបានធ្វើទុកក្នុងព្រះហឫទ័យឡើយ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៥១២] គ្រានោះឯង ធីតារបស់មារ ឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ គេចចេញទៅក្នុងទីដ៏សមគួរ ហើយក៏គិតព្រមគ្នាយ៉ាងនេះថា សេចក្តីប្រាថ្នារបស់បុរសទាំងឡាយ ផ្សេង ៗ គ្នា បើដូច្នោះគួរពួកយើងនិម្មិតនូវវណ្ណៈនៃនាងកុមារីមួយរយ ក្នុងមួយ ៗ ធ្វើឲ្យបែកទៅជាមានវណ្ណៈមួយរយ ៗ នាក់ ។ ទើបធីតារបស់មារ ឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ នាំគ្នានិម្មិត នូវវណ្ណៈនៃនាងកុមារីមួយរយក្នុងមួយ ៗ ធ្វើឲ្យបែកទៅជាមានវណ្ណៈមួយរយ ៗ នាក់ ហើយចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រសមណៈ យើងទាំងឡាយ សូមបម្រើបាទារបស់ព្រះអង្គ ។ ព្រះមានព្រះភាគ មិនបានធ្វើទុកក្នុងព្រះហឫទ័យនឹងពាក្យនោះឡើយ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៥១៣] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ ឧច្ចាវចា ខោ បុរិសានំ អធិប្បាយា យន្នូន មយំ ឯកសតឯកសតំ អវិជាតវណ្ណសតំ អភិនិម្មិនេយ្យាមាតិ ។ អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកសតឯកសតំ អវិជាតវណ្ណសតំ អភិនិម្មិនិត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ ឯតទវោចុំ ចាទេ តេ សមណ បរិចារេមាតិ ។ តម្បិ ភគវា ន មនសាកាសិ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

[៥១៤] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ

[៥១៣] គ្រានោះឯង ធីតារបស់មារ ឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ គេចចេញទៅក្នុងទីសមគួរហើយ គិតព្រមគ្នាយ៉ាងនេះថា សេចក្តីប្រាថ្នារបស់បុរសទាំងឡាយ ផ្សេង ៗ គ្នា បើដូច្នោះគួរពួកយើងនិម្មិតនូវវណ្ណៈស្រីមិនទាន់សម្រាលមួយរយ ក្នុងមួយ ៗ ធ្វើឲ្យបែកទៅជាមានវណ្ណៈមួយរយ ៗ នាក់ ។ ទើបធីតារបស់មារឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ និម្មិតនូវវណ្ណៈស្រីមិនទាន់សម្រាលមួយរយក្នុងមួយ ៗ ធ្វើឲ្យបែកទៅជាមានវណ្ណៈមួយរយ ៗ នាក់ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រសមណៈ យើងទាំងឡាយសូមបម្រើបាទាព្រះអង្គ ។ ព្រះមានព្រះភាគ មិនបានធ្វើទុកក្នុងព្រះហឫទ័យ នឹងពាក្យនោះឡើយ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៥១៤] លំដាប់នោះ ធីតារបស់មារឈ្មោះនាងតណ្ហា ១ អរ-តី ១ រាគា ១ គេចចេញទៅក្នុងទីដ៏សមគួរ ទើបគិតព្រមគ្នាយ៉ាងនេះថា

ឧច្චាវចា ខោ បុរិសានំ អធិប្បាយា យន្នូន មយំ ឯកសតឯកសតំ សក្កឹ វិជាតវណ្ណសតំ អភិនិម្មិនេយ្យាមាតិ ។ អថខោ តណ្ហា ច ។ បេ ។ សក្កឹ វិជាតវណ្ណសតំ អភិនិម្មិនិត្វា យេន ភគវា ។ បេ ។ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

[៥១៥] អថខោ តណ្ហា ច ។ បេ ។ ទុវិជាតវណ្ណសតំ អភិនិម្មិនិត្វា យេន ភគវា ។ បេ ។ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

[៥១៦] អថខោ តណ្ហា ច ។ បេ ។ មជ្ឈិមិត្ថីវណ្ណសតំ អភិនិម្មិនេយ្យាមាតិ ។ អថខោ តណ្ហា ច ។ បេ ។ មជ្ឈិមិត្ថីវណ្ណសតំ អភិនិម្មិនិត្វា យេន ភគវា ។ បេ ។ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

សេចក្តីប្រាថ្នារបស់បុរសទាំងឡាយ ផ្សេង ៗ គ្នា បើដូច្នោះ គួរតែពួកយើងនិម្មិតនូវវណ្ណៈស្រីមួយរយដែលទើបសម្រាលម្តង ក្នុងមួយ ៗ ធ្វើឲ្យបែកទៅជាមានវណ្ណៈមួយរយ ៗ នាក់ ។ គ្រានោះឯង នាងតណ្ហា ១ ។ បេ ។ និម្មិតនូវវណ្ណៈស្រីមួយរយ ដែលទើបសម្រាលម្តង ចូលទៅរកព្រះមានព្រះភាគ ។ បេ ។ ព្រោះព្រះអង្គ មានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៤១៥] លំដាប់នោះ នាងតណ្ហា ១ ។ បេ ។ និម្មិតនូវវណ្ណៈស្រីមួយរយ ដែលសម្រាលអស់វារៈពីរដង ចូលទៅរកព្រះមានព្រះភាគ ។ បេ ។ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ប់ ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៤១៦] លំដាប់នោះឯង នាងតណ្ហា ១ ។ បេ ។ ពួកយើងនិម្មិតនូវវណ្ណៈស្រីមួយរយមានវ័យជាកណ្តាល ។ គ្រានោះឯង នាងតណ្ហា ១ ។ បេ ។ ក៏និម្មិតនូវវណ្ណៈស្រីមួយរយមានវ័យជាកណ្តាល ចូរទៅរកព្រះមានព្រះភាគ ។ បេ ។ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

៣៤៣



[៤១៧] អថខោ តណ្ហា ច ។ បេ ។ មហិត្ថី-វណ្ណាសតំ អភិនិម្មិនេយ្យាមាតិ ។ អថខោ តណ្ហា ច ។ បេ ។ មហិត្ថីវណ្ណាសតំ អភិនិម្មិនិត្វា យេន ភគវា ។ បេ ។ យថាតំ អនុត្តរេ ឧបធិសង្ខយេ វិមុត្តោ ។

[៤១៨] អថខោ តណ្ហា ច អរតី ច រាគា ច មារធីតរោ ឯកមន្តំ អបក្កម្ម ឯតទវោចុំ សច្ចំ កិរ នោ បិតា អវោច

អរហំ សុគតោ លោកេ
ន រាគេន សុវានយោ
មារធេយ្យំ អតិក្កន្តោ
តស្មា សោចាមហំ ភុសន្តិ ។

យញ្ហិ មយំ សមណំ វា ព្រាហ្មណំ វា អវីតរាគំ ឥមិនា ឧបក្កមេន ឧបក្កមេយ្យាម ហទយំ វាស្ស ផលេយ្យ ឧណ្ហំ វា លោហិតំ មុខតោ ឧគ្គច្ឆេយ្យ ឧម្មាទំ វា បាបុណេយ្យ ចិត្តវិក្ខេបំ វា សេយ្យថាបិ បន នឡោ

[៥១៧] លំដាប់នោះ នាងតណ្ហា ១ ។ បេ ។ ពួកយើង និម្មិតនូវវណ្ណៈស្រីចាស់មួយរយ ។ ទើបនាងតណ្ហា ១ ។ បេ ។ និម្មិតនូវវណ្ណៈស្រីចាស់មួយរយ ចូលទៅរកព្រះមានព្រះភាគ ។ បេ ។ ព្រោះព្រះអង្គ មានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។

[៥១៨] លំដាប់នោះ ធីតារបស់មារឈ្មោះតណ្ហា ១ អរតី ១ រាគា ១ គេចចេញទៅក្នុងទីសមគួរ ហើយពោលដូច្នេះថា ឮថា បិតារបស់យើង បានពោលពិតមែនថា

ព្រះសុគត ជាព្រះអរហន្តក្នុងលោក មិនងាយនឹងនាំមក
ដោយរាគៈបានឡើយ ព្រះអង្គកន្លងវដ្តៈជាទីតាំងនៃមាររួច
ហើយ ព្រោះហេតុនោះ ទើបអញសោកស្តាយក្រៃលែង ។

ព្រោះថាពួកយើង ព្យាយាម (ធ្វើ) សមណៈឬព្រាហ្មណ៍ណាដែលមានរាគៈមិនទាន់ទៅប្រាសនៅឡើយ ដោយសេចក្តីព្យាយាមនេះ ហឫទ័យរបស់សមណព្រាហ្មណ៍នោះ គប្បីបែក ឬឈាមដ៏ក្តៅគប្បីខ្ពុរចេញអំពីមាត់ ឬដល់នូវសេចក្តីឆ្កួត ពុំនោះរាយមាយចិត្ត ដូចយ៉ាងដើមបបុស

ហារិតោ លុតោ ឧស្សុស្សតិ វិសុស្សតិ មិលាយតិ ឯវមេវ ឧសុស្សេយ្យ វិសុស្សេយ្យ មិលាយេយ្យាតិ ។ អថខោ តណ្ហា ច អរតី ច រគា ច មារធីតរោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋំសុ ។

[៤១៩] ឯកមន្តំ ឋិតា ខោ តណ្ហា មារធីតា ភគវន្តំ គាថាយ អជ្ឈភាសិ

សោកាវតិណ្ណោ នុ វនម្ហិ ឈាយសិ

វិត្តំ នុ ជិណ្ណោ ឧទ បត្ថយានោ

អាគុន្នុ គាមស្មិមកាសិ កិញ្ចិ

កស្មា ជនេន ន ករោសិ សក្ខឹ

សក្ខី ន សម្បជ្ជតិ កេនចិ តេតិ ។

មានពណ៌ខៀវដែលបុគ្គលដកចេញ តែងស្វិតស្រពោនក្រៀមទៅយ៉ាងណា សមណព្រាហ្មណ៍នោះ គប្បីស្វិតស្រពោនក្រៀមទៅ ដូច្នោះដែរ ។ លំដាប់នោះ ធីតារបស់មារ ឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ បាននាំគ្នាចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរក្នុងទីដ៏សមគួរ ។

[៥១៩] លុះមារធីតាឈ្មោះនាងតណ្ហា ឈរនៅក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

ព្រះអង្គ មានសេចក្ដីសោកគ្របសង្កត់ ទើបសញ្ជប់សញ្ជឹង
នៅក្នុងព្រៃឬ ព្រះអង្គ កាលប្រាថ្នានូវទ្រព្យ ត្រូវចាញ់គេ
ហើយឬ ឬក៏ព្រះអង្គ ធ្វើអំពើអាក្រក់ណាមួយក្នុងស្រុកទេ
ដឹង ព្រោះហេតុអ្វី បានជាព្រះអង្គមិនធ្វើនូវមិត្តភាពជាមួយ
នឹងពួកជន មិត្តភាពរបស់ព្រះអង្គ មិនសម្រេចដោយហេតុ
ណាមួយឬ ។

[៤២០] អត្ថស្ស បត្តិំ ហទយស្ស សន្តិំ
ជេត្វាន សេនំ បិយសាតរូបំ
ឯកាហំ ឈាយំ សុខមានុពោធំ
តស្មា ជនេន ន ករោមិ សក្ខិំ
សក្ខី ន សម្បជ្ជតិ កេនចិ មេតិ ។

[៤២១] អថខោ អរតី មារធីតា ភគវន្តំ គាថាយ អជ្ឈភាសិ

កថំ វិហារីពហុលោធ[១] ភិក្ខុ
បញ្ចោឃតិណ្ណោ អតរីធ ឆដ្ឋំ
កថំ ឈាយំ ពហុលំ កាមសញ្ញា
បរិពាហិរា ហោន្តិ អលទ្ធយោ តន្តិ ។

១ ម. ពហុលោ ច ។

[៥២០] ព្រះអង្គត្រាស់ថា តថាគត តែម្នាក់ឯង បាន ឈ្នះនូវសេនា ដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ កំពុងចម្រើនឈាន ក៏បានចួបនូវសេចក្ដីសុខក្នុងព្រះអរហត្ត ដែលជាចំណែកនៃប្រយោជន៍ ឬជាសេចក្ដីស្ងប់នៃហឫទ័យ ព្រោះហេតុនោះ បានជាតថាគត មិនធ្វើមិត្តភាពជាមួយនឹង ពួកជន មិត្តភាពរបស់តថាគត មិនសម្រេច ដោយហេតុ ណាមួយឡើយ ។

[៥២១] ទើបមារធីតាឈ្មោះអរតី បានពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

ភិក្ខុក្នុងសាសនានេះ ជាអ្នកច្រើនដោយវិហារធម៌ ដូចម្ដេច បានឆ្លងនូវអន្លង់ប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ហើយឆ្លងអន្លង់ ប្រព្រឹត្តទៅក្នុងមនោទ្វារមួយទៀតជាគម្រប់ ៦ ក្នុងអត្តភាព នេះ កាមសញ្ញាទាំងឡាយ ជាខាងក្រៅ មិនបានប្រទះ បុគ្គលមានឈានច្រើននោះ ដោយប្រការដូចម្ដេច ។

[៤២២] បស្សទ្ធកាយោ សុវិមុត្តចិត្តោ
អសង្ខរានោ សតិមា អនោកោ
អញ្ញាយ ធម្មំ អវិតក្កឈាយី
ន កុប្បតិ ន សរតិ ន ថិនោ
ឯវំវិហារីពហុលោធ ភិក្ខុ
បញ្ចោឃតិណ្ណោ អតរីធ ឆដ្ឋំ
ឯវំ ឈាយំ ពហុលំ កាមសញ្ញា
បរិពាហិរា ហោន្តិ អលទ្ធយោ តន្តិ ។

[៤២៣] អថខោ រាគា មារធីតា ភគវន្តំ គាថា-
យ អជ្ឈភាសិ

អច្ឆេជ្ជ តណ្ហំ គណសង្ឃចារី[១]
អទ្ធា ចរិស្សន្តិ ពហូ ច សទ្ធា[២]
ពហុំ វតាយំ ជនតំ អនោកោ
អច្ឆេជ្ជ នេស្សតិ មច្ចុរាជស្ស បារន្តិ ។

១ អដ្ឋកថាយំ គណសង្ឃបារីតិ បាឋោ ទិស្សតិ ។ ២ ឱ. ម. សត្តា ។

[៥២២] ព្រះអង្គត្រាស់ថា បុគ្គល មានកាយស្ងប់រម្ងាប់ មានចិត្តរួចស្រឡះដោយប្រពៃហើយ មិនបានតាក់តែង មានស្មារតី មិនមានទីអាល័យ បានដឹងច្បាស់នូវចតុសច្ចធម៌ មានចតុត្ថជ្ឈានប្រាសចាកវិតក្កៈ មិនកម្រើក (ព្រោះទោសៈ) មិនរឭក (ព្រោះរាគៈ) មិនងោកងក់ (ព្រោះមោហៈ) ភិក្ខុក្នុងសាសនានេះ ជាអ្នកច្រើនដោយវិហារធម៌យ៉ាងនេះ ឆ្លងនូវអន្លង់ប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ បានឆ្លងនូវអន្លង់ប្រព្រឹត្តទៅក្នុងមនោទ្វារមួយទៀតជាគម្រប់ ៦ ក្នុងអត្តភាពនេះ កាមសញ្ញាទាំងឡាយជាខាងក្រៅ មិនបានប្រទះបុគ្គលមានឈានច្រើននោះ យ៉ាងនេះឯង ។

[៥២៣] គ្រានោះឯង មារធីតាឈ្មោះរាគា បានពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

បុគ្គល ជាអ្នកប្រព្រឹត្តទៅក្នុងគណៈនិងសង្ឃ បានកាត់បង់នូវតណ្ហា មួយទៀត ពួកជនច្រើននាក់ មានសទ្ធា នឹងប្រព្រឹត្ត ដោយចំណែកមួយ ព្រះសាស្តានេះ មិនមានទីអាល័យ បានដណ្តើមយកនូវប្រជុំជនដ៏ច្រើន អំពីដៃនៃមច្ចុរាជ ហើយនាំទៅកាន់ត្រើយគឺព្រះនិព្វាន ។

[៥២៤] នយន្តិ វេ មហាវីរា
សទ្ធម្មេន តថាគតា
ធម្មេន នយមានានំ
កា ឧស្សុយា វិជានតន្តិ ។

[៥២៥] អថខោ តណ្ហា ច អរតី ច រគា ច មារធី-
តរោ យេន មារោ បាបិមា តេនុបសង្កមឹសុ ។ អទ្ទសា
ខោ មារោ បាបិមា តណ្ហញ្ច អរតិញ្ច រគញ្ច មារធីត-
រោ ទូរតោ វ អាគច្ឆន្តិយោ ទិស្វាន គាថាហិ អជ្ឈភាសិ

ពាលា កុមុទនាឡេហិ
បព្វតំ អភិមត្ថថ
គិរឹ នខេន ខនថ
អយោ ទន្តេហិ ខាទថ
សេលំវ សិរសិ ឱហច្ច
បាតាលេ គាធមេសថ
ខាណុំវ ឧរសាសជ្ជ
និព្វិជ្ជាបេថ គោតមន្តិ ។

[៥២៤] ព្រះតថាគតទាំងឡាយ មានព្យាយាមធំ តែង
ដឹកនាំសត្វ ដោយព្រះសទ្ធម្ម ប្រណែនអ្វីដល់ព្រះតថាគត
ទាំងឡាយ ដែលជាអ្នកប្រាជ្ញ អាចដឹកនាំសត្វដោយធម៌ ។

[៥២៥] លំដាប់នោះ ធីតារបស់មារឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ បាននាំគ្នាចូលទៅរកមារមានចិត្តបាប ។ មារមានចិត្តបាប ក៏បានឃើញនូវមារធីតាឈ្មោះនាងតណ្ហា ១ អរតី ១ រាគា ១ កំពុងមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលដោយគាថាទាំងឡាយដូច្នេះថា

នាងទាំងឡាយ ជាពាល ញាំញីភ្នំ ដោយដើមកុមុទ ជីក
ភ្នំ ដោយក្រចក ទំពាដែក ដោយធ្មេញ ហាក់ដូចជាយក
ដុំថ្មមកតម្កល់លើក្បាល ហើយស្វែងរកទីពឹង ក្នុងបាតាល
បៀតបៀនព្រះសមណគោតម ហាក់ដូចជាប្រហារនូវដង្គត់
ត្រង់ទ្រូង (ខ្លួនឯង) ចូរនាងទាំងឡាយ ចេញទៅ ។

ទទ្ទល្លមានា អាគញ្ឆុំ
តណ្ហា ច អរតី រគា
តា តត្ថ បនុទី សត្ថា
តុលំ ភដ្ឋំវ មាលុតោតិ[១] ។

សម្ពហុលវគ្គោ តតិយោ ។

តស្សុទ្ទានំ ភវតិ

សម្ពហុលា សមិទ្ធិ ច
គោធិកសត្តវស្សានិ
ធីតរំ ទេសិតំ ពុទ្ធ-
សេដ្ឋេន ឥមំ មារបញ្ចកន្តិ ។

មារសំយុត្តំ សមត្តំ ។

---

១ ម. ឯវំ ។ ឱ. មារុតោ ។

នាងតណ្ហា អរតី រាគា ក៏នាំគ្នាដើរមកដោយសេចក្ដីរុង-
រឿង ព្រះសាស្ដា បណ្ដេញនូវនាងទាំងនោះពីទីនោះចេញ
ដូចជាខ្យល់ដែលបក់ផាត់នូវប៉ុយដែលធ្លាក់ចុះអំពីផ្ទៃ ។

ចប់ សម្ពហុលវគ្គ ទី ៣ ។

## បញ្ជីរឿងនៃសម្ពហុលវគ្គនោះ គឺ

សម្ពហុលសូត្រ ១ សមិទ្ធិសូត្រ ១ គោធិកសូត្រ ១ សត្ត-
វស្សសូត្រ ១ ជាគម្រប់ ៥ នឹងមារធីតុសូត្រនេះ ដែលព្រះ
ពុទ្ធដ៏ប្រសើរ ទ្រង់សំដែងហើយ ។

ចប់ មារសំយុត្ត ។

# សុត្តន្តបិដកេ សំយុត្តនិកាយស្ស

# សគាថវគ្គោ

# បឋមោ ភាគោ

# ទេវតាសំយុត្តំ

# បឋមោ នឡវគ្គោ

មាតិកា អង្កេ


*បឋមំ ឱឃតរណសុត្តំ*........................................................................ ១

*ទុតិយំ និមោក្ខសុត្តំ*........................................................................ ៣

*តតិយំ ឧបនេយ្យសុត្តំ*........................................................................ ៤

*ចតុត្ថំ អច្ចេន្តិសុត្តំ*........................................................................ ៥

*បញ្ចមំ គតិច្ឆិន្ទិសុត្តំ*........................................................................ ៦

*ឆដ្ឋំ ជាគរសុត្តំ*........................................................................ ៧

*សត្តមំ អប្បដិវិទិតសុត្តំ*........................................................................ ៨

*អដ្ឋមំ សុសម្មុដ្ឋសុត្តំ*........................................................................ ៨

*នវមំ មានកាមសុត្តំ*........................................................................ ៩

*ទសមំ អរញ្ញសុត្តំ*........................................................................ ១០

# សុត្តន្តបិដក សំយុត្តនិកាយ

# សគាថវគ្គ

# បឋមភាគ

# ទេវតាសំយុត្ត

# នឡវគ្គ ទី ១

មាតិកា លេខទំព័រ


*ឱឃតរណសូត្រ ទី ១*........................................ *១*

*និមោក្ខសូត្រ ទី ២*........................................ *៣*

*ឧបនេយ្យសូត្រ ទី ៣*........................................ *៤*

*អច្ចេន្តិសូត្រ ទី ៤*........................................ *៥*

*គតិច្ឆិន្ទិសូត្រ ទី ៥*........................................ *៦*

*ជាគរសូត្រ ទី ៦*........................................ *៧*

*អប្បដិវិទិតសូត្រ ទី ៧*........................................ *៨*

*សុសម្មុដ្ឋសូត្រ ទី ៨*........................................ *៨*

*មានកាមសូត្រ ទី ៩*........................................ *៩*

*អរញ្ញសូត្រ ទី ១០*........................................ *១០*

# មាតិកាបត្តានិ

## ទុតិយោ ឆន្ទវគ្គោ

មាតិកា អង្កេ

បឋមំ នន្ទនសុត្តំ........................................................................ ១២
ទុតិយំ នន្ទិសុត្តំ........................................................................ ១៣
តតិយំ នត្ថិបុត្តសមសុត្តំ ........................................................................ ១៤
ចតុត្ថំ ខត្តិយសុត្តំ........................................................................ ១៥
បញ្ចមំ សកមានសុត្តំ........................................................................ ១៦
ឆដ្ឋំ និទ្ទាតន្ទិសុត្តំ........................................................................ ១៦
សត្តមំ ទុក្ករសុត្តំ........................................................................ ១៧
អដ្ឋមំ ហិរិសុត្តំ........................................................................ ១៨
នវមំ កុដិកាសុត្តំ........................................................................ ១៨
ទសមំ សមិទ្ធិសុត្តំ........................................................................ ២០

## តតិយោ សត្តិវគ្គោ

បឋមំ សត្តិសុត្តំ........................................................................ ៣២
ទុតិយំ ផុសតិសុត្តំ........................................................................ ៣២
តតិយំ ជដាសុត្តំ........................................................................ ៣៣
ចតុត្ថំ មនោនិវារណសុត្តំ........................................................................ ៣៤
បញ្ចមំ អរហន្តសុត្តំ ........................................................................ ៣៥
ឆដ្ឋំ បជ្ជោតសុត្តំ........................................................................ ៣៧

# សង្ខេបចង្អុលប្រាប់មាតិកា

## នន្ទនវគ្គ ទី ២

មាតិកា លេខទំព័រ

នន្ទនសូត្រ ទី ១................................................................................ ១២
នន្ទិសូត្រ ទី ២................................................................................ ១៣
នត្ថិបុត្តសមសូត្រ ទី ៣................................................................................ ១៤
ខត្តិយសូត្រ ទី ៤................................................................................ ១៥
សកមានសូត្រ ទី ៥................................................................................ ១៦
និទ្ទាតន្ទិសូត្រ ទី ៦................................................................................ ១៦
ទុក្ករសូត្រ ទី ៧................................................................................ ១៧
ហិរិសូត្រ ទី ៨................................................................................ ១៨
កុដិកាសូត្រ ទី ៩................................................................................ ១៨
សមិទ្ធិសូត្រ ទី ១០................................................................................ ២០

## សតិវគ្គ ទី ៣

សតិសូត្រ ទី ១................................................................................ ៣២
ផុសតិសូត្រ ទី ២................................................................................ ៣២
ជដាសូត្រ ទី ៣................................................................................ ៣៣
មនោនិវារណសូត្រ ទី ៤................................................................................ ៣៤
អរហន្តសូត្រ ទី ៥................................................................................ ៣៥
បជ្ជោតសូត្រ ទី ៦................................................................................ ៣៧

# មាតិកាបត្តានិ

មាតិកា អង្គេ

សត្តមំ សរសុត្តំ............................................................................ ៣៨
អដ្ឋមំ មហទ្ធនសុត្តំ........................................................................ ៣៩
នវមំ ចតុចក្កសុត្តំ.......................................................................... ៤០
ទសមំ ឯណិជង្ឃសុត្តំ...................................................................... ៤១

## ចតុត្ថោ សតុល្លប្បកាយិកាវគ្គោ

បឋមំ សព្ភិសុត្តំ ........................................................................... ៤៣
ទុតិយំ មច្ឆរិសុត្តំ.......................................................................... ៤៧
តតិយំ សាធុសុត្តំ............................................................................ ៥១
ចតុត្ថំ នសន្តិសុត្តំ ......................................................................... ៥៧
បញ្ចមំ ឧជ្ឈានសញ្ញិសុត្តំ................................................................... ៦០
ឆដ្ឋំ សទ្ធាសុត្តំ.............................................................................. ៦៣
សត្តមំ សមយសុត្តំ.......................................................................... ៦៥
អដ្ឋមំ សកលិកសុត្តំ........................................................................ ៦៨
នវមំ បឋមបជ្ជុនធីតុសុត្តំ ................................................................. ៧៤
ទសមំ ទុតិយបជ្ជុនធីតុសុត្តំ ............................................................... ៧៦

## បញ្ចមោ អាទិត្តវគ្គោ

បឋមំ អាទិត្តសុត្តំ.......................................................................... ៧៨

# សន្ទឹកាចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

សរសូត្រ ទី ៧................................................................... ៣៨

មហទ្ធនសូត្រ ទី ៨................................................................... ៣៩

ចតុចក្កសូត្រ ទី ៩................................................................... ៤០

ឯណិជង្ឃសូត្រ ទី ១០................................................................... ៤១

## សតុល្លប្បកាយិកវគ្គ ទី ៤

សព្ពិសូត្រ ទី ១................................................................... ៤៣

មច្ឆរិសូត្រ ទី ២................................................................... ៤៧

សាធុសូត្រ ទី ៣................................................................... ៥១

នសន្តិសូត្រ ទី ៤................................................................... ៥៧

ឧជ្ឈានសញ្ញិសូត្រ ទី ៥................................................................... ៦០

សទ្ធាសូត្រ ទី ៦................................................................... ៦៣

សមយសូត្រ ទី ៧................................................................... ៦៥

សកលិកសូត្រ ទី ៨................................................................... ៦៨

បឋមបជ្ជុនធីតុសូត្រ ទី ៩................................................................... ៧៤

ទុតិយបជ្ជុនធីតុសូត្រ ទី ១០................................................................... ៧៦

## អាទិត្តវគ្គ ទី ៥

អាទិត្តសូត្រ ទី ១................................................................... ៧៨

# មាតិកាបត្តានិ

មាតិកា អង្កេ

ទុតិយំ កិន្ទទសុត្តំ........................................ ៨០
តតិយំ អន្ទសុត្តំ........................................ ៨១
ចតុត្ថំ ឯកមូលសុត្តំ........................................ ៨២
បញ្ចមំ អនោមិយសុត្តំ........................................ ៨២
ឆដ្ឋំ អច្ឆរាសុត្តំ........................................ ៨៣
សត្តមំ វនរោបសុត្តំ........................................ ៨៤
អដ្ឋមំ ជេតវនសុត្តំ........................................ ៨៤
នវមំ មច្ឆរិសុត្តំ........................................ ៨៦
ទសមំ ឃដិករសុត្តំ........................................ ៨៩

## ឆដ្ឋោ ជរាវគ្គោ

បឋមំ ជរាសុត្តំ........................................ ៩៤
ទុតិយំ អជរសាសុត្តំ........................................ ៩៤
តតិយំ មិត្តសុត្តំ........................................ ៩៥
ចតុត្ថំ វត្ថុសុត្តំ........................................ ៩៦
បញ្ចមំ បឋមជនសុត្តំ........................................ ៩៦
ឆដ្ឋំ ទុតិយជនសុត្តំ........................................ ៩៧
សត្តមំ តតិយជនសុត្តំ........................................ ៩៨

# សន្លឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

កិន្ទទសូត្រ ទី ២ .................................................. ៨០
អន្ទសូត្រ ទី ៣ .................................................. ៨១
ឯកមូលសូត្រ ទី ៤ .................................................. ៨២
អនោមិយសូត្រ ទី ៥ .................................................. ៨២
អច្ឆរាសូត្រ ទី ៦ .................................................. ៨៣
វនរោបសូត្រ ទី ៧ .................................................. ៨៤
ជេតវនសូត្រ ទី ៨ .................................................. ៨៤
មច្ឆរិសូត្រ ទី ៩ .................................................. ៨៦
ឃដិករសូត្រ ទី ១០ .................................................. ៨៩

## ជរាវគ្គ ទី ៦

ជរាសូត្រ ទី ១ .................................................. ៩៤
អជរសាសូត្រ ទី ២ .................................................. ៩៤
មិត្តសូត្រ ទី ៣ .................................................. ៩៥
វត្ថុសូត្រ ទី ៤ .................................................. ៩៦
បឋមជនសូត្រ ទី ៥ .................................................. ៩៦
ទុតិយជនសូត្រ ទី ៦ .................................................. ៩៧
តតិយជនសូត្រ ទី ៧ .................................................. ៩៨

# មាតិកាបត្តានិ

មាតិកា អង្កេ

| | |
|---|---|
| អដ្ឋមំ ឧប្បថសុត្តំ............ | ៩៨ |
| នវមំ ទុតិយសុត្តំ............ | ៩៩ |
| ទសមំ កវិសុត្តំ............ | ១០០ |

## សត្តមោ អទ្ធវគ្គោ

| | |
|---|---|
| បឋមំ នាមសុត្តំ............ | ១០១ |
| ទុតិយំ ចិត្តសុត្តំ............ | ១០១ |
| តតិយំ តណ្ហាសុត្តំ............ | ១០២ |
| ចតុត្ថំ សញ្ញោជនសុត្តំ............ | ១០៣ |
| បញ្ចមំ ពន្ធនសុត្តំ............ | ១០៣ |
| ឆដ្ឋំ អព្ភាហតសុត្តំ............ | ១០៤ |
| សត្តមំ ឧឌ្ឌិតសុត្តំ............ | ១០៤ |
| អដ្ឋមំ បហិតសុត្តំ............ | ១០៥ |
| នវមំ ឥច្ឆាសុត្តំ............ | ១០៦ |
| ទសមំ លោកសុត្តំ............ | ១០៦ |

## អដ្ឋមោ ឆេត្វាវគ្គោ

| | |
|---|---|
| បឋមំ ឆេត្វាសុត្តំ............ | ១០៨ |
| ទុតិយំ រថសុត្តំ............ | ១០៩ |

# សន្ទឹកាចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

ឧប្បថសូត្រ ទី ៨ ........ ៩៨
ទុតិយសូត្រ ទី ៩ ........ ៩៩
កវិសូត្រ ទី ១០ ........ ១០០

## អន្នវគ្គ ទី ៧

នាមសូត្រ ទី ១ ........ ១០១
ចិត្តសូត្រ ទី ២ ........ ១០១
តណ្ហាសូត្រ ទី ៣ ........ ១០២
សញ្ញោជនសូត្រ ទី ៤ ........ ១០៣
ពន្ធនសូត្រ ទី ៥ ........ ១០៣
អព្ភាហតសូត្រ ទី ៦ ........ ១០៤
ឧឌ្ឌិតសូត្រ ទី ៧ ........ ១០៤
បហិតសូត្រ ទី ៨ ........ ១០៥
ឥច្ឆាសូត្រ ទី ៩ ........ ១០៦
លោកសូត្រ ទី ១០ ........ ១០៦

## យត្វាវគ្គ ទី ៨

យត្វាសូត្រ ទី ១ ........ ១០៨
រថសូត្រ ទី ២ ........ ១០៩

# មាតិកាបត្តានិ

មាតិកា អង្កេ

*តតិយំ វិត្តសុត្តំ*...................................... *១០៩*
*ចតុត្ថំ វុឌ្ឍិសុត្តំ*...................................... *១១០*
*បញ្ចមំ ភីតសុត្តំ*...................................... *១១១*
*ឆដ្ឋំ នជីរតិសុត្តំ*...................................... *១១២*
*សត្តមំ ឥស្សរសុត្តំ*...................................... *១១៤*
*អដ្ឋមំ កាមសុត្តំ*...................................... *១១៥*
*នវមំ បាថេយ្យសុត្តំ*...................................... *១១៥*
*ទសមំ បជ្ជោតសុត្តំ*...................................... *១១៦*
*ឯកាទសមំ អរណសុត្តំ*...................................... *១១៧*

# ទេវបុត្តសំយុត្តំ

## បឋមោ កស្សបវគ្គោ

*បឋមំ បឋមកស្សបសុត្តំ*...................................... *១១៩*
*ទុតិយំ ទុតិយកស្សបសុត្តំ*...................................... *១២០*
*តតិយំ មាឃសុត្តំ*...................................... *១២១*
*ចតុត្ថំ មាគធសុត្តំ*...................................... *១២២*
*បញ្ចមំ ទាមលិសុត្តំ*...................................... *១២៣*
*ឆដ្ឋំ កាមទសុត្តំ*...................................... *១២៥*

# សន្ទឹកាចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


វិត្តសូត្រ ទី ៣ .......... ១០៩

វុដ្ឋិសូត្រ ទី ៤.......... ១១០

ភីតសូត្រ ទី ៥.......... ១១១

នជីរតិសូត្រ ទី ៦.......... ១១២

ឥស្សរសូត្រ ទី ៧.......... ១១៤

កាមសូត្រ ទី ៨.......... ១១៥

បាថេយ្យសូត្រ ទី ៩.......... ១១៥

បជ្ជោតសូត្រ ទី ១០.......... ១១៦

អរណសូត្រ ទី ១១.......... ១១៧


## ទេវបុត្តសំយុត្ត

## កស្សបវគ្គ ទី ១


បឋមកស្សបសូត្រ ទី ១.......... ១១៩

ទុតិយកស្សបសូត្រ ទី ២.......... ១២០

មាឃសូត្រ ទី ៣.......... ១២១

មាគធសូត្រ ទី ៤.......... ១២២

ទាមលិសូត្រ ទី ៥.......... ១២៣

កាមទសូត្រ ទី ៦.......... ១២៥

# មាតិកាបត្តានិ

មាតិកា អង្កេ


*សត្តមំ បញ្ចាលចណ្ឌសុត្តំ.......................................................... ១២៧*

*អដ្ឋមំ តាយនសុត្តំ.......................................................... ១២៧*

*នវមំ ចន្ទិមសុត្តំ.......................................................... ១៣១*

*ទសមំ សុរិយសុត្តំ.......................................................... ១៣៣*


## ទុតិយោ អនាថបិណ្ឌិកវគ្គោ


*បឋមំ ចន្ទិមសសុត្តំ.......................................................... ១៣៦*

*ទុតិយំ វេណ្ឌុសុត្តំ.......................................................... ១៣៧*

*តតិយំ ទីឃលដ្ឋិសុត្តំ.......................................................... ១៣៨*

*ចតុត្ថំ នន្ទនសុត្តំ.......................................................... ១៣៨*

*បញ្ចមំ ចន្ទនសុត្តំ.......................................................... ១៤០*

*ឆដ្ឋំ វាសុទត្តសុត្តំ.......................................................... ១៤១*

*សត្តមំ សុព្រហ្មសុត្តំ.......................................................... ១៤១*

*អដ្ឋមំ កកុធសុត្តំ.......................................................... ១៤២*

*នវមំ ឧត្តរសុត្តំ.......................................................... ១៤៤*

*ទសមំ អនាថបិណ្ឌិកសុត្តំ.......................................................... ១៤៥*


## តតិយោ នានាតិត្ថិយវគ្គោ


*បឋមំ សិវសុត្តំ.......................................................... ១៥០*

# សន្លឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

បញ្ចាលចណ្ឌាសូត្រ ទី ៧ ........ ១២៧
តាយនសូត្រ ទី ៨ ........ ១២៧
ចន្ទិមសូត្រ ទី ៩ ........ ១៣១
សុរិយសូត្រ ទី ១០ ........ ១៣៣

## អនាថបិណ្ឌិកវគ្គ ទី ២

ចន្ទិមសសូត្រ ទី ១ ........ ១៣៦
វេណ្ឌុសូត្រ ទី ២ ........ ១៣៧
ទីឃលដ្ឋិសូត្រ ទី ៣ ........ ១៣៨
នន្ទនសូត្រ ទី ៤ ........ ១៣៨
ចន្ទនសូត្រ ទី ៥ ........ ១៤០
វាសុទត្តសូត្រ ទី ៦ ........ ១៤១
សុព្រហ្មសូត្រ ទី ៧ ........ ១៤១
កកុធសូត្រ ទី ៨ ........ ១៤២
ឧត្តរសូត្រ ទី ៩ ........ ១៤៤
អនាថបិណ្ឌិកសូត្រ ទី ១០ ........ ១៤៥

## នានាតិត្ថិយវគ្គ ទី ៣

សិវសូត្រ ទី ១ ........ ១៥០

# មាតិកាបត្តានិ

មាតិកា អង្កេ

*ទុតិយំ ខេមសុត្តំ*............................................ ១៥២

*តតិយំ សេរីសុត្តំ*............................................ ១៥៤

*ចតុត្ថំ ឃដិការសុត្តំ*............................................ ១៦០

*បញ្ចមំ ជន្តុសុត្តំ*............................................ ១៦៤

*ឆដ្ឋំ រោហិតស្សសុត្តំ*............................................ ១៦៦

*សត្តមំ នន្ទសុត្តំ*............................................ ១៧០

*អដ្ឋមំ នន្ទិវិសាលសុត្តំ*............................................ ១៧១

*នវមំ សុសិមសុត្តំ*............................................ ១៧២

*ទសមំ នានាតិត្ថិយសុត្តំ*............................................ ១៧៩

# កោសលសំយុត្តំ

## បឋមោ ទហរវគ្គោ

*បឋមំ ទហរសុត្តំ*............................................ ១៨៥

*ទុតិយំ បុរិសសុត្តំ*............................................ ១៩១

*តតិយំ រាជសុត្តំ*............................................ ១៩២

*ចតុត្ថំ បិយសុត្តំ*............................................ ១៩៤

*បញ្ចមំ អត្តរក្ខិតសុត្តំ*............................................ ១៩៨

*ឆដ្ឋំ អប្បកសុត្តំ*............................................ ២០១

# សន្ទឹកាចង្អុលច្រាប់មាតិកា

មាតិកា លេខទំព័រ

ខេមសូត្រ ទី ២ ........ ១៥២
សេរីសូត្រ ទី ៣ ........ ១៥៤
ឃដិការសូត្រ ទី ៤ ........ ១៦០
ជន្តុសូត្រ ទី ៥ ........ ១៦៤
រោហិតស្សសូត្រ ទី ៦ ........ ១៦៦
នន្ទសូត្រ ទី ៧ ........ ១៧០
នន្ទិវិសាលសូត្រ ទី ៨ ........ ១៧១
សុសិមសូត្រ ទី ៩ ........ ១៧២
នានាតិត្ថិយសូត្រ ទី ១០ ........ ១៧៩

## កោសលសំយុត្ត

## ទហរវគ្គ ទី ១

ទហរសូត្រ ទី ១ ........ ១៨៥
បុរិសសូត្រ ទី ២ ........ ១៩១
រាជសូត្រ ទី ៣ ........ ១៩២
បិយសូត្រ ទី ៤ ........ ១៩៤
អត្តរក្ខិតសូត្រ ទី ៥ ........ ១៩៨
អប្បកសូត្រ ទី ៦ ........ ២០១

# មាតិកាបត្តានិ

មាតិកា អង្កេ

សត្តមំ អត្ថករណសុត្តំ ............ ២០៣
អដ្ឋមំ មល្លិកាសុត្តំ ............ ២០៥
នវមំ យញ្ញសុត្តំ ............ ២០៧
ទសមំ ពន្ធនសុត្តំ ............ ២១០

## ទុតិយោ ជដិលវគ្គោ

បឋមំ ជដិលសុត្តំ ............ ២១៣
ទុតិយំ បញ្ចរាជសុត្តំ............ ២១៨
តតិយំ ទោណបាកសុត្តំ ............ ២២២
ចតុត្ថំ បឋមសង្គាមវត្ថុសុត្តំ ............ ២២៥
បញ្ចមំ ទុតិយសង្គាមវត្ថុសុត្តំ ............ ២២៨
ឆដ្ឋំ ធីតុសុត្តំ ............ ២៣៣
សត្តមំ បឋមអប្បមាទសុត្តំ............ ២៣៤
អដ្ឋមំ ទុតិយអប្បមាទសុត្តំ............ ២៣៦
នវមំ បឋមាបុត្តកសុត្តំ ............ ២៤២
ទសមំ ទុតិយាបុត្តកសុត្តំ............ ២៤៨

## តតិយោ បុគ្គលវគ្គោ

បឋមំ បុគ្គលសុត្តំ............ ២៥៣

# សន្ទឹកាចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

អត្តករណសូត្រ ទី ៧ ........ ២០៣

មល្លិកាសូត្រ ទី ៨ ........ ២០៥

យញ្ញសូត្រ ទី ៩ ........ ២០៧

ពន្ធនសូត្រ ទី ១០ ........ ២១០

## ជដិលវគ្គ ទី ២

ជដិលសូត្រ ទី ១ ........ ២១៣

បញ្ចរាជសូត្រ ទី ២ ........ ២១៨

ទោណបាកសូត្រ ទី ៣ ........ ២២២

បឋមសង្គាមវត្ថុសូត្រ ទី ៤ ........ ២២៥

ទុតិយសង្គាមវត្ថុសូត្រ ទី ៥ ........ ២២៨

ធីតុសូត្រ ទី ៦ ........ ២៣៣

បឋមអប្បមាទសូត្រ ទី ៧ ........ ២៣៤

ទុតិយអប្បមាទសូត្រ ទី ៨ ........ ២៣៦

បឋមាបុត្តកសូត្រ ទី ៩ ........ ២៤២

ទុតិយាបុត្តកសូត្រ ទី ១០ ........ ២៤៨

## បុគ្គលវគ្គ ទី ៣

បុគ្គលសូត្រ ទី ១ ........ ២៥៣

# មាតិកាបត្តានិ

មាតិកា អង្កេ

ទុតិយំ អយ្យិកាសុត្តំ ........ ២៦២

តតិយំ លោកសុត្តំ ........ ២៦៥

ចតុត្ថំ ឥស្សត្ថសុត្តំ ........ ២៦៧

បញ្ចមំ បព្វតោបមសុត្តំ ........ ២៧៣

# មារសំយុត្តំ

## បឋមោ តបោកម្មវគ្គោ

បឋមំ តបោកម្មសុត្តំ ........ ២៨០

ទុតិយំ នាគសុត្តំ ........ ២៨២

តតិយំ សុភសុត្តំ ........ ២៨៣

ចតុត្ថំ បឋមបាសសុត្តំ ........ ២៨៥

បញ្ចមំ ទុតិយបាសសុត្តំ ........ ២៨៧

ឆដ្ឋំ សប្បសុត្តំ ........ ២៨៩

សត្តមំ សុប្បតិសុត្តំ ........ ២៩២

អដ្ឋមំ នន្ទនសុត្តំ ........ ២៩៣

នវមំ បឋមអាយុសុត្តំ ........ ២៩៤

ទសមំ ទុតិយអាយុសុត្តំ ........ ២៩៦

# សន្លឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

អយ្យិកាសូត្រ ទី ២ .................... ២៦២

លោកសូត្រ ទី ៣ .................... ២៦៥

ឥស្សត្ថសូត្រ ទី ៤ .................... ២៦៧

បព្វតោបមសូត្រ ទី ៥ .................... ២៧៣

# មារសំយុត្ត

## តបោកម្មវគ្គ ទី ១

តបោកម្មសូត្រ ទី ១ .................... ២៨០

នាគសូត្រ ទី ២ .................... ២៨២

សុភសូត្រ ទី ៣ .................... ២៨៣

បឋមបាសសូត្រ ទី ៤ .................... ២៨៥

ទុតិយបាសសូត្រ ទី ៥ .................... ២៨៧

សប្បសូត្រ ទី ៦ .................... ២៨៩

សុប្បតិសូត្រ ទី ៧ .................... ២៩២

នន្ទនសូត្រ ទី ៨ .................... ២៩៣

បឋមអាយុសូត្រ ទី ៩ .................... ២៩៤

ទុតិយអាយុសូត្រ ទី ១០ .................... ២៩៦

# មាតិកាបត្តានិ

## ទុតិយោ ចាសាណវគ្គោ

មាតិកា អង្កេ


បឋមំ ចាសាណសុត្តំ ........ ២៩៨
ទុតិយំ សីហសុត្តំ ........ ២៩៩
តតិយំ សកលិកសុត្តំ ........ ៣០១
ចតុត្ថំ បដិរូបសុត្តំ ........ ៣០៣
បញ្ចមំ មានសសុត្តំ ........ ៣០៥
ឆដ្ឋំ បត្តសុត្តំ ........ ៣០៦
សត្តមំ អាយតនសុត្តំ ........ ៣០៨
អដ្ឋមំ បិណ្ឌសុត្តំ ........ ៣១១
នវមំ កស្សកសុត្តំ ........ ៣១៣
ទសមំ រជ្ជសុត្តំ ........ ៣១៦


## តតិយោ សម្ពហុលវគ្គោ


បឋមំ សម្ពហុលសុត្តំ ........ ៣២០
ទុតិយំ សមិទ្ធិសុត្តំ ........ ៣២៤
តតិយំ គោធិកសុត្តំ ........ ៣២៨
ចតុត្ថំ សត្តវស្សសុត្តំ ........ ៣៣៤
បញ្ចមំ មារធីតុសុត្តំ ........ ៣៣៩

# សន្ទឹកាចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

## បាសាណវគ្គ ទី ២


បាសាណសូត្រ ទី ១ .......... ២៩៨
សីហសូត្រ ទី ២ .......... ២៩៩
សកលិកសូត្រ ទី ៣ .......... ៣០១
បដិរូបសូត្រ ទី ៤ .......... ៣០៣
មានសសូត្រ ទី ៥ .......... ៣០៥
បត្តសូត្រ ទី ៦ .......... ៣០៦
អាយតនសូត្រ ទី ៧ .......... ៣០៨
បិណ្ឌសូត្រ ទី ៨ .......... ៣១១
កស្សកសូត្រ ទី ៩ .......... ៣១៣
រជ្ជសូត្រ ទី ១០ .......... ៣១៦


## សម្ពហុលវគ្គ ទី ៣


សម្ពហុលសូត្រ ទី ១ .......... ៣២០
សមិទ្ធិសូត្រ ទី ២ .......... ៣២៤
គោធិកសូត្រ ទី ៣ .......... ៣២៨
សត្តវស្សសូត្រ ទី ៤ .......... ៣៣៤
មារធីតុសូត្រ ទី ៥ .......... ៣៣៩

